18K-CA077-柬埔寨文：居士之道-字.pdf 1 2019/8/1 下午 02:06:24

As this is a Dhamma text,
we request that it be treated with respect.
If you are finished with it,
please pass it on to others or
offer it to a monastery, school or public library.
Thanks for your co-operation.
Namo Amitabha!

《柬埔寨文：居士之道 Upāsakavaṇṇanā》
財團法人佛陀教育基金會 印贈
Printed for free distribution by
**The Corporate Body of the Buddha Educational Foundation**
11F., 55 Hang Chow South Road Sec 1, Taipei, Taiwan, R.O.C.
Website: www.budaedu.org ; overseas@budaedu.org,
**This book is for free distribution, it is not to be sold.**
សម្រាប់ចែកជាធម្មទាន
Printed in Taiwan
CA077

CA077 ឧបាសកវណ្ណនា Upāsakavaṇṇanā

# ឧបាសកវណ្ណនា

## Upāsakavaṇṇanā

ភ្នំពេញ

ការផ្សាយរបស់អង្គការមូលនិធិវត្តបញ្ញាធំ

បោះពុម្ពចែកជាធម្មទាន

ព.ស. ២៥៦៣ គ.ស. ២០១៩

# ឧបាសកវណ្ណនា

# Upāsakavaṇṇanā

ភ្នំពេញ

ការផ្សាយរបស់អង្គការមូលនិធិវត្តបញ្ញាធំ

បោះពុម្ពចែកជាធម្មទាន

ព.ស. ២៥៦៣ គ.ស. ២០១៩

## **អារម្ភកថារបស់អ្នករៀបរៀង**

បុព្វហេតុ ដោយខ្ញុំមានបំណងចង់ចងចាំឲ្យជាក់ច្បាស់ នូវវិធីនៃឧបាសក ឧបាសិកា ទើបតាំងសេចក្តីព្យាយាមស្រាវជ្រាវរកក្បួនច្បាប់គម្ពីរ និងសូត្រផ្សេងៗ មានមហានាមសូត្រ, ឧបោសថសូត្រ, រាជសូត្រ, ធម្មិកសូត្រ និងអដ្ឋកថានៃសូត្រទាំងនេះខ្លះ, គម្ពីរមង្គលត្ថទីបនី, រឿងមហាជនកជាតក, កុម្ភជាតក, រឿងអនាថបិណ្ឌិកសេដ្ឋី, នាងវិសាខា, ច្បាប់ឧបោសថកថា, ច្បាប់អធិប្បាយធម្មវិភាគ, គិហិប្បដិបត្តិ, ច្បាប់វិធីថ្វាយបង្គំព្រះផ្សាយចេញពីសង្ឃបណ្ណាល័យ វត្តបទុមវតីរាជវរារាម (ក្រុងភ្នំពេញ), ច្បាប់ពុទ្ធមាមកវិធី និងច្បាប់អតិរេកសីលជាដើម យកមកពិនិត្យហើយដកស្រង់រៀបរៀងជាអត្ថបទ ១ បញ្ញត្តនាមថា "ឧបាសក-វណ្ណនា" បានសេចក្តីថា ពណ៌នាអំពីវិធីនៃឧបាសក ឧបាសិកា, ឬថាអធិប្បាយអំពីរបៀបនៃឧបាសក ឧបាសិកា, ដើម្បីជាគោលពិចារណាហើយប្រតិបត្តិក្នុងព្រះពុទ្ធសាសនាតទៅ, ឲ្យស្របទៅតាមលំអាននៃសម្តេចព្រះសង្ឃរាជ និងសម្តេចព្រះសង្ឃនាយកទាំងឡាយមាន៖

ទី១- សម្តេចព្រះសុគន្ធាសង្ឃរាជាធិបតីព្រះនាម **បញ្ញាសីលោ ប៉ាន**

ទី២- សម្តេចព្រះមង្គលទេពាចារ្យព្រះនាម **ភទ្ទគូ អៀម**

ទី៣- សម្តេចព្រះមង្គលទេពាចារ្យព្រះនាម **បញ្ញាទីបោ ស៊ុក**

ទី៤- សម្តេចព្រះសុធម្មាធិបតីព្រះនាម **ពុទ្ធនាគោ ស្រី**

ទី៥- សម្តេចព្រះសុធម្មាធិបតីព្រះនាម **ឥន្ទញាណោ ត្រុល - ឆេស ព្រះសង្ឃរាជ**

ទី៦- សម្តេចព្រះសុធម្មាធិបតីព្រះនាម **គន្ធរោ ទេព-លឿង** ជាដើម ដូចមានព្រះឆាយាលក្ខណ៍ផ្តិតជាប់នៅទីនេះ ។

កាលខ្ញុំរៀបរៀងច្បាប់នេះចប់ហើយ បានយកទៅជូនអ្នកអាចារ្យជា ហៅ ប៊ូ-ប៉ូ អតីតក្រុមជំនុំព្រះត្រៃបិដក សូមជួយពិនិត្យ អ្នកអាចារ្យនេះ បានទទួលពិនិត្យដោយរីករាយ រួចហើយ ខ្ញុំបានយកទៅប្រគេនគណៈកម្មការសង្ឃវត្តបទុមវតីរាជវរារាម ក្រុងភ្នំពេញ ដែលសម្តេចព្រះសុធម្មាធិបតី **គន្ធរោ ទេព-លឿង** សង្ឃនាយក បានតែងតាំងឡើងសម្រាប់សរសេរ និងពិនិត្យកែធម៌ប្រែ សូមជួយពិនិត្យកែសម្រួលឲ្យមានអត្ថន័យល្អពិសេសឡើង ។

គណៈកម្មការសង្ឃបានជួយពិនិត្យកែ ដោយយកព្រះទ័យទុកដាក់លុះពិនិត្យកែរួចហើយ បានប្រគល់មកឲ្យខ្ញុំវិញ ខ្ញុំក៏ចាត់ការបោះពុម្ពបានសម្រេចជារូបសៀវភៅនេះឡើង ។

ខ្ញុំព្រះករុណា សូមអរព្រះគុណជាទីបំផុត ចំពោះគណៈកម្មការសង្ឃវត្តបទុមវតី ដែលបានជួយពិនិត្យអត្ថបទឧបាសកវណ្ណនាឲ្យទាន សូមព្រះករុណាគ្រប់ព្រះអង្គ បានប្រកបដោយបរមសុខ និងសេចក្តីប្រាថ្នាគ្រប់ប្រការ ដរាបដល់អវសាននៃព្រះជន្ម ។

គណៈកម្មការសង្ឃ វត្តបទុមវតីរាជវរារាម

ដែលបានជួយពិនិត្យកែ

ក្រោមអធិបតីភាពនៃសម្តេចព្រះសុធម្មាធិបតី

**គន្ធរោ ទេព-លឿង** ព្រះសង្ឃនាយក

១- ព្រះធម្មកវីវង្ស **ចន្ទវជិរោ គុង-ឈួន** វត្តបទុមវតី

២- ព្រះមង្គលទេពាចារ្យ **ឡុង-ណារ៉** វត្តបទុមវតី

៣- ព្រះវជិរមេធា **ឡេ-ឡុង** វត្តធ្មនមណីរាម

៤- ព្រះគ្រូវិន័យធរ **គួច-សៀង** វត្តបទុមវតី

៥- ព្រះគ្រូវិសុទ្ធិវង្ស **ម៉ៅ-ខាន់** វត្តបទុមវតី

៦- ព្រះគ្រូមហាបទុម **រស់-សាវេន** វត្តបទុមវតី

៧-ព្រះគ្រូពុទ្ធប្បាទ **ជិន-សៅ** វត្តបទុមវតី

៨- ព្រះមហា **ទិន-គេន** មេគណក្រុង វត្តស្វាយពពែ,

៩- ព្រះមហា **ប៉ុក-សុន** វត្តប្រយូរវង្ស ។

ប្រសិនបើច្បាប់នេះនៅមានខុសឃ្លៀងឃ្លាតខ្វះ ខ្ញុំសូមអភ័យទោសអំពីសំណាក់នៃលោកអ្នកប្រាជ្ញទាំងឡាយ សូមជួយកែតម្រង់ឲ្យទានផង ដើម្បីទុក សម្រាប់ជាគោលប្រតិបត្តិនៃពួកបរិសទ្យ និងទុកជាសម្បត្តិក្នុងព្រះពុទ្ធសាសនាតទៅផង ។

ទីបំផុតនេះ ខ្ញុំសូមឧទ្ទិសកុសលដែលកើតឡើងអំពីកម្លាំងព្យាយាមនៃការរៀបរៀង និងចំណាយធនធានបោះពុម្ពច្បាប់នេះ ចែកជាធម្មទានជូនដល់បុព្វការីបុគ្គលទាំងឡាយ មានមាតាបិតាជាដើម សូមបានសម្រេចនូវឥដ្ឋមនុញ្ញផលកុំបីឃ្លៀងឃ្លាតឡើយ មួយទៀត ដោយតេជានុភាពនៃកុសលនេះ សូមឲ្យព្រះពុទ្ធសាសនាបានចម្រើនរុងរឿងតរៀងទៅ ។

ភ្នំពេញ នៅថ្ងៃ ៦ ១៨ ឆ្នាំចទោស័ក ព.ស.២៥១៤

ត្រូវនឹងថ្ងៃទី ៤ ខែកក្កដា គ.ស. ១៩៧០

# បញ្ជីរឿង

ទំព័រ

ឧបាសកវណ្ណនា .......... ១
វិធីឧបាសក .......... ២
មាតិកាបុច្ឆា ៦ យ៉ាង .......... ៣
បុច្ឆា វិសជ្ជនា ទី ១ .......... ៣
បាលីសូមខមាទោស .......... ៤
បាលីដែលឲ្យកើតព្រះត្រៃសរណគមន៍ .......... ៦
បានព្រះត្រៃសរណគមន៍ដោយអង្គ ៣ .......... ៨
ប្រកាសខ្លួនចំពោះព្រះរតនត្រ័យ .......... ៨
សរណគមន៍ ២ យ៉ាង .......... ៩
សរណគមន៍ ជាលោកីយ៍ ២ យ៉ាង .......... ១០
អាការៈនៃសរណគមន៍ ៤ យ៉ាង .......... ១៤
អំពីការបដិបត្តិរក្សាសរណគមន៍ .......... ១៩
អំពីអានិសង្សនៃសរណគមន៍ .......... ២០
អំពីការដាច់ និងទោសនៃការដាច់សរណគមន៍ .......... ២២
អំពីការសៅហ្មងនៃសរណគមន៍ .......... ២៣
បុច្ឆា វិសជ្ជនាទី ២ .......... ៣១

ទំព័រ

បុច្ឆា វិសជ្ជនាទី ៣ ........................................................................ ៣២
អំពីនិច្ចសីល ......................................................................................... ៣២
កិច្ចសមាទាននិច្ចសីល .......................................................................... ៣៤
អង្គនៃសិក្ខាបទទាំង ៥ ......................................................................... ៣៦
អំពីអានិសង្សនៃសីលសម្បត្តិ ................................................................ ៣៨
អំពីទោសនៃសីលវិបត្តិ ......................................................................... ៤០
អំពីឧបោសថសីល ................................................................................ ៤២
ឧបោសថកម្ម ៣ យ៉ាង ............................................................................ ៤៣
អំពីកាលសម្រាប់រក្សានូវឧបោសថ ........................................................... ៤៤
ប្រភេទនៃកិរិយារក្សានូវឧបោសថ ........................................................... ៥១
អំពីកិច្ចប្រតិបត្តិក្នុងថ្ងៃឧបោសថ ............................................................... ៥៣
វិរតិ ២ យ៉ាង .......................................................................................... ៥៧
អំពីកិច្ចសមាទានឧបោសថសីល ............................................................... ៥៧
កិច្ចសមាទានមាន ២ ប្រភេទ ..................................................................... ៦០
អំពីកិច្ចសមាទាននូវឧបោសថសីលរួចហើយ ............................................. ៦៤
អង្គនៃសិក្ខាបទឧបោសថសីល ៨ ........................................................... ៧២
អានិសង្សនៃបុគ្គលមានសីលបរិសុទ្ធ .......................................................... ៧៤

ទំព័រ

អំពីទោសនៃបុគ្គលទ្រុស្តសីល ........................................ ៧៦
អតិរេកសីល ........................................ ៧៧
សិក្ខាបទនៃអតិរេកសីល ........................................ ៨០
មេថុនសំយោគ ៧ ប្រការ ........................................ ៨៣
អំពីវត្តប្រតិបត្តិក្នុងអតិរេកសីល ........................................ ៨៤
អង្គនៃសិក្ខាបទជាតរូបរជត: ........................................ ៨៥
អានិសង្សនៃសីលមាន ១០ យ៉ាង ........................................ ៨៧
អំពីទោសនៃអ្នកគ្មានសីល ........................................ ៨៩
បុច្ឆា វិសជ្ជនា ទី ៤ ........................................ ៩០
មិច្ឆាវណិជ្ជា ៥ ប្រការ ........................................ ៩១
បុច្ឆា វិសជ្ជនា ទី ៥ ........................................ ៩២
សម្បត្តិនៃឧបាសក ៥ ........................................ ៩២
បុច្ឆា វិសជ្ជនា ទី ៦ ........................................ ៩៤
វិបត្តិនៃឧបាសក ៥ ........................................ ៩៤
ឧបាសកគុណ ........................................ ៩៥
ពណ៌នាអំពីរឿងកម្មបថ ........................................ ៩៨
អង្គនៃអកុសលកម្មបថ ១០ ........................................ ១០២

ទំព័រ

អកុសលកម្មបថ ៤០ ..........................................................១០៦
កុសលកម្មបថ ៤០............................................................ ១០៨
កម្មដ្ឋានសង្ខេប ............................................................ ១០៩
ចរិត ៦ យ៉ាង ...............................................................១១៤
និមិត្ត ៣ ភាវនា ៣...........................................................១១៧
វិនិច្ឆ័យក្នុងបឋវីកសិណ .................................................. ១១៩
វសី ការស្ទាត់ជំនាញ ៥ យ៉ាង...............................................១២៣
អង្គឈាន ................................................................... ១២៤
វិបស្សនាភាវនា ........................................................... ១២៦
ឧបាសកបដិបត្តិ-ថ្វាយបង្គំព្រះវត្តព្រឹក-ប្រែ......................................១៣១
ថ្វាយបង្គំវត្តល្ងាច-ប្រែ ........................................................១៤៧
អសុភភាវនា-ប្រែ ........................................................... ១៥៨
អភិណ្ហបច្ចវេក្ខណៈ ប្រែ.................................................... ១៥៩
មរណស្សតិភាវនា ប្រែ .......................................................១៦០
ទេវតាទិបត្តិទានគាថា ប្រែ ...................................................១៦០
បត្តិទានគាថាប្រែ ........................................................... ១៦១
ប្រកាសឧបោសថ ........................................................... ១៦៤

ទំព័រ

ពាក្យអារាធនាបរិត្ត..........................................................១៧៤
វិធីអារាធនាធម្មទេសនា ....................................................១៧៥
វិធីវេរភត្តថ្វាយសង្ឃ...........................................................១៨៣
ពាក្យថ្វាយទានផ្សេងៗ ...................................................... ១៨៥
ពាក្យបវារណាបច្ច័យ..........................................................១៨៩
ពាក្យសូមលាព្រះសង្ឃទៅផ្ទះវិញ .............................................. ១៩០

# ឧបាសកវណ្ណនា

*ពណ៌នាអំពីវិធីឧបាសក ឧបាសិកា*

*ខាងដើម ខ្ញុំសូមនមស្ការព្រះពុទ្ធ តាមទម្លាប់នៃបុរាណាចារ្យក្នុងប្រទេសទាំងពួង ។ បុរាណាចារ្យទាំងឡាយ កាលធ្វើកុសលកម្មណាមួយក្នុងព្រះពុទ្ធសាសនា មានសម្តែងធម៌, សមាទានសរណគមន៍ និងសីលជាដើម រមែងនមស្ការព្រះពុទ្ធគុណជាមុន ដោយពាក្យបាលីថា* **នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស** *។ ៣ ដង ។*

*សូមនមស្ការចំពោះព្រះពុទ្ធជាម្ចាស់អង្គនោះ, ព្រះអង្គឆ្ងាយចាកកិលេសហើយ, ត្រាស់ដឹងនូវព្រះធម៌ដ៏ប្រពៃដោយព្រះអង្គឯង, ទ្រង់ចែកធម៌ដល់សត្វទាំងឡាយ ។ លុះពោលពាក្យ* **នមោ** *នេះរួចហើយ ឬ ពោលពាក្យដទៃទៀត មាន* **ឥតិបិ សោ ភគវា អរហំ សម្មាសម្ពុទ្ធោ** *ជាដើម រួចហើយ ទើបធ្វើកុសលកម្មនោះៗតទៅទៀត ។*

*ឯកិច្ចនមស្ការដូច្នេះ ទោះបីមិនមានបង្គាប់ទុកក្នុងបាលី ឬ អដ្ឋកថាក៏ឃើញថាជាវត្តប្រតិបត្តិល្អណាស់ឥតខុសឡើយ ព្រោះបុគ្គលណាបាននមស្ការរំឭកដល់ព្រះពុទ្ធគុណជាមុនហើយ ទើបធ្វើកុសលកម្មមានសម្តែងធម៌ សមាទានសរណគមន៍ និងសីលជាដើម បុគ្គលនោះ*

ឈ្មោះថា ស្ទង់ចិត្តចុះក្នុងកុសលកម្មដែលខ្លួនធ្វើថាជាកម្មត្រឹមត្រូវតាមពុទ្ធ-ភាសិតមែន មិនមែនធ្វើតាមអំពើចិត្តឯងទេ ក៏នឹងកើតសេចក្ដីជ្រះថ្លាទ្វេឡើងយ៉ាងវិសេសក្នុងព្រះពុទ្ធគុណ ហាក់ដូចជាបានទទួលព្រះឱវាទផ្ទាល់ព្រះឱស្ឋនៃព្រះអង្គហើយធ្វើ ។ កុសលកម្មដែលបុគ្គលធ្វើនោះ អាចរាប់ថាជាសម្មាបដិបត្តិបូជាដល់សម្ដេចព្រះពុទ្ធអង្គ នឹងបានផលានិសង្សច្រើនក្រៃលែងជាងកុសលកម្ម ដែលបុគ្គលមិនបានរំឭកនូវព្រះពុទ្ធគុណជាមុននោះ ។ មួយទៀត បានឈ្មោះថាជាអ្នកប្រព្រឹត្តតាមព្រះអរិយៈទាំងពួងដែលជាពុទ្ធសាវ័ក លោកឃើញនូវព្រះពុទ្ធគុណជាក់ច្បាស់ពិតប្រាកដក្នុងព្រះទ័យក្រៃលែងជាងបុថុជ្ជនដោយកម្លាំងនៃលោកុត្តរញ្ញាណ ។ ព្រះអរិយៈទាំងឡាយ កាលបើលោកក្អក, កណ្ដាស ឬ ដួលភ្លាត់មាត់ ក៏រមែងបន្លឺវាចានមស្ការចេញព្រះនាមសម្ដេចព្រះពុទ្ធអង្គរាល់ពេលវេលា ។ ហេតុនេះ កាលបុគ្គលធ្វើកុសលកម្មណាៗ ក៏គប្បីតែនឹករំឭកដល់ព្រះពុទ្ធគុណជាមុន រួចចាំធ្វើកុសលកម្មនោះៗ តទៅទៀត ។

## វិធីឧបាសក(១)

អធិប្បាយអំពីវិធីឧបាសកដោយសង្ខេប តាមន័យក្នុងមហានាមសូត្រ ដែលសាក្យមហានាម ក្រាបបង្គំទូលសួរព្រះមានព្រះភាគ ដោយពោលបាលីថា

---

១- បានន័យដល់ឧបាសិកាផង ។

**កោ ឧបាសកោ, កស្មា ឧបាសកោតិ វុច្ចតិ, កិមស្ស សីលំ, កោ អាជីវោ, កា សម្បត្តិ, កា វិបត្តិ ។**

*បាលីនេះ ចែកជាមាតិកាបុច្ឆាមាន ៦ យ៉ាងគឺ*

*ទី១-* **កោ ឧបាសកោ** *បុគ្គលជាឧបាសកនោះ តើដូចម្តេច ?*

*ទី២-* **កស្មា ឧបាសកោតិ វុច្ចតិ** *ហេតុដូចម្តេច បានជាហៅថាឧបាសក?*

*ទី៣-* **កិមស្ស សីលំ** *សីលនៃឧបាសកនោះ តើដូចម្តេច?*

*ទី៤-* **កោ អាជីវោ** *ការចិញ្ចឹមជីវិតនៃឧបាសកនោះ តើដូចម្តេច?*

*ទី៥-* **កា សម្បត្តិ** *សម្បត្តិគឺសេចក្តីចម្រើននៃឧបាសកនោះ តើដូចម្តេច?*

*ទី៦-* **កា វិបត្តិ** *វិបត្តិគឺសេចក្តីវិនាសនៃឧបាសកនោះតើដូចម្តេច?*

*បុច្ឆាទាំង ៦ យ៉ាងនេះ ព្រះមានព្រះភាគទ្រង់វិសជ្ជនាមួយម្តងៗ ចំពោះសាក្យមហានាម មានសេចក្តីដូចតទៅនេះ៖*

*បុច្ឆាទី១-* **កោ ឧបាសកោ** *បុគ្គលជាឧបាសកនោះតើដូចម្តេច ?*

*វិសជ្ជនាទី១- បុគ្គលណាមានព្រះត្រៃសរណគមន៍ បុគ្គលនោះឈ្មោះថាឧបាសក ។*

*បុគ្គលដែលនឹងមានព្រះត្រៃសរណគមន៍ គឺព្រះពុទ្ធ ព្រះធម៌ ព្រះ-សង្ឃនោះ ត្រូវអាស្រ័យចិត្តជឿជាក់ច្បាស់ជាប្រមាណ មានជឿថា ព្រះ*

*ពុទ្ធជាទក្ខិណេយ្យបុគ្គលដ៏ប្រសើរវិសេសក្នុងលោក, ព្រះធម៌ជានិយ្យានិកៈ នាំអ្នកបដិបត្តិឲ្យរួចចាកទុក្ខ, ព្រះសង្ឃជាសុបដិបន្នបុគ្គល លោកបដិបត្តិល្អប្រពៃយ៉ាងនេះជាដើម ហើយតាំងចិត្តយកជាសរណៈទីពឹង ដោយបន្ទំវាចាចំពោះព្រះភក្ត្រព្រះពុទ្ធអង្គ ឬព្រះពុទ្ធរូប និងព្រះភិក្ខុសង្ឃ ឬ វិញ្ញូជនធ្វើនមស្ការជាមុនសិនថា* **នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស**[១] *៣ ដង ។ រួចហើយគប្បីសូមខមាទោស ។*

បាលីសូមខមាទោស[២]

*បើបុរសស្ត្រីម្នាក់ ត្រូវសូត្រថា*

**អច្ចយោ មំ ភន្តេ, អច្ចគមា, យថាពាលំ, យថាមុឡ្ហំ, យថាអកុសលំ, យោ[៣] / យា ហំ ភន្តេ, ជាតិតោ បដ្ឋាយ, បមាទំ វា អាគម្ម, អយោនិសោ, មនសិការំ វា អាគម្ម, កាយេន វា, វាចាយ វា, មនសា វា, ពុទ្ធេ វា, ធម្មេ វា, សង្ឃេ វា, អគារវំ អកាសឹ, សម្មុខាបិ, បរម្មុខាបិ, សាធុ មេ ភន្តេ សង្ឃោ, អច្ចយំ,**

១- សេចក្តីប្រែដូចខាងដើម ។

២- ស្រង់យកបាលីទាំងសេចក្តីប្រែពីច្បាប់វិធីថ្វាយបង្គំព្រះផ្សាយចេញពីសង្ឃបណ្ណាល័យវត្តបទុមវតីរាជវរារាម ។

៣- យោ សម្រាប់បុរសម្នាក់ថា, យា សម្រាប់ស្ត្រីម្នាក់ថា ។

**អច្ចយតោ, បដិគ្គណ្ហាតុ, អាយតឹ សំវរាយ ។**

**ទុតិយម្បិ . . . ។ តតិយម្បិ . . . ។**

*បពិត្រព្រះសង្ឃដ៏ចម្រើន, រីទោសខុស, បានគ្របសង្កត់ហើយ, នូវខ្ញុំព្រះករុណា, ដែលជាមនុស្សពាលយ៉ាងណា, ជាមនុស្សវង្វេងយ៉ាងណា, ជាមនុស្សមិនឈ្លាសយ៉ាងណា, បពិត្រព្រះសង្ឃដ៏ចម្រើន! ខ្ញុំព្រះករុណា, ចាប់ដើមតាំងអំពីកើតមក, អាស្រ័យហើយនូវសេចក្តីប្រមាទខ្លះ, អាស្រ័យហើយនូវការមិនបានធ្វើទុកក្នុងចិត្ត ដោយឧបាយនៃប្រាជ្ញាខ្លះ, បានធ្វើហើយនូវសេចក្តីមិនគោរព ក្នុងព្រះពុទ្ធក្តី, ក្នុងព្រះធម៌ក្តី, ក្នុងព្រះសង្ឃក្តី, ដោយកាយខ្លះ, ដោយវាចាខ្លះ, ដោយចិត្តខ្លះ, ចំពោះមុខខ្លះ, កំបាំងមុខខ្លះ, បពិត្រព្រះសង្ឃដ៏ចម្រើន, សូមព្រះសង្ឃ, ទទួលគឺអត់នូវទោសខុស, តាមទោសខុសនៃខ្ញុំព្រះករុណា, ដើម្បីនឹងសង្រួម, អស់កាលតរៀងទៅហោង។*

*បើបុរសស្ត្រីច្រើននាក់ ត្រូវសូត្រថា*

**អច្ចយោ នោ ភន្តេ, អច្ចគមា, យថា {ពាលេ[១] / ពាលា},**

**យថា {មុឡ្ហេ[២] / មុឡ្ហា} យថា {អកុសលេ[៣] / អកុសលា} {យេ[៤] / យា} មយំ ភន្តេ,**

---

១- ពាលេ, ២- មុឡ្ហេ, ៣- អកុសលេ, ៤- យេ សម្រាប់បុរសច្រើននាក់ថា ។

១- ពាលា, ២- មុឡ្ហា, ៣- អកុសលា, ៤- យា សម្រាប់ស្ត្រីច្រើននាក់ថា ។

ជាតិតោ បដ្ឋាយ, បមាទំ វា អាគម្ម, អយោនិសោ, មនសិការំ វា អាគម្ម, កាយេន វា, វាចាយ វា, មនសា វា, ពុទ្ធេ វា, ធម្មេ វា, សង្ឃេ វា, អគារវំ អកាសិម្ហា, សម្មុខាបិ, បរម្មុខាបិ, សាធុ នោ ភន្តេ សង្ឃោ, អច្ចយំ, អច្ចយតោ, បដិគ្គណ្ហាតុ, អាយតឹ សំវរាយ ។ ទុតិយម្បិ . . . ។ តតិយម្បិ . . . ។

*ប្រែដូចខាងដើម តែត្រូវថា នូវខ្ញុំព្រះករុណាទាំងឡាយ នៃខ្ញុំព្រះករុណាទាំងឡាយ ។ កិច្ចសម្តែងទោសដូច្នេះនេះ ជាឧបាយកែខ្លួនឲ្យបរិសុទ្ធឡើងបាន រួចចាកវិប្បដិសារីក្តៅក្រហាយ, រួចហើយគប្បីសូត្របាលីដែលនឹងឲ្យបានព្រះត្រៃសរណគមន៍ ។*

## បាលីដែលឲ្យកើត(១) ព្រះត្រៃសរណគមន៍

*បើបុរសស្ត្រីម្នាក់ត្រូវថា*

ឯសាហំ ភន្តេ, សុចិរបរិនិព្វុតម្បិ, តំ ភគវន្តំ, សរណំ គច្ឆាមិ, ធម្មញ្ច ភិក្ខុសង្ឃញ្ច, ឧបា { សកំ(២) / សិកំ }, មំ សង្ឃោ ធារេតុ, អជ្ជតគ្គេ, បាណុបេតំ, សរណំ

---

១- ស្រង់យកបាលីទាំងសេចក្តីប្រែពីច្បាប់វិធីថ្វាយបង្គំព្រះ ផ្សាយចេញពីសង្ឃ-បណ្ណាល័យ វត្តបទុមវតីរាជវរារាម ។

២- សកំ សម្រាប់បុរសម្នាក់ថា, សិកំ សម្រាប់ស្ត្រីម្នាក់ថា ។

**គតំ ។ ទុតិយម្បិ...។ តតិយម្បិ... ។**

*បពិត្រព្រះសង្ឃដ៏ចម្រើន! ខ្ញុំព្រះករុណានេះ, សូមដល់នូវព្រះមានព្រះភាគអង្គនោះ, សូម្បីទ្រង់បរិនិព្វានហើយ, អស់កាលជាអង្វែង, នូវព្រះធម៌ផង, នូវព្រះសង្ឃផង, ជាទីពឹង, សូមព្រះសង្ឃចាំទុក, នូវខ្ញុំព្រះករុណាថាជា {ឧបាសក / ឧបាសិកា}, ដល់ហើយនូវព្រះត្រៃសរណគមន៍, ស្មើដោយជីវិត, ចាប់ដើមអំពីថ្ងៃនេះទៅហោង ។*

*បើបុរសស្ត្រីច្រើននាក់ ត្រូវសូត្រថា*

**ឯ {តេ(១) / តា} មយំ ភន្តេ, សុចិរបរិនិព្វុតម្បិ, តំ ភគវន្តំ, សរណំ គច្ឆាម, ធម្មញ្ច ភិក្ខុសង្ឃញ្ច, ឧបា {សកេ(២) / សិកាយោ}, នោ សង្ឃោ ធារេតុ, អជ្ជតគ្គេ, បាណុបេ {តេ(៣) / តា}, សរណំ {គតេ(៤) / គតា} ។ ទុតិយម្បិ... ។ តតិយម្បិ... ។**

---

១- តេ, ២- សកេ, ៣- តេ, ៤- គតេ, សម្រាប់បុរសច្រើននាក់ថា ។

១- តា, ២- សិកាយោ, ៣- តា, ៤- គតា, សម្រាប់ស្ត្រីច្រើនាក់ថា ។

*ប្រែដូចខាងដើម តែត្រូវថា ខ្ញុំព្រះករុណាទាំងឡាយនេះ នូវខ្ញុំព្រះករុណាទាំងឡាយ ។*

*បុគ្គលដែលបានព្រះត្រៃសរណគមន៍នោះ ប្រកបដោយអង្គ ៣ ប្រការគឺ*

**១- សទ្ធា** *មានចិត្តជឿគុណព្រះរតនត្រ័យ ដែលប្រែថា កែវទាំង ៣ គឺព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ និងជឿកម្មផល ។*

**២- បញ្ញា** *មានប្រាជ្ញា ដឹង ស្គាល់ ទីកើត ទីរលត់ របស់សង្ខារ ។*

**៣- ជីវិតបរិច្ចាគ** *បើមានហេតុអ្វី ដែលនឹងឲ្យសៅហ្មង ឬដាច់ព្រះត្រៃសរណគមន៍ អាចហ៊ានប្តូរជីវិត ។*

*កាលបុគ្គលបានបំពេញកិច្ចដូចពណ៌នាមកប៉ុណ្ណោះ ឈ្មោះថាជាឧបាសកឧបាសិកា ក្នុងព្រះពុទ្ធសាសនាហើយ គប្បីប្រកាសខ្លួនចំពោះព្រះរតនត្រ័យថា*(១)

**អហំ ពុទ្ធញ្ច ធម្មញ្ច, សង្ឃញ្ច សរណំ គតោ(២) / គតា**, *ខ្ញុំដល់ហើយនូវព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃជាទីពឹង,* **ឧបាសកត្តំ(៣) / ឧបាសិកត្តំ**

១- ស្រង់យកបាលីទាំងសេចក្តីប្រែពីច្បាប់វិធីថ្វាយបង្គំព្រះ ផ្សាយចេញពីសង្ឃបណ្ណាល័យ វត្តបទុមវតី នឹងមានពោលនៅខាងចុងនៃច្បាប់នេះ ។

២- គតោ, ៣- ឧបាសកត្តំ សម្រាប់បុរសថា ។ គតា, ឧបាសិកត្តំ សម្រាប់ស្ត្រីថា ។

**ធេសេសិ, ភិក្ខុសង្ឃស្ស សម្មុខា,** *ហើយប្រកាសខ្លួនជា*

*ឧបាសក*
*ឧបាសិកា* } *ក្នុងទីចំពោះព្រះភក្ត្រនៃភិក្ខុសង្ឃ,* **ឯតំ ខោ សរណំ**

**ខេមំ, ឯតំ សរណមុត្តមំ,** *នេះជាទីពឹងដ៏ក្សេមនិងជាទីពឹងដ៏ឧត្តម* *របស់ខ្ញុំ,* **ឯតំ សរណមាគម្ម, សព្វទុក្ខា បមុច្ចយេ,** *អាស្រ័យនូវទីពឹងនេះហើយ គប្បីរួចចាកទុក្ខទាំងពួង,* **យថាពលំ ករេយ្យាហំ, សម្មាសម្ពុទ្ធសាសនំ,** *ខ្ញុំគប្បីធ្វើតាមសាសនានៃព្រះសម្មាសម្ពុទ្ធ, ដ៏សមគួរដល់កម្លាំង,* **ទុក្ខនិស្សរណស្សេវ,**

**ភាគី**[១]
**ភាគិនី** } **ហោមិ អនាគតេ,** *ខ្ញុំសូមបានចំណែកនៃព្រះនិព្វាន,*

*ជាទីរលាស់ចាកទុក្ខក្នុងកាលជាអនាគតកុំខានឡើយ ។*

*ឯវិធីនៃសរណគមន៍នេះនៅមានន័យច្រើនយ៉ាងទៀត ដូចពណ៌នាតទៅនេះ :*

**ទុវិធំ សរណគមនំ លោកុត្តរំ លោកិយញ្ចាតិ**

*សរណគមន៍បែកចេញជា ២ ប្រការគឺ*

*១- សរណគមន៍ ជាលោកុត្តរៈ ។*

*២- សរណគមន៍ ជាលោកិយៈ ។*

---

១- ភាគី សម្រាប់បុរសថា ។ ភាគិនី សម្រាប់ស្ត្រីថា ។

អធិប្បាយអំពីសរណគមន៍ទាំង ២ ប្រការ

១- សរណគមន៍ជាលោកុត្តរៈនោះ បាននឹងអរិយមគ្គញ្ញាណរបស់ព្រះអរិយៈដែលលោកបានសោតាបត្តិមគ្គ កាត់ផាច់នូវឧបក្កិលេសនៃសរណគមន៍ មានសង្ស័យជាដើមជាសមុច្ឆេទបហាន ឈោងយកព្រះនិព្វានជាអារម្មណ៍ ឲ្យសម្រេចប្រយោជន៍ គោរពព្រះរតនត្រ័យដោយកិច្ចសម្រេចក្នុងចិត្ត ព្រមទាំងប្រព្រឹត្តទៅក្នុងកាយនិងវាចា ។

២- សរណគមន៍ជាលោកិយនោះ ត្រូវមានសទ្ធាសេចក្តីជឿនិងបញ្ញាឃើញគុណព្រះរតនត្រ័យជាក់ច្បាស់ ទាល់តែបន្ទឹនូវវិធីភេទសមាទានព្រះរតនត្រ័យមានព្រះពុទ្ធជាដើមជាអារម្មណ៍ ។

ពាក្យសមាទានលោកិយសរណគមន៍នេះ តាមន័យក្នុងបាលីមាន ២ ប្រការគឺ

១- ទ្វេវាចិកសរណគមន៍ ។

២- តេវាចិកសរណគមន៍ ។

ប្រការ១- ទ្វេវាចិកសរណគមន៍នោះ បាននឹងវាចាដែលពាណិជ ២ នាក់គឺ តបុ្បសៈ និងភល្លិកៈ ក្រាបទូលសម្តេចព្រះពុទ្ធអង្គ កាលជួបគ្រាដំបូងទើបបានត្រាស់ដឹងថ្មីៗ ស្តេចគង់ក្រោមដើមកេស ។ ពាណិជនោះបានថ្វាយទេយ្យទាន ហើយក្រាបទូលថ្វាយខ្លួនជាឧបាសកប្រកាន់យកព្រះពុទ្ធនិងព្រះធម៌ជាទីពឹង ដ្បិតគ្រានោះព្រះសង្ឃមិនទាន់មាន ដោយបាលីថា :

**ឯតេ មយំ ភន្តេ, ភគវន្តំ សរណំ គច្ឆាម, ធម្មញ្ច, ឧបាសកេ, នោ ភគវា ធារេតុ, អជ្ជតគ្គេ, បាណុបេតេ, សរណំ គតេ ។**

*បពិត្រព្រះមានព្រះភាគដ៏ចម្រើន! ខ្ញុំព្រះករុណាទាំងឡាយនេះ សូមដល់នូវព្រះមានព្រះភាគផង នូវព្រះធម៌ផងជាទីពឹង សូមព្រះមានព្រះភាគទទួលចាំទុក នូវខ្ញុំព្រះករុណាទាំងឡាយ ថាជាឧបាសកដល់ហើយនូវព្រះមានព្រះភាគ និងព្រះធម៌ជាទីពឹង ស្មើដោយជីវិត ចាប់ដើមអំពីថ្ងៃនេះតទៅ ។*

*ប្រការ២- តេវាចិកសរណគមន៍នោះ តាមគម្ពីរមហាវគ្គ មហាខន្ធកៈ ពោលថា បាននឹងវាចាដែលសេដ្ឋីជាបិតាព្រះយស និងនាងសុជាតាជាមាតា ព្រមទាំងភរិយានៃព្រះយស ពោលជាដំបូងមុនគេ ហៅថាបឋម-ឧបាសក បឋមឧបាសិកា ។ មួយទៀតបាននឹងវាចាដែលទេវតានិងមនុស្សទាំងឡាយដទៃទៀត ប្រគល់កាយថ្វាយខ្លួនជាឧបាសក ឧបាសិកា ក្នុងព្រះពុទ្ធសាសនាចំពោះព្រះភក្ត្រនៃព្រះពុទ្ធអង្គដោយបាលីថា :*

**ឯសាហំ ភន្តេ, ភគវន្តំ សរណំ គច្ឆាមិ, ធម្មញ្ច ភិក្ខុសង្ឃញ្ច, ឧបាសកំ, មំ ភគវា ធារេតុ, អជ្ជតគ្គេ បាណុបេតំ, សរណំ គតំ ។**

*បពិត្រព្រះមានព្រះភាគដ៏ចម្រើន! ខ្ញុំព្រះករុណានេះសូមដល់នូវ*

ព្រះមានព្រះភាគផង នូវព្រះធម៌ផង នូវព្រះសង្ឃផងជាទីពឹង សូមព្រះមានព្រះភាគទទួលចាំទុក នូវខ្ញុំព្រះករុណាថាជាឧបាសក ឧបាសិកាដល់ហើយ នូវព្រះមានព្រះភាគ ព្រះធម៌ និងព្រះសង្ឃជាទីពឹង ស្មើដោយជីវិត ចាប់ដើមអំពីថ្ងៃនេះតទៅ ។

ឯបាលីនេះជាពាក្យដែលបុគ្គលក្រាបទូលព្រះពុទ្ធអង្គ ក្នុងទីចំពោះព្រះភក្ត្រ ដូចជាព្រះបាទបសេនទិកោសល, ព្រះបាទអជាតសត្តុ និងជនដទៃទៀតជាច្រើន, បណ្ដាបុគ្គលដែលបាននូវលោកិយសរណគមន៍ ក៏សឹងក្រាបទូលព្រះពុទ្ធអង្គដោយពាក្យតាមតួយ៉ាង ក្នុងបាលីជាឧទាហរណ៍យ៉ាងនេះទាំងអស់ ។ ហេតុដូច្នោះ ក្នុងកាលឥឡូវនេះ ទោះបីព្រះអង្គបរិនិព្វានទៅហើយក្ដី បើបុគ្គលប្រាថ្នាប្រតិបត្តិបូជា គប្បីធ្វើតាមន័យដែលមានមកនោះចុះ គប្បីចូលទៅអង្គុយជិតបូជនីយដ្ឋាន មានព្រះចេតិយជាទីបញ្ចុះព្រះបរមសារីរិកធាតុ និងព្រះបដិមាជាដើម ហើយពោលរំឭកនូវព្រះពុទ្ធគុណដោយគោរពតាមបាលីនោះចុះ ដោយតាំងចិត្តថាក្រាបទូលព្រះពុទ្ធអង្គក៏គួរ អាចកើតជាកិច្ចសមាទានសរណគមន៍បានដូចគ្នា ។

មួយទៀតបើមិនដូច្នោះទេ នឹងទៅក្នុងសំណាក់នៃព្រះភិក្ខុសង្ឃ គឺពួកនៃភិក្ខុ តាំងពី ៤ អង្គឡើងទៅក្ដី, ក្នុងសំណាក់នៃគណៈ គឺភិក្ខុ ២ អង្គ ៣ អង្គក្ដី, ក្នុងសំណាក់នៃបុគ្គល គឺភិក្ខុ ១ អង្គក្ដីក៏បាន, តែថាត្រូវ

ផ្លាស់បាលីត្រង់កណ្តាល គឺ **ភគវា ធារេតុ** នោះចេញ យកបាលីដទៃដាក់បញ្ចូលតាមសមគួរ បើសង្ឃ គណៈ ឬបុគ្គល បើបុគ្គលត្រូវថា **អយ្យោ ធារេតុ**, បើគណៈត្រូវថា **អយ្យា ធារេន្តុ**, បើសង្ឃត្រូវថា **សង្ឃោ ធារេតុ** ។

មួយវិញទៀតសោត បើបុគ្គលនោះចង់ពោលឲ្យទាន់សេចក្តីជ្រះថ្លារបស់ខ្លួនដែលកើតឡើង ក្នុងសំណាក់នៃបុគ្គលណាៗ មិនបានទេ, បើក្នុងទីប្រជុំនោះមានវិញ្ញូជនចេះដឹងព្រះពុទ្ធសាសនាច្រើនក្តី តិចក្តី គប្បីពោលនឹងវិញ្ញូជននោះដោយមិនបានចំពោះក៏គួរ, បើពោលមិនចំពោះត្រូវផ្លាស់បាលីថា **តុម្ហេ ធារេថ, ភោ ធារេតុ** ដូច្នេះទើបគួរ, ចំណែកស្ត្រី ត្រូវផ្លាស់បាលី **ឧបាសកំ** នោះចេញ ហើយប្រើបាលី **ឧបាសិកំ** ជួសវិញ ។

ឯបាលីសមាទានសរណគមន៍ដូចពោលមកនេះ មានមកក្នុងសូត្រជាច្រើន ចំពោះពាក្យសមាទាននៃបុគ្គលខ្លះដែលពោលតែមួយដងក៏បាន បើបុគ្គលប្រាថ្នាពោលពីរ បី ដងថែមទៀតក៏បាន, ត្រូវបញ្ចូលបាលីថា **ទុតិយម្បាហំ ភន្តេ . . . ។ តតិយម្បាហំ ភន្តេ . . . ។** តាមតែសទ្ធាចុះ ។ កាលព្រះពុទ្ធអង្គគង់ព្រះជន្មនៅឡើយ មានបុគ្គលជំពូកខ្លះពោល ៣ ដងដូច្នេះ ដូចជាសេនាបតីឈ្មោះ **សីហៈ** នៅក្នុងនគរពៃសាលី និងគហបតីឈ្មោះ **ឧបាលិ** ។ ចំណែកបុគ្គលដែលពោល

តែមួយដង  ក៏មានដោយច្រើនក្នុងសូត្រផ្សេងៗ ។

ក្នុងអដ្ឋកថានៃសាមញ្ញផលសូត្រ, ភយភេរវសូត្រ, ខុទ្ទកបាឋ: និង គម្ពីរសារត្ថសង្គហ: ទាំង ៤ នេះ មានសេចក្តីស្របគ្នាថា ចេតនាដែលញ៉ាំងវាចាឲ្យកើតឡើងនោះ រមែងឲ្យសម្រេចនូវអាការ: ៤ យ៉ាង, វាចាដែលបន្លឺចេញទៅនោះ ទោះបីដូចគ្នានឹងបាលីដូចពោលមកហើយនោះក្តី មិនដូចគ្នានឹងបាលីនោះក្តី ក៏មិនជាប្រមាណដែរ ឲ្យតែត្រូវនឹងអាការ: ៤ យ៉ាងនេះហើយ ក៏កើតបានជាសរណគមន៍ ។

ឯអាការ: ៤ យ៉ាងនោះគឺ

១- **អត្តសន្និយ្យាតនំ** ច ការប្រគល់កាយថ្វាយខ្លួនចំពោះព្រះរតនត្រ័យ,

២- **តប្បរាយនតា** ច ការកាន់យកព្រះរតនត្រ័យនោះជាទីពឹងប្រព្រឹត្តទៅខាងមុខ គឺអធិដ្ឋានថា បើមានទុក្ខភ័យបង្កើតឡើងហើយ នឹងទីពឹងតែព្រះរតនត្រ័យប៉ុណ្ណោះ,

៣- **សិស្សភាវូបគមោ** ច ការចូលទៅធ្វើជាសិស្សស្តាប់ឱវាទ,

៤- **ចាណិចាតោ** ច ការប្រព្រឹត្តគោរពកោតក្រែងក្រៃលែងដោយអភិវាទន៍ថ្វាយបង្គំ គឺធ្វើសាមីចិកម្មតាមកម្លាំងដែលខ្លួនអាចធ្វើបាន ។

អាការ: ៤ យ៉ាងនេះជាប្រមាណគឺជាគោលធំក្នុងសរណគមន៍ ។

*ព្រះអដ្ឋកថាចារ្យសម្តែងឧទាហរណ៍ក្នុងអាការៈទាំង ៤ យ៉ាងនេះតទៅទៀតថា :*

*អាការៈជាដំបូង-* **អត្តសន្និយ្យាតនំ ច** *ការប្រគល់កាយថ្វាយខ្លួនដល់ព្រះរតនត្រ័យនោះ អធិប្បាយថា បើបុគ្គលណាប្រកបដោយសទ្ធា និងបញ្ញាខ្ទាំងក្លាដូចពោលហើយ បុគ្គលនោះប្រាថ្នានឹងប្រគល់កាយថ្វាយខ្លួនដល់ព្រះរតនត្រ័យ ត្រូវពោលពាក្យបាលីថា :*

**អជ្ជ អាទឹ កត្វា អហំ អត្តានំ ជីវិតំ ពុទ្ធស្ស និយ្យាទេមិ**
**អជ្ជ អាទឹ កត្វា អហំ អត្តានំ ជីវិតំ ធម្មស្ស និយ្យាទេមិ**
**អជ្ជ អាទឹ កត្វា អហំ អត្តានំ ជីវិតំ សង្ឃស្ស និយ្យាទេមិ**

*ខ្ញុំព្រះករុណាសូមប្រគល់កាយថ្វាយខ្លួន គឺជីវិត ចំពោះព្រះពុទ្ធចាប់តាំងអំពីថ្ងៃនេះជាដើមរៀងទៅ ។ ក្នុងបទព្រះធម៌ និងព្រះសង្ឃក៏ប្រែដូចគ្នាយ៉ាងនេះ ឈ្មោះថា អត្តសន្និយ្យាតនៈ ។*

*ឯពាក្យថា អត្តសន្និយ្យាតនៈ ការប្រគល់កាយថ្វាយខ្លួននោះ គឺប្រគល់ជីវិត ទោះបីជីវិតនឹងក្ស័យក្តី ក៏មិនលះបង់ចោលព្រះរតនត្រ័យឡើយ ។ អាការៈប្រគល់កាយថ្វាយខ្លួននេះ ស្របតាមពាក្យដែលមានមកក្នុងបាលីថា* **អជ្ជតគ្គេ បាណុបេតំ សរណំ គតំ** *។*

*អាការៈជាគម្រប់ ២-* **តប្បរាយណតា ច** *ការកាន់យកព្រះរតនត្រ័យជាទីពឹងប្រព្រឹត្តទៅខាងមុខនោះ ត្រូវពោលពាក្យបាលីថា :*

**អជ្ជ អាទឹ កត្វា អហំ ពុទ្ធបរាយណោ ឥតិ មំ ធារេថ**

**អជ្ជ អាទឹ កត្វា អហំ ធម្មបរាយណោ ឥតិ មំ ធារេថ**

**អជ្ជ អាទឹ កត្វា អហំ សង្ឃបរាយណោ ឥតិ មំ ធារេថ**

*ខ្ញុំព្រះករុណាសូមយកព្រះពុទ្ធជាទីពឹងប្រព្រឹត្តទៅខាងមុខ ចាប់តាំងអំពីថ្ងៃនេះជាដើមរៀងទៅ សូមលោកទាំងឡាយចាំទុកនូវខ្ញុំព្រះករុណា (ថាជាឧបាសក ឧបាសិកា) ដោយអាការៈដូច្នេះ ។ ក្នុងបទព្រះធម៌, ព្រះសង្ឃ ក៏ប្រែដូចគ្នា ។*

*ឯពាក្យដទៃៗ ដែលសម្តែងក្នុងអដ្ឋកថា ថាជាទីពឹង ជាទីអាស្រ័យ ជាទីរំលត់ភ័យ ក៏សង្គ្រោះចូលក្នុងអាការៈនេះទាំងអស់, អាការៈនេះស្របនឹងបាលីថា* **ឯសាហំ ភន្តេ ភគវន្តំ សរណំ គច្ឆាមិ ធម្មញ្ច ភិក្ខុសង្ឃញ្ច មំ ភគវា ធារេតុ ។**

*អាការៈជាគម្រប់ ៣-* **សិស្សភាវូបគមោ ច** *ការចូលទៅធ្វើជាសិស្សស្តាប់ឱវាទនោះ ត្រូវពោលពាក្យបាលីថា :*

**អជ្ជ អាទឹ កត្វា អហំ ពុទ្ធស្ស អន្តេវាសិកោ ឥតិ មំ ធារេថ**

**អជ្ជ អាទឹ កត្វា អហំ ធម្មស្ស អន្តេវាសិកោ ឥតិ មំ ធារេថ**

**អជ្ជ អាទឹ កត្វា អហំ សង្ឃស្ស អន្តេវាសិកោ ឥតិ មំ ធារេថ**

*ខ្ញុំព្រះករុណា សូមជាបុគ្គលប្រកបនៅខាងក្នុងនៃព្រះពុទ្ធ ចាប់តាំងពីថ្ងៃនេះជាដើមរៀងទៅ សូមលោកទាំងឡាយចាំទុកនូវខ្ញុំព្រះករុណា*

(ថាជាឧបាសក ឧបាសិកា) ដោយអាការៈដូច្នេះ ។ ក្នុងបទព្រះធម៌ ព្រះសង្ឃ ក៏ប្រែដូចគ្នា ។ ឯពាក្យថា **ពុទ្ធស្ស អន្តេវាសិកោ** នេះស្របនឹងបាលីថា **ឯសាហំ ភន្តេ ។ ល ។ ឧបាសកំ មំ ភគវា ធារេតុ** ។

ឯសិស្សភាវូបគមៈនេះ ដូចជាសរណគមន៍នៃព្រះមហាកស្សបត្ថេរ កាលដែលឧទ្ទិសចំពោះបុគ្គលដ៏ប្រសើរលើសក្នុងលោក ហើយក៏បួស ស្វែងរកអាចារ្យ ដើម្បីនឹងប្រគល់ខ្លួនដាច់ជាសាវ័កទទួលឱវាទ លុះដើរ មកបានឃើញសម្តេចព្រះពុទ្ធអង្គគង់ក្រោមដើមពហុបុត្តកនិគ្រោធ គឺដើម ជ្រៃប្រកបដោយសិរីវិសាល បញ្ចេញនូវព្រះឆព្វណ្ណរង្សីរស្មីទាំង ៦ ពណ៌ ប្រាលប្រវាត់ទៅក្នុងទិសានុទិស ក៏មានចិត្តជ្រះថ្លាសម្គាល់ថា លោកនេះ គួរធ្វើជាគ្រូប្រដៅយើងឲ្យរួចចាកទុក្ខទាំងពួងបាន ទើបបន្លឺវាចាថា **សត្ថារំ វតាហំ បស្សាមិ** យើងបានឃើញព្រះដ៏ជាគ្រូនៃយើង, លោកិយសរណគមន៍នៃព្រះមហាកស្សបត្ថេរនេះ សម្រេចទៅដោយពាក្យ មានប្រមាណប៉ុណ្ណោះ ។ ហេតុដូច្នោះ សម្តេចព្រះពុទ្ធអង្គកាលទ្រង់ប្រទាន បព្វជ្ជាដល់ព្រះមហាកស្សបត្ថេរ ទ្រង់មិនបានប្រទានសរណគមន៍ទៀតទេ ទ្រង់ប្រទានឱវាទ ឧបសម្បទវិសេសដល់ព្រះមហាកស្សបត្ថេរតែម្នាក់ឯង, ទើបឃើញថាការបញ្ចេញវាចាប្រគល់ខ្លួនជាសិស្ស ឬ បញ្ចេញវាចាទទួល ធ្វើតាមឱវាទយ៉ាងនេះ ក៏កើតជាសរណគមន៍បាន ។

*អាការៈទាំង ៣ យ៉ាង ដូចន័យដែលពណ៌នាមកនេះ ជាអាការៈមានកម្លាំងតែងប្រព្រឹត្តទៅដោយត្រង់ចំពោះព្រះរតនត្រ័យ អាចធ្វើបុគ្គលឲ្យកើតជាឧបាសក ឧបាសិកាបានដោយពិត ។*

*អាការៈគម្រប់ ៤-* **ចាណិចាតោ ច** *ការប្រព្រឹត្តគោរពកោតក្រែងក្រៃលែងដោយអភិវាទន៍ថ្វាយបង្គំ នឹងសម្រេចជាសរណគមន៍បានដោយអំណាចនៃបុគ្គលយល់ឃើញគុណព្រះរតនត្រ័យ ថាជាវត្ថុដ៏ប្រសើរពិតប្រាកដ ទើបធ្វើអភិវាទន៍សំពះគោរពកោតក្រែងដោយកាយ ហើយបញ្ចេញវាចាប្តេជ្ញាថា :*

**អជ្ជ អាទឹ កត្វា អហំ អភិវាទនបច្ចុបដ្ឋានំ អញ្ជលីកម្មំ សាមីចិកម្មំ ពុទ្ធាទីនំយេវ តិណ្ណំ វត្ថូនំ ករោមិ ឥតិ មំ ធារេថ ។**

*ខ្ញុំព្រះករុណា សូមធ្វើអភិវាទន៍ថ្វាយបង្គំ កោតក្រែងតែព្រះរតន-ត្រ័យមានព្រះពុទ្ធជាដើម ចាប់តាំងអំពីថ្ងៃនេះរៀងទៅ សូមលោកទាំងឡាយចាំទុកនូវខ្ញុំព្រះករុណា (ថាជាឧបាសក ឧបាសិកា) ដោយអាការៈដូច្នេះ ។*

*កាលគោរពដោយកាយទ្វារ និងវចីទ្វារ ព្រមទាំងចិត្តក៏ជ្រះថ្លាប្រព្រឹត្តទៅតាមនិព្វានគាមិនីបដិបទា សេចក្តីប្រតិបត្តិជាហេតុនឹងឲ្យដល់នូវព្រះនិព្វាន ក្នុងព្រះរតនត្រ័យដូច្នេះហើយ ទើបកើតជាសរណគមន៍ ។*

ឯបាណិបាតោនេះមាន ៤ ប្រការគឺ គោរពដោយយល់ថាជាញាតិ ១ គោរពដោយហេតុខ្លាច ១ គោរពដោយយល់ថាជាអាចារ្យ ១ គោរពដោយយល់ថាជាទក្ខិណេយ្យបុគ្គល ១ ។ ការដែលកើតជាសរណគមន៍ឈ្មោះបាណិបាតោនោះ ពីព្រោះគោរពដោយយល់ថាព្រះមានព្រះភាគជាទក្ខិណេយ្យបុគ្គលដ៏ប្រសើរ ។ សេចក្តីគោរព ៣ ប្រការគឺ គោរពដោយយល់ថាជាញាតិ, គោរពដោយហេតុខ្លាច និងគោរពដោយយល់ថាជាអាចារ្យ ៣ ប្រការនេះ មិនកើតជាសរណគមន៍ឡើយ ។ ហេតុដូច្នោះ បុគ្គលណាមួយជាស្តេចសាក្យរាជក្តី ស្តេចកោលិយក្តី បើគោរពព្រះមានព្រះភាគដោយសម្គាល់ថា ព្រះមានព្រះភាគជាញាតិនៃខ្លួនយ៉ាងនេះ ក៏មិនកើតជាសរណគមន៍ទេ ។ បុគ្គលដែលគោរពព្រះមានព្រះភាគដោយគិតខ្លាចថា ព្រះសមណគោតមនោះជាព្រះមហាក្សត្រគេតែងធ្វើសក្ការបូជា ព្រះអង្គមានអានុភាពច្រើន បើយើងមិនគោរពនឹងធ្វើឲ្យយើងវិនាស, ការគោរពដោយគិតខ្លាចយ៉ាងនេះ មិនកើតជាសរណគមន៍ទេ ។ បុគ្គលណាមួយរឭកឃើញបុរិមជាតិថា ធ្លាប់ធ្វើជាសិស្សរៀនសិល្បសាស្ត្រក្នុងសំណាក់ព្រះអង្គដែលទ្រង់នៅជាពោធិសត្វក្តី ការគោរពដោយសម្គាល់ថាព្រះមានព្រះភាគជាអាចារ្យនៃខ្លួនយ៉ាងនេះ ក៏មិនកើតជាសរណគមន៍ទេ ។

## អំពីការបដិបត្តិរក្សាសរណគមន៍

បុគ្គលដែលមានសរណគមន៍ ក៏ពីព្រោះចិត្តគោរពថា ព្រះមាន

ព្រះភាគជាអគ្គបុគ្គលប្រសើរដោយវិសេស, នឹងដាច់សរណគមន៍ ក៏ពីព្រោះចិត្តគោរពត្រូវទៅមានអន្យតិរ្ថិយជាដើម ថាប្រសើរដោយវិសេស ។ បុគ្គលជាឧបាសក ឧបាសិកា មានសរណគមន៍ហើយ បើទៅសំពះញាតិដែលបួសក្នុងពួកអន្យតិរ្ថិយនិគ្រណ្ឋ ដោយសម្គាល់ថាជាញាតិនៃខ្លួន សរណគមន៍ក៏មិនដាច់ នឹងពោលទៅថ្វីដល់បុគ្គលដែលមិនបានបួស ទោះបីសំពះដោយគិតថាជាញាតិ សរណគមន៍ក៏មិនដាច់ ។ បុគ្គលមានសរណគមន៍ហើយទៅសំពះស្តេច ដោយគិតថា ស្តេចជាធំ បើយើងមិនសំពះក៏នឹងធ្វើឲ្យយើងវិនាសមិនខាន យ៉ាងនេះសរណគមន៍ក៏មិនដាច់ ។ បុគ្គលមានសរណគមន៍ហើយ ទៅសំពះអន្យតិរ្ថិយដែលបង្ហាញនូវសិល្បសាស្ត្រណាមួយ ដោយគិតថាជាអាចារ្យនៃខ្លួន សរណគមន៍ក៏មិនដាច់ ។ កាលបើបុគ្គលមានសេចក្តីសង្ស័យក្នុងសរណគមន៍របស់ខ្លួន គប្បីលើកយកអង្គនៃសរណគមន៍ទាំង ៣ ប្រការគឺ សទ្ធា ១ បញ្ញា ១ ជីវិតបរិច្ចាគ ១ ដូចបានពោលហើយខាងដើមមកពិចារណាហើយវិនិច្ឆ័យចុះ បើសរណគមន៍របស់បុគ្គលគង់ទ្រង់នៅបរិសុទ្ធ ផូរផង់ហើយ នឹងបានសម្រេចផលានិសង្សដ៏ប្រសើរ ។

## អំពីអានិសង្សនៃសរណគមន៍

សរណគមន៍ជាលោកុត្តរៈ មានអានិសង្សឲ្យសម្រេចមគ្គផលនិព្វាន

សរណគមន៍ជាលោកិយៈ មានអានិសង្សឲ្យសោយសម្បត្តិក្នុង

វដ្តសង្សារ ជាសុគតិភូមិ ។

មានពាក្យព្រះមហាព្រហ្មពោលគាថា ក្នុងសំណាក់នៃព្រះមានព្រះភាគថា :

យេកេចិ ពុទ្ធំ សរណំ គតា សេ
ន តេ គមិស្សន្តិ អបាយភូមឹ
បហាយ មានុសំ ទេហំ
ទេវកាយំ បរិបូរេស្សន្តីតិ ។

បុគ្គលទាំងឡាយណាមួយដល់នូវព្រះពុទ្ធជាទីពឹង បុគ្គលទាំងឡាយនោះ នឹងមិនទៅកាន់អបាយភូមិ កាលបើលះបង់នូវរាងកាយនៃមនុស្សនេះហើយ នឹងទៅសោយសម្បត្តិក្នុងសួគ៌ទេវលោក ។

ន័យមួយទៀតសោត ព្រះធម្មសង្គាហកត្ថេរទាំងឡាយពោលថា កាលនោះព្រះឥន្ទ្រាធិរាជ មួយអន្ទើដោយទេវតាទាំងឡាយ ៨ ម៉ឺនអង្គ ចូលទៅកាន់សំណាក់ព្រះមហាមោគ្គល្លានត្ថេរ ក្រាបថ្វាយបង្គំហើយគង់ក្នុងទីមួយដ៏សមគួរ រួចទូលសួរព្រះមហាមោគ្គល្លានត្ថេរៗ លោកបានថ្វាយព្រះពរថា បពិត្រទេវរាជជាធំក្រៃលែងជាងទេវតា! បុគ្គលដែលមានសរណគមន៍ហើយរមែងញ៉ាំងប្រយោជន៍ឲ្យសម្រេចដោយពិត ។ បពិត្រទេវរាជ! សត្វទាំងឡាយជំពូកខ្លះ ធ្វើកាលកិរិយាក្ស័យជីវិតអំពីមនុស្សនេះទៅ បានទៅកើតក្នុងសួគ៌ទេវលោក ដោយហេតុដែលយកព្រះពុទ្ធ

ជាទីពឹង ហើយមានអានុភាពគ្របសង្កត់ទេវតាទាំងឡាយដទៃ ដោយសម្បត្តិទិព្វ ១០ ប្រការគឺ មានអាយុជាទិព្វ ១ មានពណ៌រស្មីជាទិព្វ ១ មានសេចក្តីសុខជាទិព្វ ១ មានយសជាទិព្វ ១ មានអធិបតីជាទិព្វ ១ មានរូបជាទិព្វ ១ មានសំឡេងជាទិព្វ ១ មានក្លិនជាទិព្វ ១ មានរសជាទិព្វ ១ មានសម្ផស្សជាទិព្វ ១ ។ បើយកព្រះធម៌ក្តី ព្រះសង្ឃក្តី ជាទីពឹងក៏មានផលដូចគ្នា ។

## អំពីការដាច់ និងទោសនៃការដាច់សរណគមន៍

តាមន័យដែលមានមកក្នុងសាមញ្ញផលសូត្រ និងកូដទន្តសូត្រថា :

សរណគមន៍ជាលោកុត្តរៈ មិនដាច់ទេ ។ មានសេចក្តីថា :

ព្រះអរិយៈទាំងឡាយអស់ជីពជន្មហើយ កើតក្នុងជាតិទី២-៣-៤ទៀត ក៏មិនមានសេចក្តីជឿគ្រូដទៃក្រៅចាកព្រះរតនត្រ័យឡើយ បានជាការដាច់ ឬ សៅហ្មងសរណគមន៍នេះគ្មានទេ ។

សរណគមន៍ជាលោកិយៈ នឹងដាច់មាន ២ ប្រការគឺ ដាច់ឥតទោស ១ ដាច់មានទោស ១ ។

ដាច់ឥតទោស បាននឹងបុគ្គលនោះស្លាប់ទៅ សរណគមន៍ក៏ដាច់តែឥតទោស ។

ដាច់មានទោស បាននឹងបុគ្គលប្រព្រឹត្តទៅដោយហេតុទាំងឡាយគឺ ប្រគល់ខ្លួនដល់គ្រូដទៃ មានអន្យតិរ្ថិយនិគ្រណ្ឋជាដើម និងទេវតាវិសេស

មានព្រះឥសូរ និងព្រះនារាយណ៍ជាដើម ថាប្រសើរលើសជាងព្រះរតនត្រ័យ, សរណគមន៍នេះក៏ដាច់ហើយមានទោស ។

ឯទោសនៃការដាច់សរណគមន៍នោះ មានផលផ្ទុយអំពីអានិសង្ស គឺញ៉ាំងបុគ្គលនោះឲ្យទៅកាន់អបាយភូមិមាននរកជាដើម និងប្រាសចាកអំពីសម្បត្តិសួគ៌ ទេវលោក, និងប្រាសចាកសម្បត្តិទិព្វ ១០ ប្រការ ដូចន័យដែលពោលហើយក្នុងអានិសង្សនៃអ្នកមានសរណគមន៍ ខាងដើមស្រាប់ ។

## អំពីការសៅហ្មង និងការជម្រះទោស

សរណគមន៍ជាលោកិយនឹងសៅហ្មងនោះ ព្រោះបុគ្គលប្រព្រឹត្តនូវហេតុទាំងឡាយគឺ មានសេចក្ដីសង្ស័យក្នុងគុណព្រះរតនត្រ័យ មានសង្ស័យថា ព្រះពុទ្ធ ឬ មិនមែនព្រះពុទ្ធជាដើម, មានសេចក្ដីឃើញខុស គឺប្រកាន់ខុសថាជាត្រូវ មានគិតប្រទូសរ៉ាយព្រះរតនត្រ័យជាដើមដោយចិត្តជាអកុសល, មិនគោរព ដោយកាយ វាចា និងចិត្ត បើប្រកបដោយហេតុដូច្នេះហើយ សរណគមន៍នៃបុគ្គលនោះសៅហ្មង គឺមិនរុងរឿង មិនបរិសុទ្ធ មិនផូរផង់ ។ បើសរណគមន៍សៅហ្មងដោយចិត្តជាអកុសលមានសង្ស័យជាដើមហើយ បុគ្គលនោះគប្បីជម្រះបន្ទោបង់នូវឧបក្កិលេសនៃសរណគមន៍នោះ ដោយយោនិសោមនសិការៈ រឭកនឹកដល់គុណព្រះរតនត្រ័យជាអនេកប្បការ ដោយអំណាចនៃភាវនា

មានពុទ្ធានុស្សតិជាដើម ដើម្បីបន្ទោបង់នូវឧបក្កិលេសនោះឲ្យសាបសូន្យចេញ ។ បើមិនបាត់ដោយការធ្វើដូច្នោះទេ គប្បីទៅកាន់សំណាក់នៃអ្នកប្រាជ្ញ ធ្វើនូវធម្មសាកច្ឆា ឬសូមឱវាទពីលោកក្តី ដែលនាំឲ្យកើតជ្រះថ្លាក្នុងព្រះរតនត្រ័យឡើង មួយទៀត ធម៌ណាដែលខ្លួនធ្លាប់ស្តាប់ធ្លាប់រៀនមកជា **បសាទនីយកថា** នាំឲ្យកើតសេចក្តីជ្រះថ្លា ក៏គប្បីពិចារណាធម៌នោះរម្ងាប់បង់នូវឧបក្កិលេស មានវិចិកិច្ឆាជាដើមដោយតទង្គប្បហានៈនិងវិក្ខម្ភនប្បហានៈជាដើម ។ បើបុគ្គលប្រតិបត្តិដូច្នោះហើយ ទោះបីមិនបានសូមខមាទោសចំពោះព្រះរតនត្រ័យក្តី បុគ្គលនោះក៏ឈ្មោះថា មានសរណគមន៍ដ៏បរិសុទ្ធតាមប្រក្រតី ។ ដ្បិតសរណគមន៍សៅហ្មងដោយឧបក្កិលេសធម៌ណា ឧបក្កិលេសធម៌នោះ បុគ្គលបានកម្ចាត់បង់ហើយ ។ ឯសេចក្តីប្រតិបត្តិដូចពោលមកនេះ ឈ្មោះថាប្រតិបត្តិជម្រះនូវសរណគមន៍ដែលសៅហ្មងក្នុងចិត្ត ។ មួយទៀត សរណគមន៍នៃបុគ្គលដែលសៅហ្មងតាំងនៅក្នុងចិត្ត បើបុគ្គលញ៉ាំងអកុសលចិត្តនោះឲ្យប្រព្រឹត្តទៅ ប្រារព្ធនូវបុគ្គលណាជាហេតុ គប្បីញ៉ាំងបុគ្គលនោះឲ្យអត់ទោសចេញផង ធ្វើបែបនេះប្រពៃណាស់ ព្រោះមនោកម្មជំពូកខ្លះនឹងឲ្យទោសឃើញច្បាស់ក្នុងបច្ចុប្បន្ន ដូចជាកម្មនៃសោរេយ្យសេដ្ឋីបុត្ត ដែលគិតប្រមាថដោយអំណាចនៃរាគចិត្តក្នុងព្រះមហាកច្ចាយនត្ថេរ ក៏ឲ្យផលឃើញច្បាស់ក្នុងបច្ចុប្បន្នញ៉ាំងសេដ្ឋីបុត្តនោះឲ្យក្លាយទៅជាស្ត្រី ។ គ្រាក្រោយ ស្ត្រីភាពនោះ

ញុំាងព្រះមហាកច្ចាយនត្ថេរឲ្យអត់ទោស ទើបត្រឡប់ទៅជាបុរសវិញ ហេតុដូច្នោះ កិរិយាដែលបុគ្គលសូមខមាទោសនេះ ជាគរុកម្ម ជាវត្តប្រតិបត្តិសមគួរក្រៃពេកណាស់ ។

កាលបើឧបក្កិលេសនៃសរណគមន៍នោះខ្លាំងក្លាឡើងលើសប្រមាណ ប្រព្រឹត្តទៅក្នុងកាយទ្វារ វចីទ្វារ អាចញុំាងបុគ្គលនោះឲ្យធ្វើនូវអគារវៈ ដោយកាយ និងវាចា គឺធ្វើអគារវៈដោយកាយ មានមិនបានអភិវាទ ថ្វាយបង្គំ, បាំងតាំងយូ, ពាក់ស្បែកជើង, ដណ្តប់ស្មាទាំងពីរខាង, ទទូរក្បាល, ស្តោះទឹកមាត់, បន្ទោបង់ឧច្ចារៈ, បស្សាវៈ ផ្លូតទឹកនិងលាងជើង ជាដើម ជាការមិនសមគួរ កើតដោយអកុសលចិត្តក្នុងទីចំពោះព្រះភក្ត្រនៃព្រះពុទ្ធអង្គ ក្នុងទីឧបចារៈនៃព្រះពុទ្ធបដិមា និងចេតិយស្ថានក្តី, ធ្វើអគារវៈក្នុងព្រះធម៌ ដោយកាយវិការ មានធ្វើឲ្យកើតអន្តរាយក្នុងទីសម្តែងធម៌, ស្តាប់ធម៌ និងរៀនធម៌ជាដើមក្តី, ធ្វើអគារវៈក្នុងព្រះសង្ឃដោយហោចទៅ សូម្បីគ្រាន់តែធ្វើអគារវៈក្នុងភិក្ខុបុថុជ្ជនមានសីលបរិសុទ្ធដែលប្រតិបត្តិដើម្បីឲ្យបានសោតាបត្តិមគ្គ ១ អង្គក្តី បើបុគ្គលធ្វើដូច្នោះឈ្មោះថា កាយិក-អគារវៈ គឺធ្វើអគារវៈក្នុងព្រះរតនត្រ័យដោយកាយ ។ កាលបុគ្គលលុះក្នុងអំណាចឧបក្កិលេសនៃសរណគមន៍ មានទិដ្ឋិឃើញខុសជាត្រូវ ធ្វើអគារវៈដោយវាចា ពោលតិះដៀលព្រះរតនត្រ័យដោយទោសចិត្តក្តី មានសេចក្តីប្រមាថប្រារព្ធព្រះពុទ្ធរតនៈ ព្រះធម្មរតនៈ ព្រះសង្ឃរតនៈ ជាហេតុ

ហើយពោលវាចាដោយកីឡាធិប្បាយប្រាថ្នានឹងលេង ជាពាក្យដែលបុគ្គលគប្បីសើចក្តី ឈ្មោះថា វាចិកអគារវៈ គឺធ្វើអគារវៈក្នុងព្រះរតនត្រ័យដោយវាចា ។ កាលសរណគមន្ទូបក្កិលេសកើតខ្ញាំងក្លា ញុាំងកាយនិងវាចាជាអគារវៈឲ្យកើតឡើងដូចពោលមកនេះ សរណគមន៍នោះ ក៏ឈ្មោះថាសៅហ្មង ។ បើបុគ្គលប្រាថ្នានឹងជម្រះឲ្យបរិសុទ្ធ គប្បីញុាំងព្រះរតនត្រ័យឲ្យអត់ទោស ដោយកាយ វចីបយោគ គឺសូមខមាទោសនឹងព្រះរតនត្រ័យជាមុន ទើបរួចទោស សរណគមន៍នោះ ក៏បរិសុទ្ធល្អឡើងវិញដូចដើម ។

ពាក្យដែលពោលមកនេះ សំដៅយកអគារវកិរិយាដែលកើតឡើងព្រោះជាអកុសលដ៏សម្បយុត្តដោយវិចិកិច្ឆាសង្ស័យ នឹងឃើញដោយវិបល្លាសប៉ុណ្ណោះទើបសៅហ្មងសរណគមន៍ ។ បើបុគ្គលមានចិត្តប្រកបដោយសេចក្តីគោរព ទោះបីប្រមាទភ្លាំងភ្លាត់វង្វេងភ្លេចស្មារតីទៅ ហើយធ្វើនូវកាយកម្ម វចីកម្ម ជាអគារវៈដូចពោលហើយនោះក្តី មិនបានឱកាសដើម្បីធ្វើគារវៈដោយមានធុរៈ មានហេតុប្រញាប់រហ័សក្រៃពេកណាស់ជាដើមក្តី នឹងដោយមានអាពាធក្នុងកាយធ្វើគារវៈមិនបានក្តី បើញុាំងចិត្តឲ្យកើតជ្រះថ្លាឡើង សរណគមន៍មិនសៅហ្មងទេ ។ មួយវិញទៀតសោត បុគ្គលណាតិះដៀលព្រះចេតិយ ព្រះពុទ្ធបដិមា ដោយហេតុជាងធ្វើមិនល្អ ប្រាថ្នានឹងឲ្យជាងធ្វើល្អក្តី បុគ្គលនោះក៏មិនបាន

ឈ្មោះថាធ្វើអគារវៈក្នុងព្រះពុទ្ធឡើយ, បុគ្គលបានស្តាប់នូវព្រះធម៌ ដែលបុគ្គលដទៃសម្តែងមិនត្រូវក្តី ស្តាប់មិនយល់មិនចូលចិត្តក្តី សម្គាល់ឃើញថាជាទោសក្នុងទីនោះៗ ហើយពោលចោទថាខុស សាកសួរដើម្បីនឹងជម្រះនូវសេចក្តីសង្ស័យ នឹងចង់ល្បងប្រាជ្ញានៃបុគ្គលដទៃក្តី ឬពោលទោសក្នុងធម៌ឡើងឲ្យបុគ្គលដទៃកម្ចាត់បង់នូវទោសនោះក្តី មិនឈ្មោះថាធ្វើអគារវៈក្នុងព្រះធម៌ទេ, បុគ្គលឃើញភិក្ខុបុថុជ្ជនធ្វើមិនត្រូវ មិនល្អ ដោយកាយទុច្ចរិត និងវចីទុច្ចរិត ហើយពោលតិះដៀលតាមទោសដែលមានក្តី ស្រដីហាមប្រាមដើម្បីនឹងឲ្យវៀរលែងកម្មនោះ ដោយគិតនឹងឲ្យជាប្រយោជន៍ក្តី ក៏មិនឈ្មោះថាធ្វើអគារវៈក្នុងព្រះសង្ឃដែរ ។ តែបើបុគ្គលប្រារព្ធយកហេតុនោះជាដើម ហើយវិតក្កតទៅថា ក្នុងធម៌វិន័យណាមានពាក្យដ៏វិបល្លាសប្រកបដោយទោសដូច្នេះ ទំនងជាធម៌នោះមិនមែនជាធម៌នាំសត្វចេញចាកទុក្ខបានក្តី ក្នុងសាសនាណាមានភិក្ខុជាពាលប្រព្រឹត្តអាក្រក់ដូច្នេះ សាសនានោះឃើញថាមិនមានខ្លឹមសារក្តី បើបុគ្គលសង្ស័យដោយហេតុដូច្នេះហើយ ៗ ញុំាងអកុសលចិត្តឲ្យកើតឡើងសរណគមន៍នោះទើបឈ្មោះថាមានឧបក្កិលេសសៅហ្មង ។ ហេតុដូច្នោះ បើបុគ្គលឃើញនូវទោសក្នុងពាក្យសម្តែងធម៌ដូចពោលមកហើយនោះ ក៏គប្បីសាកសួរអ្នកប្រាជ្ញឲ្យអស់សង្ស័យ បើមិនចូលចិត្ត ក៏គប្បីសន្និដ្ឋានទុកក្នុងចិត្តថា "ធម៌នេះរមែងបរិសុទ្ធផូរផង់ដោយប្រការទាំងពួង" មិន

មានទោសទេ តែយើងស្តាប់មិនយល់មិនចូលចិត្តទៅជាថាខុសក្តី និង ធម្មកថិកអ្នកសម្តែងប្រកាន់ខុសហើយពោលមិនល្អក្តី យើងឃើញដូចជា ពាក្យប្រកបដោយទោស ដែលសម្តែងក្នុងទីនោះៗ ។ បើបុគ្គលឃើញ នូវទុច្ចរិតនៃភិក្ខុជំពូកខ្លះ ក៏គប្បីសន្និដ្ឋានចូលចិត្តថា សេចក្តីអាក្រក់នោះ ជាកម្មរបស់ភិក្ខុនោះឯង កុំគប្បីចូលចិត្តច្រឡំក្នុងពួកព្រះអរិយសង្ឃ ដ្បិតភិក្ខុនោះជាមនុស្សប្រកបដោយកិលេស មិនបានប្រតិបត្តិតាម សម្មាបដិបទាជារបស់នៃព្រះអរិយៈប៉ុណ្ណោះ បើបុគ្គលរក្សានូវសេចក្តីជ្រះថ្លា នៃខ្លួនបានដូច្នេះ សរណគមន៍នៃបុគ្គលនោះ ក៏ពុំសៅហ្មងឡើយ ។

ឯការធ្វើអគារវៈក្នុងព្រះរតនត្រ័យ ប្រកបដោយចិត្តជាអកុសលនោះ បើបុគ្គលធ្វើអគារវៈក្នុងព្រះពុទ្ធរតនៈ កាលបើដឹងទោសខ្លួនហើយ គប្បី សូមខមាទោសក្នុងសំណាក់នៃព្រះពុទ្ធក្តី ក្នុងទីព្រះចេតិយក្តី ក៏ឈ្មោះថា ញុំាងទោសឲ្យជ្រះស្រឡះបាន ។ ដូច ជដិលសេដ្ឋី កាលសាសនាព្រះ ពុទ្ធកស្សប សេដ្ឋីនោះកើតជាជាងទង បានប្រមាថដោយពាក្យអាក្រក់ ចំពោះព្រះពុទ្ធកស្សបជាម្ចាស់ លុះព្រះអង្គស្តេចរំលត់ខន្ធបរិនិព្វានទៅ ហើយ គ្រាក្រោយជាងទងនោះដឹងទោសខ្លួន បាននាំយកផ្កាឈើធ្វើដោយ មាស ៣ សន្ទឹក ទៅកាន់លានព្រះចេតិយ ធ្វើសក្ការបូជា ហើយស្មៀក ដណ្តប់សំពត់ទទឹកជោកជាទណ្ឌកម្ម ទើបក្រាបទូលសូមខមាទោស ដោយចេតនាជាកុសលធ្វើនូវទោសនោះឲ្យជ្រះស្រឡះ ជាងទងនោះមិន

បានទៅកើតក្នុងនរកទេ ។ លុះដល់សាសនាព្រះពុទ្ធជាម្ចាស់យើងនេះ បានមកកើតជាជដិលសេដ្ឋី មានសម្បត្តិ គឺក្អមមាសកម្ពស់ ៨០ ហត្ថ កើតឡើងជាគ្រឿងសម្រាប់បុណ្យ ។ បើបុគ្គលខុសក្នុងព្រះធម្មរតនៈ កាលបើដឹងទោសខ្លួនហើយ គប្បីសូមខមាទោសក្នុងទីសម្តែងធម៌ចំពោះព្រះកក្ត្រព្រះធម្មកថិកក្តី ដូចជាព្រះសុមនត្ថេរ គង់នៅក្នុងព្រះវិហារនាកោះលង្កា បានពោលពាក្យទ្រគោះចំពោះព្រះចុលនាគត្ថេរ ជាកូនសិស្សនៃខ្លួន ដែលពោលនូវធម៌ដ៏ប្រពៃ ថាសម្តីខុសដោយក័ន្តប្រឡំ ។ លុះគ្រាក្រោយបានពិចារណាយល់ឃើញថា ខ្លួនស្រដីមិនត្រូវ ព្រះចុលនាគត្ថេរដែលពោលនោះមិនបានខុសចាកធម៌វិន័យឡើយ ក៏បង្អង់មិនទាន់បានទៅសម្តែងទោសនោះ ។ លុះមកដល់អដ្ឋមីឧបោសថជាទីប្រជុំធំកាលមហាថេរទាំងឡាយជាពហុស្សូតប្រជុំគ្នាច្រើន ព្រះចុលនាគត្ថេរនោះឡើងគង់លើធម្មាសនៈរៀបចំនឹងសម្តែងធម៌ ទើបព្រះសុមនត្ថេរចូលទៅគោះខ្នងធម្មាសនៈឲ្យជាសញ្ញា លុះព្រះចុលនាគត្ថេរបែរក្រឡេកមកហើយ ព្រះសុមនត្ថេរ ក៏សម្តែងនូវទោសដែលខ្លួនស្រដីខុសនោះឲ្យពុប្រាកដឡើងក្នុងកណ្តាលនៃបរិស័ទនោះ ។ បើបុគ្គលធ្វើអគារវៈក្នុងព្រះសង្ឃរតនៈ កាលដឹងទោសខ្លួនហើយ គប្បីឲ្យប្រជុំសង្ឃក្នុងទីសីមាណាមួយ ហើយគប្បីសម្តែងនូវទោសដែលខ្លួនបានធ្វើនោះ រួចសូមខមាទោសចុះ ។ បើបានប្រទូសរ៉ាយដោយកាយ និងវាចាជាអគារវៈ

ដល់ភិក្ខុជាព្រះអរិយៈ និងបុថុជ្ជនមានសីលអង្គណាមួយក្តី ក៏គប្បីចូលទៅជិតភិក្ខុដែលខ្លួនបានប្រមាថនោះ ហើយធ្វើអភិវាទនកម្មនមស្ការ រួចត្រូវសម្តែងនូវទោសដែលខ្លួនបានធ្វើថា "ខ្ញុំព្រះករុណាបានធ្វើដូច្នោះៗ ក្នុងលោកដ៏មានអាយុ ជាកម្មដ៏លាមក សូមលោកដ៏មានអាយុមេត្តាអត់ទោសនោះៗ ដល់ខ្ញុំព្រះករុណា" ។ បុគ្គលបានធ្វើដូច្នេះ ឈ្មោះថាញុំាងទោសឲ្យរម្ងាប់បាន, បើភិក្ខុដែលខ្លួនប្រមាថទៅកាន់ទីឆ្ងាយ ឬនៅទីឆ្ងាយខ្លួនមិនអាចទៅដល់ ក៏គប្បីបញ្ជូនពាក្យបណ្តាំទៅសូមខមាទោសចុះ, បើភិក្ខុដែលខ្លួនប្រមាថនោះជាព្រះអរហន្ត រំលត់ខន្ធបរិនិព្វានទៅហើយ បុគ្គលនោះគប្បីតាមទៅខមាទោសក្នុងទីបរិនិព្វាន ទីដែលធ្វើឈាបនកិច្ចនិងចេតិយស្ថានជាទីបញ្ចុះព្រះធាតុនៃព្រះអរហន្តនោះ ហើយធ្វើសក្ការ-បូជានឹកគោរពដល់លោកដែលគង់ព្រះជន្មនៅ រួចសូមខមាទោសចុះ ។ ទោះបីព្រះសេខបុគ្គលនិងភិក្ខុបុថុជ្ជនដែលមានសីលបរិសុទ្ធ ធ្វើកាលកិរិយាក្ស័យជីវិតទៅកើតក្នុងទីដទៃ ក៏ត្រូវប្រព្រឹត្តដូចពោលហើយនោះ ។ បើភិក្ខុដែលខ្លួនប្រមាថនោះ ជាភិក្ខុចរទៅម្នាក់ឯង គ្មានទីសំណាក់អាស្រ័យនៅក្តី ទីធ្វើកាលកិរិយាក្ស័យជីវិតទៅក្តី នៃភិក្ខុនោះមិនប្រាកដត្រង់ណាសូម្បីដូច្នោះ បុគ្គលដែលធ្វើខុស គប្បីទៅកាន់សំណាក់នៃសង្ឃក្តី នៃភិក្ខុដែលជាអ្នកប្រាជ្ញអង្គណាមួយក្តី ហើយសម្តែងនូវទោសដែលខ្លួនធ្វើនោះថា ខ្ញុំព្រះករុណាធ្វើខុសដូច្នេះៗ ដល់លោកដ៏មានអាយុអង្គនោះៗ

សូមលោកអត់ទោសដល់ខ្ញុំព្រះករុណាចុះ ហើយគប្បីមើលទៅដោយសម្គាល់ឃើញថា ភិក្ខុនោះនៅក្នុងទិសណា ឲ្យបែរមុខត្រង់ទៅទិសនោះ ហើយឱនទមស្ការពោលថា **សោ ខមតុ** លោកដ៏មានអាយុនោះចូរអត់ទោសដល់ខ្ញុំព្រះករុណាផងចុះ ។ បើបុគ្គលជាឧបាសក ឧបាសិកា ធ្វើខុសឃើញទោសដូច្នេះហើយ ស្វែងរកសង្ឃ រកបុគ្គលមិនបាន នឹងសម្តែងទោសក្នុងសំណាក់នៃឧបាសក ដែលជាបុគ្គលឈ្លាសវៃក្នុងធម៌វិន័យ និងមានសីលស្មើគ្នា ហើយធ្វើនមស្ការដល់ព្រះរតនត្រ័យ ទើបសូមខមាទោស ក៏ឃើញថាគួរ ។ ឯវិធីខមាទោសនោះ សូមមើលទំព័រទី ៥ ខាងដើម ។

[១]បុ. ទី ២- **កាស្មា ឧបាសកោតិ វុច្ចតិ** ហេតុដូចម្តេចបានជាហៅថាឧបាសក?

[២]វិ. ទី ២- សេចក្តីក្នុងសំណួរទី ២ នេះ តាមច្បាប់នៃឧបោសថកថា ថាព្រោះបុគ្គលនោះចូលទៅអង្គុយជិតព្រះរតនត្រ័យ, មានន័យដូចម្តេចពុំបានពណ៌នា ។ តែបើតាមសំណួរនេះគួរយល់ថា ព្រោះហេតុបុគ្គលនោះជឿគុណព្រះរតនត្រ័យ បានប្រតិបត្តិប្រកបដោយអាការៈទាំង ៤ ប្រការណាមួយ ដូចន័យដែលបានពោលហើយក្នុងសំណួរទី ១ ខាងដើម ។

១- បុ. ពាក្យបំប្រួញ គឺបុច្ឆា ជាពាក្យពេញ, ២- វិ. ពាក្យបំប្រួញ គឺ វិសជ្ជនាជាពាក្យពេញ ។

បុ. ទី ៣- **កិមស្ស សីលំ** សីលនៃឧបាសកនោះ តើដូចម្តេច?

វិ. ទី ៣- សីលនៃឧបាសកនោះ, តាមន័យនៃមហានាមសូត្រ ព្រះមានព្រះភាគ ទ្រង់សម្តែងចំពោះសាក្យមហានាមថា បាននឹងនិច្ចសីល, គឺ វេរវិរតិ ៥, ឬបញ្ចសីល (សីល ៥), ថាជាសីលនៃគ្រហស្ថ គឺជាសីលនៃឧបាសក ។

អំពីនិច្ចសីល

ពាក្យដែលពោលថា **សីលៈ** ៗ ប្រែថា ប្រក្រតី កាយ វាចា ល្អ, ទម្លាប់ កាយ វាចារៀបរយល្អ, សណ្តាប់ធ្នាប់ កាយ វាចា ល្អ, ឈ្មោះថាសីល ។

ពាក្យដែលពោលថា **និច្ចសីលៈ** ៗ ប្រែថា សីលដែលបុគ្គលត្រូវរក្សាជាប់ជានិច្ច មិនដែលខានពេលណា ឈ្មោះថា និច្ចសីល, និច្ចសីលនេះប្រកបដោយអង្គ ៥ ឬមានសិក្ខាបទ ៥ គឺ

១- វៀរចាកសម្លាប់សត្វដោយខ្លួនឯង និងប្រើអ្នកដទៃឲ្យសម្លាប់,

២- វៀរចាកលួចលាក់បំបាត់ទ្រព្យអ្នកដទៃដោយខ្លួនឯង និងប្រើអ្នកដទៃឲ្យលួចលាក់បំបាត់,

៣- វៀរចាកប្រព្រឹត្តខុសក្នុងកាមទាំងឡាយ, (គឺប្រព្រឹត្តខុសក្នុងវត្ថុដែលជាទីប្រាថ្នា មានបុត្រ ភរិយា ស្វាមីនៃអ្នកដទៃ) ជាដើម ។

៤- វៀរចាកនិយាយកុហកអ្នកដទៃ ។

៥- វៀរចាកហេតុជាទីតាំងនៃសេចក្ដីប្រមាទ, គឺផឹកសុរា និងមេរ័យដែលជាគ្រឿងស្រវឹងផ្សេងៗ ។

កិច្ចដែលឧបាសក ឧបាសិកា នឹងសមាទាននូវនិច្ចសីល ប្រកបដោយអង្គ ៥ ឬមានសិក្ខាបទ ៥ នេះ គប្បីនមស្ការនឹករឭកដល់ព្រះរតនត្រ័យជាមុន រួចហើយទើបសមាទានសីលជាក្រោយ ត្រូវប្រកបដោយវិរតិចេតនា សមាទានកាន់យកដោយខ្លួនឯងក្ដី ក្នុងសំណាក់នៃភិក្ខុសាមណេរ ឬឧបាសក ឧបាសិកា ដែលមានសីល ១០ ឬ សីល ៨ ក្ដី តាមសមគួរដល់កិច្ចដែលអាចធ្វើបាន ។ ឯកិច្ចដែលនមស្ការនិងសមាទាននូវនិច្ចសីលនេះ តាមបុរាណាចារ្យលោកបានរៀបចំទុកមកជារបៀបដូច្នេះ ៖

## កិច្ចនមស្ការ

ទី ១- ប្រកាសខ្លួនដោយបាលីថា **អហំ ពុទ្ធញ្ច ធម្មញ្ច, សង្ឃញ្ច សរណំ គតោ ។ ល ។**[១]

ទី ២- ថ្វាយបង្គំព្រះរតនត្រ័យ ដោយបាលីថា **អរហំ**

---

១- បានពោលហើយខាងដើម ត្រង់កិច្ចប្រកាសខ្លួនជាឧបាសក ។

**សម្មាសម្ពុទ្ធោ ភគវា ។ ល ។**[១]

*ទី ៣- ថ្វាយគ្រឿងសក្ការៈ ដោយបាលីថា* **ឥមានិ មយំ បដិមារូចានិ ។ ល ។**[២] *ឬ* **យមហំ សម្មាសម្ពុទ្ធំ ភគវន្តំ សរណំ គតោ ។ ល ។**[៣]

*ទី ៤- នមស្ការព្រះរតនត្រ័យ ដោយបាលីថា* **នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស,** *៣ ដង*[៤] *ដូច្នេះ ជាដើម ។ បើនឹងសូត្រជមិងទៃតាមប្រាថ្នាតទៅទៀតក៏គួរ ។*

## កិច្ចសមាទាននិច្ចសីល

*ទី ១- អារាធនាសមាទាននូវនិច្ចសីល ដោយបាលីថា :*

**អហំ**[៥] / **មយំ** } **ភន្តេ តិសរណេន សហ, បញ្ចង្គសមន្នាគតំ**

**និច្ចសីលំ យាចា** **មិ**[៦] / **ម** } *៣ ដង ។*

*បពិត្រព្រះករុណាដ៏ចម្រើន!* *ខ្ញុំព្រះករុណា*[៧] / *យើងខ្ញុំព្រះករុណា* } *សូមនូវនិច្ចសីល*

---

១-២-៣- មានពោលដោយពិស្តារក្នុងច្បាប់វិធីថ្វាយបង្គំព្រះ ផ្សាយចេញពីសង្ឃបណ្ណាល័យវត្តបទុមវតី ។ នឹងមានពោលនៅខាងចុងនៃច្បាប់នេះ ។

៤- បានពោលហើយនៅខាងដើមត្រង់នមស្ការ ។

៥-៦- អហំ, មិ សម្រាប់មនុស្សម្នាក់ថា, មយំ, ម សម្រាប់មនុស្សច្រើននាក់ថា ។

៧-ខ្ញុំព្រះករុណាសម្រាប់មនុស្សម្នាក់ថា, យើងខ្ញុំព្រះករុណា សម្រាប់មនុស្សច្រើននាក់ថា ។

ដែលប្រកបដោយអង្គប្រាំប្រការ ព្រមទាំងព្រះត្រៃសរណគមន៍ ។

ទី ២- សមាទាននូវនិច្ចសីលប្រកបដោយអង្គ ៥ ឬសិក្ខាបទ ៥ ប្រការ តាមលំដាប់បាលីថា :

១- **បាណាតិបាតា វេរមណីសិក្ខាបទំ សមាទិយាមិ** ខ្ញុំព្រះករុណា សមាទាននូវសិក្ខាបទ, គឺវៀរចាកសម្លាប់សត្វដោយខ្លួនឯង, និងប្រើអ្នកដទៃឲ្យសម្លាប់ ។

២- **អទិន្នាទានា វេរមណីសិក្ខាបទំ សមាទិយាមិ** ខ្ញុំព្រះករុណា សមាទាននូវសិក្ខាបទ, គឺវៀរចាកលួចលាក់បំបាត់ទ្រព្យអ្នកដទៃដោយខ្លួនឯង, និងប្រើអ្នកដទៃឲ្យលួចលាក់បំបាត់ ។

៣- **កាមេសុ មិច្ឆាចារា វេរមណីសិក្ខាបទំ សមាទិយាមិ** ខ្ញុំព្រះករុណា សមាទាននូវសិក្ខាបទ, គឺវៀរចាកប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ។

៤- **មុសាវាទា វេរមណីសិក្ខាបទំ សមាទិយាមិ** ខ្ញុំព្រះករុណា សមាទាននូវសិក្ខាបទ, គឺវៀរចាកនិយាយកុហកអ្នកដទៃ ។

៥- **សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណីសិក្ខាបទំ សមាទិយាមិ** ខ្ញុំព្រះករុណា សមាទាននូវសិក្ខាបទ, គឺវៀរចាកហេតុជាទីតាំងនៃសេចក្តីប្រមាទ, គឺផឹកនូវសុរា និងមេរ័យ, ដែលជាគ្រឿងស្រវឹងផ្សេងៗ ។

ឯនិច្ចសីលប្រកបដោយអង្គ ៥ ឬមានសិក្ខាបទ ៥ គឺវេរវិរតិ ៥ ប្រការនេះ, ក្នុងមហានាមសូត្រពោលថា ព្រះមានព្រះភាគទ្រង់ត្រាស់សម្ដែងចំពោះសាក្យមហានាមថា ឧបាសកណាបានវៀរចាកវេរា ៥ ប្រការនេះ ឧបាសកនោះ ឈ្មោះថា ជាអ្នកមានសីល, និងទ្រង់ត្រាស់សម្ដែងថា ការវៀរចាកវេរា ៥ ប្រការនេះ ថាជាសីលនៃឧបាសក ឬ ថាជាសីលនៃគ្រហស្ថ ។ មួយទៀត ព្រះមានព្រះភាគទ្រង់ត្រាស់សម្ដែងថា ការវៀរចាកវេរា ៥ ប្រការនេះ ឈ្មោះថា **អភយទាន** ឬ **អវេរទាន** ។ អភយទានប្រែថា ការឲ្យនូវអភ័យ គឺឲ្យរួចចាកសេចក្ដីខ្លាច ឲ្យនូវសេចក្ដីមិនមានទុក្ខ និងសេចក្ដីមិនបៀតបៀនផ្សេងៗ ដល់សត្វទាំងឡាយ, អវេរទាន ប្រែថា ការឲ្យសេចក្ដីមិនមានពៀរ គឺមិនចងពៀរគ្នា ចំពោះសត្វទាំងឡាយ ។

## អង្គនៃសិក្ខាបទទាំង ៥ គឺ

និច្ចសីលមានសិក្ខាបទ ៥ នេះ ក្នុងសិក្ខាបទមួយៗ មានអង្គសម្រាប់វិនិច្ឆ័យឲ្យដឹងជាក់ច្បាស់ថា អ្នករក្សាសិក្ខាបទនោះៗ បានបរិសុទ្ធផូរផង់ ឬក៏ដាច់ធ្លុះធ្លាយ ដូចតទៅនេះ៖

## បាណាតិបាតមានអង្គ ៥ គឺ

១- **បាណោ** សត្វមានជីវិត

២- **បាណសញ្ញី** ដឹងថាសត្វមានជីវិត

៣- **វធកចិត្តំ** ចិត្តគិតនឹងសម្លាប់

៤- ឧបក្កមោ ព្យាយាមនឹងសម្លាប់

៥- តេន មរណំ សត្វស្លាប់ដោយព្យាយាមនោះ ។

## អទិន្នាទានមានអង្គ ៥ គឺ

១- បរបរិគ្គហិតំ ទ្រព្យមានម្ចាស់គ្រប់គ្រងរក្សាទុក,

២- បរបរិគ្គហិតសញ្ញី[១] ដឹងថាទ្រព្យមានម្ចាស់គ្រប់គ្រងរក្សាទុក,

៣- ថេយ្យចិត្តំ ចិត្តគិតនឹងលួចយក,

៤- ឧបក្កមោ ព្យាយាមនឹងលួចយក,

៥- តេន ហរណំ លួចយកបានដោយព្យាយាមនោះ ។

## កាមេសុមិច្ឆាចារមានអង្គ ៤ គឺ

១- អគមនីយវត្ថុ វត្ថុមិនគួរដល់គឺមិនគួរសេព,

២- តស្មឹ សេវនចិត្តំ ចិត្តគិតនឹងសេពក្នុងអគមនីយវត្ថុនោះ,

៣- សេវនប្បយោគោ ព្យាយាមនឹងសេព,

៤- មគ្គេន មគ្គប្បដិបាទនំ[២] ញាំងមគ្គនិងមគ្គឲ្យដល់គ្នា ។

## មុសាវាទមានអង្គ ៤ គឺ

១- អតថំ វត្ថុ វត្ថុមិនពិតត្រង់,

---

១- តាមមង្គលត្ថទីបនីថា បរបរិគ្គហិតសញ្ញិតា ។ ២- តាមមង្គលត្ថទីបនីថា មគ្គេន មគ្គប្បដិបត្តិ អធិវាសនំ ។

២- **វិសំវាទនចិត្តំ** *ចិត្តគិតនឹងនិយាយឲ្យខុស,*

៣- **តជ្ជោ វាយាមោ** *ព្យាយាមនឹងនិយាយពាក្យដែលខុសនោះ,*

៤- **បរស្ស តទត្ថវិជាននំ** *ញុំាងអ្នកដទៃឲ្យដឹងច្បាស់នូវសេចក្តីនោះ ។*

## សុរាមេរយៈមានអង្គ ៤ គឺ

១- **មទនីយវត្ថុ** *វត្ថុដែលស្រវឹង,*

២- **ចាតុកាម្យតាចិត្តំ** *ចិត្តប្រាថ្នាដើម្បីនឹងផឹក,*

៣- **តជ្ជោ វាយាមោ** *ព្យាយាមនឹងផឹកនូវវត្ថុស្រវឹងនោះ,*

៤- **បិវតិបវិសនំ** *ផឹកចូលទៅក្នុងបំពង់កកើតរឹករាយ ។*

*អង្គនៃសិក្ខាបទទាំងឡាយនេះ គប្បីដឹងថា កាលឧបាសក ឧបាសិកាប្រព្រឹត្តកន្លងសិក្ខាបទណា បើកិរិយាធ្វើនោះ ប្រកបព្រមដោយអង្គនោះៗ គប្បីដឹងថា សិក្ខាបទនោះ ដាច់ធ្លុះធ្លាយហើយ បើមិនប្រកបព្រមដោយអង្គទេ ឈ្មោះថាគង់នៅ តែមិនបរិសុទ្ធផូរផង់ ។*

## អំពីអានិសង្សនៃសីលសម្បត្តិ

*ពាក្យថា* **សីលសម្បត្តិ** *សំដៅយកបុគ្គលដែលសមាទានរក្សាសីលតាំងនៅដោយបរិសុទ្ធ មិនប្រព្រឹត្តកន្លងសិក្ខាបទណាមួយ ឈ្មោះថាសីលសម្បត្តិ ។*

(១)អានិសង្សនៃសីលសម្បត្តិនេះ ព្រះមានព្រះភាគទ្រង់ត្រាស់សម្ដែងប្រាប់ពួកគហបតី អ្នកស្រុកបាតលិគ្រាម ដោយនិទស្សនន័យដូច្នេះថា :

## បុគ្គលអ្នកមានសីលបរិសុទ្ធមានអានិសង្ស ៥ យ៉ាងគឺ

១- **អប្បមាទាធិករណំ មហន្តំ ភោគក្ខន្ធំ អធិគច្ឆតិ** បុគ្គលអ្នកមានសីលបរិសុទ្ធ រមែងបាននូវភោគសម្ប័ទដ៏ធំវិសេស មានសេចក្ដីមិនប្រមាទជាហេតុ ។

២- **កល្យាណោ កិត្តិសទ្ទោ អព្ភុគ្គច្ឆតិ** កិត្តិស័ព្ទដ៏ពីរោះនៃបុគ្គលអ្នកមានសីលបរិសុទ្ធ រមែងខ្ចរខ្ចាយទៅសព្វទិស ។

៣- **យទិ ខត្តិយបរិសំ យទិ ព្រាហ្មណបរិសំ យទិ គហបតិបរិសំ យទិ សមណបរិសំ វិសារទោ ឧបសង្កមតិ អមង្កុភូតោ** បុគ្គលអ្នកមានសីលបរិសុទ្ធ កាលបើចូលកាន់ទីប្រជុំនៃក្សត្រិយ៍, ព្រាហ្មណ៍, គហបតី, សមណៈ បរិស័ទណាៗ ក៏មិនកោតញញើតក្រែងខ្លាចតេជានុភាពនៃបរិស័ទនោះៗ គឺជាបុគ្គលក្លាហានមិនអៀនអន់ ។

៤- **អសម្មុឡ្ហោ កាលំ ករោតិ** បុគ្គលអ្នកមានសីលបរិសុទ្ធ ជាមនុស្សមិនវង្វេង ក្នុងខណៈធ្វើកាលកិរិយា ។

---
១- សុត្តន្តបិដក ទីឃនិកាយ មហាវគ្គ មហាបរិនិព្វានសូត្រ ទំព័រ ១៨៥ ។

៥- **សុគតឹ សគ្គំ លោកំ ឧបបជ្ជតិ** *បុគ្គលអ្នកមានសីលបរិសុទ្ធ កាលបែករាងកាយទៅខាងមុខអំពីមរណៈហើយ រមែងកើតក្នុងសុគតិលោក គឺសួគ៌ ។*

*កាលបុគ្គលសមាទាននិច្ចសីលមានសិក្ខាបទ ៥ ចប់ហើយ លោកអ្នកឲ្យសីល រមែងប្រាប់អានិសង្ស ៣ ប្រការគឺ*(១) ៖

១- **សីលេន សុគតឹ យន្តិ** *ជនទាំងឡាយបានសុគតិដោយសារសីល,*

២- **សីលេន ភោគសម្បទា** *ជនទាំងឡាយបានភោគសម្ប័ទ ដោយសារសីល,*

៣- **សីលេន និព្វុតឹ យន្តិ** *ជនទាំងឡាយបានព្រះនិព្វានដោយសារសីល ។*

## អំពីអាទីនវៈ គឺទោសនៃសីលវិបត្តិ

*ពាក្យថា* **សីលវិបត្តិ** *សំដៅយកអ្នកប្រព្រឹត្តកន្លងសីល គឺមិនរក្សាសីល ឬថាទ្រុស្តសីល ។*

**អាទីនវៈ**(២) *គឺទោសនៃសីលវិបត្តិនេះ ព្រះមានព្រះភាគទ្រង់ត្រាស់សម្តែងប្រារព្ធនឹងគហបតី អ្នកស្រុកបាតលិគ្រាមនោះដែរ ដោយនិទស្សនន័យដូច្នេះថា ៖*

---

១- តាមច្បាប់វិធីថ្វាយបង្គំព្រះ ផ្សាយចេញពីសង្ឃបណ្ណាល័យវត្តបទុមវតី ។

២- សុត្តន្តបិដក ទីឃនិកាយ មហាវគ្គ មហាបរិនិព្វានសូត្រ ទំព័រ ១៨៤ ។

## បុគ្គលមិនមានសីល មានទោស ៥ យ៉ាងគឺ

១- រមែងវិនាសភោគៈ ព្រោះមានសេចក្ដីក្ដៅក្រហាយជាហេតុ,

២- ល្បីកេរ្ដិ៍ឈ្មោះអាក្រក់ មិនពីរោះស្ដាប់នៃជនទាំងពួង,

៣- បើចូលកាន់ទីប្រជុំនៃក្សត្រិយ៍, ព្រាហ្មណ៍, គហបតី, សមណៈ និងបរិស័ទនានា ក៏មិនមានតេជានុភាព មិនក្លាហានឡើយ,

៤- មានស្មារតីវង្វេងវាយមាយក្នុងវេលាជិតនឹងស្លាប់ ព្រោះមានវិប្បដិសារី ក្ដៅក្រហាយស្ដាយក្រោយដោយសីលវិបត្តិនៃខ្លួន,

៥- លុះដល់ទម្លាយខន្ធទៅហើយ រមែងទៅកាន់អបាយភូមិ ។

**ឯវំ វុត្តញ្ច** និច្ចសីលដែលមានន័យដូចពោលមកហើយនេះ ជាសីលយ៉ាងទាប ជាសីលជាន់ដំបូង, ជាគ្រឿងលះកិលេសយ៉ាងគ្រោតគ្រាត ។

ឯនិច្ចសីលនេះ ជាប្រធាននៃសីលទាំងអស់ ព្រោះថាឧបោសថសីលក្ដី អតិរេកសីលក្ដី សីល ១០ របស់សាមណេរក្ដី សីល ៤ របស់ភិក្ខុក្ដី សុទ្ធតែកើតអំពី **និច្ចសីល** ។ បើបុគ្គលណារក្សានិច្ចសីលមិនជាប់ទេ បុគ្គលនោះនឹងរក្សាសីលអ្វីៗ ទៀត មានឧបោសថសីលជាដើមក៏មិនជាប់ដែរ ។ ម្យ៉ាងទៀត និច្ចសីលនេះ ជាសីលសម្រាប់លោក ជាសីលរបស់អ្នកស្រឡាញ់សុខ ស្អប់ខ្ពើមទុក្ខ សូម្បីក្នុងកាលចន្លោះព្រះពុទ្ធក៏មាននិច្ចសីលដែរ ។

**យោ ច សទ្ធាសម្បន្នោ** បុគ្គលជាឧបាសក ឧបាសិកាណា ប្រកបដោយសទ្ធា ចិត្តជឿជាក់ច្បាស់នូវសាសនានៃព្រះមានព្រះភាគ ខ្ជាំងក្លាហើយ ប្រាថ្នានឹងបំពេញកុសលដោយការរក្សាសីលឲ្យលើសពីនិច្ចសីលតទៅទៀត, បុគ្គលជាឧបាសក ឧបាសិកានោះ គប្បីរក្សានូវឧបោសថសីលតទៅ។

## អំពីឧបោសថសីល

ព្រះមានព្រះភាគ ទ្រង់ត្រាស់សម្ដែងឧបោសថសីល ចំពោះនាងវិសាខាមហាឧបាសិកា, តាមន័យដែលមានមកក្នុងឧបោសថសូត្រ និងរាជសូត្រ ។

ពាក្យថា **ឧបោសថៈ ៗ** ប្រែថា សីលជាទីញ៉ាំងចិត្តនៃអ្នករក្សាឲ្យបរិសុទ្ធស្អាតប្រាសចាកទោស ។ ឧបោសថសីលនេះប្រកបដោយអង្គ ៨ ឬមានសិក្ខាបទ ៨ ប្រការគឺ

១- វៀរចាកសម្លាប់សត្វដោយខ្លួនឯង និងប្រើអ្នកដទៃឲ្យសម្លាប់,

២- វៀរចាកលួចលាក់បំបាត់ទ្រព្យអ្នកដទៃដោយខ្លួនឯង និងប្រើអ្នកដទៃឲ្យលួចលាក់បំបាត់,

៣- វៀរចាកសេពនូវមេថុនធម៌,

៤- វៀរចាកនិយាយកុហកអ្នកដទៃ,

៥- វៀរចាកហេតុជាទីតាំងនៃសេចក្ដីប្រមាទ, គឺផឹកសុរា និង

មេរ័យ ដែលជាគ្រឿងស្រវឹងផ្សេងៗ,

៦- វៀរចាកបរិភោគអាហារក្នុងវេលាខុស,

៧- [១]វៀរចាករាំច្រៀងប្រគំតូរ្យតន្ត្រី, ព្រមទាំងមើលស្ដាប់របាំចម្រៀងតូរ្យតន្ត្រីដែលជាសត្រូវដល់កុសលធម៌, និងវៀរចាកប្រដាប់តាក់តែងរាងកាយ ដោយកម្រងផ្កា, គ្រឿងក្រអូប, គ្រឿងលាប, និងគ្រឿងអលង្ការផ្សេងៗ,

៨- វៀរចាកទីដេកទីអង្គុយដ៏ខ្ពស់, និងទីដេកទីអង្គុយដ៏ធំ និងប្រសើរ ។

**តិវិធំ ឧបោសថកម្មំ** វិឧបោសថកម្មនោះ ស្រដីតាមកាលសម្រាប់រក្សាមាន ៣ ប្រការគឺ

**១- បកតិឧបោសថ ។**

**២- បដិជាគរឧបោសថ ។**

**៣- បាដិហារិយឧបោសថ ។**

**តេសំ អត្ថោ** អត្ថនៃឧបោសថទាំង ៣ នេះ បើពោលតាមព្យញ្ជនៈ, ពាក្យថា **បកតិឧបោសថ** ប្រែថា ឧបោសថនៃបុគ្គលអ្នកប្រព្រឹត្តទៅដោយប្រក្រតី, គឺថាជាឧបោសថដែលអ្នកប្រាជ្ញធ្វើមកអំពីកាលមុន, ប្រកបដោយអង្គ ៨ ឬ សិក្ខាបទ ៨ ប្រការ រក្សាកំណត់អស់ថ្ងៃ ១

---

១- បានជាប្រែ រាំ នៅមុនច្រៀង ព្រោះតាមបាលីនៃសិក្ខាបទនេះគឺ នច្ច រាំ ឬរបាំ, គីត ច្រៀង ឬ ចម្រៀង ។

*យប់ ១ ក្នុង ១ ខែ ៨ ដង ។* **បដិជាគរឧបោសថ** *ប្រែថា ឧបោសថនៃបុគ្គលភ្ញាក់រឭករឿយៗ គឺរក្សាឧបោសថវិសេសក្នុងថ្ងៃខាងមុខ និងថ្ងៃខាងក្រោយនៃថ្ងៃបកតិឧបោសថទាំង ៨ ។* **បាដិហារិយឧបោសថ** *ប្រែថា ឧបោសថដែលបុគ្គលគប្បីរក្សាឲ្យជាប់រៀងទៅ, រាល់ថ្ងៃ កំណត់ក្នុង ១ ឆ្នាំ រក្សាម្តង តាមកាលដ៏គួរ ។*

## អំពីកាលសម្រាប់រក្សានូវឧបោសថ

*កាលដែលត្រូវរក្សាឧបោសថនោះ តាមពាក្យក្នុងគម្ពីរអដ្ឋកថាទាំងពួងថា* **បកតិឧបោសថ** *ត្រូវរក្សាក្នុងថ្ងៃ ៥ កើត ៨ កើត ១៤ កើត ១៥ កើត ថ្ងៃទាំង ៤ នេះ ជាថ្ងៃឧបោសថក្នុងសុក្កបក្ខ, ថ្ងៃ ៥ រោច ៨ រោច ១៤ រោច ១៥ រោច ថ្ងៃទាំង ៤ នេះជាថ្ងៃឧបោសថក្នុងកាឡបក្ខ, ក្នុង ១ ខែមានបកតិឧបោសថកាល ៨ ថ្ងៃ ។* **តទញ្ញ និច្ចសីលំ** *រីថ្ងៃទាំងឡាយដទៃមិនមែនជាថ្ងៃបកតិឧបោសថ បុគ្គលគប្បីរក្សានូវនិច្ចសីល គឺសីល ៥ និងកម្មបថ ១០*[១] *ហើយនិងបម្រើមាតាបិតា គ្រូឧបជ្ឈាយ៍ និងអាចារ្យតទៅ ។*

**បដិជាគរឧបោសថ** *ក្នុង ១ ខែរក្សាបាន ១១ ថ្ងៃ គឺថ្ងៃ ៤ កើត ៦ កើត ៧ កើត ៩ កើត ១៣ កើត, ថ្ងៃ ១ រោច ៤ រោច ៦ រោច ៧ រោច ៩ រោច ១៣ រោច ផ្សំទាំងអស់ជាថ្ងៃបដិជាគរឧបោសថកាល*

---

១- កម្មបថ នឹងមានពោលនៅខាងចុងនៃច្បាប់នេះ ។

១១ ថ្ងៃៗ ថ្ងៃនេះជាថ្ងៃខាងដើម និងខាងចុងនៃថ្ងៃបកតិឧបោសថ, បើខែខាត លោកឲ្យយកថ្ងៃ ១២ រោច ជាថ្ងៃបដិជាគរឧបោសថ ព្រោះយកថ្ងៃ ១៣ រោច ១៤ រោច ជាថ្ងៃបកតិឧបោសថ ។ ក្នុងដីកានៃរាជ-សូត្រពោលទុកដោយវិសេសថា ចាតុទ្ទសីឧបោសថ ថ្ងៃ ១៤ ខាងខ្នើត និងថ្ងៃចាតុទ្ទសីឧបោសថ ថ្ងៃ ១៤ ខាងរនោច ថ្ងៃទាំង ២ នេះគ្មានថ្ងៃជូនទេ បណ្ណរសីឧបោសថថ្ងៃ ១៥ ខាងខ្នើតនោះ មានតែថ្ងៃ ១ រោចជាថ្ងៃជូន គ្មានថ្ងៃទទួល, បណ្ណរសីឧបោសថ ថ្ងៃ ១៥ ខាងរនោច និងចាតុទ្ទសីឧបោសថថ្ងៃ ១៤ ខាងរនោចក្នុងខែខាត ថ្ងៃទាំង ២ នេះគ្មានថ្ងៃទទួលនិងថ្ងៃជូនទេ ព្រោះថ្ងៃបដិបទ ១ កើតខែថ្មីនឹងយកមកផ្សំជាថ្ងៃជូនក្នុងខែកន្លងទៅនោះមិនបាន ព្រះអដ្ឋកថាចារ្យមិនបានអនុញ្ញាតទេ ។ កាលពិគ្រោះមើលតាមគម្ពីរអដ្ឋកថាទាំងពួង បានសេចក្ដីថា បដិជាគរ-ឧបោសថ គឺរក្សាក្នុងថ្ងៃទទួលនិងថ្ងៃជូននោះ ជាឧបោសថសម្រាប់បុគ្គលដែលមានសទ្ធាខ្លាំងក្លា ចង់រក្សាឲ្យបានថ្ងៃច្រើនជាងបកតិឧបោសថប៉ុណ្ណោះ ។ បើបុគ្គលមិនឧស្សាហ៍ទេ ទោះបីរក្សាតែបកតិឧបោសថទាំង ៨ ថ្ងៃក៏គួរ តាមតែសទ្ធា ។ បើបុគ្គលមិនរក្សាបកតិឧបោសថទេនឹងរក្សាតែបដិជាគរឧបោសថប៉ុណ្ណោះមិនគួរ ព្រោះបដិជាគរឧបោសថនេះ ជាបដិជគ្គនបក្ខ គឺជាថ្ងៃបក្ខពួកដែលត្រូវជម្រះឧបោសថក្នុងថ្ងៃបកតិឧបោសថឲ្យបរិសុទ្ធក្រៃលែងប៉ុណ្ណោះ ។ **តេជញ្ញ និច្ចសីលំ**

រីថ្ងៃទាំងឡាយមិនមែនជាថ្ងៃបដិជាគរឧបោសថ គប្បីរក្សានូវនិច្ចសីល គឺសីល ៥ និងកម្មបថ ១០ ហើយនិងបម្រើមាតាបិតា គ្រូឧបជ្ឈាយ៍ និងអាចារ្យតរៀងទៅ ។

**បាដិហារិយឧបោសថ** ព្រះអដ្ឋកថាចារ្យអនុញ្ញាតទុកថា បើបុគ្គលអ្នករក្សាឧបោសថនោះ មានធុរៈកង្វល់ដោយការងារផ្សេងៗ មិនបានឱកាសដើម្បីនឹងរក្សាឧបោសថទេ នឹងរក្សាតែនិច្ចសីល គឺសីល ៥ និងកម្មបថ ១០ រាល់ខែ មិនបានរក្សាឧបោសថសោះ ក៏គួរ តែថាក្នុងឆ្នាំនោះ ត្រូវឧបាសកនោះធ្វើបាដិហារិយឧបោសថសង់ជួសម្តងទើបគួរ កាលប្រតិបត្តិដូច្នេះ រដូវកាលទាំង ៨ ខែ គឺរដូវក្តៅ ៤ ខែ រដូវរងា ៤ ខែ ក៏ជាកាលនៃនិច្ចសីល គឺសីល ៥ ទាំងអស់ មិនបានជាកាលនៃបាដិហារិយឧបោសថទេ តែខែទាំង ៤ ដែលមានក្នុងរដូវភ្លៀងជាកាលនៃបាដិហារិយឧបោសថទាំងអស់ ។ បាដិហារិយឧបោសថនោះ ស្រដីតាមអដ្ឋកថា និងដីកានៃរាជសូត្រ ប្រែថា ឧបោសថដែលបុគ្គលគប្បីរក្សាឲ្យជាប់រៀងទៅរាល់ថ្ងៃ កំណត់ក្នុង ១ ឆ្នាំរក្សាម្តង តាមកាលដ៏គួរ, ហេតុដូច្នោះបុគ្គលដែលមិនបានសមាទាននូវឧបោសថក្នុងថ្ងៃបកតិឧបោសថទេ គប្បីសមាទានឲ្យជាប់រៀងទៅ អស់កាល ៣ ខែព្ធដ៏ខាងក្នុងវស្សា កាលប្រតិបត្តិដូច្នេះ ឈ្មោះថា **តេមាសនិពទ្ធបាដិហារិយឧបោសថ**, បើមិនអាចដើម្បីនឹងរក្សាដូច្នេះបាន នឹងរក្សាឲ្យជាប់រៀងទៅរាល់ថ្ងៃ តែមួយខែ

ជាចន្លោះនៃបវារណាទាំង ២ គឺតាំងអំពីមួយរោចខែអស្សុជ ទៅដល់ពេញបូណ៌មីខែកត្តិក ក៏គួរ ហៅថា **ឯកមាសនិពទ្ធឧបោសថ**, បើមិនអាចដើម្បីនឹងរក្សាដូច្នោះទៀត នឹងរក្សាតែកន្លះខែ តាំងអំពីមួយរោចខែអស្សុជ ដរាបអស់ខែអស្សុជ ក៏គួរ ឈ្មោះថា **អឌ្ឍមាសបាដិហារិយនិពទ្ធឧបោសថ** ។ ឯវត្តប្រតិបត្តិក្នុងបាដិហារិយឧបោសថ ដូចពណ៌នាមកនេះ តាមអដ្ឋកថានិងដីកានៃរាជសូត្រ ។

ក្នុងធម្មិកសូត្រ ដែលមានមកក្នុងគម្ពីរសុត្តនិបាតនោះ ពោលថាព្រះមានព្រះភាគទ្រង់សម្ដែងថា ឧបោសថកាល គឺកាលសម្រាប់រក្សានូវឧបោសថមាន ៤ ប្រការគឺ **ចាតុទ្ទសីឧបោសថ ១ បណ្ណរសីឧបោសថ ១ អដ្ឋមីឧបោសថ ១ បាដិហារិយឧបោសថ ១** ។ បុគ្គលមានសទ្ធារក្សានូវឧបោសថអស់ថ្ងៃនិងយប់ ក្នុងថ្ងៃជាទីពេញនៃតិថីគម្រប់ ១៤ ឈ្មោះថា ចាតុទ្ទសីឧបោសថ, ក្នុងថ្ងៃជាទីពេញនៃតិថីគម្រប់ ១៥ ឈ្មោះថា បណ្ណរសីឧបោសថ, ក្នុងថ្ងៃជាទីពេញនៃតិថីគម្រប់ ៨ ឈ្មោះថា អដ្ឋមីឧបោសថ, បុគ្គលរក្សានូវអដ្ឋឧបោសថ ៨ ប្រការជាប់ជានិច្ចអស់កាលដ៏យូរ មិនលោះខានថ្ងៃ ១ ឡើយ ឈ្មោះថា បាដិហារិយឧបោសថ ។ ក្នុងបាលីនៃសូត្រនេះគ្រាន់តែពោលថា បាដិហារិយឧបោសថប៉ុណ្ណោះ មិនអធិប្បាយថាជាអ្វីឡើយ ។

ក្នុងគម្ពីរអដ្ឋកថានៃធម្មិកសូត្រ កែសេចក្ដីថា បាដិហារិយឧបោសថ

នោះ គឺឧបោសថដែលបុគ្គលរក្សាជាប់ជានិច្ច ក្នុងខែទាំង ៥ គឺតាំងអំពី ១ កើតខែអាសាឍ ទៅដល់ថ្ងៃខែដាច់ខែកត្តិក ។

មានពាក្យអាចារ្យទាំងឡាយដទៃ អាចារ្យជំពូកខ្លះពោលថា បាដិហារិយឧបោសថនោះ គឺឧបោសថដែលបុគ្គលរក្សាជានិច្ចជាប់រៀងទៅអស់ខែទាំង ៣ គឺ ខែអាសាឍ, ខែកត្តិក និងខែផល្គុន ។ អាចារ្យជំពូកខ្លះពោលថា បាដិហារិយឧបោសថនោះ មិនមែនជាដទៃទេ គឺថ្ងៃទទួល និងថ្ងៃជូននៃចាតុទ្ទសីឧបោសថ, បណ្ណរសីឧបោសថ និងអដ្ឋមីឧបោសថនោះឯង ។ ពាក្យផ្សេងៗ គ្នានេះ តាមប្រាថ្នានៃអាចារ្យនោះៗ, បើអ្នកបដិបត្តិចូលចិត្តដោយប្រការណា ក៏គប្បីកាន់យកដោយប្រការនោះៗចុះ ។ ប្រការ ១ សោត បើបុគ្គលចង់ធ្វើឲ្យអស់សង្ស័យ ឲ្យត្រូវដោយប្រការទាំងពួង ក៏គប្បីរក្សាជាប់គ្នារៀងទៅទាំង ៥ ខែ គឺតាំងអំពី ១ កើតខែអាសាឍ ដរាបដល់ដាច់ខែកត្តិក ហើយរក្សាឲ្យអស់ទាំងក្នុងខែផល្គុន, ឯខែដែលសល់ពីនោះ ត្រូវរក្សាតែថ្ងៃទទួល និងថ្ងៃជូន និងបកតិឧបោសថទាំង ៣ យ៉ាងនេះកុំឲ្យដាច់ បានឈ្មោះថាប្រតិបត្តិឲ្យអស់សង្ស័យក្នុងពាក្យនៃអាចារ្យ ។ ពាក្យដែលពោលមកនេះ ជាពាក្យក្នុងគម្ពីរអដ្ឋកថានៃធម្មិកសូត្រ ។

អំពីកាលសម្រាប់រក្សានូវឧបោសថ ក្នុងថ្ងៃ ៥ កើត ៥ រោច ឈ្មោះបញ្ចមីឧបោសថ នោះគ្មានក្នុងបាលីទេ តែព្រះសង្ឃតិកាចារ្យ កាលគ្រា

ធ្វើបឋមសង្គាយនា ពិភាក្សាយល់ព្រមគ្នាថា ព្រះមានព្រះភាគនិព្វាន ទៅហើយ មិនគួរពុទ្ធបរិស័ទនឹងប្រមាទទេ គួរតែស្តាប់ព្រះធម៌ឲ្យច្រើន, កាលបើស្តាប់ព្រះធម៌ដោយមិនបានរក្សានូវឧបោសថ ចិត្តនោះក៏មិនស្ងប់ស្ងាត់ ស្តាប់ព្រះធម៌ក៏មិនគោរព, ឯថ្ងៃសម្រាប់រក្សាឧបោសថដែលមានមកពីមុននោះវយាលពេកណាស់ ទើបព្រមព្រៀងគ្នាបញ្ញត្តនូវ **បញ្ចមីឧបោសថ** គឺថ្ងៃ ៥ កើត ៥ រោច ជាថ្ងៃរក្សានូវឧបោសថ និងស្តាប់ព្រះធម៌មួយថ្ងៃទៀតក្នុងព្រះពុទ្ធសាសនា ។ ហេតុដូច្នោះ ព្រះអដ្ឋកថាចារ្យ ទើបរាប់យកបញ្ចមីឧបោសថ ចូលជាថ្ងៃឧបោសថ ១ ថ្ងៃទៀត តាំងអំពីគ្រានោះមក ។

មានពាក្យព្រះសិរីមង្គលត្ថេរ ដែលរៀបរៀងគម្ពីរមង្គលត្ថទីបនី កាត់ដាច់ជាពាក្យសន្និដ្ឋានទុកថា ឲ្យអ្នកប្រាជ្ញកាន់យកតាមចូលចិត្តចុះ ថាពាក្យក្នុងគម្ពីរអដ្ឋកថាទាំងពួងដែលតាំងទុកមិនត្រូវគ្នានោះ រមែងប្រព្រឹត្តទៅតាមប្រាជ្ញានៃអាចារ្យដែលពោលក្នុងអដ្ឋកថានោះៗ បើនឹងពោលដោយពិត មិនមែនខុសចាកពុទ្ធាធិប្បាយទេ ឲ្យអ្នកប្រាជ្ញកាន់យកថាថ្ងៃខាងខ្នើត និងខាងរនោច ៨ ថ្ងៃ មានថ្ងៃ ៥ កើត ៥ រោច ជាដើមដែលមានរាល់ខែនោះ ឈ្មោះថា **បកតិឧបោសថកាល** និង ១១ ថ្ងៃ មានថ្ងៃ ៤ កើត ៤ រោចជាដើម ដ៏ជាថ្ងៃខាងមុខ ខាងក្រោយនៃបកតិឧបោសថនោះឈ្មោះថា **បដិជាគរឧបោសថកាល**, និងខាងក្នុងរដូវភ្លៀង ៤ ខែ គឺ

តាំងពី ១ កើតខែអាសាឍទៅដល់ពេញបូណ៌មីខែកត្តិក ឈ្មោះថា **បាដិហា-រិយឧបោសថកាល,** ក្នុងកាលទាំងនេះ ដែលគួរនឹងរក្សានូវឧបោសថឲ្យជាប់ជានិច្ចទៅចុះ ព្រោះវេលារដូវភ្លៀងនេះ ជាវេលាដែលមនុស្សត្រូវបន្ថយការងារ ជាវេលានៅចាំវស្សានៃពួកសមណៈ គួរតែមនុស្សនឹងបំពេញនូវកុសល មានឲ្យទាន រក្សាសីល និងស្តាប់ព្រះធម៌ជាដើម ឲ្យបានច្រើនដោយពិត ។ បើបុគ្គលប្រព្រឹត្តដូច្នេះ ឈ្មោះថារក្សានូវឧបោសថក្នុងកាលដែលមានបង្គាប់ទុកមក បានឈ្មោះថាប្រតិបត្តិតាមធម្មានុធម្ម-បដិបទា បានឈ្មោះថាបូជាចំពោះព្រះមានព្រះភាគដោយបដិបត្តិបូជាដ៏វិសេស អាចញ៉ាំងសាសនានៃព្រះមានព្រះភាគឲ្យរុងរឿងបាន ហេតុប្រតិបត្តិត្រឹមត្រូវមិនបានវិបរិត ។

មានអាចារ្យជំពូកខ្លះឥតប្រាជ្ញាពោលតែតាមគាប់ចិត្តខ្លួនថា បើបុគ្គលមានសទ្ធាជ្រះថ្លាប្រាថ្នានឹងរក្សានូវឧបោសថក្នុងវេលាណាៗ ក្នុងថ្ងៃណាៗ ក៏បាន ទោះបីមិនមែនជាថ្ងៃឧបោសថក៏ដោយ ពាក្យដែលពោលនេះខុសឆ្ងាយណាស់ មិនត្រូវទេ បើកាន់យកតាមទំនើងចិត្តដូច្នេះហើយ ថ្ងៃឧបោសថដែលព្រះមានព្រះភាគទ្រង់កំណត់ទុកនោះ ទៅជាឥតអំពើរកប្រយោជន៍គ្មាន បើនឹងពោលតាមអត្ថដោយពិត ឧបោសថដែលបុគ្គលរក្សាក្នុងកាលខុសពីបង្គាប់នោះ មិនបានកើតជាឧបោសថទេ ។

# ប្រភេទនៃកិរិយារក្សាឧបោសថ

**អយញ្ច ឧបោសថោ** *រីឧបោសថនេះស្រដីដោយប្រភេទនៃកិរិយាដែលបុគ្គលរក្សាល្អ និងអាក្រក់មាន ៣ ប្រភេទគឺ*

**១- គោបាលឧបោសថ(១) ។**

**២- និគណ្ឋឧបោសថ ។**

**៣- អរិយឧបោសថ ។**

*អធិប្បាយអំពីឧបោសថទាំង ៣ ប្រភេទនេះ ដោយសង្ខេបខ្លីៗ កាត់យកតែគោលសេចក្ដី តាមន័យដែលមានក្នុងគម្ពីរអដ្ឋកថានៃឧបោសថ-សូត្រថា :*

**គោបាលឧបោសថ** *នោះ បុគ្គលរក្សាឧបោសថក្នុងព្រះពុទ្ធសាសនា តែជាឧបោសថដ៏ទន់ទាប ជាវិស័យនៃបុគ្គលពាលមានចិត្តលោភ វង្វេងទៅដោយកាមគុណ, បើពោលដោយត្រង់ សមាទានវិធីខាងដើមនោះក៏ដូចគ្នានឹងអរិយឧបោសថដែរ តែមិនមែនជាអរិយឧបោសថ ព្រោះបុគ្គលអ្នករក្សាមានចេតនាមិនបរិសុទ្ធ ប្រៀបដូចជាមនុស្សរក្សាគោបានតែថ្លៃឈ្នួលឃ្វាលគោប៉ុណ្ណោះ មិនបានបរិភោគនូវ* **បញ្ចគោរស** *គឺសេចក្ដីសុខដែលបុគ្គលគប្បីបានដោយការរក្សានូវឧបោសថ និងការចម្រើនភាវនាទេ ហេតុដូច្នោះ ឧបោសថនេះទើបមានអានិសង្សតិច មិនបាន*

---

១- ក្នុងព្រះត្រៃបិដកថា គោបាលុបោសថ, និគណ្ឋុបោសថ, អរិយុបោសថ ។

ផលរីកផ្សាយបរិបូណ៌ក្រៃពេកដោយវិសេសទេ មិនមានរស្មីឱភាសក្ដី រុងរឿងដោយផលឧបោសថកម្មនោះទេ បើប្រៀបនឹងអរិយឧបោសថ បីដូចជាយកអំពិលអំពែកទៅប្រៀបនឹងមណ្ឌលនៃព្រះអាទិត្យ ព្រះចន្ទ ។

**និគណ្ឋឧបោសថ** នោះ ជាឧបោសថរបស់អន្យតិរ្ថិយ៍និគ្រណ្ឋក្រៅព្រះពុទ្ធសាសនា, ពួកនិគ្រណ្ឋទាំងឡាយបានស្ដាប់អ្នកប្រាជ្ញពុទ្ធសាសនាលោកពោលថាឧបោសថៗ ក៏ចាំបានយកទៅរក្សា តែមិនបានដឹងវត្តប្រតិបត្តិថាឧបោសថនោះត្រូវរក្សាយ៉ាងណាទេ ក៏បញ្ញត្តវត្តប្រតិបត្តិនៃឧបោសថនោះតាមអំពើចិត្តដល់សាវ័កនៃខ្លួន, ហេតុដូច្នោះ និគណ្ឋ-ឧបោសថនោះ ទើបមិនមែនជាកុសល ព្រោះលោកចិត្តដ៏សម្បយុត្តដោយទិដ្ឋិជាបុស ឧបោសថនោះមានមិច្ឆាទស្សនៈឃើញខុសជាទីតាំង, កាលបុគ្គលរក្សានូវនិគណ្ឋឧបោសថនោះ មិនបានសោយផលជាឥដ្ឋា-រម្មណ៍គឺ រូប សំឡេង ក្លិន រស ដែលបុគ្គលគប្បីប្រាថ្នាមាត្រាជាតិចតួចទេ ។

ឯឧបោសថ ២ ប្រការនេះ អ្នកប្រាជ្ញមិនចូលចិត្តឡើយ ព្រោះឧបោសថ ១ មានផលតិច, ឧបោសថ ១ គ្មានផលសោះ, លោកបំណងតែរក្សាអរិយឧបោសថ ១ ប៉ុណ្ណោះ ដែលជាឧបោសថដ៏ឧត្តមក្រៃលែង ។

អរិយឧបោសថនោះ ព្រះអដ្ឋកថាចារ្យសម្ដែងថា កាលបើបុគ្គលមានសទ្ធាខ្ជាំងក្លា ប្រាថ្នានឹងរក្សានូវអរិយឧបោសថ បើជិតដល់ថ្ងៃនឹងរក្សានូវឧបោសថ ដូចជាកំណត់ថាព្រឹកស្អែកនេះជាថ្ងៃឧបោសថ បុគ្គលគប្បី

ចាត់ចែងធ្វើនូវកិច្ចមានអាហារជាដើម របស់ណាដែលខ្លួនគប្បីបរិភោគក្នុងវេលាព្រឹកនោះ ក៏គប្បីចាត់ចែងធ្វើឲ្យស្រេចអំពីថ្ងៃមុននោះ ឲ្យគ្រប់ប្រការ, ដែលពោលថាឲ្យចាត់ចែងអាហារនោះ ស្រដីដោយអំណាចនៃបុគ្គលដែលចាត់ចែងអាហារចិញ្ចឹមជីវិតខ្លួនជាប្រក្រតី ។ បើបុគ្គលមានសភាពដូច្នោះទៅខ្វល់ខ្វាយក្នុងថ្ងៃឧបោសថដោយកិច្ចស្ងួនដណ្តាំ ចាត់ចែងនូវអាហារនោះសោត ចិត្តនៃបុគ្គលនោះក៏នឹងសហគតៈប្រឡូកប្រឡំដោយអភិជ្ឈា ព្រោះប្រព្រឹត្តទៅក្នុងរសនៃអាហារ គឺសេចក្តីប្រាថ្នានូវរសនៃអាហារដោយប្រការដ៏ច្រើន, បើបុគ្គលប្រព្រឹត្តដូច្នោះ ឧបោសថនោះទៅជាគោបាលឧបោសថ មិនមែនជាអរិយឧបោសថទេ, ហេតុដូច្នោះ បុគ្គលត្រូវចាត់ចែងនូវអាហារឲ្យជួនល្មមគ្រប់ប្រការ ក្នុងថ្ងៃឧបោសថកុំឲ្យរវល់ចាត់ចែងទៀតទើបគួរ, បើបុគ្គលណាមានអ្នកចាត់ចែងនូវអាហារឲ្យហើយ បុគ្គលនោះពុំមានកិច្ចដែលនឹងចាត់ចែងនូវអាហារទេ ។

## អំពីកិច្ចប្រតិបត្តិក្នុងថ្ងៃឧបោសថ

កិច្ចប្រតិបត្តិក្នុងថ្ងៃឧបោសថនោះ តាមមហាជនកជាតក, កុម្ភជាតក, និងរឿងអនាថបិណ្ឌិកសេដ្ឋី និទានទាំង ៣ នេះ ស្រដីដោយវិសេសទុកថា ថ្ងៃណាជាថ្ងៃឧបោសថ បើបុគ្គលនឹងរក្សានូវឧបោសថនោះត្រូវខ្ពុរមាត់ចេញឲ្យស្អាតជាមុនរួចសមាទាននូវឧបោសថទើបគួរ ។ ហេតុដូច្នោះ ព្រះមហាជនកបរមពោធិសត្វ កាលដល់ថ្ងៃឧបោសថក៏ខ្ពុរព្រះឱស្ឋ

ហើយទើបសមាទាននូវឧបោសថ ។ ឯកិច្ចប្រតិបត្តិឲ្យខ្ពួរមាត់ចេញជាមុន មានក្នុងនិទានទាំង ៣ នេះ ពុំមានក្នុងអដ្ឋកថាដទៃ មានអដ្ឋកថាឧបោសថ-សូត្រជាដើមទេ ។ ក្នុងឧបោសថសូត្រនេះ មានវិធីវិសេសដែលព្រះអដ្ឋកថាចារ្យ និងដីកាចារ្យពោលទុកថា បុគ្គលនឹងសមាទាននូវឧបោសថក្នុងវេលាព្រឹកនោះ អំពីមុនមិនទាន់សមាទាន កុំប្រព្រឹត្តទម្លាយសីល គឺទម្លាយនូវសិក្ខាបទនៃឧបោសថសីល ក្នុងថ្ងៃនោះឡើយ កាលនឹងសមាទាននោះ គប្បីកំណត់នូវកាល គឺថ្ងៃ ១ យប់ ១ ដ៏ជាថ្ងៃឧបោសថ ហើយគប្បីអធិដ្ឋានដោយវាចាថា :

**ឥមញ្ច**(១) **រត្តឹ ឥមញ្ច ទិវសំ ឧបោសថិកោ ភវិស្សាមិ** ខ្ញុំនឹងជាបុគ្គលរក្សានូវឧបោសថ កំណត់អស់ថ្ងៃ ១ យប់ ១ ។

## អធិដ្ឋានដោយវាចាម្យ៉ាងទៀតថា

**ឥមញ្ច**(២) **រត្តឹ ឥមញ្ច ទិវសំ ពុទ្ធប្បញ្ញត្តំ ឧបោ-សថំ អធិដ្ឋាមិ** ខ្ញុំសូមអធិដ្ឋាននូវឧបោសថ ដែលព្រះពុទ្ធជាម្ចាស់ទ្រង់បញ្ញត្តទុកមកហើយ កំណត់អស់ថ្ងៃនេះ និងយប់នេះ ។ វាចាអធិដ្ឋានទាំង ២ យ៉ាងនេះ បើអ្នកប្រតិបត្តិចូលចិត្តតាមបែបណា ក៏គប្បីកាន់យកតាមបែបនោះចុះ ។ បើនឹងអធិដ្ឋានដោយភាសានៃខ្លួន ក៏គួរ ហើយគប្បីសូត្រឧបោសថសីលគ្រប់សិក្ខាបទទាំង ៨ ប្រការតទៅ

---

១- តាមច្បាប់ ឧបោសថកថា ។ ២- តាមច្បាប់ពុទ្ធមាមកវិធី ។

រួចទើបរង់ចាំសមាទាននូវឧបោសថសីលតទៅជាឯក្រោយ ។ បើបាន អធិដ្ឋានដូច្នេះហើយ ទោះបីកាលដែលសល់នៅក្នុងវេលាព្រឹក ក៏ឈ្មោះថា បានកាន់យកប្រពៃដោយប្រការទាំងពួង ដ្បិតចេតនានោះជាចេតនាដ៏ ខ្លាំងក្លា មានផលានិសង្សច្រើន ពាក្យនេះមានតែក្នុងអដ្ឋកថា និងដីកា នៃឧបោសថសូត្រ ពុំមានក្នុងទីដទៃទេ ។ កាលធ្វើបុព្វកិច្ចដូច្នោះរួច ហើយ គប្បីសមាទាននូវឧបោសថសីលមានអង្គ ៨ ប្រការគឺ សិក្ខាបទ ៨ ប្រការនោះ ក្នុងសំណាក់នៃភិក្ខុ ភិក្ខុនីក្តី ក្នុងសំណាក់នៃសាមណេរ សាមណេរីក្តី ក្នុងសំណាក់នៃឧបាសក ឧបាសិកា ដែលមានប្រាជ្ញាដឹង លក្ខណៈដែលនឹងប្រតិបត្តិក្នុងសីល ១០ និងឧបោសថសីលក្តី បើមិនបាន នូវបុគ្គលដូច្នោះទេ នឹងសមាទានដោយខ្លួនឯងក្តី ក៏គួរ ឬក៏បានសូត្រ សមាទានដោយខ្លួនឯង ក្នុងពេលដែលអធិដ្ឋានរួចហើយនោះ ទុកជា សមាទានដោយខ្លួនឯងជាការស្រេចគ្រប់គ្រាន់ហើយ ។ ព្រោះដ្បិត សីលនៃគ្រហស្ថ គឺបុគ្គលជាឧបាសក-សិកានេះ មិនបាននិយមកំណត់ ដូចជាបព្វជ្ជានៃសាមណេរទេ ។ ឯបព្វជ្ជានៃសាមណេរសម្រេចតែក្នុង សំណាក់នៃភិក្ខុ មិនបានសម្រេចក្នុងសំណាក់នៃបុគ្គលដទៃឡើយ ដ្បិត បុគ្គលដទៃក្រៅចាកភិក្ខុ មិនគួរឲ្យបព្វជ្ជាដល់កុលបុត្រដទៃបានទេ ក្រៅ ពីភិក្ខុនីមិនគួរនឹងឲ្យបព្វជ្ជាដល់ស្ត្រីបានទេ ។ បើបុរសស្ត្រីនឹងបំបួសខ្លួន ជាសាមណេរ សាមណេរី ដោយខ្លួនឯងក្តី នឹងឲ្យបុគ្គលដទៃក្រៅពីភិក្ខុ

ភិក្ខុនី បំបួសក្តី ក៏មិនឡើងជាសាមណេរ សាមណេរី ។ ឯគ្រហស្ថ គឺបុគ្គលជាឧបាសក ឧបាសិកានោះ នឹងសមាទាននូវឧបោសថ មានសិក្ខាបទ ៨ នោះមិនមែនដូច្នោះទេ កិច្ចដែលនឹងសមាទាននោះ សម្រេចដោយចេតនានៃបុគ្គលនោះឯង ។ ឯពាក្យដែលពោលថាឲ្យសមាទានក្នុងសំណាក់នៃភិក្ខុ ភិក្ខុនី និងសាមណេរ សាមណេរី និងឧបាសក ឧបាសិកា ដែលដឹងនូវលក្ខណៈនៃសីល ១០ នោះ ស្រដីដោយសរុបសមគួរ ។ ព្រោះដ្បិតបុគ្គលបានសមាទាននូវសីលក្នុងសំណាក់នៃលោកដ៏មានប្រាជ្ញា លោកនឹងប្រដៅឲ្យរក្សានូវសីលនោះ ដោយកិច្ចសមាទាន និងកិច្ចប្រតិបត្តិជាឧក្រិដ្ឋល្អ ។ មួយទៀត បើបុគ្គលនោះបានសមាទានក្នុងសំណាក់នៃបុគ្គលគួរនឹងគោរពហើយ ទោះបីតទៅឯមុខ វីតិក្កមចេតនានឹងកន្ទងនូវសីលដែលនឹងកើតឡើង បុគ្គលនោះក៏នឹងគប្បីអៀនអន់ឯងមិនអាចនឹងកន្ទងនូវសីលបាន ។ ឯកិរិយាដែលសមាទានក្នុងសំណាក់នៃបុគ្គលដទៃ មានសេចក្តីដូចពណ៌នាមកនេះ នឹងសម្រេចសមាទានព្រោះបុគ្គលដទៃក៏ទេ ។ ហេតុដូច្នោះ បើបុគ្គលណាមិនបាននូវគរុដ្ឋានិយបុគ្គលនេះ នឹងសមាទានដោយខ្លួនឯងបាន មិនទាស់ខុសអ្វីទេ ។

កិរិយាសមាទានដោយខ្លួនឯងនេះ សំដៅចេតនានៃបុគ្គលណាដែលប្រព្រឹត្តទៅដោយឧស្សាហ៍ខ្មីឃ្មាតខ្លាំងក្លា និងវៀរចាកអកុសលទោស

មានបាណាតិបាតជាដើម ដរាបដល់ញ៉ាំងបុគ្គលនោះ ឲ្យបញ្ចេញនូវវាចាសមាទានបាន ចេតនានោះឈ្មោះថា សមាទាននូវសីល ចាប់ដើមអំពីពេលនោះទៅ សីលក៏បានឈ្មោះថាបរិបូណ៌ក្នុងសន្តាននៃបុគ្គលនោះ ។

វិរតិ គឺចេតនានៃបុគ្គលវៀរចាកទោសមាន ២ ប្រការគឺ

១- **សមាទានវិរតិ** វៀរចាកទោស ដោយបានសមាទានសីល ។

២- **សម្បត្តិវិរតិ** វៀរចាកទោស តាមធម្មតាខ្លួនឯង ។

វិរតិណារបស់បុគ្គលដែលវៀរចាកទោស មានបាណាតិបាតជាដើម ដោយខ្លួនបានសមាទាននូវសីល វិរតិនោះឈ្មោះថា **សមាទានវិរតិ** ។

វិរតិណារបស់បុគ្គលដែលមិនបានសមាទាននូវសីល ហើយវៀរចាកទោស មានបាណាតិបាតជាដើម តាមធម្មតាខ្លួនឯង វិរតិនោះឈ្មោះថា **សម្បត្តិវិរតិ** ។

## អំពីកិច្ចសមាទាននូវឧបោសថសីល

កាលបុគ្គលសមាទាននូវឧបោសថសីលនោះ ត្រូវនមស្ការវំឭកដល់ព្រះរតនត្រ័យជាមុន រួចហើយទើបសមាទាននូវឧបោសថសីលប្រកបដោយកិច្ចប្រតិបត្តិនិងវិរតិចេតនាដូចពោលខាងដើម, ឯកិច្ចនមស្ការ និងសមាទាននូវឧបោសថសីលនេះ តាមបុរាណាចារ្យលោកបានរៀបចំទុកមកជារបៀបដូច្នេះ៖

មុនដំបូងត្រូវធ្វើកិច្ចនមស្ការ (ឯកិច្ចនមស្ការនេះដូចន័យដែលបាន

ពោលហើយក្នុងកិច្ចសមាទាននូវនិច្ចសីលខាងដើម) ។

កិច្ចជាគម្រប់ពីរត្រូវធ្វើកិច្ចសមាទាននូវឧបោសថសីល ។

បុគ្គលទាំងឡាយដែលជាអ្នកសមាទាននូវឧបោសថសីល បានមកប្រជុំគ្នា លុះធ្វើកិច្ចនមស្ការរួចហើយ អាចារ្យ ឬ បុគ្គល ១ នាក់ជាមេគេ (ត្រូវសម្រេចកិច្ចត្រង់ទី ១ គឺ) សូត្រប្រកាសឧបោសថសីល ដោយបាលីថា :

**អដ្ឋ ភោន្តោ { សុក្កា / កាឡ } បក្ខស្ស { អដ្ឋមី / ចាតុទ្ទសី / បណ្ណរសី } ចិរសោ** ។ល ។[១]

ទី ២- អារាធនាសមាទាននូវឧបោសថសីល ដោយបាលីថា :

**{ អហំ[២] / មយំ } ភន្តេ តិសរណេន សហ, អដ្ឋង្គសមន្នាគតំ**

**ឧបោសថំ យាចា { មិ[៣] / ម }**, ៣ ដង ។

បពិត្រព្រះករុណាដ៏ចម្រើន! { ខ្ញុំព្រះករុណា / យើងខ្ញុំព្រះករុណា } សូមនូវឧបោសថសីល

ដែលប្រកបដោយអង្គ ៨ ប្រការ ព្រមទាំងព្រះត្រៃសរណគមន៍ ។

---

១- មានពិស្តារនៅខាងចុងច្បាប់នេះ ។ ២- អហំ, ៣- មិ, ខ្ញុំព្រះករុណាសម្រាប់មនុស្សម្នាក់ថា, បើគ្នាច្រើនត្រូវថា មយំ, ម, យើងខ្ញុំព្រះករុណា ។

តាមទម្លាប់ដែលបុរាណាចារ្យធ្វើតៗ មក កាលឧបាសក ឧបាសិកា សមាទាននូវនិច្ចសីល គឺសីល ៥ ក្តី នូវឧបោសថសីលក្តី រមែងសមាទានសរណគមន៍ជាមុន ទើបបានសមាទានសីលជាក្រោយ ។ ឯកិរិយាដែលសមាទាននូវសរណគមន៍នោះ ក៏ជាកុសលដ៏ប្រសើរដែលបានពោលបាលីព្រះត្រៃសរណគមន៍ដោយគោរពដល់ព្រះរតនត្រ័យហើយ តែនឹងបានជាប្រមាណក្នុងសមាទានសីលក៏ទេ ដ្បិតសរណគមន៍ជាលោកិយដែលមានក្នុងគ្រហស្ថ គឺឧបាសកនោះ បើគ្រហស្ថ គឺឧបាសកនោះមិនកាន់យកគ្រូដទៃ ថាប្រសើរជាងព្រះរតនត្រ័យដរាបណា សរណគមន៍ក៏មិនដាច់ គង់នៅបរិបូណ៌ក្នុងសន្តានដរាបនោះ បើសមាទានម្តងហើយក៏ប្រព្រឹត្តទៅលុះអស់ជីវិត ទោះបីនឹងសៅហ្មងខ្វះក្នុងចន្លោះៗ ដោយធ្វើអគារវៈ និងសង្ស័យ ក្នុងព្រះរតនត្រ័យ ដោយសេចក្តីល្ងង់ខ្លៅ បុគ្គលនោះគប្បីជម្រះទោសនោះ ដោយសូមខមាទោស និងបន្ទោបង់កាត់សេចក្តីសង្ស័យនោះចេញចុះ មិនបាច់សមាទានថ្មីទៀតទេ, មួយទៀត ព្រះអដ្ឋកថាចារ្យ និងដីកាចារ្យ លោកមិនបានបង្គាប់ទុកក្នុងអដ្ឋកថា និងដីកាណាមួយឡើយ ថាបើបុគ្គលនឹងសមាទាននូវនិច្ចសីល ឬឧបោសថសីលឲ្យសមាទាននូវសរណគមន៍ជាមុននោះ ។ ហេតុដូច្នោះ បុគ្គលមានសរណគមន៍បរិបូណ៌ហើយ បើមិនសមាទានសរណគមន៍ទេ នឹងសមាទាននូវសីលតែម្តងក៏បាន, ប៉ុន្តែបើសមាទានសរណគមន៍ផង ក៏រឹង

វីតតែប្រពៃណាស់ទៅទៀត មិនខុសអ្វីទេ ធ្វើចុះ ។ បើបុគ្គលណាមិនទាន់មានសរណគមន៍ទេ ជាមនុស្សមិច្ឆាទិដ្ឋិពីកាលមុនក្តី មិនដឹងច្បាស់នូវគុណព្រះរតនត្រ័យក្តី លុះជ្រះថ្លាក្នុងព្រះពុទ្ធសាសនា គប្បីសមាទាននូវសរណគមន៍ជាមុនហើយ សមាទាននូវសីលជាខាងក្រោយ ទើបគួរ ព្រោះសរណគមន៍ជាហេតុខាងដើម នៃបុគ្គលដែលនឹងចូលកាន់ព្រះពុទ្ធ-សាសនា, កុសលទាំងពួងដែលបុគ្គលគប្បីធ្វើក្នុងព្រះពុទ្ធសាសនា ក៏មានសរណគមន៍ជាហេតុខាងដើមរបស់បុគ្គលនោះស្រាប់ហើយ ។

## កិច្ចសមាទានមានប្រភេទ ២ យ៉ាងគឺ

១- **បច្ចេកសមាទាន** សមាទានផ្សេងៗ គ្នា ។

២- **ឯកជ្ឈសមាទាន** សមាទានរួមចូលតែម្តង ។

ឧបាសក ឧបាសិកា ដែលសមាទាននូវឧបោសថសីល មានសិក្ខាបទ ៨ ប្រការ ជាបច្ចេកសមាទាន គឺសមាទានសិក្ខាបទមួយៗ ម្តងញែកឲ្យដាច់ពីគ្នា ដោយបាលីថា :

១- **បាណាតិបាតា វេរមណីសិក្ខាបទំ សមាទិយាមិ,** ខ្ញុំព្រះករុណា សមាទាននូវសិក្ខាបទ, គឺវៀរចាកសម្លាប់សត្វដោយខ្លួនឯងនិងប្រើអ្នកដទៃឲ្យសម្លាប់ ។

២- **អទិន្នាទានា វេរមណីសិក្ខាបទំ សមាទិយាមិ,** ខ្ញុំព្រះករុណា សមាទាននូវសិក្ខាបទ, គឺវៀរចាកលួចលាក់បំបាត់ទ្រព្យ

អ្នកដទៃដោយខ្លួនឯង និងប្រើអ្នកដទៃឲ្យលួចលាក់បំបាត់ ។

៣- **អព្រហ្មចរិយា វេរមណីសិក្ខាបទំ សមាទិយាមិ,** ខ្ញុំព្រះករុណា សមាទាននូវសិក្ខាបទ, គឺវៀរចាកសេពនូវមេថុនធម៌ ។

៤- **មុសាវាទា វេរមណីសិក្ខាបទំ សមាទិយាមិ,** ខ្ញុំព្រះករុណា សមាទាននូវសិក្ខាបទ, គឺវៀរចាកនិយាយកុហកអ្នកដទៃ ។

៥- **សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណីសិក្ខាបទំ សមាទិយាមិ,** ខ្ញុំព្រះករុណា សមាទាននូវសិក្ខាបទ, គឺវៀរចាកហេតុជាទីតាំងនៃសេចក្ដីប្រមាទ, គឺផឹកនូវសុរា និងមេរ័យ ដែលជាគ្រឿងស្រវឹងផ្សេង ៗ ។

៦- **វិកាលភោជនា វេរមណីសិក្ខាបទំ សមាទិយាមិ,** ខ្ញុំព្រះករុណា សមាទាននូវសិក្ខាបទ, គឺវៀរចាកបរិភោគអាហារក្នុងវេលាខុស ។

៧- **នច្ចគីតវាទិតវិសូកទស្សនមាលាគន្ធវិលេបនធារណមណ្ឌនវិភូសនដ្ឋានា វេរមណីសិក្ខាបទំ សមាទិយាមិ,** ខ្ញុំព្រះករុណា សមាទាននូវសិក្ខាបទ, គឺវៀរចាករាំច្រៀងប្រគំតូរ្យតន្ត្រី, ព្រមទាំងមើលស្ដាប់របាំចម្រៀងតូរ្យតន្ត្រី ដែលជាសត្រូវដល់កុសលធម៌, និងវៀរចាកប្រដាប់តាក់តែងរាងកាយដោយកម្រងផ្កា

គ្រឿងក្រអូប គ្រឿងលាប និងគ្រឿងអលង្ការផ្សេងៗ ។

៨- **ឧច្ចាសយនមហាសយនា វេរមណីសិក្ខាបទំ សមាទិយាមិ,** ខ្ញុំព្រះករុណា សមាទាននូវសិក្ខាបទ, គឺវៀរចាកទីដេកទីអង្គុយដ៏ខ្ពស់ និងទីដេកទីអង្គុយដ៏ធំ និងប្រសើរ ។

សមាទានយ៉ាងនេះ ឈ្មោះថា បច្ចេកសមាទាន គឺសមាទានសិក្ខាបទមួយៗ ម្តង ផ្សេងៗ គ្នា ។

**ឯកជ្ឈសមាទាន** គឺសមាទានរួបចូលតែម្តងនោះ, នឹងសមាទានដោយបាលីថា **ពុទ្ធប្បញ្ញត្តំ ឧបោសថំ សមាទិយាមិ** ខ្ញុំព្រះករុណា សមាទាននូវឧបោសថ ដែលព្រះពុទ្ធជាម្ចាស់ទ្រង់បញ្ញត្តទុកក្តី, **អដ្ឋង្គិកំ ឧបោសថំ សមាទិយាមិ** ខ្ញុំព្រះករុណា សមាទាននូវឧបោសថ ប្រកបដោយអង្គ ៨ ប្រការក្តី, **ឥមំ អដ្ឋង្គសមន្នាគតំ ពុទ្ធប្បញ្ញត្តំ ឧបោសថំ ឥមញ្ច រត្តឹ ឥមញ្ច ទិវសំ សម្មទេវ អភិរក្ខិតុំ សមាទិយាមិ** ខ្ញុំព្រះករុណា សមាទាននូវឧបោសថ ដ៏ប្រកបដោយអង្គ ៨ ប្រការ ដែលព្រះពុទ្ធជាម្ចាស់ទ្រង់ត្រាស់បញ្ញត្តទុកមកនេះ កំណត់អស់ថ្ងៃ ១ យប់ ១ មានវេលានេះជាដើមក្តី, ដូច្នេះក៏គួរឈ្មោះថា ឯកជ្ឈសមាទាន គឺសមាទានរួបសិក្ខាបទ ទាំង ៨ ចូលគ្នាតែម្តង ។

មួយទៀត នឹងសមាទានជាបច្ចេកសមាទាន និងឯកជ្ឈសមាទាន

ដូចពោលមកហើយនេះ ដោយភាសានៃខ្លួនៗ មិនបានពោលតាមបាលីឡើយ បើចាំអធិប្បាយសេចក្តីនោះ យកមកពោលក៏គួរទាំងអស់ គង់នឹងកើតជាសមាទាន, តែដោយសេចក្តីប្លែកគ្នា បើបុគ្គលសមាទានជាបច្ចេកសមាទាន វិរតិចេតនាក៏កើតផ្សេងៗ រមែងឲ្យសម្រេចការវៀរចាកទោសនៃសិក្ខាបទនោះៗ បាន ។ បើបុគ្គលសមាទានជា **ឯកជ្ឈសមាទាន** វិរតិចេតនាក៏កើតតែ ១ វិរតិចេតនាតែ ១ នោះ រមែងឲ្យសម្រេចនូវកិច្ចនៃវិរតិចេតនាច្រើន គឺវៀរចាកកន្លងទោសគ្រប់សិក្ខាបទទាំង ៨ ប្រការ ដូចជាបច្ចេកសមាទានដែរ, តែថាបើសមាទានជាបច្ចេកសមាទានក្តី ជាឯកជ្ឈសមាទានក្តី គប្បីបន្ទីវាចាឲ្យលាន់ឮ បើគិតនឹកតែក្នុងចិត្ត មិនកើតជាសមាទានទេ ដ្បិតព្រះពុទ្ធអង្គទ្រង់មានបំណងយកសមាទានចេតនា ដែលខ្ទាំងក្ទាដរាបដល់តាក់តែងវាចាឲ្យលាន់ឮបាន យកវចីទ្វារិកចេតនានោះជាប្រមាណក្នុងទីនេះ ព្រះអង្គមិនបានយកតែត្រង់ មនោទ្វារិកចេតនាស្ងៀមនឹកតែក្នុងចិត្តជាប្រមាណក្នុងទីនេះទេ, ពោលមកប៉ុណ្ណេះនាំឲ្យយល់ឃើញសេចក្តីថា បើបុគ្គលជាឧបាសកឧបាសិកានឹងសមាទាននូវនិច្ចសីល ឬ ឧបោសថសីល គប្បីតាំងចិត្តគិតបណ្តើរតាមអត្ថនៃសមាទានបាលីនោះឲ្យច្បាស់ក្នុងចិត្ត ដូចជាបុគ្គលឲ្យនូវប្តេជ្ញាដោយភាសានៃខ្លួននោះ ទើបនឹងកើតជាសមាទាន ។ បើបុគ្គលដែលសមាទាននូវនិច្ចសីល ឬ ឧបោសថសីលនោះ មានចិត្តរាយ

*មាយអណ្ដែងអណ្ដូងទៅក្នុងទីដទៃក្ដី, មិនដឹងនូវសេចក្ដីសមាទានបាលីនោះដោយភាវៈនៃខ្លួនជាមនុស្សខ្លៅក្ដី ទោះបីនឹងសមាទានដោយពោលបាលីត្រូវអក្ខរវិធីទាំងអស់ មិនមានចេតនាដឹងសេចក្ដីនោះសោះ ក៏មិនកើតជាសមាទានឡើយ ។ ព្រោះកម្ម គឺសមាទាននូវសីលនេះជាចេតនាកម្ម មានចេតនាដឹងនូវអត្ថនៃសមាទាននោះ ហើយបន្ទឹនូវវាចាដែលសម្ដែងនូវអត្ថនោះដោយភាសាបាលីក្ដី ដោយភាសានៃខ្លួនក្ដី ចេញមកបាននោះជាប្រមាណ ។ មួយទៀត បុគ្គលគឺ ភិក្ខុ ភិក្ខុនី សាមណេរ សាមណេរី និងឧបាសក ឧបាសិកា ដែលជាពហុស្សុត កាលនឹងប្រដៅអ្នកដទៃឲ្យសមាទានសីល គប្បីប្រាប់បុគ្គលដែលសមាទាននោះឲ្យចូលចិត្តក្នុងវិរតិចេតនាដូចពោលហើយ ទើបឲ្យសមាទានចុះ នឹងប្រាប់តែបាលីទទេ ដូចប្រដៅក្មេងមិនដឹងសេចក្ដីនោះមិនត្រូវទេ ។ បើបុគ្គលឯណាជាវិញ្ញូជនដឹងហើយ ប្រកបដោយគារវៈ កាលនឹងសមាទាននូវសិក្ខាបទហើយចូលមកឲ្យប្រដៅ ទោះនឹងប្រដៅតែបាលីក៏គួរ ព្រោះបុគ្គលនោះចេះដឹងហើយ ។ បើបុគ្គលនោះមិនបានឲ្យប្រដៅទេ គ្រាន់តែពោលសមាទានឲ្យស្ដាប់ក្ដី គប្បីស្ងៀមស្ដាប់តទៅ ។ បើបុគ្គលនោះពោលភ្លាំងភ្លាត់ខុសទៅខ្លះ គប្បីជួយតម្រង់ឲ្យត្រឹមត្រូវចុះ ។*

## អំពីកិច្ចសមាទាននូវឧបោសថសីលរួចហើយ

*កាលបើបុគ្គលសមាទាននូវឧបោសថសីលរួចហើយនោះ គប្បីពិចារណាដូច្នេះថា :*

**អរិយា ឧបោសថំ សមាទិយន្តិ** *ព្រះអរិយៈទាំងឡាយ រក្សានូវឧបោសថ មិនប្រមាទ តែងញុំាំងព្រះទ័យឲ្យផូរផង់ប្រាសចាក កិលេសមាននីវរណៈជាដើម, សូម្បីយើងក៏ជាអ្នកមិនប្រមាទ នឹងញុំាំងចិត្តឲ្យផូរផង់អស់ថ្ងៃ ១ យប់ ១ មានវេលានេះជាដើម ដោយហេតុនោះ ឈ្មោះថាយើងធ្វើតាមព្រះអរិយៈទាំងឡាយ ។*

**យាវជីវំ[១] អរហន្តោ បាណាតិបាតំ បហាយ បាណាតិបាតា បដិវិរតា និហិតទណ្ឌា និហិតសត្ថា លជ្ជី ទយាបន្នា សព្វភូតហិតានុកម្បី វិហរន្តិ អហម្បជ្ជ ឥមញ្ច រត្តឹ ឥមញ្ច ទិវសំ បាណាតិបាតំ បហាយ**

<table>
<tr><td rowspan="2">បាណាតិបាតា បដិវិរ</td><td>តោ[២]</td><td rowspan="2">និហិតទ</td><td>ណ្ឌោ</td><td rowspan="2">និហិតស-</td></tr>
<tr><td>តា</td><td>ណ្ឌា</td></tr>
</table>

<table>
<tr><td>ត្ថោ</td><td rowspan="2">ល</td><td>ជ្ជី</td><td rowspan="2">ទយាប</td><td>ន្នោ</td><td rowspan="2">សព្វភូតហិតានុក</td><td>ម្បី</td></tr>
<tr><td>ត្ថា</td><td>ជ្ជិនី</td><td>ន្នា</td><td>ម្បិនី</td></tr>
</table>

**ឥមិនាបិ អង្គេន អរហតំ អនុករោមិ ឧបោសថោ ច មេ ឧបវុត្ថោ ភវិស្សតិ ។**

*ព្រះអរហន្តទាំងឡាយ លោកលះវៀរបាណាតិបាត លោកមានអាជ្ញាដាក់បង់ហើយ មានសស្ត្រាវុធដាក់បង់ហើយ មានសេចក្ដីអៀន*

---

១- សុត្តន្តបិដក, អង្គុត្តរនិកាយ, តិកនិបាត, ទំព័រ ២៧៤ ។

២- តោ សម្រាប់បុរសម្នាក់ថា, តា សម្រាប់ស្ត្រីម្នាក់ថា ។

អន់នឹងបាបដល់ព្រមហើយ មានសេចក្តីអាសូរដល់សត្វ អនុគ្រោះដល់សត្វទាំងពួងកើតហើយ ដរាបលុះអស់ជីវិត សូម្បីយើងនឹងលះវៀរបាណាតិបាត មានអាជ្ញាដាក់បង់ហើយ មានសស្ត្រាវុធដាក់បង់ហើយ មានសេចក្តីអៀនអន់នឹងបាបដល់ព្រមហើយ មានសេចក្តីអាសូរដល់សត្វ អនុគ្រោះដល់សត្វទាំងពួងកើតហើយ អស់ថ្ងៃ ១ យប់ ១ មានវេលានេះជាដើម ក៏ដូច្នោះដែរ, ដោយហេតុនេះ ឈ្មោះថាយើងបានធ្វើតាមព្រះអរហន្តទាំងឡាយ, មួយសោត ឧបោសថសីល ឈ្មោះថាយើងបានរក្សា ។

យាវជីវំ អរហន្តោ អទិន្នាទានំ បហាយ អទិន្នាទានា បដិវិរតា ទិន្នាទាយី ទិន្នបាដិកង្ខី អថេនេន សុចិភូតេន អត្តនា វិហរន្តិ អហម្បជ្ជ ឥមញ្ច រត្តឹ ឥមញ្ច ទិវសំ អទិន្នាទានំ បហាយ អទិន្នាទានា បដិវិរ-{ តោ / តា } ទិន្នាទា{ យី / យិនី } ទិន្នបាដិក{ ង្ខី / ង្ខិនី } អថេនេន សុចិ-ភូតេន អត្តនា វិហរាមិ ឥមិនាបិ អង្គេន អរហតំ អនុករោមិ ឧបោសថោ ច មេ ឧបវុត្ថោ ភវិស្សតិ ។

ព្រះអរហន្តទាំងឡាយ លោកលះវៀរកាន់យករបស់ដែលគេមិនឲ្យ លោកកាន់យករបស់ដែលគេឲ្យ ប្រាថ្នារបស់ដែលគេឲ្យ មានខ្លួនដ៏

ស្អាត មិនជាចោរ ដរាបលុះអស់ជីវិត សូម្បីយើងលះវៀរកាន់យករបស់ដែលគេមិនឲ្យ កាន់យករបស់ដែលគេឲ្យ ប្រាថ្នារបស់ដែលគេឲ្យ មានខ្លួនដ៏ស្អាត មិនជាចោរ អស់ថ្ងៃ ១ យប់ ១ មានវេលានេះជាដើម ក៏ដូច្នោះដែរ, ដោយហេតុនេះ ឈ្មោះថាយើងធ្វើតាមព្រះអរហន្តទាំងឡាយ, មួយសោត ឧបោសថសីល ឈ្មោះថាយើងបានរក្សា ។

**យាវជីវំ អរហន្តោ អព្រហ្មចរិយំ បហាយ ព្រហ្មចារី អារាចារី បដិវិរតា មេថុនា ធម្មា គាមធម្មា អហម្បជ្ជ ឥមញ្ច រត្តឹ ឥមញ្ច ទិវសំ អព្រហ្មចរិយំ បហាយ**

**ចារី / ចារិនី } ព្រហ្ម; ចារី / ចារិនី } អារា; តោ / តា } បដិវិរ; មេថុនា ធម្មា**

**គាមធម្មា ឥមិនាបិ អង្គេន អរហតំ អនុករោមិ ឧបោសថោ ច មេ ឧបវុត្ថោ ភវិស្សតិ ។**

ព្រះអរហន្តទាំងឡាយ លោកលះវៀរអព្រហ្មចរិយៈ ដូចព្រហ្មប្រព្រឹត្តឆ្ងាយអំពីមេថុនធម្ម ជារបស់នៃអ្នកស្រុក ដរាបលុះអស់ជីវិត សូម្បីយើងនឹងលះវៀរអព្រហ្មចរិយៈ ដូចព្រហ្ម ប្រព្រឹត្តឆ្ងាយអំពីមេថុនធម្មជារបស់នៃអ្នកស្រុក អស់ថ្ងៃ ១ យប់ ១ មានវេលានេះជាដើម ក៏ដូច្នោះដែរ, ដោយហេតុនេះ ឈ្មោះថាយើងធ្វើតាមព្រះអរហន្តទាំងឡាយ, មួយសោត ឧបោសថសីល ឈ្មោះថាយើងបានរក្សា ។

យាវជីវំ អរហន្តោ មុសាវាទំ បហាយ មុសាវាទា បដិវិរតា សច្ចវាទី សច្ចសន្ធា ថិតា បច្ចយិកា អវិសំវាទកា លោកស្ស អហម្បជ្ជ ឥមញ្ច រត្តឹ ឥមញ្ច

ទិវសំ មុសាវាទំ បហាយ មុសាវាទា បដិវិរ {តោ / តា} សច្ច-

វា {ទី / ទិនី} សច្ចស {ន្ធោ / ន្ធា} ថិ {តោ / តា} បច្ចយិ {កោ / កា} អវិសំវា

{ទកោ / ទិកា} លោកស្ស ឥមិនាបិ អង្គេន អរហតំ អនុករោមិ

ឧបោសថោ ច មេ ឧបវុត្ថោ ភវិស្សតិ ។

*ព្រះអរហន្តទាំងឡាយ លោកលះវៀរពោលពាក្យកុហក លោកពោលពាក្យទៀងត្រង់ តំណពាក្យទៀងត្រង់ ស្ថិតស្ថេរគួរគោរព មិនពោលបញ្ឆោតលោកទាំងពួង ដរាបលុះអស់ជីវិត សូម្បីយើងនឹងលះវៀរពោលពាក្យកុហក ពោលតែពាក្យទៀងត្រង់ ស្ថិតស្ថេរគួរគោរព មិនពោលបញ្ឆោតលោកទាំងពួង អស់ថ្ងៃ ១ យប់ ១ មានវេលានេះជាដើមក៏ដូច្នោះដែរ, ដោយហេតុនេះ ឈ្មោះថាយើងធ្វើតាមព្រះអរហន្តទាំង-ឡាយ, មួយសោត ឧបោសថសីល ឈ្មោះថាយើងបានរក្សា ។*

យាវជីវំ អរហន្តោ សុរាមេរយមជ្ជប្បមាទដ្ឋានំ

បហាយ សុរាមេរយមជ្ជប្បមាទដ្ឋានា បដិវិរតា អហម្បជ្ជ ឥមញ្ច រត្តឹ ឥមញ្ច ទិវសំ សុរាមេរយមជ្ជ-ប្បមាទដ្ឋានំ បហាយ សុរាមេរយមជ្ជប្បមាទដ្ឋានា

បដិវិរ{តោ/តា} ឥមិនាបិ អង្គេន អរហតំ អនុករោមិ

ឧបោសថោ ច មេ ឧបវុត្ថោ ភវិស្សតិ ។

*ព្រះអរហន្តទាំងឡាយ លោកលះវៀរហេតុជាទីតាំងនៃសេចក្តីប្រមាទ គឺផឹកនូវសុរា និងមេរ័យ ដែលជាគ្រឿងស្រវឹងទាំងពួង ដរាបលុះអស់ជីវិត សូម្បីយើងនឹងលះវៀរហេតុជាទីតាំងនៃសេចក្តីប្រមាទ គឺផឹកនូវសុរា និងមេរ័យ ដែលជាគ្រឿងស្រវឹងទាំងពួង អស់ថ្ងៃ ១ យប់ ១ មានវេលានេះជាដើម ក៏ដូច្នោះដែរ, ដោយហេតុនេះ ឈ្មោះថាយើងធ្វើតាមព្រះអរហន្តទាំងឡាយ, មួយសោត ឧបោសថសីល ឈ្មោះថាយើងបានរក្សា ។*

យាវជីវំ អរហន្តោ ឯកភត្តិកា រត្តូបរតា វិរតា វិកាលភោជនា អហម្បជ្ជ ឥមញ្ច រត្តឹ ឥមញ្ច ទិវសំ

ឯកភត្តិ{កោ/កា} រត្តូបរ{តោ/តា} វិរ{តោ/តា} វិកាលភោជនា

ឥមិនាបិ អង្គេន អរហតំ អនុករោមិ ឧបោសថោ ច មេ ឧបវុត្ថោ ភវិស្សតិ ។

*ព្រះអរហន្តទាំងឡាយ លោកមានកត្តតែមួយវេលា វៀរវិកាល-ភោជន ដរាបលុះអស់ជីវិត សូម្បីយើងមានកត្តតែមួយវេលា វៀរវិកាល-ភោជន អស់ថ្ងៃ ១ យប់ ១ មានវេលានេះជាដើម ក៏ដូច្នោះដែរ, ដោយហេតុនេះ ឈ្មោះថាយើងធ្វើតាមព្រះអរហន្តទាំងឡាយ, មួយសោតឧបោសថសីល ឈ្មោះថាយើងបានរក្សា ។*

យាវជីវំ អរហន្តោ នច្ចគីតវាទិតវិសូកទស្សនមាលាគន្ធវិលេបនធារណមណ្ឌនវិភូសនដ្ឋានា បដិវិរតា អហម្បជ្ជ ឥមញ្ច រត្តឹ ឥមញ្ច ទិវសំ នច្ចគីតវាទិតវិសូកទស្សនមាលាគន្ធវិលេបនធារណមណ្ឌនវិភូសនដ្ឋានា បដិវិរ{តោ/តា} ឥមិនាបិ អង្គេន អរហតំ អនុករោមិ ឧបោសថោ ច មេ ឧបវុត្ថោ ភវិស្សតិ ។

*ព្រះអរហន្តទាំងឡាយ លោកលះវៀររាំច្រៀង ប្រគំតូរ្យតន្ត្រី ព្រមទាំងមើល ស្តាប់ របាំ ចម្រៀង តូរ្យតន្ត្រី និងវៀរប្រដាប់តាក់តែងរាងកាយដោយកម្រងផ្កា គ្រឿងក្រអូប គ្រឿងលាប និងគ្រឿងអលង្ការផ្សេងៗ ដរាបលុះអស់ជីវិត សូម្បីយើងនឹងលះវៀរច្រៀង រាំ ប្រគំតូរ្យតន្ត្រី ព្រមទាំងមើល ស្តាប់ របាំ ចម្រៀង តូរ្យតន្ត្រី និងវៀរប្រដាប់តាក់តែងរាងកាយដោយកម្រងផ្កា គ្រឿងក្រអូប គ្រឿងលាប និងគ្រឿងអលង្ការផ្សេងៗ*

*អស់ថ្ងៃ ១ យប់ ១ មានវេលានេះជាដើម ក៏ដូច្នោះដែរ, ដោយហេតុនេះ ឈ្មោះថាយើងធ្វើតាមព្រះអរហន្តទាំងឡាយ, មួយសោតឧបោសថសីល ឈ្មោះថាយើងបានរក្សា ។*

យាវជីវំ អរហន្តោ ឧច្ចាសយនមហាសយនំ បហាយ ឧច្ចាសយនមហាសយនា បដិវិរតា តិណសន្ថារកេ វា អហាម្បជ្ជេ ឥមញ្ច រត្តឹ ឥមញ្ច ទិវសំ ឧច្ចាសយន-មហាសយនំ បហាយ ឧច្ចាសយនមហាសយនា បដិវិរ{តោ / តា} នីចសេយ្យំ កប្បេមិ មញ្ចកេ វា តិណ-សន្ថារកេ វា ឥមិនាបិ អង្គេន អរហតំ អនុករោមិ ឧបោសថោ ច មេ ឧបវុត្ថោ ភវិស្សតិ ។

*ព្រះអរហន្តទាំងឡាយ លោកលះវៀរទីដេកទីអង្គុយដ៏ខ្ពស់ និងទីដេកទីអង្គុយដ៏ធំ និងប្រសើរ គឺគ្រែតាំងមានជើងខ្ពស់ហួសប្រមាណ និងកម្រាលមានខាងក្នុងដាក់គរ និងសំឡី និងកម្រាលដ៏រចនាផ្សេងៗ ដរាបលុះអស់ជីវិត សូម្បីយើងនឹងលះវៀរទីដេកទីអង្គុយដ៏ខ្ពស់ និងទីដេកទីអង្គុយដ៏ធំ និងប្រសើរ គឺគ្រែតាំងមានជើងខ្ពស់ហួសប្រមាណ និងកម្រាលមានខាងក្នុងដាក់គរ និងសំឡី និងកម្រាលដ៏រចនាផ្សេងៗ អស់ថ្ងៃ ១ យប់ ១ មានវេលានេះជាដើម ក៏ដូច្នោះដែរ, ដោយហេតុនេះ ឈ្មោះ*

ថាយើងធ្វើតាមព្រះអរហន្តទាំងឡាយ, មួយសោត ឧបោសថសីល ឈ្មោះថាយើងបានរក្សា ។

**កម្មដ្ឋានំ ភាវេន្តិ** ព្រះអរិយៈទាំងឡាយតែងជម្រះព្រះទ័យឲ្យផូរផង់ប្រាសចាកកិលេស ដោយសមថកម្មដ្ឋាន និងវិបស្សនាកម្មដ្ឋាន(១), សូម្បីយើងក៏នឹងជម្រះចិត្ត ដោយកម្មដ្ឋានទាំងឡាយនោះ អស់ថ្ងៃ ១ យប់ ១ មានវេលានេះជាដើម ដោយហេតុនោះ ឈ្មោះថាយើងធ្វើតាមព្រះអរិយៈទាំងឡាយ ។

**មហប្ផលានិសំសោ** បុគ្គលរក្សានូវឧបោសថសីលហើយបានពិចារណាដូច្នេះ ឈ្មោះថាបានរក្សាអរិយឧបោសថ មានផលានិសង្សដ៏ច្រើនជាយ៉ាងក្រៃលែង ។

## អង្គនៃសិក្ខាបទឧបោសថសីល ៨

ឧបោសថសីលមានសិក្ខាបទ ៨ នេះ ក្នុងសិក្ខាបទមួយៗ មានអង្គសម្រាប់វិនិច្ឆ័យ ឲ្យដឹងថាអ្នករក្សាសិក្ខាបទនោះៗ បានបរិសុទ្ធផូរផង់ឬដាច់ធ្លុះធ្លាយ ។

អង្គនៃសិក្ខាបទ ៤ គឺ បាណាតិបាត, អទិន្នាទាន, មុសាវាទ និងសុរាមេរយៈ ដូចគ្នានឹងនិច្ចសីល ដែលបានពោលខាងដើមរួចហើយ ។ ក្នុងទីនេះពោលតែសិក្ខាបទ ៤ ទៀតគឺ អព្រហ្មចរិយៈ, វិកាលភោជនៈ,

---

១- សមថកម្មដ្ឋាន និងវិបស្សនាកម្មដ្ឋាន នឹងមានពោលនៅខាងចុងនៃច្បាប់នេះ ។

*នច្ចគីត និងឧច្ចាសយនៈ ដូចតទៅ :*

## អព្រហ្មចរិយៈមានអង្គ ៤ គឺ

១- **សេវនវត្ថុ** *វត្ថុជាទីទម្លាយនូវសីល គឺទ្វារមគ្គទាំង ៣០[១] ណាមួយ,*

២- **សេវនចិត្តំ** *ចិត្តគិតនឹងសេព,*

៣- **តជ្ជោ វាយាមោ** *ព្យាយាមនឹងសេព,*

៤- **មគ្គេន មគ្គប្បដិបាទនំ** *ញ៉ាំងមគ្គនិងមគ្គឲ្យដល់គ្នា ។*

## វិកាលភោជនៈមានអង្គ ៤ គឺ

១- **វិកាលោ** *ថ្ងៃរសៀល,*

២- **យាវកាលិកំ** *របស់គួរបរិភោគក្នុងកាល,*

៣- **តជ្ជោ វាយាមោ** *ព្យាយាមនឹងបរិភោគ,*

៤- **អជ្ឈោហរណំ** *បរិភោគចូលទៅក្នុងបំពង់ក ។*

**នច្ចគីត** និង **មាលា** *ញែកចេញជា ២ ដើម្បីនឹងឲ្យដាច់អង្គដោយឡែកពីគ្នាគឺ*

## នច្ចគីតមានអង្គ ៣ គឺ

១- **នច្ចាទិ** *រាំច្រៀងជាដើម,*

---

១-មិនបានពោលក្នុងទីនេះទេ ព្រោះមានពោលក្នុងវិនយវណ្ណនាដោយពិស្តារហើយ ។

២- **តប្បុរេក្ខារតា** នឹងចង់រាំច្រៀង,

៣- **ទស្សនាទិ** ទៅមើល ទៅស្ដាប់ជាដើម។

## មាលាមានអង្គ ៣ គឺ

១- **មាលាទិ** គ្រឿងប្រដាប់មានផ្កាជាដើម,

២- **តប្បុរេក្ខារតា** នឹងចង់តែងប្រដាប់,

៣- **ធារណាទិ** តែងប្រដាប់ជាដើម។

## ឧច្ចាសយនៈ មានអង្គ ៣ គឺ

១- **អកប្បិយសណ្ឋារតា** ទ្រទ្រង់គ្រឿងកម្រាលមិនគួរ,

២- **អតីតប្បមាណកំ** កន្លងប្រមាណ,

៣- **សយនាសនំ** ដេក អង្គុយ ។

អង្គនៃសិក្ខាបទទាំងឡាយនេះគប្បីយល់ថា កាលបុគ្គលប្រព្រឹត្តកន្លងសិក្ខាបទណា បើកិរិយាធ្វើនោះប្រកបព្រមដោយអង្គដូចមានចែងក្នុងសិក្ខាបទនោះ គប្បីសន្និដ្ឋានថា សិក្ខាបទនោះដាច់ធ្លុះធ្លាយ ហើយបើមិនប្រកបព្រមដោយអង្គនោះទេ ឈ្មោះថាគង់នៅបរិសុទ្ធផូរផង់ដូចដើម ។

## អំពីអានិសង្សនៃបុគ្គលមានសីលបរិសុទ្ធ

អានិសង្សនៃបុគ្គលមានសីលបរិសុទ្ធនេះ ក៏មានន័យពោលក្នុងនិច្ចសីលខាងដើមខ្លះហើយ សូមពោលអានិសង្សសីលក្នុងទីនេះបន្ថែមទៀត ។

*បុគ្គលឯណាដែលបានសមាទាននូវសីល រក្សានូវសីលឲ្យបរិសុទ្ធ បរិបូណ៌ប្រពៃ មិនប្រព្រឹត្តកន្លងនូវសិក្ខាបទនៃសីល បុគ្គលនោះឈ្មោះថា មានសីលបរិសុទ្ធ ។*

**សីលកណ្ឋា អនុត្តរោ**[១] *បុគ្គលណាមានសីលដ៏ស្អាតបរិសុទ្ធ ហើយ បុគ្គលនោះឈ្មោះថាមានក្លិនក្រអូប ។*

**សីលំ ចាជេយ្យមុត្តមំ** *បុគ្គលណាមានសីលដ៏ស្អាតបរិសុទ្ធ ហើយ បុគ្គលនោះឈ្មោះថាមានស្បៀងដ៏ឧត្តមជាប់រៀងទៅ ។*

**សីលំ អាភរណំ សេដ្ឋំ** *បុគ្គលណាមានសីលដ៏ស្អាតបរិសុទ្ធ ហើយ បុគ្គលនោះឈ្មោះថាមានគ្រឿងតាក់តែងនូវរាងកាយ ឲ្យថ្កើងរុងរឿងក្នុងលោកិយនេះនិងបរលោក ។*

**សីលំ អចាយសញ្ញនំ** *បុគ្គលណាមានសីលដ៏ស្អាតបរិសុទ្ធ ហើយ បុគ្គលនោះឈ្មោះថាមាននាទីបិទនូវអបាយ គឺមិនបានទៅកើតក្នុងអបាយឡើយ ។*

**សីលំ សមាធិគាមិនី** *សីលនេះជាទីញ៉ាំងបុគ្គលទាំងឡាយឲ្យដល់នូវសមាធិដ៏ប្រសើរ ។*

**សីលេន**[២] **សុគតឹ យន្តិ** *ជនទាំងឡាយបានសុគតិ ដោយសារសីល ។*

---

១- ពោលតាមច្បាប់ ឱវាទបោសថកថា ។ ២- ពោលតាមច្បាប់វិធីថ្វាយបង្គំព្រះ ផ្សាយចេញពីសង្ឃបណ្ណាល័យវត្តបទុមវតី ។

**សីលេន  ភោគសម្បទា** *ជនទាំងឡាយបានភោគសម្ប័ទ ដោយសារសីល ។*

**សីលេន និព្វានំ យន្តិ** *ជនទាំងឡាយបានព្រះនិព្វាន ដោយ សារសីល ។*

## អំពីទោសនៃបុគ្គលទ្រុស្តសីល (ឱបោសថសីល)

*ទោសនៃបុគ្គលទ្រុស្តសីលនេះ  កំមានន័យពោលក្នុងនិច្ចសីលខាង ដើមខ្លះហើយ  សូមពោលអំពីទោសទ្រុស្តសីលក្នុងទីនេះបន្ថែមទៀត ។*

**ទុស្សីលោ**[១] **អសមាហិតោ** *បុគ្គលណាមិនបានរក្សានូវ សីល ឬប្រព្រឹត្តកន្ទង់នូវសីល បុគ្គលនោះឈ្មោះថាមានចិត្តមិនតាំងមាំ ។*

**អសទ្ធោ ទុស្សីលោ** *បុគ្គលទ្រុស្តសីល ឈ្មោះថាជាមនុស្ស មិនមានចិត្តជឿក្នុងសាសនានៃព្រះមានព្រះភាគ ។*

**ទុស្សីលោ អចាយតតោ អាហុ** *មនុស្សទ្រុស្តសីលតែង ទៅកាន់អបាយ (នរក ប្រេត អសុរកាយ តិរច្ឆាន) ។*

**អកាតញ្ញូ** *ឈ្មោះថាជាមនុស្សអកតញ្ញូ គឺមិនដឹងនូវគុណនៃ ព្រះរតនត្រ័យ ។*

**និម្មាតាបិតរោ** *ឈ្មោះថាជាមនុស្សមិនមានមាតាបិតាក្នុងលោកិយ នេះនិងបរលោក ។*

---

១- ពោលតាមច្បាប់ ឱបោសថកថា ។

**អជាថោ ទុក្កតោ** *ឈ្មោះថាជាមនុស្សកំព្រាក្រលំបាកឥតទីពឹង ។*

**និប្បច្ចយោ និយតគតិកោ** *ជាមនុស្សមានគតិទៀងតែនឹងទៅកើតក្នុងនរក មិនមានបច្ច័យជួយទំនុកបម្រុងឲ្យល្អឡើយ ។*

**ឯវំ វុត្តញ្ច** *ឯឧបោសថសីលមានន័យដូចពោលមកហើយនេះ ជាសីលយ៉ាងកណ្តាល ជាជាន់បន្ទាប់ ជាគ្រឿងលះកិលេសយ៉ាងកណ្តាល ។*

**យោ ច សទ្ធាសម្បន្នោ** *បុគ្គលជាឧបាសក ឧបាសិកាណាប្រកបព្រមដោយចិត្ត ជឿជាក់ច្បាស់នូវសាសនា នៃព្រះមានព្រះភាគខ្ជាំងក្លាហើយ បានសមាទានរក្សានូវ* **ទសសីល** *គឺសីល ១០ ជាប់ជានិច្ចតរៀងទៅ ឧបាសក ឧបាសិកានោះ ឈ្មោះថាបានប្រតិបត្តិសង្រួមក្នុងអតិរេកសីល គឺសីលដ៏លើសលុប ដ៏ប្រសើរ ។ អ្នករក្សាសីលនេះគួរធ្វើខ្លួន ឬប្រព្រឹត្តខ្លួនឲ្យដូចព្រះអនាគាមិបុគ្គល ។*

## អតិរេកសីល(១)

**អតិរេកសីល** *នេះ ប្រែថាសីលដ៏លើសលុប ដ៏ប្រសើរលើសសម្រាប់ឧបាសក ឧបាសិកា អ្នកមានសទ្ធាខ្ជាំងក្លារក្សា, ឬហៅថា* **ទសសីល** *គឺសីល ១០ ដូច្នេះក៏បាន ។*

---

១- បរមត្ថជោតិកា អដ្ឋកថា ខុទ្ទកបាឋ ។ នឹងដកស្រង់យកន័យតាមច្បាប់អតិរេកសីល ដែលព្រះធម្មវរោត្តម តុង-ឈួន រៀបរៀង ។

# កិច្ចសមាទាននូវអតិរេកសីល

*មុនដំបូង ឧបាសក ឧបាសិកា គប្បីរៀបចំខ្លួនឲ្យសមគួរត្រូវតាមឋានៈជាអ្នកមិនមានកង្វល់ ឬព័ន្ធព័ទ្ធដោយកិច្ចគ្រប់យ៉ាងដែលជាអំពើដឹកនាំចិត្តឲ្យធាប់ប្រែក្លាយទៅជាចិត្តសៅហ្មងកករល្អក់ រួចប្តេជ្ញាថា អាត្មាអញនឹងជាអ្នករក្សានូវសីល ១០ ឲ្យបរិសុទ្ធផូរផង់, រួចហើយគប្បីធ្វើកិច្ចដូចតទៅនេះ ៖*

*ទី១- នមស្ការព្រះរតនត្រ័យ (ឯកិច្ចនមស្ការនេះដូចន័យដែលបានពោលក្នុងកិច្ចសមាទាននៃសីលខាងដើម) ។*

*ទី២- គប្បីធ្វើកិច្ចសមាទាននូវអតិរេកសីល គឺទសសីល(សីល ១០) ក្នុងទីចំពោះព្រះភក្ត្រព្រះភិក្ខុសង្ឃ ឬសាមណេរ ។*

## អារាធនាសមាទាននូវអតិរេកសីលដោយបាលីថា

**អហំ[១] / មយំ } ភន្តេ តិសរណេន សហ ទសសីលំ យាចា { មិ / ម**

*៣ ដង ។*

*បពិត្រព្រះករុណាដ៏ចម្រើន! ខ្ញុំព្រះករុណា សូមនូវទសសីល គឺ*

---

១- តាមខុទ្ទកបាឋៈ ម្យ៉ាងទៀត តាមលោកនិយមតគ្នាមកថាដូច្នេះ ៖

អហំ / មយំ } ភន្តេ តិសរណេន សហ ទសង្គសមន្នាគតំ អតិរេកសីលំ យាចា { មិ / ម } ៣ ដង ។

បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំព្រះករុណាសូមនូវអតិរេកសីល ប្រកបដោយអង្គ ១០ ប្រការ ព្រមទាំងព្រះត្រៃសរណគមន៍ ។

សីល ១០ ប្រការ ព្រមទាំងព្រះត្រៃសរណគមន៍ ។

លោកអ្នកឲ្យសីល សូត្រនាំមុន, ឧបាសក ឧបាសិកា ចាំសូត្រតាមក្រោយ ជាពាក្យនមស្ការបាលីថា **នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស,** ៣ ដង ។ សេចក្តីប្រែដូចពោលហើយក្នុងខាងដើម ។

## ព្រះត្រៃសរណគមន៍

ក្នុងខណៈដែលបន្ទីវាចាទទួលព្រះត្រៃសរណគមន៍នោះ គប្បីតាំងចិត្តថា "យើងយកព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ជាទីពឹងស្មើជីវិត" ដោយបាលីថា

**ពុទ្ធំ សរណំ គច្ឆាមិ** ខ្ញុំព្រះករុណា ដល់នូវព្រះពុទ្ធជាទីពឹង,
**ធម្មំ សរណំ គច្ឆាមិ** ខ្ញុំព្រះករុណា ដល់នូវព្រះធម៌ជាទីពឹង,
**សង្ឃំ សរណំ គច្ឆាមិ** ខ្ញុំព្រះករុណា ដល់នូវព្រះសង្ឃជាទីពឹង,
**ទុតិយម្បិ** អស់វារៈជាគម្រប់ ២ ដងផង, **តតិយម្បិ** អស់វារៈជាគម្រប់ ៣ ដងផង ។

លោកអ្នកឲ្យសីលថា **តិសរណគមនំ និដ្ឋិតំ,** ព្រះត្រៃសរណគមន៍ចប់ហើយ ។

ឧបាសក ឧបាសិកា ទទួលថា **អាម ភន្តេ** ព្រះករុណា ។

## សិក្ខាបទ ១០ នៃអតិរេកសីល គឺទសសីល

*ក្នុងខណៈដែលនឹងបន្ទឹវាចាទទួលសិក្ខាបទ ១០ គប្បីតាំងវិរតិចេតនាលះវៀរនូវទោសនោះៗ ទៅតាមសិក្ខាបទដែលបានទទួល គឺតាំងចិត្តថាខ្ញុំមិនសម្លាប់សត្វ ១ មិនលួចទ្រព្យគេ ១ មិនប្រព្រឹត្តធម៌ពុំប្រសើរ (គឺសេពមេថុន) ១ មិននិយាយកុហក ១ មិនផឹកទឹកស្រវឹង ១ មិនបរិភោគអាហារក្នុងវេលាខុស ១ មិនរាំ មិនច្រៀង ព្រមទាំងមិនមើលស្តាប់របាំ ចម្រៀង ១ មិនតាក់តែងរាងកាយដោយកម្រងផ្កា, គ្រឿងក្រអូប, គ្រឿងលាប និងមិនទ្រទ្រង់គ្រឿងអលង្ការរចនាផ្សេងៗ ១ មិនដេកមិនអង្គុយលើទីខ្ពស់-ធំនិងទីប្រសើរ ១ មិនទទួលកាន់យកនូវមាស និងប្រាក់ ១ ។*

## ការបន្លឺវាចាទទួលសិក្ខាបទ ១០ ដោយបាលីដូចតទៅ

*(សិក្ខាបទ ៦ ខាងដើម គឺបាណាតិបាត, អទិន្នាទាន, អព្រហ្មចរិយៈ, មុសាវាទ, សុរាមេរយៈ និងវិកាលភោជនៈ មានសេចក្តីប្រែដូចសិក្ខាបទក្នុងឧបោសថសីល ខាងដើមស្រាប់ហើយ សូមពោលតែបាលី មិនប្រែទៀតទេ, ឯសិក្ខាបទ ៤ ខាងចុងគឺ នច្ចគីត, មាលា, ឧច្ចាសយនៈ និងជាតរូបរជតៈ ពោលដោយមានសេចក្តីប្រែជាមួយផង)៖*

១- **បាណាតិបាតា វេរមណីសិក្ខាបទំ សមាទិយាមិ,**

២- **អទិន្នាទានា វេរមណីសិក្ខាបទំ សមាទិយាមិ,**

៣- **អព្រហ្មចរិយា វេរមណីសិក្ខាបទំ សមាទិយាមិ,**

៤- **មុសាវាទា វេរមណីសិក្ខាបទំ សមាទិយាមិ,**

៥- **សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណីសិក្ខាបទំ សមាទិយាមិ,**

៦- **វិកាលភោជនា វេរមណីសិក្ខាបទំ សមាទិយាមិ,**

៧- **នច្ចគីតវាទិតវិសូកទស្សនា វេរមណីសិក្ខាបទំ សមាទិយាមិ** *ខ្ញុំព្រះករុណា សមាទាននូវសិក្ខាបទ, គឺវៀរចាករាំច្រៀង ប្រគំតូរ្យតន្ត្រី, ព្រមទាំងមើលស្តាប់របាំចម្រៀងតូរ្យតន្ត្រី និងល្បែងដែលជាសត្រូវដល់កុសលធម៌ ។*

៨- **មាលាគន្ធវិលេបនធារណមណ្ឌនវិភូសនដ្ឋានា វេរមណីសិក្ខាបទំ សមាទិយាមិ** *ខ្ញុំព្រះករុណា សមាទាននូវសិក្ខាបទ គឺវៀរចាកប្រដាប់តាក់តែងរាងកាយដោយកម្រងផ្កាគ្រឿងក្រអូបគ្រឿងលាប និងគ្រឿងអលង្ការផ្សេងៗ ។*

៩- **ឧច្ចាសយនមហាសយនា វេរមណីសិក្ខាបទំ សមាទិយាមិ,** *ខ្ញុំព្រះករុណា សមាទាននូវសិក្ខាបទ គឺវៀរចាកទីដេកទីអង្គុយដ៏ខ្ពស់ និងទីដេកទីអង្គុយដ៏ធំ និងប្រសើរ ។*

១០- **ជាតរូបរជតប្បដិគ្គហណា វេរមណីសិក្ខាបទំ សមាទិយាមិ** *ខ្ញុំព្រះករុណា សមាទាននូវសិក្ខាបទ គឺវៀរចាកទទួលកាន់យកនូវមាស និងប្រាក់ ។*

## សមាទានរួមថា

**ឥមានិ ទសសិក្ខាបទានិ សមាទិយាមិ ។** *៣ ដង ។*

*ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទទាំងឡាយ ១០ នេះ ។*

*លោកអ្នកឲ្យសីល គប្បីឲ្យឱវាទថា :*

**ឥមានិ ទសសិក្ខាបទានិ តុម្ហេហិ ឧបាសកឧបាសិកាភូតេហិ អខណ្ឌំ កត្វា អប្បមាទេន សាធុកំ រក្ខិតព្វានិ** *លោកអ្នកជាឧបាសក ឧបាសិកាទាំងឡាយ, គប្បីរក្សានូវសិក្ខាបទទាំង ១០ នេះ ឲ្យបានជាអតិរេកសីលដ៏បរិសុទ្ធប្រពៃ ដោយសេចក្ដីមិនប្រមាទ កុំឲ្យដាច់ និងសៅហ្មងឡើយ ។*

*អ្នកសមាទានទទួលថា :*

**អាម ភន្តេ** *ព្រះករុណា ។*

*លោកអ្នកឲ្យសីល គប្បីប្រាប់អានិសង្សនៃអតិរេកសីល, (ឯអានិសង្សនឹងមានពោលនៅខាងមុខ) ។*

*កាលបុគ្គលជាឧបាសក ឧបាសិកា សមាទានរួចហើយ គប្បីប្រព្រឹត្តធម្មចរិយាវត្ត សង្រួមឥន្ទ្រិយ៍ទាំង ៦ គឺ ភ្នែក, ត្រចៀក, ច្រមុះ, អណ្ដាត កាយ, ចិត្ត ឲ្យប្រពៃ ហើយលះវៀរមេថុនសំយោគ ។*

## មេថុនសំយោគ(១)

*ព្រះមានព្រះភាគ កាលគង់ក្នុងវត្តជេតពន ក្បែរក្រុងសាវត្ថី ទ្រង់*

---

១- សត្តវិធមេថុនសំយោគសូត្រ ក្នុងភាណវារៈ ដែលអ្នកអាចារ្យ ប៊ូ-ប៉ូ ប្រែរៀបរៀង ។

ប្រារព្ធចំពោះ ជានុស្សោណិព្រាហ្មណ៍ សម្តែងនូវមេថុនសំយោគ (ការប្រកបក្នុងកិច្ចដែលជាគ្រឿងរួមបវេណីបុរស និងស្ត្រី (រួមសំវាស) នេះមាន ៧ ប្រការ ។

## មេថុនសំយោគ ៧ ប្រការគឺ

១- សេចក្តីត្រេកអរដោយការស្អិតស្អាង ការអប់ ការផ្ងូតទឹក ការនួតនៃមាតុគ្រាម[១] ហើយមានចិត្តតម្រេកទៅរកមេថុនក្នុងការបម្រើនោះ ។

២- គ្រាន់តែសើចក្អាកក្អាយប្រឡែងលេង សើចជាមួយនឹងមាតុគ្រាម ហើយមានចិត្តតម្រេកទៅរកមេថុន ក្នុងការលេងសើចនោះ ។

៣- គ្រាន់តែសម្លឹងភ្នែកមាតុគ្រាម ដោយភ្នែករបស់ខ្លួន ហើយមានចិត្តតម្រេកទៅរកមេថុន ដោយការសម្លឹងនោះ ។

៤- គ្រាន់តែស្តាប់សំឡេងមាតុគ្រាម និយាយក្តី យំក្តី សើចក្តី ច្រៀងក្តី ហើយមានចិត្តតម្រេកទៅរកមេថុន ដោយសំឡេងនោះ ។

៥- គ្រាន់តែរំពឹងនឹកដល់ការរឿងចាស់ ដែលកន្លងទៅហើយ ដែលធ្លាប់រួមមូលមិត្រកៀកកើយ និយាយលេងជាមួយនឹងមាតុគ្រាម ហើយមានចិត្តតម្រេកទៅរកមេថុន ។

៦- គ្រាន់តែឃើញគហបតី ដែលគេបរិបូណ៌ដោយកាមគុណ ៥ នៅបម្រើជាប្រក្រតី ហើយមានចិត្តតម្រេកទៅរកមេថុន ។

---

១- ត្រង់ពាក្យថាមាតុគ្រាមគ្រប់ៗ បើបុរសរក្សា ថាមាតុគ្រាមដដែល, បើស្ត្រីរក្សាថាបុរសវិញ ។

៧- គ្រាន់តែប្រព្រឹត្តព្រហ្មចរិយៈ តាំងចិត្តប្រាថ្នាដើម្បីនឹងបានជាទេវតា ឬចំពោះជាទេវតាអង្គណាមួយ ហើយមានចិត្តត្រេកទៅរកមេថុន ។

ភិក្ខុ សាមណេរ ឧបាសក ឧបាសិកា ដែលជាអ្នកប្ដេជ្ញាខ្លួនថាជាព្រហ្មចារីបុគ្គលមែនៗ គឺប្រព្រឹត្តមិនសេពមេថុនធម្ម មួយអន្ទើដោយមាតុគ្រាមសោះឡើយ សូម្បីគ្រាន់តែនៅត្រេកអររីករាយ ដោយមេថុន ៧ ប្រការនេះក៏ពុំបានដែរ ត្រូវតែលះវៀរមេថុនសំយោគនេះជាដាច់ខាត ទើបព្រហ្មចរិយធម៌បរិសុទ្ធផូរផង់ល្អ ។

## អំពីវត្តប្រតិបត្តិក្នុងអតិរេកសីល

ឯវត្តប្រតិបត្តិ ត្រូវប្រព្រឹត្តមានកិរិយាដូចជាអនាគាមិបុគ្គល ឬប្រព្រឹត្តមានកិរិយាដូចជាបិប្ផលិមាណព និងនាងភទ្ទកាបិលានី ដែលប្រព្រឹត្តមេថុនវិរតិព្រហ្មចរិយធម៌ ហើយគប្បីចម្រើនភាវនា មានពុទ្ធានុស្សតិជាដើម និងស្ដាប់នូវធម្មទេសនាជាវត្ត ។

បុគ្គលជាឧបាសក ឧបាសិកា រក្សានូវអតិរេកសីល បើមានសង្ស័យថារក្សាមិនបរិសុទ្ធ និងដាច់ធ្លុះធ្លាយនូវសិក្ខាបទណាមួយ បុគ្គលនោះគប្បីពិចារណាតាមអង្គនៃសិក្ខាបទនោះ ហើយវិនិច្ឆ័យតទៅ ។

## អង្គនៃសិក្ខាបទអតិរេកសីល គឺទសសីល (សីល ១០)

អង្គនៃសិក្ខាបទគឺ បាណាតិបាត, អទិន្នាទាន, មុសាវាទ, សុរាមេរយៈ

ដូចបានពោលក្នុងនិច្ចសីលខាងដើម, សិក្ខាបទគឺ អព្រហ្មចរិយៈ, វិកាលភោជនៈ, នច្ចគីត, មាលា និងឧច្ចាសយនៈ ដូចបានពោលក្នុងឧបោសថសីលខាងដើម, ក្នុងទីនេះ សូមពោលតែសិក្ខាបទជាតរូបរជតៈមួយ ។

## ជាតរូបរជតៈ មានអង្គ ៣ គឺ

១- **ជាតរូបរជតំ** មាសនិងប្រាក់ (និងរូបិយៈគ្រប់បែប),

២- **អត្តឧទ្ទិសតា** ចំពោះជារបស់ខ្លួន,

៣- **គហណំ** ទទួលទុកដាក់ដោយខ្លួនឯង ឬប្រើអ្នកដទៃឲ្យទទួលទុកដាក់ ហើយត្រេកអរ ។

អង្គនៃសិក្ខាបទទាំង ១០ នេះ ក្នុងសិក្ខាបទមួយៗ លុះតែប្រព្រឹត្តកន្លងគ្រប់អង្គ ទើបឈ្មោះថាប្រព្រឹត្តកន្លង ។

បើឧបាសក ឧបាសិកា ពិចារណាមើលសិក្ខាបទទាំង ៥-៨ ឬទាំងនេះគ្រប់សព្វទៅ ឃើញថាមិនដាច់មិនធ្លុះធ្លាយទេ ព្រោះសិក្ខាបទមួយៗមានអង្គជាគ្រឿងពិនិត្យ ដូចបាណាតិបាត មានអង្គ ៥ បើប្រព្រឹត្តមិនប្រកបព្រមដោយអង្គទាំង ៥ នេះទេ ឈ្មោះថាមិនដាច់សិក្ខាបទបាណាតិ-បាតនោះទេ ។ សេចក្តីនេះ ពិតណាស់ហើយ តែសូមអ្នកសមាទានសីល កុំអស់ហើយត្រឹមអង្គនៃសិក្ខាបទប៉ុណ្ណោះ សូមពិនិត្យមើលចិត្តរបស់ខ្លួនឲ្យល្អិតទៅទៀត ឲ្យដឹងថាចិត្តយើងប្រកបដោយមេថុនសំយោគ

ទាំង ៧ ប្រការណាមួយដែរឬទេ? បើពិនិត្យទៅឃើញថាចិត្តយើងនៅសៅហ្មងដោយមេថុនសំយោគណាមួយនោះ ចូរខំដុសខាត់ជម្រះចិត្តឲ្យជ្រះស្រឡះពីមេថុនសំយោគទាំង ៧ ប្រការកុំខាន ទើបសីលរបស់យើងបរិសុទ្ធផូរផង់ល្អ មានផលានិសង្សដ៏បរិបូណ៌ ។

## អំពីអានិសង្សនៃអ្នករក្សាសីល

ផលានិសង្សនៃបុគ្គលដែលបានរក្សានូវអតិរេកសីល សីលបរិសុទ្ធមានន័យដូចដែលបានពោលខ្វះហើយក្នុងនិច្ចសីល និងឧបោសថសីលនោះដែរ ។ តទៅសូមពោលតែអានិសង្សខ្វះ ដើម្បីបន្ថែមលើអានិសង្សដែលពោលរួចមកហើយនោះ ។

### លោកអ្នកឲ្យសីល រមែងប្រាប់អានិសង្ស ៣ ប្រការគឺ[១]

១- **សីលេន សុគតឹ យន្តិ** បុគ្គលទាំងឡាយបានដល់នូវសុគតិដោយសារសីល ។

២- **សីលេន ភោគសម្បទា** បុគ្គលទាំងឡាយបានដល់នូវភោគសម្បទ័ និងបរិវារសម្បទ័ ដោយសារសីល ។

៣- **សីលេន និព្វុតឹ យន្តិ** បុគ្គលទាំងឡាយបានដល់នូវទីរលត់ទុក្ខ គឺព្រះនិព្វាន ដោយសារសីល ។

ឯអានិសង្សដែលនឹងពោលតទៅនេះ កំត្រូវសម្រេចផលដល់អ្នក

---

១- ពោលតាមច្បាប់អតិរេកសីល ។

រក្សាសីលនានាបរិសុទ្ធផងដែរ ពុំមែនចំពោះតែអតិរេកសីលនោះទេ ។

[១]កាលព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន ជារបស់អនាថ-បិណ្ឌិកសេដ្ឋី សាងថ្វាយ ជិតក្រុងសាវត្ថី ព្រះអង្គប្រារព្ធនឹងព្រះអានន្ទ ដែលទូលសួរព្រះអង្គ អំពីសីល មានអ្វីជាអានិសង្ស? ព្រះអង្គទ្រង់ត្រាស់សម្ដែងថា

អានិសង្សនៃសីលមាន ១០ ប្រការគឺ

១- **អវិប្បដិសារៈ** សេចក្ដីមិនក្ដៅក្រហាយ,

២- **ចាមុជ្ជៈ**[២] សេចក្ដីរីករាយទន់,

៣- **បីតិ** សេចក្ដីរីករាយខ្លាំង,

៤- **បស្សទ្ធិ** សេចក្ដីស្ងប់រម្ងាប់,

៥- **សុខៈ** សេចក្ដីសុខ,

៦- **សមាធិ** ការតាំងចិត្តមាំ,

៧- **យថាភូតញ្ញាណទស្សនៈ** ការឃើញនូវសច្ចៈ ៤ ដោយញាណតាមពិត,

៨- **និព្វិទា** សេចក្ដីនឿយណាយ,

៩- **វិរាគៈ** ការប្រាសចាកតម្រេក,

---

១- សុត្តន្តបិដក អង្គុត្តរនិកាយ ឯកាទសកនិបាត និស្សយវគ្គទី ១, ដែលអ្នកអាចារ្យប៊ូ-ប៉ូ ប្រែរៀបរៀង ។ ២- ក្នុងសូត្រខ្លះ ប្រើបាមោជ្ជៈ ប្រែបានដូចគ្នានឹងបាមុជ្ជៈដែរ ។

១០- **វិមុត្តិញ្ញាណទស្សនៈ** ការពិចារណាឲ្យដឹងច្បាស់ នូវទីកើតទីរលត់នៃសង្ខារ ។

ព្រះមានព្រះភាគ ទ្រង់ត្រាស់ពន្យល់តទៅទៀតថា

បុគ្គលដែលមានសីលពេញបរិបូណ៌ហើយ មិនចាំបាច់ទន្ទឹងទេ ទៀងតែនឹងបានអវិប្បដិសារៈជាអានិសង្ស ។

កាលបានអវិប្បដិសារៈហើយ ទៀងតែនឹងបានបាមុជ្ជៈ ជាអានិសង្ស

| | | | | |
|---|---|---|---|---|
| - | បាមុជ្ជៈ | - | បីតិ | - |
| - | បីតិ | - | បស្សទ្ធិ | - |
| - | បស្សទ្ធិ | - | សុខៈ | - |
| - | សុខៈ | - | សមាធិ | - |
| - | សមាធិ | - | យថាភូតញ្ញាណទស្សនៈ | - |
| - | យថាភូតញ្ញាណទស្សនៈ | - | និព្វិទា | - |
| - | និព្វិទា | - | វិរាគៈ | - |
| - | វិរាគៈ | - | វិមុត្តិញ្ញាណទស្សនៈ | - |

កាលព្រះពុទ្ធអង្គ ទ្រង់ពន្យល់អានិសង្សនៃសីល បណ្តោយគ្នាតាមលំដាប់ដូច្នេះហើយ ទើបព្រះអង្គទ្រង់ពន្យល់អំពីអានិសង្សសីល ចាប់ពីចុងប្រាសឡើងទៅខាងដើមវិញថា

| | | |
|---|---|---|
| វិរាគៈ | មានវិមុត្តិញ្ញាណទស្សនៈ | ជាអានិសង្ស |
| និព្វិទា | មាន វិរាគៈ | - |
| យថាភូតញ្ញាណទស្សនៈ | មាន និព្វិទា | - |
| សមាធិ | មានយថាភូតញ្ញាណទស្សនៈ | - |
| សុខៈ | មាន សមាធិ | - |
| បស្សទ្ធិ | មាន សុខៈ | - |
| បីតិ | មាន បស្សទ្ធិ | - |
| បាមុជ្ជៈ | មាន បីតិ | - |
| អវិប្បដិសារៈ | មាន បាមុជ្ជៈ | - |

## អំពីទោសនៃអ្នកគ្មានសីល

កាលព្រះពុទ្ធអង្គទ្រង់ពន្យល់អានិសង្សនៃសីលចប់ហើយ ទើបព្រះអង្គទ្រង់ពន្យល់អំពីទោសនៃអ្នកគ្មានសីលតទៅ :

## បុគ្គលគ្មានសីល តែងមិនបានអវិប្បដិសារៈ

| | | | | |
|---|---|---|---|---|
| កាលបើគ្មាន | អវិប្បដិសារៈហើយ | | បាមុជ្ជៈ | ក៏គ្មាន |
| - | បាមុជ្ជៈ | - | បីតិ | - |
| - | បីតិ | - | បស្សទ្ធិ | - |
| - | បស្សទ្ធិ | - | សុខៈ | - |
| - | សុខៈ | - | សម្មាសមាធិ | - |

កាលបើគ្មាន សម្មាសមាធិហើយ យថាភូតញ្ញាណទស្សនៈ ក៏គ្មាន

| | | | |
|---|---|---|---|
| - | យថាភូតញ្ញាណទស្សនៈ | - | និព្វិទា | - |
| - | និព្វិទា | - | វិរាគៈ | - |
| - | វិរាគៈ | - | វិមុត្តិញ្ញាណទស្សនៈ | - |

បុគ្គលជំពូកនេះ ប្រៀបដូចជាដើមឈើ ដែលគ្មានមែកនិងស្លឹក, កាលបើគ្មានមែកនិងស្លឹកនោះ ក្រមរក្តី សំបកក្តី ស្រាយក្តី ខ្លឹមក្តី របស់ដើមឈើនោះ ក៏មិនពេញលេញដែរ ។

(ឯទោសនៃអ្នកគ្មានអតិរេកសីលនេះ ក៏មានន័យដូចដែលបានពោលហើយក្នុងនិច្ចសីល និងឧបោសថសីលខាងដើមនោះដែរ ការដែលពោលបន្ថែមមកប៉ុណ្ណេះ ល្មមយកជាគតិបានហើយ) ។

**ឃរំ វុត្តញ្ច** ឯអតិរេកសីលដែលពោលមកនេះ ជាសីលយ៉ាងឧក្រិដ្ឋ ជាសីលជាន់ខ្ពស់ ជាគ្រឿងលះកិលេសយ៉ាងល្អិត ។

ម្យ៉ាងទៀត បើឧបាសក ឧបាសិកា មិនអាចនឹងរក្សានូវអតិរេកសីលបានទេ គប្បីរក្សាតែត្រឹមឧបោសថសីល ប្រកបដោយអង្គ ៨ ប្រការឲ្យបរិសុទ្ធល្អ តាមកាលកំណត់ ក៏ជាការល្អប្រពៃណាស់ហើយ ។ ឬ ថាបើពុំអាចនឹងរក្សានូវឧបោសថសីលបានទេ នឹងរក្សាត្រឹមតែនិច្ចសីល គឺបញ្ចសីល (សីល ៥) ក៏ជាការប្រពៃណាស់ហើយ ។

បុ. ទី ៤- **កោ អាជីវោ** ការចិញ្ចឹមជីវិតនៃឧបាសកនោះ តើដូចម្តេច?

វ. ទី ៤- ឧបាសក ឧបាសិកា ត្រូវវៀរចាកការចិញ្ចឹមជីវិតដោយ **មិច្ឆាវណិជ្ជា** គឺធ្វើជំនួញការលក់ខុសចាកគន្លងធម៌ ៥ ប្រការ, ហើយគប្បីចិញ្ចឹមជីវិតដោយ **សម្មាអាជីវៈ** ប្រកបដោយគន្លងធម៌ ។

មិច្ឆាវណិជ្ជា ធ្វើជំនួញ ការលក់ខុសចាកគន្លងធម៌ ៥ ប្រការនោះគឺ[១]

១- **សត្ថវណិជ្ជា** ជួញគ្រឿងប្រហារ,

២- **សត្តវណិជ្ជា** ជួញមនុស្ស,

៣- **មំសវណិជ្ជា** ជួញសត្វរស់ ដែលគេនឹងសម្លាប់យកសាច់,

៤- **មជ្ជវណិជ្ជា** ជួញទឹកស្រវឹង,

៥- **វិសវណិជ្ជា** ជួញថ្នាំពិស ។

អធិប្បាយអំពីជំនួញ ៥ ប្រការ

ទី ១- **សត្ថវណិជ្ជា** ជួញគ្រឿងប្រហារ, គ្រឿងប្រហារនោះសំដៅយកគ្រឿងប្រហារគ្រប់បែប ដែលជារបស់ធ្វើជីវិតនៃមនុស្សនិងសត្វតិរច្ឆានឲ្យវិនាសអន្តរាយ ដូចយ៉ាងកាំបិត, កាំភ្លើង, លំពែង, ដាវ, ចម្រូង, សំណាញ់, អួន, លប ជាដើម ។

ទី ២- **សត្តវណិជ្ជា** ជួញមនុស្ស, ជួញមនុស្សនោះសំដៅយកលក់ គឺល្បួងលួងលោម បញ្ឆោតយកមនុស្សមកលក់ ។

ទី ៣- **មំសវណិជ្ជា** ជួញសត្វរស់ដែលគេនឹងសម្លាប់យកសាច់,

---

១- សុត្តន្តបិដក អង្គុត្តរនិកាយ បញ្ចកនិបាត ឆដ្ឋមភាគ ទំព័រ ១៦០ ។

ជួញសត្វរស់ដែលគេនឹងសម្លាប់យកសាច់ និងសាច់សត្វដែលខ្លួនសម្លាប់ដើម្បីជួញធ្វើជាអាហារ ។

ទី ៤- **មជ្ជវណិជ្ជា** ជួញទឹកស្រវឹង, ទឹកស្រវឹងនោះ សំដៅយកទឹកស្រវឹងគ្រប់បែប ដែលធ្វើអ្នកផឹកឲ្យស្រវឹងភ្លេចស្មារតី ឲ្យកើតសេចក្តីប្រមាទ ។

ទី ៥- **វិសវណិជ្ជា** ជួញថ្នាំពិស, ថ្នាំពិសនោះ សំដៅយកថ្នាំពិសគ្រប់បែប ដែលធ្វើអ្នកបរិភោគឲ្យវិនាសជីវិត និងរាងកាយបាន ។

ឯជំនួញ ៥ ប្រការនេះ ឧបាសក ឧបាសិកា ត្រូវលះវៀរឲ្យដាច់ស្រឡះចេញ ព្រោះជំនួញទាំងនេះ សុទ្ធតែជាគ្រឿងបណ្តាលឲ្យកើតបាណាតិបាតខ្លះ ឲ្យទាបថោកខ្លះដែលឧបាសកឧបាសិកាមិនគួរធ្វើឡើយ ។

បុ. ទី ៥- **កា សម្បត្តិ** សម្បត្តិ គឺសេចក្តីចម្រើននៃឧបាសកនោះតើដូចម្តេច?

វិ. ទី ៥- សម្បត្តិនៃឧបាសកមាន ៥ ប្រការគឺ[១]

១- ឧបាសកប្រកបដោយសទ្ធា,

២- ឧបាសកមានសីលបរិសុទ្ធ,

៣- ឧបាសកមិនភ្ញាក់ផ្អើលដោយមង្គល គឺជឿកម្ម មិនជឿមង្គល,

៤- ឧបាសកមិនស្វែងរកខេត្តបុណ្យ ក្រៅព្រះសាសនា,

៥- ឧបាសកបំពេញបុណ្យតែក្នុងព្រះពុទ្ធសាសនា ។

---

១- សុត្តន្តបិដក អង្គុត្តរនិកាយ បញ្ចកនិបាត ឆដ្ឋមភាគ ទំព័រ ១៨៦ ។

# អធិប្បាយអំពីសម្បត្តិទាំង ៥ ប្រការ

ទី ១- ឧបាសកប្រកបដោយសទ្ធានោះ គឺឧបាសក ឧបាសិកា ជឿរបស់ដែលគួរជឿ ដូចជឿគុណព្រះរតនត្រ័យ, ជឿថាធ្វើល្អបានល្អ ធ្វើអាក្រក់បានអាក្រក់, ឬជឿថាសត្វមានកម្មជារបស់ខ្លួន, មានកម្មជាកំណើត, មានកម្មជាទីពឹងពាក់អាស្រ័យ ធ្វើល្អនឹងបានល្អ ធ្វើអាក្រក់នឹងបានអាក្រក់ នឹងត្រូវទទួលផលរបស់កម្មនោះ, ជាអ្នកមិនជឿរឿងដែលមិនពិត ឬរឿងក្លែងក្លាយ ដោយមិនបានពិចារណារកហេតុផលជាមុន ។

ទី ២- ឧបាសកមានសីលបរិសុទ្ធនោះ គឺជាអ្នកមានកាយ វាចាមានមារយាទរៀបរយស្ងប់ស្ងៀម ជាអ្នកមានសីលមិនដាច់ពពាលពព្រុស គឺនៅស្អាតគ្រប់បរិបូណ៌ តាមដែលខ្លួនបានសមាទានមកឥតខ្វះកន្ទុះឡើយ ។

ទី ៣- ឧបាសកមិនភ្ញាក់ផ្អើលដោយមង្គល, គឺមិនជឿមង្គលភ្ញាក់ផ្អើលផ្សេងៗ ដូចមិនជឿឫក្សយាម មិនជឿគ្រោះល្អ គ្រោះអាក្រក់ មិនជឿថាព្រះនោះព្រះនេះសោយអាយុ នឹងបានទទួលជោគល្អ ឬជោគអាក្រក់ដូច្នេះ ដូច្នោះជាដើម ជឿតែកម្មនិងផលរបស់កម្ម ជាគោលកំណត់ គឺជឿថាបុគ្គលប្រព្រឹត្តហេតុល្អបានទទួលផលល្អ បុគ្គលប្រព្រឹត្តហេតុអាក្រក់បានទទួលផលអាក្រក់ អំពើល្អ អាក្រក់ដែលខ្លួនបានប្រព្រឹត្តរួចហើយនោះជាហេតុសុខនិងទុក្ខ ដែលខ្លួនបានទទួលនោះជាផលនៃ

អំពើល្អ-អាក្រក់ដែលខ្លួនបានធ្វើហើយ មិនមែនគ្រោះល្អ ឬគ្រោះអាក្រក់ឲ្យផលឡើយ ដូចពុទ្ធភាសិតថា **កល្យាណការី កល្យាណំ** ធ្វើហេតុល្អរមែងបានផលល្អ, **បាបការី ច បាបកំ** ធ្វើហេតុអាក្រក់រមែងបានផលអាក្រក់ដូច្នេះ ។

ទី ៤- ឧបាសកមិនស្វែងរកខេត្របុណ្យ ក្រៅព្រះពុទ្ធសាសនានោះ សេចក្តីថា បុណ្យឯណាៗ ដែលសាសនាដទៃ មានគ្រិស្តសាសនា ឬអិស្លាមសាសនាជាដើម គេនិយមថាជាផ្លូវធ្វើបុណ្យរបស់គេ យើងមិនត្រូវនិយមធ្វើតាមគេដូច្នោះឡើយ គឺមិននិយមធ្វើតាមលទ្ធិសាសនាដទៃៗ ។

ទី ៥- បំពេញបុណ្យតែក្នុងព្រះពុទ្ធសាសនានោះ សេចក្តីថាបុញ្ញ-កិរិយាវត្ថុណាដែលច្បាប់ព្រះពុទ្ធសាសនានិយមឲ្យធ្វើ ឧបាសកក៏បំពេញតែបុញ្ញកិរិយាវត្ថុនោះ ដូចការឲ្យទានរក្សាសីល ចម្រើនភាវនាជាដើម ។

បុ. ទី ៦- **កា វិបត្តិ** វិបត្តិគឺសេចក្តីវិនាសនៃឧបាសក តើដូចម្តេច?

វិ. ទី ៦- វិបត្តិនៃឧបាសកមាន ៥ ប្រការគឺ[១]

១- ឧបាសកមិនមានសទ្ធា,

២- ឧបាសកមិនមានសីល,

---

១- សុត្តន្តបិដក អង្គុត្តរនិកាយ បញ្ចកនិបាត ធម្មភាគ ទំព័រ ១៨៥ ។

៣- ឧបាសកប្រកាន់មង្គលភ្ញាក់ផ្អើល គឺជឿមង្គល មិនជឿកម្ម,

៤- ឧបាសកស្វែងរកខេត្របុណ្យ ក្រៅព្រះពុទ្ធសាសនា,

៥- ឧបាសកបំពេញបុណ្យ ក្រៅព្រះពុទ្ធសាសនា ។

ឧបាសក ឧបាសិកា ត្រូវវៀរចាកវិបត្តិ ៥ ប្រការនេះឲ្យដាច់ ព្រោះវិបត្តិនេះ ផ្ទុយនឹងសម្បត្តិ ៥ ប្រការ ។

មួយទៀត ឧបាសក ឧបាសិកា ត្រូវប្រកបដោយគុណធម៌ ១០ យ៉ាង ដែលហៅថាឧបាសកគុណ ។

## ឧបាសកគុណ[១]

### គុណនៃឧបាសក ឧបាសិកា[២]

ធម៌សម្រាប់ឧបាសក ឧបាសិកា ប្រតិបត្តិដើម្បីនឹងឲ្យកើត ឲ្យចម្រើននូវសម្បត្តិទាំងពួង ឈ្មោះថាគុណ, គុណនេះជារបស់ឧបាសក ឧបាសិកា ហៅថា ឧបាសកគុណ មាន ១០ យ៉ាងគឺ

១- **សង្ឃេន សទ្ធឹ សមានសុខទុក្ខោ ហោតិ** ឧបាសកអ្នករួមសេចក្ដីសុខទុក្ខជាមួយភិក្ខុសង្ឃ គឺថាបើភិក្ខុសង្ឃមានសេចក្ដីសុខក៏ត្រេកអរ បើភិក្ខុសង្ឃមានសេចក្ដីទុក្ខព្រួយ ក៏កើតទុក្ខព្រួយជាមួយផង ។

២- **កាយិកវាចសិកញ្ច សុរក្ខិតំ ហោតិ** ឧបាសក

១- មិលិន្ទបញ្ហា ។ ២- ពាក្យថាឧបាសក ត្រូវទាំងឧបាសិកាផង ។

មានកាយកម្ម និងវចីកម្មរក្សាហើយដោយប្រពៃ ។

៣- **ធម្មោ អធិបតេយ្យោ ហោតិ** ឧបាសកមានធម៌ជាអធិបតី គឺថា កាលបើប្រព្រឹត្តធ្វើអ្វីៗ រមែងកាន់យកធម៌ជាធំ ជាទីតាំងជាទីអាងមាំមិនឲ្យខុស មិនឲ្យឃ្លៀងឃ្លាតអំពីធម៌ឡើយ ។

៤- **យថាថាមេន សំវិភាគរតោ វ ហោតិ** ឧបាសកជាអ្នកត្រេកអរក្នុងការបរិច្ចាគទាន តាមសមគួរដល់កម្លាំងទ្រព្យនៃខ្លួន គឺធ្វើទានតាមសមគួរដល់ទ្រព្យតិច និងច្រើន បើមានតិចក៏ធ្វើតិច បើមានច្រើនក៏ធ្វើច្រើន មិនមាន **មច្ឆរិយធម៌** គ្របសង្កត់សន្តានចិត្តឡើយ ។

៥- **ជិនសាសនំ ជានិតុញ្ច វាយមតិ** ឧបាសកឧស្សាហ៍ព្យាយាម ដើម្បីនឹងឲ្យដឹងច្បាស់នូវសាសនៈ គឺពាក្យប្រៀនប្រដៅពាក្យបណ្តាំនៃព្រះជិនស្រី ។

៦- **សម្មាទិដ្ឋិកោ វ ហោតិ** ឧបាសកជាសម្មាទិដ្ឋិ គឺមានប្រាជ្ញាឃើញត្រូវតាមសេចក្តីពិត ។

៧- **អបគតោ កោតុហលមង្គលិកោ ច ហោតិ** ឧបាសកប្រាសចាកមង្គលភ្ញាក់ផ្អើល គឺជាអ្នកប្រកាន់ជឿថា មង្គលមានឫក្សពារវេលាជាដើម មិនអាចឲ្យផលបានឡើយ មានតែកម្មជាកុសលនិងអកុសលនោះទេ ទើបផ្តល់ជាផលឲ្យដល់អ្នកធ្វើបាន ។

៨- **ជីវិតហេតុ បិ អញ្ញំ សត្ថារំ ន ឧទ្ទិសតិ** ឧបាសក

បើទុកជាមានហេតុគួរដល់នូវសេចក្ដីវិនាសជីវិតយ៉ាងណាក្ដី កំមិនលះបង់ព្រះរតនត្រ័យ ហើយត្រឡប់ទៅកាន់យកមនុស្សដទៃជាគ្រូអាចារ្យ ជាទីពឹងរបស់ខ្លួនថាប្រសើរជាងព្រះរតនត្រ័យនោះឡើយ ។

៩- **សមគ្គារាមោ ៗ ហោតិ** ឧបាសកមានសេចក្ដីត្រេកអរក្នុងសាមគ្គីធម៌ គឺសេចក្ដីព្រមព្រៀងគ្នា ។

១០- **សាសនេ ចរតិ** ឧបាសកប្រព្រឹត្តល្អក្នុងព្រះពុទ្ធសាសនា គឺប្រព្រឹត្តតាមតែធម៌វិន័យ ជាពុទ្ធសាសនា ។

ឧបាសកគុណទាំង ១០ យ៉ាងនេះ ឧបាសក ឧបាសិកា គប្បីប្រតិបត្តិតាមកុំឲ្យឃ្លៀងឃ្លាតឡើយ ព្រោះជាធម៌អាចនឹងធ្វើចិត្តឧបាសកឧបាសិកា អ្នកប្រតិបត្តិឲ្យស្អុចរិតផ្លូវផង់ក្នុងព្រះពុទ្ធសាសនា ហើយឲ្យបានជាបច្ច័យនៃនិព្វានសម្បត្តិផង ។

បានពណ៌នាមក អំពីវិធីនៃឧបាសក ឧបាសិកា ដោយពាក្យបុច្ឆានិងវិសជ្ជនាមាន ៦ ប្រការ សង្ខេបសេចក្ដីតែប៉ុណ្ណោះ ។

---

## កម្មបថកថា[១]

# ពណ៌នាអំពីរឿងកម្មបថ

*ក្នុងសុត្តន្តបិដក អង្គុត្តរនិកាយ ទសកនិបាត ទ្វាទសមភាគ ទំព័រ ១២៣-១២៩ ។*

*ព្រះមានព្រះភាគ ទ្រង់ត្រាស់ទេសនាប្រដៅពួកជនសាលេយ្យកៈ ហៅថា សាលេយ្យកសូត្រ អំពីកម្មបថនេះ ។*

*ពាក្យថា* **កម្មបថៈៗ** *ប្រែថា គន្លងនៃកម្ម ឬគន្លងនៃអំពើ, ផ្លូវនៃកម្ម ឬផ្លូវនៃអំពើ ។ កម្មបថនេះចែកជា ២ ប្រភេទគឺ* **កុសលកម្មបថ ១ អកុសលកម្មបថ ១ ។**

**កុសលកម្មបថ** *ប្រែថា ផ្លូវនៃកម្មដែលជាកុសល ឬជាបុណ្យ មាន ១០ ប្រការ ចែកជាពួក មាន ៣ ពួកគឺ* **កាយកម្ម** *កម្មប្រព្រឹត្តទៅតាមផ្លូវកាយមាន ៣,* **វចីកម្ម** *កម្មប្រព្រឹត្តទៅតាមផ្លូវវាចាមាន ៤,* **មនោកម្ម** *កម្មប្រព្រឹត្តទៅតាមផ្លូវចិត្តមាន ៣ (នឹងមានពោលទៅខាងមុខ) ។ កាលបុរសស្ត្រីណា ប្រព្រឹត្តបដិបត្តិតាមផ្លូវនៃកម្មនេះហើយ បុរសស្ត្រីនោះរមែងបានសេចក្តីរីករាយទាំងក្នុងលោកនេះ ទាំងក្នុងបរលោក ។*

**អកុសលកម្មបថ** *ប្រែថា ផ្លូវនៃកម្មជាអកុសល ឬជាបាប មាន ១០*

---

១- ដកស្រង់សង្ខេបសេចក្តីយកន័យតែគោល ៗ ពីច្បាប់ឱបករណ៍ធម្មវិភាគដែលព្រះធម្មវិរោត្តម គុង-ឈួន រៀបរៀង, ពីច្បាប់ឱបោសថកថា, និងអំពីច្បាប់អធិប្បាយធម្មវិភាគដែលអ្នកអាចារ្យ ស៊ុន-ហ៊ាន រៀបរៀង ។

*ប្រការ ចែកជា ៣ ពួកគឺ* **កាយកម្ម** *កម្មប្រព្រឹត្តទៅតាមផ្លូវកាយមាន ៣,* **វចីកម្ម** *កម្មប្រព្រឹត្តទៅតាមផ្លូវវាចាមាន ៤,* **មនោកម្ម** *កម្មប្រព្រឹត្តទៅតាមផ្លូវចិត្តមាន ៣, (នឹងមានពោលទៅខាងមុខ) ។ កាលបុរសស្ត្រីណា ប្រព្រឹត្តធ្វើដំណើរទៅតាមផ្លូវគឺកម្មនេះ បុរសស្ត្រីនោះ ឈ្មោះថាដំណើរទៅរកបាបអកុសល មិនមែនទៅរកបុណ្យកុសលទេ ។*

## កម្មបថ[១] ផ្លូវនៃកម្ម

### *ប្រភេទខាងកុសលកម្មបថ ១០*

**ទស កុសលកម្មបថា** *រីកុសលកម្មបថទាំងឡាយ ១០ ជាទីញ៉ាំងសត្វទាំងឡាយឲ្យដល់នូវសេចក្តីសុខដ៏ប្រសើរ* **ឯវំ បដិបជ្ជា** *យើងទាំងឡាយគប្បីបដិបត្តិតាមយ៉ាងនេះ៖*

**តិវិធំ កាយកម្មំ** *រីកម្មប្រព្រឹត្តទៅតាមផ្លូវកាយ មាន ៣ ប្រការគឺ* **បាណាតិបាតា វេរមណី** *វៀរចាកសម្លាប់សត្វ ១* **អទិន្នាទានា វេរមណី** *វៀរចាកលួចលាក់បំបាត់ទ្រព្យអ្នកដទៃ ១* **កាមេសុ មិច្ឆាចារា វេរមណី** *វៀរចាកប្រព្រឹត្តខុសក្នុងកាមទាំងឡាយ គឺប្រព្រឹត្តខុសក្នុងវត្ថុជាទីប្រាថ្នាមានបុត្រ ភរិយា ស្វាមី នៃអ្នកដទៃជាដើម ១ ។* **តិវិធំ កាយសុចរិតំ** *សេចក្តីប្រព្រឹត្តស្អាតដោយកាយប្រាសចាកទោស ៣ ប្រការនេះ ឈ្មោះថា* **កាយសុចរិត** *។*

---

១- ស្រង់យកពីច្បាប់ឧបោសថកថា, គួរទន្ទេញតាំងពីកម្មបថនេះរហូតដល់ចប់អង្គនៃមិច្ឆាទិដ្ឋិឲ្យចាំមាត់ស្ទាត់ស្ទួនបាន និងសូត្រក្នុងវេលាថ្វាយបង្គំព្រះរតនត្រ័យផងក៏គួរ ។

**ចតុព្វិធំ វចីកម្មំ** *វីកម្មប្រព្រឹត្តទៅតាមផ្លូវវាចា មាន ៤ ប្រការគឺ* **មុសាវាទា វេរមណី** *វៀរចាកនិយាយកុហកអ្នកដទៃ ១* **បិសុណាយ វាចាយ វេរមណី** *វៀរចាកនិយាយពាក្យញុះញង់អ្នកដទៃ ១* **ផរុសាយ វាចាយ វេរមណី** *វៀរចាកនិយាយពាក្យទ្រគោះចាក់ដោតអ្នកដទៃ ១* **សម្ផប្បលាបា វេរមណី** *វៀរចាកនិយាយពាក្យឥតប្រយោជន៍ ១ ។* **ចតុព្វិធំ វចីសុចរិតំ** *សេចក្តីប្រព្រឹត្តល្អទៅតាមផ្លូវវាចា ប្រាសចាកទោស ៤ ប្រការនេះ ឈ្មោះថា* **វចីសុចរិត** ។

**តិវិធំ មនោកម្មំ** *វីកម្មប្រព្រឹត្តទៅតាមផ្លូវចិត្តមាន ៣ ប្រការគឺ* **អនភិជ្ឈា** *មិនសម្លឹងចង់បានទ្រព្យអ្នកដទៃ ១* **អព្យាបាទ** *មិនចងចិត្តប្រទូសរ៉ាយអ្នកដទៃ ១* **សម្មាទិដ្ឋិ** *ឃើញត្រូវតាមគន្លងធម៌ ១* **តិវិធំ មនោសុចរិតំ** *សេចក្តីប្រព្រឹត្តល្អទៅតាមផ្លូវចិត្តប្រាសចាកទោស ៣ ប្រការនេះ ឈ្មោះថា* **មនោសុចរិត** ។

**ឥតិ អគារវិនយំ** *ដូច្នេះ ធម៌ទាំង ១០ នេះ ឈ្មោះថា អគារវិន័យយើងទាំងឡាយគប្បីប្រតិបត្តិតាម* **ពុទ្ធភាសិតំ** *នូវពុទ្ធភាសិត ដែលព្រះមានព្រះភាគទ្រង់សម្តែងប្រពៃហើយ ។*

## កម្មបថផ្លូវនៃកម្ម

*ប្រភេទខាងអកុសលកម្មបថ ១០*

**ទស អកុសលកម្មបថា** *វីអកុសលកម្មបថទាំងឡាយ ១០*

ជាទីញុំាងសត្វទាំងឡាយឲ្យដល់នូវសេចក្ដីទុក្ខលំបាក **ឃរំ ន បដិបជា** យើងទាំងឡាយកុំគប្បីប្រតិបត្តិតាមយ៉ាងនេះ ។

**តិវិធំ កាយកម្មំ** វិកម្មប្រព្រឹត្តទៅតាមផ្លូវកាយ មាន ៣ ប្រការ គឺ **បាណាតិបាត** សម្លាប់សត្វ ១ **អទិន្នាទាន** លួចលាក់បំបាត់ទ្រព្យអ្នកដទៃ ១ **កាមេសុមិច្ឆាចារ** ប្រព្រឹត្តខុសក្នុងកាមទាំងឡាយ គឺប្រព្រឹត្តក្នុងវត្ថុជាទីប្រាថ្នា មានបុត្រ ភរិយា ស្វាមីនៃអ្នកដទៃជាដើម ១ ។ **តិវិធំ កាយទុច្ចរិតំ** សេចក្ដីប្រព្រឹត្តអាក្រក់ដោយកាយប្រកបដោយទោស ៣ ប្រការនេះ ឈ្មោះថា **កាយទុច្ចរិត** ។

**ចតុវិធំ វចីកម្មំ** វិកម្មប្រព្រឹត្តទៅតាមផ្លូវវាចាមាន ៤ ប្រការគឺ **មុសាវាទា** និយាយកុហកអ្នកដទៃ ១ **បេសុញ្ញវាចា** វាចាញុះញង់អ្នកដទៃ ១ **ផរុសវាចា** វាចាទ្រគោះបាក់ដោតអ្នកដទៃ ១ **សម្ផប្បលាបវាចា** វាចាឥតប្រយោជន៍ ១ ។ **ចតុវិធំ វចីទុច្ចរិតំ** សេចក្ដីប្រព្រឹត្តអាក្រក់ដោយវាចាប្រកបដោយទោស ៤ ប្រការនេះ ឈ្មោះថា **វចីទុច្ចរិត** ។

**តិវិធំ មនោកម្មំ** វិកម្មប្រព្រឹត្តទៅតាមផ្លូវចិត្តមាន ៣ ប្រការគឺ **អភិជ្ឈា** សម្លឹងចង់បានទ្រព្យរបស់អ្នកដទៃ ១ **ព្យាបាទ** ចងចិត្តប្រទូស្តរ៉ាយអ្នកដទៃ ១ **មិច្ឆាទិដ្ឋិ** យល់ឃើញខុសថាជាត្រូវ ១ ។ **តិវិធំ មនោទុច្ចរិតំ** សេចក្ដីប្រព្រឹត្តអាក្រក់ដោយចិត្តប្រកបដោយទោស ៣ ប្រការនេះ ឈ្មោះថា **មនោទុច្ចរិត** ។

**ឯវំ ទសទុច្ចរិតំ ធម្មំ** *វិទុច្ចរិតធម៌ ១០ ប្រការយ៉ាងនេះ* **ពុទ្ធភាសិតំ** *ជាពុទ្ធភាសិត គឺព្រះមានព្រះភាគទ្រង់សម្តែងទុកហើយ ។*

## អង្គនៃអកុសលកម្មបថ ១០ គឺ

**បញ្ចសម្ភារា បាណាតិបាតា** *វិបាណាតិបាតមានអង្គ ៥ គឺ* **បាណោ** *សត្វមានជីវិត ១* **បាណសញ្ញិតា** *ដឹងថាសត្វមានជីវិត ១* **វធកាចិត្តំ** *ចិត្តគិតនឹងសម្លាប់ ១* **ឧបក្កមោ** *ព្យាយាមនឹងសម្លាប់ ១* **តេន មរណំ** *សត្វស្លាប់ដោយព្យាយាមនោះ ១ ។*

**បញ្ចសម្ភារា អទិន្នាទានា** *វិអទិន្នាទានមានអង្គ ៥ គឺ* **បរបរិគ្គហិតំ** *ទ្រព្យមានអ្នកដទៃថែរក្សា ១* **បរបរិគ្គហិតសញ្ញិតា** *ដឹងថាទ្រព្យមានអ្នកដទៃថែរក្សា ១* **ថេយ្យចិត្តំ** *ចិត្តគិតនឹងលួចយក ១* **ឧបក្កមោ** *ព្យាយាមនឹងលួចយក ១* **តេន ហរណំ** *នាំទ្រព្យយកមកបានដោយសេចក្តីព្យាយាមនោះ ១ ។*

**ចតុសម្ភារា កាមេសុ មិច្ឆាចារា** *វិកាមេសុមិច្ឆាចារមានអង្គ ៤ គឺ* **អគមនីយវត្ថុ** *វត្ថុមិនគួរសេព ១* **តស្មឹ សេវនចិត្តំ** *ចិត្តគិតនឹងសេពនូវវត្ថុមិនគួរសេពនោះ ១* **សេវនប្បយោគោ** *ព្យាយាមនឹងសេព ១* **មគ្គេន មគ្គប្បដិបាទនំ** *ញុំាំងមគ្គនិងមគ្គឲ្យដល់គ្នា ១ ។*

**ចតុសម្ភារា មុសាវាទា** *វិមុសាវាទមានអង្គ ៤ គឺ* **អតថំ វត្ថុ** *វត្ថុមិនពិតត្រង់ ១* **វិសំវាទនចិត្តំ** *ចិត្តគិតនឹងនិយាយឲ្យខុស ១*

**តជ្ជោ វាយាមោ** *ព្យាយាមនឹងនិយាយឲ្យខុស* ១ **បរស្ស តទត្ថវិជាននំ** *អ្នកដទៃដឹងច្បាស់នូវសេចក្តីនោះ* ១ ។

**ចតុសម្ភារា បេសុញ្ញវាចា** *វីបេសុញ្ញវាចា* មានអង្គ ៤ គឺ **ភេទនបុរេក្ខារតា** *គិតនឹងនិយាយបំបែកអ្នកដទៃ* ១ **បិយកម្យតា** *ប្រាថ្នាឲ្យអ្នកដទៃស្រឡាញ់ខ្លួន* ១ **តជ្ជោ វាយាមោ** *ព្យាយាមនឹងនិយាយឲ្យអ្នកដទៃបែកគ្នា* ១ **តទត្ថវិជាននំ** *អ្នកទាំងពីរដឹងសេចក្តីនោះប្រាកដហើយ* ១ ។

**តិសម្ភារា ផរុសវាចា** *វីផរុសវាចា* មានអង្គ ៣ គឺ **អក្កោសិតបជំ** *ជេរប្រទេចជាក្រសែទៅ* ១ **កុប្បិតចិត្តំ** *ចិត្តខឹងកម្រើកញាប់ញ័រ* ១ **អក្កោសនា** *បានជេរប្រទេច* ១ ។

**ទ្វេសម្ភារា សម្ផប្បលាបា** *វីសម្ផប្បលាបា* មានអង្គ ២ គឺ **និរត្ថកថា** *ពោលនូវពាក្យឥតប្រយោជន៍* ១ **កថាបិកថនំ** *ពោលហើយពោលទៀតដូចៗ គ្នា* ១ ។

**ទ្វេសម្ភារា អភិជ្ឈា** *វីអភិជ្ឈា* មានអង្គ ២ គឺ **បរភណ្ឌំ** *ទ្រព្យរបស់អ្នកដទៃ* ១ **អត្តនោ បរិណាមនំ** *បង្អោនមកដើម្បីខ្លួន* ១ ។

**ទ្វេសម្ភារា ព្យាបាទា** *វីព្យាបាទមានអង្គ* ២ គឺ **បរសត្តា** *សត្វទាំងឡាយដទៃ* ១ **តស្ស វិនាសចិន្តា** *ចិត្តគិតធ្វើឲ្យសត្វវិនាសទៅ* ១ ។

**ទ្វេសម្ភារា មិច្ឆាទិដ្ឋិ** *វីមិច្ឆាទិដ្ឋិមានអង្គ ២ គឺ* **វិប្បរិតា** *របស់ដែលត្រូវ ត្រឡប់ទៅជាខុស ១* **តស្សបដ្ឋាធំ** *ប្រកាន់ខុសនោះ ថាជាត្រូវ ត្រូវថាជាខុសវិញ ១ ។*

**មិច្ឆាទិដ្ឋិនេះបានឥឹងទិដ្ឋិ ២ គឺ**

**សស្សតទិដ្ឋិ** *សេចក្ដីយល់ឃើញថា មនុស្សសត្វស្លាប់ហើយ កើតទៀតទៀង ១ ។*

**ឧច្ឆេទទិដ្ឋិ** *សេចក្ដីយល់ឃើញថា មនុស្សសត្វចុតិពីលោកនេះ ទៅសូន្យ ១ ។*

**តិសម្ភារា សស្សតទិដ្ឋិ** *វីសស្សតទិដ្ឋិ មានអង្គ ៣ គឺ* **អមរាវិក្ខេប** *យល់ឃើញថា មនុស្សសត្វដែលកើតមកក្នុងលោក នេះដូចម្ដេច ស្លាប់ទៅកើតក្នុងបរលោកទៀត ទៀងតែទៅកើតដូច្នោះ វិញដដែល ១* **ឥស្សរនិម្មានវាទ** *យល់ឃើញថា មនុស្សសត្វទាំង-ឡាយ ព្រះឥសូរបែងភាគឲ្យមកកើត ១* **យាមសុទ្ធិកា** *យល់ឃើញ ថា ធ្វើបាបជាទម្ងន់ ត្រូវធ្វើចង្រ្កមចម្រើនភាវនាតែប៉ុណ្ណោះក៏រួចបាន ១ ។*

**តិសម្ភារា ឧច្ឆេទទិដ្ឋិ** *វីឧច្ឆេទទិដ្ឋិ មានអង្គ ៣ គឺ* **នត្ថិ-កទិដ្ឋិ** *យល់ឃើញថា ធ្វើបុណ្យមិនបានបុណ្យ ១* **អកិរិយទិដ្ឋិ** *យល់ឃើញថា ធ្វើបាបមិនបានបាប ១* **អហេតុកទិដ្ឋិ** *យល់ឃើញ ថា មនុស្សសត្វនឹងល្អក៏ល្អឯង នឹងអាក្រក់ក៏អាក្រក់ឯង តាមធម្មតា គ្មានអ្វីតាក់តែងទេ ១ ។*

អង្គនៃអកុសលកម្មបថទាំងឡាយគប្បីយល់ថា កាលបុគ្គលប្រព្រឹត្ត ប្រកបគ្រប់អង្គក្នុងកម្មណាហើយ គប្បីសន្និដ្ឋានថាកម្មនោះ ជាអកុសល ជាទុច្ចរិតដោយពិត ។ បុគ្គលគប្បីវៀរចាកគ្រប់កម្មជាអកុសល ជាទុច្ចរិតទាំង ១០ ប្រការនេះឲ្យផុតស្រឡះទាំងអស់ ហើយប្រព្រឹត្តកាន់យកតែកម្មជាកុសល ជាសុចរិតទាំង ១០ ប្រការ ឲ្យបរិសុទ្ធបរិបូណ៌ប្រពៃក្នុងសន្តានឡើង ។

## អំពីទោសច្រើននិងតិច

អកុសលកម្មបថទាំង ១០ នេះ ដែលនឹងមានទោសច្រើន ក៏ព្រោះតែកិលេសចេតនា និងសេចក្ដីព្យាយាមដ៏ខ្លាំងក្លា, វត្ថុដ៏ខ្ពង់ខ្ពស់, និងប្រកបដោយគុណច្រើន, ដែលនឹងមានទោសតិច ក៏ដោយកិលេសចេតនា, សេចក្ដីព្យាយាមតិច, វត្ថុដ៏សៅហ្មង និងមានគុណតិច ។

ពាក្យថាកិលេសនោះ សំដៅយករាគៈ ទោសៈ មោហៈ ។ ចេតនានោះ សំដៅយកគំនិតគិតទុកយូរៗ ឬគិតរឿយៗ ។ វត្ថុនោះ សំដៅយករបស់ដែលល្អ និងអាក្រក់ ។ គុណនោះ សំដៅយកអ្នកមានសីល ឬអ្នកធ្វើប្រយោជន៍បានច្រើនជាដើម ។

មួយទៀត ក្នុងសុត្តន្តបិដក អង្គុត្តរនិកាយ ចតុក្កនិបាត ព្រះមានព្រះភាគទ្រង់ត្រាស់ទេសនាចំពោះភិក្ខុទាំងឡាយ អំពីកម្មបថនេះថា ៖

## អកុសលកម្មបថមាន ៤០ ប្រការ

*មានបាលីសម្តែងថា* **ចតូហិ ភិក្ខវេ ធម្មេហិ សមន្នា-គតោ ឯវំ និរយេ ។ ល ។** *ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយអកុសលកម្មបថ ៤០ ប្រការ រមែងទៅកាន់នរក* **កាតមេហិ ចត្តាឡីសាយ** *អកុសលកម្មបថ ៤០ ប្រការនោះ ដូចម្តេចខ្លះ?*

### បាណាតិបាតមាន ៤ គឺ

១- **អត្តនា ច បាណាតិបាតី ហោតិ** *ជាអ្នកសម្លាប់សត្វដោយខ្លួនឯង ។*

២- **បរញ្ច បាណាតិបាតេ សមាទបេតិ** *បបួលអ្នកដទៃក្នុងការសម្លាប់សត្វ ។*

៣- **បាណាតិបាតេ ច សមនុញ្ញោ ហោតិ** *ជាអ្នកត្រេកអរតាមក្នុងការសម្លាប់សត្វ ។*

៤- **បាណាតិបាតស្ស ច វណ្ណំ ភាសតិ** *និយាយសរសើរការសម្លាប់សត្វ ។*

### អទិន្នាទានមាន ៤ គឺ

៥- **អត្តនា ច អទិន្នាទាយី ហោតិ** *លួចលាក់បំបាត់ទ្រព្យរបស់អ្នកដទៃដែលគេមិនបានឲ្យដោយខ្លួនឯង ។*

៦- **បរញ្ច អទិន្នាទានេ សមាទបេតិ** *បបួលអ្នកដទៃក្នុងអទិន្នាទាន ។*

៧- **អជិជ្ឈាជានេ ច សមនុញ្ញោ ហោតិ** *ជាអ្នកត្រេកអរតាមអំពើក្នុងអទិន្នាទាន ។*

៨- **អជិជ្ឈាជានស្ស ច វណ្ណំ ភាសតិ** *និយាយសរសើរអទិន្នាទាន ។*

## កាមេសុមិច្ឆាចារ មាន ៤គឺ

៩- **អត្តនា ច កាមេសុ មិច្ឆាចារី ហោតិ** *ជាអ្នកប្រព្រឹត្តក្នុងកាមដោយខ្លួនឯង ។*

១០- **បរញ្ច កាមេសុ មិច្ឆាចារេ សមាទបេតិ** *បបួលអ្នកដទៃក្នុងកាមេសុមិច្ឆាចារ ។*

១១- **កាមេសុ មិច្ឆាចារេ សមនុញ្ញោ ហោតិ** *ជាអ្នកត្រេកអរតាមក្នុងកាមេសុមិច្ឆាចារ ។*

១២- **កាមេសុ មិច្ឆាចារស្ស វណ្ណំ ភាសតិ** *និយាយសរសើរកាមេសុមិច្ឆាចារ ។*

*។ល។*

*អធិប្បាយក្នុងអកុសលកម្មបថ ១ត ទៅទៀត ក៏គប្បីចែកដោយន័យដូច្នេះ ដរាបលុះគ្រប់ ៤០ ប្រការ ។*

*សម្គាល់ហេតុ បុរាណាចារ្យមានប្រាជ្ញាពោលជាបញ្ហាថា "សម្លាប់លោកសង្ឃ មានទោសតិច, សម្លាប់ខ្លាមានទោសច្រើន" ក៏ព្រោះតែ*

*ប្រកបដោយខ ៣ គឺត្រេកអរតាមក្នុងការសម្លាប់ និងខ ៤ ពោលសរសើរបាណាតិបាត ធ្វើឲ្យការសម្លាប់ខាក្លាយទៅជាមានទោសច្រើន (គឺបាបច្រើនជាងសម្លាប់មនុស្សដូចគ្នា) ចំណែកសម្លាប់លោកសង្ឃ ថាមានទោសតិច ព្រោះបាបចំពោះសម្លាប់មនុស្សដូចគ្នានោះ នឹងមានអ្នកណាត្រេកអរតាមពោលសរសើរឃាតកម្មនេះគ្មាន ។*

## កុសលកម្មបថមាន ៤០ ប្រការ

*គប្បីជ្រាបដោយន័យដូចគ្នា ដូចតទៅនេះ*

## បាណាតិបាតមាន ៤ គឺ

១- **អត្តនា ច បាណាតិបាតា បដិវិរតោ ហោតិ** *ជាអ្នកវៀរចាកបាណាតិបាត ដោយខ្លួនឯង ។*

២- **បរញ្ច បាណាតិបាតា វេរមណិយា សមាទបេតិ** *បបួលអ្នកដទៃក្នុងការវៀរចាកបាណាតិបាត ។*

៣- **បាណាតិបាតា វេរមណិយា សមនុញ្ញោ ហោតិ** *ត្រេកអរតាមក្នុងការវៀរចាកបាណាតិបាត ។*

៤- **បាណាតិបាតា វេរមណិយា ច វណ្ណំ ភាសតិ** *ពោលសរសើរការវៀរចាកបាណាតិបាត ។*

*។ ល ។*

*អធិប្បាយក្នុងកុសលកម្មបថ ខតៗ ទៅទៀត ក៏គប្បីចែកដោយន័យ*

*នេះ ដរាបលុះគ្រប់ ៤០ ប្រការ ។*

*ដូច្នេះ សូមលោកអ្នកសិក្សា ពិចារណាតាមន័យនេះក្នុងវារៈកម្មបថនេះ ហើយប្រតិបត្តិតាមតទៅចុះ ។*

កម្មបថកថា សង្ខេបតែប៉ុណ្ណោះ

---

**កម្មដ្ឋានសង្ខេប**[១]

*កាលឧបាសក ឧបាសិកា បានប្រព្រឹត្តបរិបូណ៌ដោយសីល ដែលជាគ្រឿងហាមឃាត់នូវសេចក្តីអាក្រក់ ដោយកាយវាចាបានហើយ គប្បីស្តាប់ធម៌ សាកច្ឆាធម៌ និងធ្វើភាវនាតទៅទៀត ដើម្បីហាមឃាត់នីវរណូបក្កិលេស និងបាបធម៌ ដែលជាគ្រឿងធ្វើចិត្តឲ្យសៅហ្មង ។*

*ពាក្យថា* **ភាវនា** *នេះ ប្រែថា ចម្រើនធម៌ក្នុងចិត្ត ឬថាសេចក្តីប្រព្រឹត្តធម៌ឲ្យកើតមានឡើងក្នុងចិត្ត ។ ភាវនានេះពោលដោយប្រភេទមាន ២ ប្រភេទគឺ* **សមថភាវនា ១ វិបស្សនាភាវនា ១ ។**

**សមថភាវនា** *នោះ ប្រែថា សេចក្តីប្រព្រឹត្តធម៌ឲ្យកើតមានឡើងក្នុងចិត្ត ធ្វើចិត្តឲ្យស្ងប់រម្ងាប់ចាកបាបធម៌ ។ សមថភាវនានេះ ជាឧបាយគ្រឿងសង្រួមបិទរាំងនីវរណូបក្កិលេស មិនឲ្យកើតមានក្នុងសន្តានចិត្តបាន ឬថាជាគ្រឿងឧបាយសង្កត់សង្កិនចិត្តមិនឲ្យបម្រះនទៀលបាន ។*

---

១- ស្រង់សង្ខេបសេចក្តីយកន័យតែគោលៗ ពីច្បាប់សមថកម្មដ្ឋាន របស់ព្រះមហាង្ហួន-វ៉ាត និងពីច្បាប់ឧបករណ៍វិបស្សនាកម្មដ្ឋាន របស់ព្រះធម្មវរោត្តម តុង-ឈួន ប្រែចេញពីភាសាសៀមមករៀបរៀង និងអំពីច្បាប់ឧបោសថកថា ។

**វិបស្សនាភាវនា** នោះ ប្រែថា សេចក្តីប្រព្រឹត្តធម៌ឲ្យកើតមានឡើងក្នុងចិត្ត ធ្វើប្រាជ្ញាឲ្យឃើញច្បាស់ ឃើញវិសេស តាមពិត ។ វិបស្សនាភាវនានេះ ជាគ្រឿងពិចារណាឲ្យឃើញច្បាស់ តាមពិត ឬថា ជាគ្រឿងធ្វើប្រាជ្ញាឲ្យពិចារណាឃើញច្បាស់នូវដំណើរសង្ខារ តាមការពិត ។

ពាក្យថា **កម្មដ្ឋានៈៗ** នេះ ប្រែថា ធម៌ជាទីតាំងនៃសេចក្តីប្រព្រឹត្តក្នុងចិត្ត ។ កម្មដ្ឋាននេះ ពោលដោយប្រភេទមាន ២ ប្រភេទគឺ សមថកម្មដ្ឋាន ១ វិបស្សនាកម្មដ្ឋាន ១ ។

**សមថកម្មដ្ឋាន** ប្រែថា ធម៌ជាទីតាំងនៃសេចក្តីប្រព្រឹត្តក្នុងចិត្ត ធ្វើចិត្តឲ្យស្ងប់រម្ងាប់ចាកបាបធម៌ ។

**វិបស្សនាកម្មដ្ឋាន** ប្រែថា ធម៌ជាទីតាំងនៃសេចក្តីប្រព្រឹត្តក្នុងចិត្ត ធ្វើប្រាជ្ញាឲ្យឃើញច្បាស់ ឲ្យឃើញវិសេស តាមការពិត ។

ពាក្យពោលប្លែកគ្នា ត្រង់ពាក្យថា **ភាវនា** បានសេចក្តីថា ការធ្វើធម៌ឲ្យកើតមានឡើងក្នុងចិត្ត ។ ពាក្យថា **កម្មដ្ឋាន** បានសេចក្តីថា ធម៌ជាទីតាំងនៃសេចក្តីប្រព្រឹត្តក្នុងចិត្ត ។ បើពោលថា សេចក្តីប្រព្រឹត្តធម៌ត្រូវថា **ភាវនា** បើពោលដល់ធម៌ជាទីតាំង ត្រូវថា **កម្មដ្ឋាន** ។

## សមថភាវនា

តាមគម្ពីរអភិធម្មត្ថសង្គហៈ និងគម្ពីរវិសុទ្ធិមគ្គ សម្តែងធម៌ដែលជាអារម្មណ៍របស់សមថភាវនាទុក មាន ៧ ពួក ចែកជា ៤០ ប្រការគឺ

*កសិណ ១០ ពួក ១, អសុភ ១០ ពួក ១, អនុស្សតិ ១០ ពួក ១, ព្រហ្មវិហារ ៤ ពួក ១, អាហារេបដិកូលសញ្ញា ១ ពួក ១, ចតុធាតុវវត្ថាន ១ ពួក ១, អរូប ៤ ពួក ១ ត្រូវជា ៧ ពួក រួបរួមជាកម្មដ្ឋាន ៤០ ប្រការ ។*

*កសិណ ១០ នោះគឺ* **បឋវីកសិណ** *សម្ងឹងដីជាអារម្មណ៍ ១* **អាបោកសិណ** *សម្ងឹងទឹកជាអារម្មណ៍ ១* **តេជោកសិណ** *សម្ងឹងភ្លើងជាអារម្មណ៍ ១* **វាយោកសិណ** *សម្ងឹងខ្យល់ជាអារម្មណ៍ ១* **នីលកសិណ** *សម្ងឹងពណ៌ខៀវជាអារម្មណ៍ ១* **បីតកសិណ** *សម្ងឹងពណ៌លឿងជាអារម្មណ៍ ១* **លោហិតកសិណ** *សម្ងឹងពណ៌ក្រហមជាអារម្មណ៍ ១* **ឱទាតកសិណ** *សម្ងឹងពណ៌សជាអារម្មណ៍ ១* **អាលោកកសិណ** *សម្ងឹងពន្លឺភ្លឺជាអារម្មណ៍ ១* **អាកាសកសិណ** *សម្ងឹងអាកាសជាអារម្មណ៍ ១ ត្រូវជាកសិណ ១០ ។*

*អសុភ ១០ នោះគឺ* **ឧទ្ធុមាតកំ** *សាកសពដែលស្អុយហើមឡើង ១* **វិនីលកំ** *សាកសពដែលមានពណ៌ខៀវ ១* **វិបុព្វកំ** *សាកសពដែលមានខ្ទុះហូរចេញ ១* **វិច្ឆិទ្ទកំ** *សាកសពដែលដាច់កណ្ដាលខ្លួន ១* **វិខាយិតកំ** *សាកសពដែលមានសត្វឆ្មាត ក្អែក សុនខ ជាដើម ប្រទង់ប្រទាញចឹកខាំស៊ីហើយ ១* **វិក្ខិត្តកំ** *សាកសពដែលមានដៃនិងជើង និងក្បាលដាច់ទៅនៅខាង ១* **ហតវិក្ខិត្តកំ** *សាកសពដែល*

*មនុស្សមានពៀរជាសត្រូវកាប់ចិញ្ច្រាំកាត់ជាកំណាត់ៗ ១* **លោហិតកំ** *សាកសពដែលត្រូវប្រហារដោយសស្ត្រា មានលោហិតហូរដាបទៅ ១* **បុឡុវកំ** *សាកសពដែលមានដង្កូវវារលូនទៅ ១* **អដ្ឋិកំ** *សាកសពដែលនៅសល់តែពង់ឆ្អឹង ១ រួមជាអសុភ ១០ ។*

*អនុស្សតិ ១០ នោះគឺ* **ពុទ្ធានុស្សតិ** *រឭកដល់គុណព្រះពុទ្ធជាអារម្មណ៍ ១* **ធម្មានុស្សតិ** *រឭកដល់គុណព្រះធម៌ជាអារម្មណ៍ ១* **សង្ឃានុស្សតិ** *រឭកដល់គុណព្រះសង្ឃជាអារម្មណ៍ ១* **សីលានុស្សតិ** *រឭកដល់សីលដែលខ្លួនរក្សាជាអារម្មណ៍ ១* **ចាគានុស្សតិ** *រឭកដល់ទានដែលខ្លួនបរិច្ចាគហើយជាអារម្មណ៍ ១* **ទេវតានុស្សតិ** *រឭកដល់ទេវតាដែលមានសីលាទិគុណស្មើដូចគ្នានឹងខ្លួន តាំងទេវតាទាំងអម្បាលនោះទុកជាសាក្សីហើយ ត្រឡប់រឭកដល់សីលាទិគុណរបស់ខ្លួនជាអារម្មណ៍ ១* **មរណានុស្សតិ** *រឭកដល់សេចក្តីស្លាប់របស់ខ្លួន និងសត្វដទៃ ជាអារម្មណ៍ ១* **កាយគតានុស្សតិ** *រឭកទៅក្នុងកាយមានសក់ រោម ក្រចក ធ្មេញ ស្បែក ជាដើម ដោយសភាពជារបស់បដិកូលជាអារម្មណ៍ ១* **អានាបានស្សតិ** *រឭកដល់ខ្យល់ដង្ហើមចូល ចេញ វែង ខ្លី ជាអារម្មណ៍ ១* **ឧបសមានុស្សតិ** *រឭកដល់ព្រះនិព្វានថាជាទីរម្ងាប់ ជាទីរំលត់ភ្លើងកិលេស និងភ្លើងទុក្ខ ជាបរមសុខយ៉ាងក្រៃពេក ជាអារម្មណ៍ ១ រួមជាអនុស្សតិ ១០ ។*

**ព្រហ្មវិហារ** ៤ នោះគឺ មេត្តាព្រហ្មវិហារ គិតឲ្យសត្វទាំងពួងនៅជាសុខទូទៅ ១ ករុណាព្រហ្មវិហារ គិតឲ្យសត្វទាំងពួងដែលកំពុងមានទុក្ខឲ្យផុតចាកទុក្ខទាំងអស់ ១ មុទុតាព្រហ្មវិហារ[១] គិតឲ្យសត្វទាំងពួងដែលបានសុខសម្បត្តិហើយ ឲ្យតាំងនៅក្នុងសុខសម្បត្តិរបស់ខ្លួនៗ កុំវិយោគព្រាត់ប្រាសចាកសុខសម្បត្តិដែលខ្លួនបានហើយ ១ ឧបេក្ខាព្រហ្មវិហារ មានសេចក្ដីព្រងើយជាកណ្ដាលៗ មិនសោមនស្ស មិនទោមនស្សក្នុងសត្វទាំងអស់ ដែលបានសុខបានទុក្ខ ១ រួមជាព្រហ្មវិហារ ៤ ។

**អាហារេ បដិក្កូលសញ្ញា** នោះថា សេចក្ដីកំណត់ដឹងសម្គាល់ក្នុងអាហារ ដែលជារបស់បរិភោគ ឃើញថាជារបស់បដិកូលគួរខ្ពើមលុះត្រាតែមិនត្រេកអរក្នុងឱជារស ។

**ចតុធាតុវវត្ថាន** នោះថា កំណត់ពិចារណានូវកាយដោយសភាពជាធាតុទាំង ៤ គឺ ដី ទឹក ភ្លើង ខ្យល់ ឲ្យឃើញពិត ទាល់តែដក **សត្តូបលទ្ធិ** (ប្រកាន់ថាសត្វ) **សត្តសញ្ញា** (សម្គាល់ថាសត្វ) ចេញបាន ។

**អរូប** ៤ នោះគឺ **អាកាសានញ្ចាយតនៈ** សម្ងឹងអាកាសដែលមានដួងកសិណ ដោះរើឡើងហើយសល់នៅតែអាកាសទទេ ដោយបរិកម្មនឹកថា អាកាសមានទីបំផុតមិនមានដូច្នេះ ជាអារម្មណ៍ ជាអណ្ដូងកើត ១ **វិញ្ញាណញ្ចាយតនៈ** សម្ងឹងអរូបវិញ្ញាណជាដំបូង បរិកម្ម

---
១- ច្បាប់ខ្លះ ប្រើមុទិតា ប្រែដូចជាមុទុតាដែរ ។

នឹកថា វិញ្ញាណមិនមានទីបំផុតដូច្នេះ ជាអារម្មណ៍ ជាអណ្ដូងកើត ១ **អាកិញ្ចញ្ញាយតនៈ** សម្ងឹងសេចក្ដីមិនមានអរូបវិញ្ញាណដំបូងដោយបរិកម្មនឹកថា បន្តិចបន្តួចមិនមានដូច្នេះ ជាអារម្មណ៍ ជាអណ្ដូងកើត ១ **នេវសញ្ញានាសញ្ញាយតនៈ** សម្ងឹងអរូបវិញ្ញាណទី ៣ ដោយបរិកម្មនឹកថា នេះល្អិតណាស់ នេះល្អិតណាស់ នឹងថាមានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែន ដូច្នេះ ជាអារម្មណ៍ ជាអណ្ដូងកើត ១ រួមជាអរូប ៤ ដូច្នេះ ។

កុលបុត្រអ្នកមានសទ្ធាប្រាថ្នានឹងចម្រើនសមថភាវនានេះ កាលនឹកដល់ធម៌ ៧ ពួក ចែកជាកម្មដ្ឋាន ៤០ ប្រការអម្បាលនេះ ឲ្យជាអារម្មណ៍ នឹងសិក្សាក្នុងធម៌ ៧ ពួក ចែកជាកម្មដ្ឋាន ៤០ ប្រការអម្បាលនេះ ឲ្យដឹងឲ្យចូលចិត្ត ចាំបានស្ទាត់ជំនាញមែនទែន លុះសិក្សាដឹងចូលចិត្តចាំបានប្រាកដស្ទាត់ជំនាញហើយ កម្មដ្ឋានបទណាជាទីគាប់អធ្យាស្រ័យគួរដល់ចរិតរបស់ខ្លួន ក៏គប្បីសម្ងឹងនឹកដល់កម្មដ្ឋានបទនោះ ជាអារម្មណ៍ចុះ ។

ចរិតរបស់មនុស្សក្នុងលោកនេះមាន ៦ ប្រការគឺ **រាគចរិត** ប្រព្រឹត្តទៅតាមរាគៈ ១ **ទោសចរិត** ប្រព្រឹត្តទៅតាមទោសៈ ១ **មោហចរិត** ប្រព្រឹត្តទៅតាមមោហៈ ១ **សទ្ធាចរិត** ប្រព្រឹត្តទៅតាមសេចក្ដីជឿ ១ **ពុទ្ធិចរិត** ប្រព្រឹត្តទៅតាមសេចក្ដីដឹងពិត ១ **វិតក្កចរិត** ប្រព្រឹត្តទៅតាមវិតក្កៈ ១ រួមជាចរិត ៦ ប្រការដូច្នេះ ។

អធិប្បាយ មនុស្សដែលមានចិត្តច្រើនហ៊ឺហាថ្ងៃថ្លា ស្រឡាញ់ចូលចិត្តក្នុងសេចក្ដីលម្អសម្រស់ សន្ដានចិត្តច្រើនទៅដោយសេចក្ដីតម្រេកត្រេកត្រអាលក្នុងរូប សំឡេង ក្លិន រស គ្រឿងសម្ផស្ស ដែលជាឥដ្ឋារម្មណ៍ ឲ្យកើតសេចក្ដីសុខដល់កាយនិងចិត្តបាន ចាត់ជារាគចរិតមានរាគៈជាគ្រឿងប្រព្រឹត្តជាប្រក្រតីរបស់ខ្លួន ។ មនុស្សមានចិត្តច្រើនធុរឆេវឆាវក្រោធខឹងឆាយៗ សន្ដានចិត្តធ្ងន់ទៅក្នុងទោសៈច្រើនបង្កទុក្ខទោមនស្សឲ្យដល់អ្នកដទៃ ចាត់ជាទោសចរិត មានទោសជាគ្រឿងប្រព្រឹត្តជាប្រក្រតីរបស់ខ្លួន ។ មនុស្សដែលមានចិត្តច្រើនភ្លេចភ្លាំង សតិមិនមាំទាំ និយាយស្ដីក៏ច្រើនភ្លាំងភ្លាត់ត្រូវខ្លះ ខុសខ្លះ ចាត់ជាមោហចរិតមានមោហៈជាគ្រឿងប្រព្រឹត្តជាប្រក្រតីរបស់ខ្លួន ។ មនុស្សដែលមានសន្ដានចិត្តជឿគេឆាយៗ ក្នុងពាក្យសម្ដីដែលពោលល្អនិងអាក្រក់ជាបុណ្យនិងបាបជាដើម ចាត់ជាសទ្ធាចរិត មានសទ្ធាជាគ្រឿងប្រព្រឹត្តជាប្រក្រតីរបស់ខ្លួន ។ មនុស្សដែលមានប្រាជ្ញាស្រួចស្រស់វាងវៃ បានឮស្ដាប់រឿងឯណាច្រើនចាំបាននិងដឹងច្បាស់ចាក់ធ្លុះទៅដោយរហ័ស ចាត់ជាពុទ្ធិចរិតមានសេចក្ដីដឹងជាគ្រឿងប្រព្រឹត្តជាប្រក្រតីរបស់ខ្លួន ។ មនុស្សដែលមានសន្ដានចិត្តគិតត្រិះរិះ ពិចារណាទៅមិនសូវហ្នឹងហ្នំបាន មិនសូវដឹងច្បាស់ចាក់ធ្លុះទៅបាន ចាត់ជាវិតក្កចរិត មានវិតក្កៈជាគ្រឿងប្រព្រឹត្តជាប្រក្រតីរបស់ខ្លួន ។

មនុស្សដែលជា **រាគចរិត** នោះ គួរចម្រើនកម្មដ្ឋាន ១១ ប្រការគឺ អសុភ ១០ កាយគតាសតិ ១ ព្រោះកម្មដ្ឋានអម្បាលនេះជាទីសប្បាយរបស់មនុស្សដែលជារាគចរិតនោះ ។ មនុស្សដែលជា **ទោសចរិត** នោះ គួរចម្រើនកម្មដ្ឋាន ៨ ប្រការគឺ វណ្ណកសិណ ៤ និងព្រហ្មវិហារ ៤ ។ វណ្ណកសិណ ៤ នោះគឺ នីលកសិណ បីតកសិណ លោហិតកសិណ ឱទាតកសិណ ។ ព្រហ្មវិហារ ៤ នោះគឺ មេត្តា ករុណា មុទិតា ឧបេក្ខា ។ ព្រោះកម្មដ្ឋានទាំង ៨ នេះជាទីសប្បាយរបស់មនុស្សដែលជាទោសចរិតនោះ ។ មនុស្សដែលជា **មោហចរិត** និងមនុស្សដែលជា **វិតក្កចរិត** នោះ គួរចម្រើនអានាបានស្សតិ ព្រោះអានាបានស្សតិកម្មដ្ឋាននេះ ជាទីសប្បាយរបស់មនុស្សដែលជាមោហចរិត និងមនុស្សដែលជាវិតក្កចរិតនោះ ។ មនុស្សដែលជា **សទ្ធាចរិត** នោះ គួរចម្រើនអនុស្សតិ ៦ គឺ ពុទ្ធានុស្សតិ ធម្មានុស្សតិ សង្ឃានុស្សតិ សីលានុស្សតិ ចាគានុស្សតិ ទេវតានុស្សតិ ព្រោះអនុស្សតិ ៦ នេះ ជាទីសប្បាយរបស់មនុស្សដែលជាសទ្ធាចរិតនោះ ។ មនុស្សដែលជា **ពុទ្ធិចរិត** នោះ គួរចម្រើនកម្មដ្ឋាន ៤ គឺ មរណស្សតិ ឧបសមានុស្សតិ អាហារេបដិកូលសញ្ញា ចតុធាតុវវត្ថាន ព្រោះកម្មដ្ឋាន ៤ នេះ ជាទីសប្បាយរបស់មនុស្សដែលជាពុទ្ធិចរិតនោះ ។

កម្មដ្ឋាន ៨ គឺ អរូបកម្មដ្ឋាន ៤ ភូតកម្មដ្ឋាន ៤ គឺ បឋវី អាបោ

*តេជោ វាយោ នេះជាទីសប្បាយនៃចរិតទាំងអស់, តែអរូបកម្មដ្ឋានទាំង ៤ នោះ កុលបុត្រមិនគួរនឹងចម្រើនជាមុនទេ គប្បីចម្រើនកម្មដ្ឋានដទៃៗណាមួយជាផ្ទៃមុនសិន ទើបគួរចម្រើនអរូបកម្មដ្ឋាននោះជាខាងក្រោយបាន ។*

*ក្នុងកម្មដ្ឋាន ៤០ ប្រការ មាននិមិត្ត ៣ យ៉ាង មានភាវនា ៣ យ៉ាង ។*

## និមិត្ត ៣ យ៉ាងគឺ

## បរិកម្មនិមិត្ត ១ ឧគ្គហនិមិត្ត ១ បដិភាគនិមិត្ត ១

**បរិកម្មនិមិត្ត** *និង* **ឧគ្គហនិមិត្ត** *ទាំងពីរយ៉ាងនេះ បានទូទៅក្នុងកម្មដ្ឋានទាំងអស់ ។* **បដិភាគនិមិត្ត** *នោះ បានចំពោះកម្មដ្ឋាន ២២ ប្រការ គឺ កសិណ ១០ អសុភ ១០ កាយគតាសតិ ១ អានាបានស្សតិ ១ តែប៉ុណ្ណោះ ។*

## ភាវនា ៣ យ៉ាងគឺ

## បរិកម្មភាវនា ១ ឧបចារភាវនា ១ អប្បនាភាវនា ១

**បរិកម្មភាវនា** *បានទូទៅក្នុងកម្មដ្ឋានទាំងអស់ ។* **ឧបចារភាវនា** *នោះ បានកម្មដ្ឋាន ១០ ប្រការគឺ ពុទ្ធានុស្សតិ ធម្មានុស្សតិ សង្ឃានុស្សតិ សីលានុស្សតិ ចាគានុស្សតិ ទេវតានុស្សតិ ឧបសមានុស្សតិ មរណានុស្សតិ អាហារេបដិកូលសញ្ញា ចតុធាតុវវត្ថាន អម្បាលនេះ រមែងឲ្យសម្រេចតែត្រឹមឧបចារភាវនាប៉ុណ្ណោះ មិនអាចឲ្យបានសម្រេច*

ដល់អប្បនាភាវនាទេ ព្រោះជាកម្មដ្ឋានសុខុមល្អិតពេកណាស់ មិនប្រាកដជាក់ច្បាស់បាន ដែលចិត្តនិងចេតសិកមិនអែបនែបជាប់ស្អិទ្ធតាំងនៅបានយូរ ទើបគ្រាន់តែបានឧបចារភាវនាប៉ុណ្ណោះ ។

ក៏ឯអប្បនាភាវនានោះ បានក្នុងកម្មដ្ឋាន ៣០ គឺ កសិណ ១០ អសុភ ១០ អានាបានស្សតិ ១ កាយគតាសតិ ១ ព្រហ្មវិហារ ៤ អរូប ៤ ទាំងនេះ រមែងឲ្យបានសម្រេចរហូតដល់អប្បនាភាវនា ព្រោះកម្មដ្ឋានអម្បាលនេះជាអារម្មណ៍គ្រោតគ្រាតប្រាកដច្បាស់ ដែលចិត្ត និងចេតសិកអែបនែបជាប់ស្អិទ្ធបានយូរទើបជាអប្បនាភាវនា តែរូបជ្ឈាននិងអរូបជ្ឈានជាតួអប្បនាភាវនាស្រាប់ហើយ ។

កម្មដ្ឋាន ៣០ ដែលសម្រេចជាអប្បនាភាវនានោះ នឹងបានមានអានុភាពស្មើគ្នាក៏ទេ អសុភ ១០ និងកាយគតាសតិ ១, ១១ ប្រការនេះមានអានុភាពឲ្យបានតែត្រឹមរូបាវចរបឋមជ្ឈាន ម្យ៉ាងប៉ុណ្ណោះ ។

ព្រហ្មវិហារ ៣ គឺ មេត្តា ករុណា មុទិតា ទាំង ៣ នេះ មានអានុភាពឲ្យបានរូបាវចរជ្ឈាន តាំងអំពីបឋមជ្ឈានឡើងទៅ រហូតដល់ចតុត្ថជ្ឈាន ។ ឧបេក្ខាព្រហ្មវិហារទី ៤ នោះ មានអានុភាពឲ្យបានត្រឹមតែបញ្ចមរូបាវចរជ្ឈានម្យ៉ាង ។

អរូបកម្មដ្ឋាន ៤ មានអានុភាពចំពោះឲ្យបានតែអរូបជ្ឈានម្យ៉ាង រាប់កម្មដ្ឋានឲ្យសម្រេចរូបាវចរជ្ឈាន ២៦ និងឲ្យសម្រេចអរូបាវចរជ្ឈាន ៤

ទើបរួមជាកម្មដ្ឋានដែលឲ្យសម្រេចអប្បនាភាវនា ៣០ ដោយប្រការដូច្នេះ ។

លំដាប់នេះនឹងសម្ដែងវិធីដែលនឹងភាវនាក្នុងកម្មដ្ឋាន ៧ ពួក ចែកជា ៤០ ប្រការដោយសង្ខេប លើកយកតែបឋវីកសិណមួយ មកពណ៌នាជាឧទាហរណ៍ ជាគ្រឿងវិនិច្ឆ័យតទៅ៖

កុលបុត្រអ្នកមានសទ្ធា ប្រាថ្នានឹងចម្រើនកម្មដ្ឋាន ដែលឈ្មោះថា **បឋវីកសិណ** នោះ គប្បីកាត់បលិពោធកង្វល់អាល័យតូច-ធំ ឲ្យអស់ចេញ ហើយទៅកាន់ទីស្ងាត់ សម្លឹងពិចារណាដីដែលខ្លួនតាក់តែងជាដួងកសិណជាអារម្មណ៍ ឬនឹងសម្លឹងពិចារណាដីដែលនៅនឹងផែនដី និងដីកន្ទែងលានស្រូវជាដើម ជាអារម្មណ៍ក៏ដោយ, កាលនឹងពិចារណាដីដែលមិនបានតាក់តែងជាដួងកសិណនោះ គប្បីកំណត់ឲ្យមានទីបំផុតដោយមូលប៉ុនកញ្ច្រែងយ៉ាងធំ ទទឹង ១ ចំអាម ៤ ធ្នាប់ យ៉ាងតូចប៉ុនវង្វង់មាត់ផ្ដិល កុំកំណត់ឲ្យធំឲ្យតូចទៅជាងនោះ ហើយគប្បីធ្វើបរិកម្មនឹកថា **បឋវីៗ ដីៗ** ដូច្នេះរឿយៗ ទៅកុំឈប់ បើមានវាសនាបារមីធ្លាប់បានសន្សំអប់រំមកអំពីជាតិមុនៗ ហើយ ក៏អាចបានសម្រេចឈាន បើគ្មានវាសនាបារមីទេ ជាការលំបាកដែលនឹងសម្រេចឈានដោយសម្លឹងផែនដីដូចពោលមកនេះ នឹងត្រូវធ្វើជាដួងកសិណ, កាលនឹងធ្វើជាដួងកសិណនោះ គប្បីរកដីដែលមានពណ៌ក្រហម ដូចពន្លឺព្រះអាទិត្យកាលទើបនឹងរះឡើង មកធ្វើ កាលនឹងធ្វើនោះ កុំធ្វើក្នុងកន្លែងដែលមនុស្សត្រាច់ទៅមក

គប្បីធ្វើក្នុងទីស្ងាត់ទីកំបាំង ដួងកសិណ នឹងធ្វើឲ្យជារបស់តាំងនៅនឹងតែមួយកន្លែងក៏បាន នឹងធ្វើឲ្យជារបស់យកទៅទីណាបានក៏បាន ហើយដីដែលនឹងធ្វើឲ្យជាដួងកសិណនោះ គប្បីជម្រះឲ្យបរិសុទ្ធធ្វើឲ្យជារង្វង់មូលទទឹង ១ ចំអាម ៤ ធ្នាប់ ដុសខាត់ឲ្យរាបស្មើដូចផ្ទៃស្គរ ហើយគប្បីបោសប្រាសទីនោះឲ្យរលីង ស្អាត ប្រាសចាកសំរាមកម្ទេច ហើយគប្បីងូតទឹកជម្រះកាយឲ្យអស់ញើសក្អែល, កាលនឹងអង្គុយភាវនានោះ គប្បីអង្គុយលើតាំងដែលមានជើងខ្ពស់ ១ ចំអាម ៤ ធ្នាប់ អង្គុយឲ្យឃ្លាតពីដួងកសិណចេញទៅប្រមាណ ៤ ហត្ថ ១ ចំអាម អាការដែលអង្គុយនោះ ឲ្យអង្គុយពែនភ្នែន ជើងស្តាំសង្កត់លើជើងឆ្វេង ដៃស្តាំសង្កត់លើដៃឆ្វេង តាំងកាយឲ្យត្រង់បែរមុខទៅកាន់ដួងកសិណ ហើយគប្បីពិចារណាទោសរបស់កាមគុណផ្សេងៗ និងតាំងចិត្តឲ្យត្រេកអរក្នុងឈានដែលជាឧបាយនឹងលើកខ្លួនចេញចាកកាមគុណ នឹងកន្លងរំលងកងទុក្ខទាំងអស់ ហើយគប្បីរឭកគិតទៅក្នុងគុណរបស់ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ញុំាងសេចក្តីរីករាយប្រាមោទ្យឲ្យកើតឡើងហើយ គប្បីធ្វើចិត្តឲ្យគោរពស្រឡាញ់ចូលចិត្តក្នុងពិធីផ្លូវបដិបត្តិឲ្យមាំថា បដិបត្តិដូច្នេះ បានឈ្មោះថា **នេក្ខម្មបដិបត្តិ** ព្រះអរិយៈទាំងឡាយ មានព្រះពុទ្ធជាម្ចាស់ជាដើម នឹងបានលះវៀរចេញក៏ទេ សុទ្ធសឹងតែបដិបត្តិដូច្នេះគ្រប់ព្រះអង្គ លុះនឹកដូច្នេះរួចហើយ គប្បីតាំងចិត្តថា យើងនឹងបានសោយសុខដែលកើតអំពីវិវេក ដោយបដិបត្តិនេះ

យ៉ាងពិតប្រាកដ ញ៉ាំងឧស្សាហ៍ឲ្យកើតឡើងហើយ ទើបបើកភ្នែកឡើងមើលដួងកសិណ, កាលបើកភ្នែកឡើងនោះ កុំបើកឲ្យធំពេក នឹងធ្វើចក្ខុឲ្យលំបាក ។ មួយទៀត មណ្ឌលនៃដួងកសិណនឹងប្រាកដច្បាស់ណាស់ ចិត្តដែលកាន់យកដួងកសិណនិមិត្តជាអារម្មណ៍នោះ ក៏នឹងធូរថយរួញរាខ្ជិលច្រអូសទៅ ហេតុដូច្នេះ ទើបបើកដោយអាការដ៏ស្មើ (ជាប្រក្រតី) ដូចយ៉ាងបុគ្គលដែលឆ្លុះកញ្ចក់មើលស្រមោលមុខរបស់ខ្លួន ដែលប្រាកដក្នុងផ្ទៃកញ្ចក់ដូច្នោះ ។

ម្យ៉ាងទៀត កាលសម្លឹងមើលដួងកសិណនោះ កុំពិចារណាពណ៌ គប្បីកំណត់ថា របស់នេះជាដីប៉ុណ្ណោះ តែពណ៌ដីនោះ នឹងលះចេញក៏មិនបាន ព្រោះថាពណ៌និងដួងកសិណនោះ នៅជាមួយគ្នា មើលតែកសិណដូចជាមើលពណ៌ផង ហេតុដូច្នោះ គប្បីរួមដួងកសិណនោះចូលជាមួយគ្នា ហើយមើលដួងកសិណនិងពណ៌នោះឲ្យព្រមគ្នា កំណត់ថារបស់នេះជាដី ហើយទើបបរិកម្មនឹកថា **បឋវី ៗ ដីៗ** ដូច្នេះរៀងៗ ទៅមួយរយដង, មួយពាន់ដង, កាលធ្វើបរិកម្មថា បឋវីៗ ដីៗ នោះ កុំបើកភ្នែកមើលជានិច្ច បើកភ្នែកមើលបន្តិចហើយ គប្បីធ្មេចភ្នែកទៅវិញ ធ្មេចភ្នែកទៅបន្តិចហើយ គប្បីបើកភ្នែកឡើងមើលទៀត គប្បីបដិបត្តិដូច្នេះ ទៅត្រាតែបានឧគ្គហនិមិត្ត, ឯកសិណនិមិត្ត ដែលជាអារម្មណ៍ជាទីតាំងនៃចិត្ត ក្នុងកាលធ្វើបរិកម្ម ឈ្មោះថា **បរិកម្មនិមិត្ត**, កិរិយាដែលធ្វើបរិកម្ម

ថា បឋវីៗ ដីៗ នោះ ឈ្មោះថា **បរិកម្មភាវនា**, កាលតាំងចិត្តក្នុងកសិណ-និមិត្ត ធ្វើបរិកម្មថា បឋវីៗ ដីៗ នោះ បើកសិណនិមិត្តមកប្រាកដក្នុងមនោទ្វារ ធ្មេចភ្នែកចុះ កសិណនិមិត្តក៏ប្រាកដនៅយ៉ាងនោះក្នុងមនោទ្វារ ដូចបើកភ្នែកហើយក្នុងកាលណា ឈ្មោះថា **ឧគ្គហនិមិត្ត** ក្នុងកាលនោះ, កាលបានឧគ្គហនិមិត្តហើយ គប្បីតាំងចិត្តទុកក្នុងឧគ្គហនិមិត្តនោះ កំណត់ឲ្យលើសដោយវិសេសឡើងទៅ ។

កាលបដិបត្តិដូច្នេះ ក៏នឹងសង្កត់ **នីវរណធម៌** ចេញបានដោយលំដាប់ៗ កិលេសក៏នឹងស្ងប់រម្ងាប់ចាកសន្តាន សមាធិនឹងក្លាហានជា **ឧបចារសមាធិ** បដិភាគនិមិត្តក៏នឹងកើតឡើង ឧគ្គហនិមិត្ត និងបដិភាគនិមិត្តនេះផ្សេងគ្នាៗ ឧគ្គហនិមិត្តនោះ នៅប្រកបដោយកសិណទោស គឺនៅប្រាកដជាពណ៌ដីនៅឡើយ, បដិភាគនិមិត្តនោះ ប្រាកដបរិសុទ្ធល្អជាងឧគ្គហនិមិត្ត ដូចរង្វង់កញ្ចក់ដែលបុគ្គលដកចេញពីស្រោម ចេញពីថង់ដូច្នោះ ចាប់ដើមអំពីបដិភាគនិមិត្តកើតឡើងហើយ នីវរណធម៌ទាំងអស់ក៏រម្ងាប់ទៅ ចិត្តនោះក៏បានឈ្មោះថា តាំងខ្ជាប់ជាឧបចារសមាធិ សម្រេចកិច្ចជាកាមាវចរ-ភាវនា, កាលបានឧបចារសមាធិហើយ បើខំព្យាយាមឡើងទៅមិនឈប់ឈរ ក៏នឹងបានសម្រេចអប្បនាសមាធិ ដែលជាតួឈានចំណែករូបាវចរ, ការធ្វើសេចក្តីព្យាយាមទាល់តែបានសម្រេចអប្បនាឈានកើតឡើងក្នុងសន្តានហើយ ក៏គប្បីកំណត់ថា យើងប្រព្រឹត្តឥរិយាបថ

យ៉ាងនេះៗ នៅក្នុងសេនាសនៈយ៉ាងនេះៗ ភោជនាហារដែលជាទីសប្បាយយ៉ាងនេះៗ ទើបបានសម្រេចឈាន ។ យោគាវចរកុលបុត្រដែលបានឈានសមាបត្តិ ដោយវិធីដូចពោលមកនេះនោះ ដែលឲ្យកំណត់ឥរិយាបថ, សេនាសនៈ និងអាហារនេះទុក ដើម្បីនឹងបានបន្តកាលខាងមុខ ដួនជាមានសេចក្ដីប្រមាទ ឈាននឹងសាបសូន្យទៅ, កាលនឹងចម្រើនបន្តទៅជាថ្មីនោះ នឹងប្រព្រឹត្តឥរិយាបថ, និងសេពសេនាសនៈ និងភោជនាហារ ដូចយ៉ាងអំពីមុន ឈានដែលសាបសូន្យទៅហើយនោះក៏នឹងកើតឡើងបានបរិបូណ៌ក្នុងសន្តានវិញទៀត ។

កាលយោគាវចរបានសម្រេចបឋមជ្ឈានហើយ ក៏គប្បីបដិបត្តិក្នុងបឋមជ្ឈាននោះ ឲ្យបានស្ទាត់ជំនាញល្អជាមុនហើយ ទើបនឹងចម្រើនទុតិយជ្ឈានបន្តទៅបាន, ឯបឋមជ្ឈាននោះនឹងស្ទាត់ជំនាញ ក៏ត្រូវប្រកបដោយវសី ៥ គឺ **អាវជ្ជនវសី ១ សមាបជ្ជនវសី ១ អធិដ្ឋានវសី ១ វុដ្ឋានវសី ១ បច្ចវេក្ខណវសី ១** រួមជា ៥ ។ **អាវជ្ជនវសី** ស្ទាត់ជំនាញក្នុងការនឹក បើប្រាថ្នានឹកដល់អង្គឈានដែលខ្លួនបាន ក៏អាចនឹកបានដោយឆាប់រហ័ស មិនយឺតយូរទៅរហូតដល់ខាងមុខអំពីជវនចិត្តទី ៤ ទី ៥ ធ្លាក់ចុះកាន់ភវង្គចិត្ត ២ ខណៈ ៣ ខណៈ ។ **សមាបជ្ជនវសី** នោះស្ទាត់ជំនាញក្នុងការដែលនឹងចូល អាចចូលឈានបានក្នុងលំដាប់អាវជ្ជ-នវសី ដែលពិចារណានូវអារម្មណ៍គឺ បដិភាគនិមិត្តមិនបានយឺតយូរ ។

**អធិដ្ឋានវសី** នោះ ស្ទាត់ជំនាញក្នុងការដែលនឹងរក្សាទុក មិនឲ្យឈានចិត្តនោះធ្លាក់ចុះកាន់ភវង្គ តាំងឈានចិត្តទុកបានតាមកំណត់កាល ប្រាថ្នានឹងតាំងទុកអស់កាលប៉ុន្មាន ក៏តាំងទុកអស់កាលប៉ុណ្ណោះបាន ។ **វុដ្ឋានវសី** នោះ ស្ទាត់ជំនាញក្នុងការដែលនឹងចេញចាកឈាន កំណត់ទុកថា វេលានោះៗ នឹងចេញ ក៏ចេញបានតាមកំណត់មិនខុសវេលាដែលកំណត់ទុក ។ **បច្ចវេក្ខណវសី** នោះ ស្ទាត់ជំនាញក្នុងការដែលនឹងពិចារណា ប្រាថ្នានឹងពិចារណាអង្គឈានដែលខ្លួនបានហើយ ក៏អាចនឹងពិចារណាដោយរហ័សមិនយឺតយូរ មានន័យដូចពោលក្នុងអាវជ្ជនវសីនោះ, កាលព្រះយោគាវចរបានសម្រេចបឋមជ្ឈាន ស្ទាត់ជំនាញល្អដោយវសីទាំង ៥ ដូចពោលមកនេះហើយ បើមិនស្ទាត់ជំនាញក្នុងបឋមជ្ឈានជាមុនហើយ នឹងចម្រើនទុតិយជ្ឈានតឡើងទៅ ក៏នឹងសាបសូន្យចាកបឋមជ្ឈាន និងទុតិយជ្ឈានទាំង ២ ចំណែក, ព្រោះហេតុដូច្នេះទើបលោកហាមឃាត់ទុកថា បើនៅមិនទាន់ស្ទាត់ជំនាញក្នុងបឋមជ្ឈានទេ កុំគប្បីចម្រើនទុតិយជ្ឈាន លុះតែស្ទាត់ជំនាញក្នុងបឋមជ្ឈានដោយវសី ៥ ប្រការហើយ ទើបគួរចម្រើនទុតិយជ្ឈានបន្តឡើងទៅ, កាលស្ទាត់ជំនាញក្នុងទុតិយជ្ឈានហើយ ទើបគួរចម្រើនតតិយជ្ឈាន ចតុត្ថជ្ឈាន បញ្ចមជ្ឈានបន្តៗ ឡើងទៅដោយលំដាប់ ដូចពោលមកហើយនោះ ។

បឋមជ្ឈាននោះ មានអង្គ ៥ គឺ **វិតក្កៈ** ត្រិះរិះគិត មានលក្ខណៈ

លើកចិត្តឡើងកាន់អារម្មណ៍ ជាអង្គទី ១ **វិចារៈ** សេចក្ដីពិចារណា មានលក្ខណៈស្រាវជ្រាវនូវអារម្មណ៍ ជាអង្គទី ២, **បីតិ** ចេតសិកដែលញុំាងកាយ និងចិត្តឲ្យឆ្អែត ឲ្យពេញ មាន ៥ ប្រការគឺ **ខុទ្ទកាបីតិ** កាយនិងចិត្តឆ្អែតទាល់តែធ្វើឲ្យព្រឺរោម (បះប្រាងឡើង) ធ្វើទឹកភ្នែកឲ្យហូរ ១ **ខណិកាបីតិ** កាយ និងចិត្តឆ្អែត មានពន្លឺភ្លឺ ដូចផ្លេកបន្ទោរប្រាកដក្នុងចក្ខុ ១ **ឱក្កន្តិកាបីតិ** កាយ និងចិត្តឆ្អែត ប្រាកដដូចរលកបោកបក់ឲ្យរន្ធើឲ្យញ័រ ១ **ឧព្វេង្គាបីតិ** កាយនិងចិត្តឆ្អែត ធ្វើឲ្យកាយស្រាលលឿនលយ (អណ្ដែត) ទៅបាន ១ **ផរណាបីតិ** កាយ និងចិត្តឆ្អែតធ្វើឲ្យត្រជាក់សប្បាយជ្រួតជ្រាបទៅសព្វសព៌ាង្គកាយ ១ បីតិមាន ៥ ប្រការដូច្នេះ រួមជាអង្គ ១ ចាត់ជាអង្គទី ៣, **សុខៈ** ដែលប្រព្រឹត្តទៅក្នុងកាយ និងចិត្ត ១ ចាត់ជាអង្គទី ៤, **ឯកគ្គតា** ភាពជាចិត្តមានអារម្មណ៍តែមួយមិនអណ្ដែតអណ្ដូង ១ ចាត់ជាអង្គទី ៥ ។ ទុតិយជ្ឈាននោះមានអង្គ ៣ គឺ បីតិ ១ សុខៈ ១ ឯកគ្គតា ១ ។ តតិយជ្ឈាននោះមានអង្គ ២ គឺ សុខៈ ១ ឯកគ្គតា ១ ។ ចតុត្ថជ្ឈាននោះមានអង្គ ២ គឺ ឯកគ្គតា ១ ឧបេក្ខា ១ ដូច្នេះចាត់ដោយចតុក្កន័យ ។ បើចាត់ជាបញ្ចកន័យ បឋមជ្ឈានមានអង្គ ៥ គឺ វិតក្កៈ វិចារៈ បីតិ សុខៈ ឯកគ្គតា ។ ទុតិយជ្ឈានមានអង្គ ៤ គឺ វិចារៈ បីតិ សុខៈ ឯកគ្គតា ។ តតិយជ្ឈានមានអង្គ ៣ គឺ បីតិ សុខៈ ឯកគ្គតា ។ ចតុត្ថជ្ឈានមានអង្គ ២ គឺ

*សុខ: ឯកគ្គតា ។ បញ្ចមជ្ឈានមានអង្គ ២ គឺ ឯកគ្គតា ឧបេក្ខា ។ កុលបុត្រអ្នកចម្រើនកសិណនោះ អាចសម្រេចឈានសមាបត្តិដោយចតុក្កន័យ បញ្ចកន័យ ដូចពណ៌នាមកនេះ ។ ពណ៌នាមកក្នុងសមថភាវនាដោយសង្ខេបតែប៉ុណ្ណេះ ។*

## វិបស្សនាភាវនា

*លំដាប់នេះនឹងសម្តែងអំពីវិបស្សនាភាវនា*

*កាលបើបុគ្គលមានចរិត ៦ យ៉ាង តាមគម្រោងគោលការធ្វើសង្កេតបានទទួលកម្មដ្ឋាន ៤០ ប្រភេទណាមួយ ឲ្យសមគួរដល់ចរិត ដើម្បីធ្វើសេចក្តីព្យាយាមឲ្យកើតសមាធិ មានសេចក្តីស្ងប់ចិត្តហើយលើកឡើងកាន់វិបស្សនាតទៅ ដូចនឹងសម្តែងតួយ៉ាងតទៅនេះ ពួកកសិណ ១០ លើកយកតែ បឋវីកសិណមកពណ៌នា បឋវីកសិណនេះ ជាកម្មដ្ឋានដែលជាសាធារណ:ដល់ចរិតទាំង ៦ ដោយការយកដីមកធ្វើជារូបវង់មូល ល្មមសមគួរដល់ខ្សែភ្នែកដែលអាចមើលបាន ហើយសម្លឹងបរិកម្មថា ដីៗ លុះភាពដីនោះ ប្រាកដជិតជាប់ភ្នែកជាប់ចិត្ត ធ្មេចក៏ឃើញដូចបើកភ្នែក ហៅថា* **ឧគ្គហនិមិត្ត,** *ហើយសម្លឹងពង្រីកឲ្យធំ ឬតូច បានតាមត្រូវការ ហៅថា* **បដិភាគនិមិត្ត,** *លុះវិធីសម្លឹងយូរជាប់ប្រាកដមានពណ៌ក្រហមល្អស្រស់ ដូចកញ្ចក់ ជា* **ឧបចារសមាធិ** *សម្លឹងយូរដោយបង្ខឹកឲ្យអង្គឈានគឺ* **វិតក្កៈ** *នឹកដល់ដីកម្មដ្ឋាន,* **វិចារ:** *ផ្គងឲ្យដឹងចំពោះដីប៉ុណ្ណោះ*

**បីតិ** ឆ្អែតចិត្ត ស្រួលចិត្តក្នុងអារម្មណ៍ដីនោះ, **សុខៈ** គឺសប្បាយចិត្ត ស្អាតចិត្តក្នុងអារម្មណ៍ដីនោះ, **ឯកគ្គតា** ដឹងចំពោះដីនោះ នៅព្រងើយៗ រំលត់ចាកអារម្មណ៍ដទៃអស់ ជា **អប្បនាសមាធិ**, មានសមាធិមាំមួន មិនញាប់ញ័រ ហៅថាបឋមជ្ឈាន, កាលនៅជាប់នឹងបឋវីកសិណសម្ងឹងដី លុះមិនត្រូវអាស្រ័យវិតក្កៈ ត្រិះរិះនឹកដល់ លះវិតក្កៈចេញបាន ឈានឡើងកាន់ទុតិយជ្ឈាន, កាលសម្ងឹងដីទៅ លុះមិនត្រូវផ្គងចិត្តឲ្យដឹងអារម្មណ៍ដីនោះហើយ ក៏នឹងលះវិចារៈ ឈានឡើងកាន់តតិយជ្ឈាន, កាលសម្ងឹងដីទៅ លុះលះបីតិសេចក្ដីឆ្អែតចិត្តចេញបាន សល់តែសុខៈ និងឯកគ្គតា ក៏ឈ្មោះថាឈានឡើងកាន់ចតុត្ថជ្ឈាន, លុះលះសុខៈបាន មានឧបេក្ខា និងឯកគ្គតា មាំមួននៅជាប់នឹងបឋវីកសិណនោះ ឈ្មោះថាឈានឡើងកាន់បញ្ចមជ្ឈាន, យ៉ាងនេះចាត់ជា **សមបិៈ** ស្ងប់ចាកនីវរណៈទាំងពួងគឺ **កាមច្ឆន្ទៈ** សេចក្ដីពេញចិត្តក្នុងកាមមិនកើតឡើង, **ព្យាបាទៈ** សេចក្ដីព្យាបាទមិនកើតឡើង, **ថីនមិទ្ធៈ** សេចក្ដីងោកងក់ងុយដេកមិនកើតឡើង, **ឧទ្ធច្ចកុក្កុច្ចៈ** សេចក្ដីរាយមាយរំខានចិត្តមិនកើតឡើង, **វិចិកិច្ឆា** សេចក្ដីសង្ស័យមិនកើតឡើង មានចិត្តស្ងប់ស្ងៀមចុះកាន់អារម្មណ៍បឋវីកសិណជាបាទ ដែលនឹងឲ្យកើតឡើងកាន់វិបស្សនាបាន ។ បើអ្នកចម្រើនសមថកម្មដ្ឋាននេះទៅចូលចិត្តក្នុងអារម្មណ៍ជាប់ចិត្តនៅ មានតណ្ហាចូលទៅអាស្រ័យនៅ ក៏នឹងជាប់នៅត្រឹមណោះ

ឬសម្គាល់ខុសថាក្តីស្ងាត់កើតពីការសម្ងំនដី ទាល់តែបានអប្បនាសមាធិនោះជាទីបំផុតហើយ មិនចម្រើនវិបស្សនាដើម្បីឲ្យច្បាស់នូវព្រះនិព្វានទេ ក៏នឹងបានឈ្មោះថាជាអ្នកនៅក្នុងវដ្ដ: ជាអ្នកមានព្រហ្មលោកជាទីនៅសូន្យឈានចាកព្រហ្ម និងអរូបព្រហ្មហើយ ក៏ត្រឡប់មកកើតជាទេវតា ឬមនុស្សទៀត មកធ្វើអាក្រក់ ក៏នឹងឲ្យកើតក្នុងអបាយទៀត ដូច្នេះ ទើបជាការចាំបាច់ដល់អ្នកធ្វើឈានទាំងឡាយ នឹងត្រូវលើកឈានឡើងកាន់វិបស្សនា ឃើញរូបនាមក្នុងអង្គឈាននោះជា **អនិច្ចំ ទុក្ខំ អនត្តា** ដែលជារបស់ **មហគ្គតចិត្ត** គឺចិត្តដែលបានឈាន ព្រោះអង្គឈានជា **នាមខន្ធ** សង្គ្រោះដូច្នេះ៖

| | | | |
|---|---|---|---|
| វិតក្កៈ | ជាសង្ខារខន្ធ | គឺ | នាមធម៌ ។ |
| វិចារៈ | ជាសង្ខារខន្ធ | គឺ | នាមធម៌ ។ |
| បីតិ | ជាសង្ខារខន្ធ | គឺ | នាមធម៌ ។ |
| សុខៈ | ជាវេទនាខន្ធ | គឺ | នាមធម៌ ។ |
| ឯកគ្គតា | ជាសង្ខារខន្ធ | គឺ | នាមធម៌ ។ |

ចិត្តដែលអង្គឈានទាំង ៥ ប្រកប ជាវិញ្ញាណខន្ធ គឺ នាមធម៌, សេចក្តីចាំអារម្មណ៍មានបឋវីកសិណជាដើម ជាសញ្ញាខន្ធ ជានាមធម៌, ហទយវត្ថុរូប ជារូបធម៌, ចំណែកបឋវីកសិណនោះ ជាបញ្ញត្តិអារម្មណ៍ មិនមែនជារូបនាម ។

ព្រោះដូច្នោះ កាលទឹកដល់ដី រូបនាមក៏កើតឡើង កាលឈប់ទឹកដល់ដី រូបនាមក៏រលត់ទៅ ជា **អនិច្ចំ** តាំងនៅមិនបាន ជា **ទុក្ខំ** ធន់ទ្រាំនៅមិនបាន ជា **អនត្តា** បង្គាប់បញ្ជាមិនបាន ដូច្នេះ កាលវិបស្សនាពិចារណាលុះមានញាណកើតឡើងតាមលំដាប់ទាំង ១៦ ។ ញាណ ១៦ នោះគឺ **នាមរូបបរិច្ឆេទញ្ញាណ** ញាណឃើញទាំងរូបទាំងនាម ១ **នាមរូបបច្ចយបរិគ្គហញ្ញាណ** ញាណឃើញបច្ច័យរបស់នាមរូប ១ **សម្មសនញ្ញាណ** ញាណឃើញត្រៃលក្ខណៈរបស់នាមរូប ១ **ឧទយព្វយញ្ញាណ** ញាណឃើញរូបនាមទាំងកើតទាំងរលត់ ១ **ភង្គញ្ញាណ** ញាណឃើញរូបនាមរលត់ទៅ ៗ ១ **ភយតូបដ្ឋានញ្ញាណ** ញាណឃើញរូបនាមជាភ័យ ១ **អាទីនវញ្ញាណ** ញាណឃើញរូបនាមជាទោស ១ **និព្វិទាញាណ** ញាណឃើញរូបនាមគួរនឿយណាយ ១ **មុញ្ចិតុកម្យតាញាណ** ញាណឃើញរូបនាមប្រាថ្នានឹងរត់ឲ្យផុត ១ **បដិសង្ខាញាណ** ញាណឃើញរូបនាមរិះរកផ្លូវ ១ **សង្ខារុបេក្ខាញាណ** ញាណឃើញរូបនាមតាមពិតថារត់មិនផុត ១ **អនុលោមញ្ញាណ** ញាណឃើញរូបនាមតាមកម្លាំងកិច្ចក្នុងអរិយសច្ចលើសឡើង ១ **គោត្រភូញាណ** ញាណឆ្លងគោត្រគោងយកព្រះនិព្វាន ១ **មគ្គញ្ញាណ** ញាណឃើញព្រះនិព្វាន ១ ខណៈ ១ **ផលញ្ញាណ** ញាណឃើញព្រះនិព្វាន ២-៣ ខណៈ ១ **បច្ចវេក្ខណញ្ញាណ** ញាណឃើញមគ្គផល និព្វាន និង

*កិលេសដែលសល់ ១ រួមត្រូវជា ១៦ ញាណ ។ កាលពិចារណាទាល់តែមានញាណ ១៦ នេះកើតឡើងហើយ អស់អាសវក្កិលេស មានព្រះនិព្វានជាអារម្មណ៍ បានទទួលឆាយាថាជា* **សមថយានិកៈ** *អ្នកមានសេចក្ដីស្ងប់ជាគ្រឿងនាំទៅ ជាព្រះអរិយបុគ្គលប្រភេទឈានលាភីបុគ្គល (មានបឋវីកសិណ ជាកម្មដ្ឋាន អាចជ្រែកដីបាន ផ្លូវវែងធ្វើឲ្យខ្លីបាន ផ្លូវខ្លីធ្វើឲ្យវែងបាន និមិត្តវត្ថុផ្សេងៗ បាន ដូចភ្នំ ព្រៃ ឈើ ស្រុក ប្រាសាទជាដើម) ពណ៌នាមកក្នុងវិបស្សនាភាវនា ដោយសង្ខេបតែប៉ុណ្ណេះ ។*

*មួយទៀត[១] សប្បុរសពុទ្ធបរិស័ទទាំងឡាយ ដែលបានចម្រើនសមថភាវនា និងវិបស្សនាភាវនា ដូចន័យដែលពោលមកនេះ ក៏នឹងមានផលានិសង្សច្រើនគឺ នឹងមានចិត្តជាសម្មាទិដ្ឋិ សេចក្ដីឃើញប្រពៃតាមពុទ្ធោវាទ ១, នឹងរម្ងាប់កិលេសគឺ* **រាគៈ ទោសៈ មោហៈ** *ឲ្យស្រាលស្តើងចាកសន្ដានចិត្ត និងបានជាឧបនិស្ស័យដល់ព្រះនិព្វាន ១ កាលវេលាជិតនឹងស្លាប់ នឹងបានជាទីឈោងចាប់យកសមថភាវនា និងវិបស្សនាភាវនានេះមកជាអារម្មណ៍ សង្កត់សង្កិនន្ធូវទុក្ខវេទនា ឲ្យស្រាលស្តើងចាកសន្ដានចិត្ត ជាផ្លូវទៅកាន់សុគតិ ១ ។*

*ហេតុដូច្នោះ សាធុសប្បុរសពុទ្ធបរិស័ទទាំងឡាយ ដែលមានសទ្ធាក្នុងព្រះពុទ្ធសាសនា ចូរចម្រើនសមថភាវនា និងវិបស្សនាភាវនាឲ្យបានបរិបូណ៌ចុះ ។*

កម្មដ្ឋានសង្ខេប តែប៉ុណ្ណោះ

---

១- ពោលតាមន័យច្បាប់ឱ្យបោសថកថា ។

# ឧបាសកបដិបត្តិ

*វិធីបដិបត្តិនៃ ឧបាសក ឧបាសិកា មានថ្វាយបង្គំព្រះរតនត្រ័យជាដើម ។*

## កិច្ចថ្វាយបង្គំព្រះរតនត្រ័យព្រឹក[១] ប្រែ

*កាលដល់ពេលធ្វើវត្តព្រឹក គប្បីចូលទៅកាន់ទីបូជនីយស្ថាន មានព្រះវិហារជាដើម ហើយតាក់តែងគ្រឿងសក្ការបូជា មានទៀន ធូបជាដើម ចំពោះព្រះភក្ត្រព្រះពុទ្ធរូប រួចហើយមេនាំគប្បីអង្គុយលុតជង្គង់លើកដៃប្រណម្យអំពីមុខបរិស័ទទាំងពួង នាំសូត្រធម៌ថ្វាយបង្គំព្រះរតនត្រ័យ (ឯពួកឧបាសក ក៏អង្គុយលុតជង្គង់ ឬ ប្រហោង ពួកឧបាសិកាអង្គុយបត់ជើងរាប លើកដៃប្រណម្យ សូត្រធម៌ថ្វាយបង្គំព្រះរតនត្រ័យតាមមេនាំ) ដូចន័យតទៅនេះ ៖*

## ទី ១- កិច្ចប្រកាសខ្លួន

**អហំ ពុទ្ធញ្ច ធម្មញ្ច, សង្ឃញ្ច សរណំ { គតោ[២] / គតា,**

*ខ្ញុំដល់ហើយនូវព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃជាទីពឹង,*

---

១- តាំងពីកិច្ចទី ១ រហូតទល់នឹងចប់វត្តព្រឹកប្រែនេះ ស្រង់យកបាលីទាំងសេចក្ដីប្រែពីច្បាប់វិធីថ្វាយបង្គំព្រះផ្សាយចេញពីសង្ឃបណ្ណាល័យវត្តបទុមវតី ។

២- គតោ សម្រាប់បុរសថា, គតា សម្រាប់ស្ត្រីថា ។

**ឧបាសកត្តំ**[១] } **ធារេសិ, ភិក្ខុសង្ឃស្ស សម្មុខា,**
**ឧបាសិកត្តំ**

*ហើយប្រកាសខ្លួនជា* *ឧបាសក* / *ឧបាសិកា* } *ក្នុងទីចំពោះព្រះភក្ត្រនៃភិក្ខុសង្ឃ*

**ឯតំ មេ សរណំ ខេមំ, ឯតំ សរណមុត្តមំ,** *នេះជាទីពឹងដ៏ក្សេមនិងជាទីពឹងដ៏ឧត្តមរបស់ខ្ញុំ,* **ឯតំ សរណមាគម្ម, សព្វទុក្ខា បមុច្ចយេ,** *អាស្រ័យនូវទីពឹងនេះហើយគប្បីរួចចាកទុក្ខទាំងពួង,* **យថាពលំ ករេយ្យាហំ, សម្មាសម្ពុទ្ធសាសនំ,** *ខ្ញុំគប្បីធ្វើតាមនូវសាសនានៃព្រះសម្មាសម្ពុទ្ធ, ដ៏សមគួរដល់កម្លាំង,*

**ទុក្ខនិស្សរណស្សេវ,** **ភាគី**[២] / **ភាគិនី** } **ហោមិ អនាគតេ,** *ខ្ញុំសូមបានចំណែកនៃព្រះនិព្វាន, ជាទីរលាស់ចាកទុក្ខ ក្នុងកាលជាអនាគតកុំខានឡើយ ។*

## ទី ២- កិច្ចថ្វាយបង្គំព្រះរតនត្រ័យ

**អរហំ សម្មាសម្ពុទ្ធោ ភគវា,** *ព្រះពុទ្ធជាម្ចាស់ព្រះអង្គឆ្ងាយ*

---

ឯកិច្ចប្រកាសខ្លួននេះសម្រាប់តែពួកគ្រហស្ថ ដែលដល់ព្រះត្រៃសរណគមន៍ហើយ គប្បីសូត្រក្នុងពិធីធ្វើកិច្ចជាកុសលណាមួយ មានការសមាទានសីល ឬថ្វាយបង្គំព្រះវត្តព្រឹកល្ងាចជាដើម ឯពួកបព្វជិតគឺ ភិក្ខុ សាមណេរ មិនត្រូវសូត្រទេ ។

១- ឧបាសកត្តំ ២- ភាគី សម្រាប់បុរសថា, ឧបាសិកត្តំ, ភាគិនី សម្រាប់ស្ត្រីថា ។

*ចាកកិលេសហើយ, ត្រាស់ដឹងនូវព្រះធម៌ដ៏ប្រពៃដោយព្រះអង្គឯង, ទ្រង់ចែកធម៌ដល់សត្វទាំងឡាយ,* **ពុទ្ធំ ភគវន្តំ អភិវាទេមិ**, *ខ្ញុំក្រាបថ្វាយបង្គំនូវព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគ ។*

ក្រាបថ្វាយបង្គំម្តង

**ស្វាក្ខាតោ ភគវតា ធម្មោ**, *ព្រះធម៌ដែលព្រះមានព្រះភាគទ្រង់សម្តែងប្រពៃហើយ,* **ធម្មំ នមស្សាមិ**, *ខ្ញុំក្រាបថ្វាយបង្គំនូវព្រះធម៌ ។*

ក្រាបថ្វាយបង្គំម្តង

**សុបដិបន្នោ ភគវតោ សាវកសង្ឃោ**, *ព្រះសង្ឃសាវ័កនៃព្រះមានព្រះភាគលោកបដិបត្តិប្រពៃហើយ,* **សង្ឃំ វន្ទាមិ**, *ខ្ញុំក្រាបថ្វាយបង្គំនូវព្រះសង្ឃ ។*

ក្រាបថ្វាយបង្គំម្តង

## ទី ៣- ថ្វាយគ្រឿងសក្ការៈ

*ថ្វាយចំពោះព្រះពុទ្ធ*

**អហំ**(១)
**ឥមានិ** } **បដិមារូបានិ, តំ ភគវន្តំ ឯវមានកំ**
**មយំ**

---

ពាក្យថា ឥមានិ និងបដិមារូបានិ សម្រាប់ព្រះពុទ្ធរូបច្រើនអង្គ, បើមានព្រះពុទ្ធរូបមួយអង្គត្រូវផ្លាស់ ឥមានិ ជា ឥមំ បដិមារូបានិ ជា បដិមារូបំ ។

១- អហំ សម្រាប់បុរសស្ត្រីម្នាក់ថា, មយំ សម្រាប់គ្នាច្រើនថា ។

**វិយ មញ្ញមា** { **ឆោ**(១) *ខ្ញុំ* / **ឆា**, *យើងខ្ញុំ* } *សម្គាល់នូវពិម្ពព្រះពុទ្ធរូបទាំងឡាយនេះ,* *ថាដូចជាព្រះមានព្រះភាគព្រះអង្គគង់ព្រះជន្មនៅឡើយ,* **ឌីបធូចាធិ-សក្ការេហិ អភិបូជយា** { **ម្មិ**(២) / **ម**, } *ហើយបូជាដោយសក្ការៈទាំងឡាយមានទៀនធូបជាដើម,* **សាធុ** { **មេ**(៣) / **ឆោ** } **ភន្តេ ភគវា, សុចិរ-បរិនិព្វុតោបិ, ឥមំ ឌីបធូចាធិសក្ការំ បដិគ្គណ្ហាតុ,** *បពិត្រព្រះមានព្រះភាគដ៏ចម្រើន សូម្បីព្រះអង្គបរិនិព្វានកន្លងទៅហើយអស់កាលយូរ, សូមទ្រង់ទទួលនូវសក្ការៈមានទៀនធូបជាដើមនេះរបស់* { *ខ្ញុំ* / *យើងខ្ញុំ*, }

**មេ** / **ឆោ** } **មាតាបិតុគរុអាឌីនញ្ចេវ,** { **មយ្ហញ្ច**(៤) / **អម្ហាកញ្ច** } **ឌីឃរត្តំ អត្ថាយ ហិតាយ សុខាយ,** *ដើម្បីជាប្រយោជន៍ ជាគុណ និងសេចក្ដីសុខ, ដល់លោកដ៏មានគុណទាំងឡាយ, មានមាតាបិតា គ្រូ*

---

១- មាឆោ សម្រាប់បុរសម្នាក់ឯងឋា, មាឆា សម្រាប់ ស្ត្រីបុរសច្រើនឋា ។

២, ៣, ៤, មិ, មេ, មយ្ហញ្ច, សម្រាប់បុរសឬស្ត្រីម្នាក់ឯងឋា, ម, ឆោ, អម្ហាកញ្ច សម្រាប់គ្នាច្រើនឋា ។

ឧបជ្ឈាយាចារ្យជាដើម របស់ { ខ្ញុំ / យើងខ្ញុំ } ផង, ដល់ { ខ្ញុំ / យើងខ្ញុំ } ផង, អស់រាត្រីដ៏វែងតរៀងទៅ ។

## ថ្វាយបំពោះព្រះរតនត្រ័យ

**យមហំ សម្មាសម្ពុទ្ធំ ភគវន្តំ សរណំ** { **គតោ**[១] / **គតា**, } ខ្ញុំដល់ហើយនូវព្រះមានព្រះភាគអង្គណា, ដែលព្រះអង្គត្រាស់ដឹងនូវព្រះធម៌ដ៏ប្រពៃដោយព្រះអង្គឯងជាទីពឹង, **តំ ភគវន្តំ ឥមេហិ សក្កា-រេហិ អភិបូជយាមិ,** ខ្ញុំបូជានូវព្រះមានព្រះភាគអង្គនោះ ដោយសក្ការៈទាំងឡាយនេះ, **តំ ភគវន្តំ អភិវាទេមិ,** ខ្ញុំក្រាបថ្វាយបង្គំនូវព្រះមានព្រះភាគអង្គនោះ ។

ក្រាបថ្វាយបង្គំម្តង

**យមហំ ស្វាក្ខាតំ ភគវតា ធម្មំ សរណំ** { **គតោ**[២] / **គតា**, } ខ្ញុំដល់ហើយនូវព្រះធម៌ណា, ដែលព្រះមានព្រះភាគទ្រង់សម្តែងប្រពៃហើយជាទីពឹង, **តំ ធម្មំ ឥមេហិ សក្ការេហិ អភិបូជយាមិ,** ខ្ញុំបូជានូវព្រះធម៌នោះដោយសក្ការៈទាំងឡាយនេះ, **តំ ធម្មំ នមស្សាមិ,**

១-២- គតោ សម្រាប់បុរសជា, គតា សម្រាប់ស្ត្រីជា ។

ខ្ញុំក្រាបថ្វាយបង្គំនូវព្រះធម៌នោះ ។

ក្រាបថ្វាយបង្គំម្តង

**យមហំ សុបដិបន្នំ សង្ឃំ សរណំ** { **គតោ**[១] / **គតា**, } ខ្ញុំដល់

ហើយនូវព្រះសង្ឃអង្គណា, ដែលលោកបដិបត្តិប្រពៃហើយជាទីពឹង, **តំ សង្ឃំ ឥមេហិ សក្ការេហិ អភិបូជយាមិ**, ខ្ញុំបូជានូវព្រះសង្ឃអង្គនោះដោយសក្ការៈទាំងឡាយនេះ, **តំ សង្ឃំ វន្ទាមិ**, ខ្ញុំក្រាបថ្វាយបង្គំនូវព្រះសង្ឃអង្គនោះ ។

ក្រាបថ្វាយបង្គំម្តង

## ទី ៤- កិច្ចថ្វាយបង្គំព្រះរតនត្រ័យវត្តព្រឹក-ប្រែ

មេនាំសូត្របណាមវចនៈ ថា

**ហន្ទ មយំ ពុទ្ធស្ស ភគវតោ បុព្វភាគនមការំ ករោម សេ**, មុនដំបូងយើងទាំងឡាយនមស្ការចំពោះព្រះមានព្រះភាគ ដែលព្រះអង្គត្រាស់ដឹងហើយ ។

សូត្រនមស្ការព្រមគ្នា

**នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។** សូត្រ ៣ ដង ។សូមនមស្ការចំពោះព្រះពុទ្ធជាម្ចាស់អង្គនោះ, ព្រះអង្គ

១- គតោ សម្រាប់បុរសថា, គតា សម្រាប់ស្ត្រីថា ។

*ឆ្ងាយចាកកិលេសហើយ, ត្រាស់ដឹងនូវព្រះធម៌ដ៏ប្រពៃដោយព្រះអង្គឯង, ទ្រង់ចែកធម៌ដល់សត្វទាំងឡាយ ។*

## ពាក្យសរសើរព្រះពុទ្ធគុណ

*មេនាំ សូត្រថា*

**ហន្ទ មយំ ពុទ្ធាភិថុតឹ ករោម សេ,** *យើងទាំងឡាយសរសើរព្រះពុទ្ធគុណ ។*

*សូត្រព្រមគ្នា*

**យោ សោ តថាគតោ,** *រីព្រះតថាគតអង្គណា,* **អរហំ,** *ព្រះអង្គឆ្ងាយចាកកិលេសហើយ,* **សម្មាសម្ពុទ្ធោ,** *ព្រះអង្គត្រាស់ដឹងនូវព្រះធម៌ដ៏ប្រពៃដោយព្រះអង្គឯង,* **វិជ្ជាចរណសម្បន្នោ,** *ព្រះអង្គដល់ព្រមដោយវិជ្ជានិងចរណៈហើយ,* **សុគតោ,** *ព្រះអង្គយាងទៅប្រពៃហើយ,* **លោកវិទូ,** *ព្រះអង្គទ្រង់ជ្រាបច្បាស់នូវលោកហើយ,* **អនុត្តរោ បុរិសទម្មសារថិ,** *ព្រះអង្គទ្រង់ទូន្មាននូវបុរសដ៏គួរទូន្មានពុំមានអ្នកណាលើស,* **សត្ថា ទេវមនុស្សានំ,** *ព្រះអង្គជាគ្រូនៃទេវតានិងមនុស្សទាំងឡាយ,* **ពុទ្ធោ,** *ព្រះអង្គមានព្រះគុណរីកពេញហើយ,* **ភគវា,** *ព្រះអង្គទ្រង់ចែកធម៌ដល់សត្វទាំងឡាយ,* **យោ ឥមំ លោកំ សទេវកំ សមារកំ សព្រហ្មកំ, សស្សមណព្រាហ្មណឹ បជំ សទេវមនុស្សំ សយំ អភិញ្ញា សច្ឆិកត្វា បវេទេសិ,**

*ព្រះតថាគតអង្គណាទ្រង់ប្រកាសនូវលោកនេះ ព្រមទាំងទេវតា មារ ព្រហ្ម, នូវពពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ និងមនុស្សជាសម្មតិទេព, និងមនុស្សដ៏សេស ឲ្យប្រាកដហើយ, ព្រោះទ្រង់ធ្វើឲ្យជាក់ច្បាស់ដោយប្រាជ្ញាដ៏ក្រៃពេកចំពោះព្រះអង្គឯង,* **យោ ធម្មំ ទេសេសិ**, *ព្រះតថាគតអង្គណាទ្រង់សម្តែងហើយនូវធម៌,* **អាទិកល្យាណំ**, *ជាធម៌ពីរោះខាងដើម,* **មជ្ឈេកល្យាណំ**, *ជាធម៌ពីរោះត្រង់កណ្តាល* **បរិយោសានកល្យាណំ**, *ជាធម៌ពីរោះក្នុងទីបំផុត,* **សាត្ថំ សព្យញ្ជនំ កេវលបរិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ បកាសេសិ**, *ទ្រង់ប្រកាសហើយនូវព្រហ្មចរិយធម៌ព្រមទាំងអត្ថ និងព្យញ្ជនៈ, ដ៏បរិសុទ្ធបរិបូណ៌ពុំមានសេសសល់ ។* **តមហំ ភគវន្តំ អភិបូជយាមិ**, *ខ្ញុំបូជានូវព្រះតថាគតដ៏មានព្រះភាគអង្គនោះ,* **តមហំ ភគវន្តំ សិរសា នមាមិ**, *ខ្ញុំក្រាបថ្វាយបង្គំនូវព្រះតថាគតដ៏មានព្រះភាគអង្គនោះដោយសិរសា ។*

ក្រាបថ្វាយបង្គំម្តង

## ពាក្យសរសើរព្រះធម្មគុណ

*មេនាំ សូត្រថា*

**ហន្ទ មយំ ធម្មាភិថុតឹ ករោម សេ**, *យើងទាំងឡាយសរសើរព្រះធម្មគុណ ។*

*សូត្រព្រមគ្នា*

**យោ សោ ស្វាក្ខាតោ ភគវតា ធម្មោ**, *ព្រះធម៌ណា ដែលព្រះមានព្រះភាគទ្រង់សម្តែងប្រពៃហើយ*, **សន្ទិដ្ឋិកោ**, *ជាធម៌ ដែលអ្នកបដិបត្តិឃើញច្បាស់ដោយខ្លួនឯង*, **អកាលិកោ**, *ជាធម៌ ឲ្យផលពុំមានកំណត់កាល*, **ឯហិបស្សិកោ**, *ជាធម៌មានអាការៈអាច ហៅអ្នកដទៃមកមើលបាន*, **ឱបនយិកោ**, *ជាធម៌គួរបង្អោនមកដាក់ ក្នុងចិត្តបាន*, **បច្ចត្តំ វេទិតព្វោ វិញ្ញូហិ**, *ជាធម៌ដែលអ្នកប្រាជ្ញ ទាំងឡាយគប្បីដឹងចំពោះខ្លួន ។* **តមហំ ធម្មំ អភិបូជយាមិ**, *ខ្ញុំបូជានូវព្រះធម៌នោះ*, **តមហំ ធម្មំ សិរសា នមាមិ**, *ខ្ញុំក្រាប ថ្វាយបង្គំនូវព្រះធម៌នោះដោយសិរសា ។*

ក្រាបថ្វាយបង្គំម្តង

## ពាក្យសរសើរព្រះសង្ឃគុណ

*មេនាំ សូត្រថា*

**ហន្ទ មយំ សង្ឃាភិថុតឹ ករោម សេ**, *យើងទាំង-ឡាយសរសើរព្រះសង្ឃគុណ ។*

*សូត្រព្រមគ្នា*

**យោ សោ សុបដិបន្នោ ភគវតោ សាវកសង្ឃោ** *ព្រះសង្ឃសាវ័កអង្គណានៃព្រះមានព្រះភាគ លោកបដិបត្តិប្រពៃហើយ,*

**ឧជុបដិបន្នោ ភគវតោ សាវកសង្ឃោ,** *ព្រះសង្ឃសាវ័កនៃព្រះមានព្រះភាគលោកបដិបត្តិត្រង់ហើយ,* **ញាយបដិបន្នោ ភគវតោ សាវកសង្ឃោ,** *ព្រះសង្ឃសាវ័កនៃព្រះមានព្រះភាគលោកបដិបត្តិដើម្បីចេញចាកសង្សារទុក្ខហើយ,* **សាមីចិបដិបន្នោ, ភគវតោ សាវកសង្ឃោ,** *ព្រះសង្ឃសាវ័កនៃព្រះមានព្រះភាគលោកបដិបត្តិសមគួរនឹងព្រះនិព្វានហើយ,* **យទិទំ,** *ព្រះសង្ឃសាវ័កអង្គនោះគឺ,* **ចត្តារិ បុរិសយុគានិ,** *បើរាប់ជាគូនៃបុរសមានបួនគូ,* **អដ្ឋ បុរិសបុគ្គលា,** *បើរាប់រៀងបុរសបុគ្គលមានប្រាំបី,* **ឯស ភគវតោ សាវកសង្ឃោ,** *នេះជាព្រះសង្ឃសាវ័កនៃព្រះមានព្រះភាគ,* **អាហុនេយ្យោ,** *លោកគួរទទួលរបស់ដែលគេនាំមកបូជា,* **បាហុនេយ្យោ,** *លោកគួរទទួលរបស់ដែលគេនាំមកទទួលភ្ញៀវ,* **ទក្ខិណេយ្យោ** *លោកគួរទទួលទក្ខិណាទាន,* **អញ្ជលិករណីយោ,** *លោកគួរទទួលអញ្ជលីប្រណម្យ,* **អនុត្តរំ បុញ្ញក្ខេត្តំ លោកស្ស,** *លោកជាស្រែបុណ្យដ៏ប្រសើរលើសនៃសត្វលោក ។* **តមហំ សង្ឃំ អភិបូជយាមិ,** *ខ្ញុំបូជានូវព្រះសង្ឃអង្គនោះ,* **តមហំ សង្ឃំ សិរសា នមាមិ,** *ខ្ញុំក្រាបថ្វាយបង្គំនូវព្រះសង្ឃអង្គនោះដោយសិរសា ។*

ក្រាបថ្វាយបង្គំម្តង

ហើយអង្គុយរាប

# រតនត្តយប្បណាមគាថា

*មេនាំ សូត្រថា*

**ហន្ទ មយំ រតនត្តយប្បណាមគាថាយោ ចេវ សំវេគ-វត្ថុបរិកិត្តនបាឋញ្ច ភណាម សេ,** *យើងទាំងឡាយសូត្រគាថានមស្ការព្រះរតនត្រ័យ និងបាលីសម្តែងនូវសេចក្តីសង្វេគ ៗ សូត្រព្រមគ្នា.*

**ពុទ្ធោ សុសុទ្ធោ ករុណាមហណ្ណវោ,** *ព្រះពុទ្ធជាម្ចាស់ទ្រង់មានព្រះទ័យដ៏បរិសុទ្ធ, មានព្រះករុណាដូចជាអន្លង់ដ៏ធំ* **យោច្ចន្ត-សុទ្ធព្វរញាណលោចនោ,** *ទ្រង់មានព្រះនេត្រគឺញាណដ៏បរិសុទ្ធក្រៃពេក,* **លោកស្ស បាបូបកិលេសឃាតកោ,** *ទ្រង់កម្ចាត់បង់នូវសេចក្តីអាក្រក់ ជាគ្រឿងសៅហ្មងរបស់សត្វលោក,* **វន្ទាមិ ពុទ្ធំ អហមាទរេន តំ,** *ខ្ញុំក្រាបថ្វាយបង្គំនូវព្រះពុទ្ធជាម្ចាស់អង្គនោះដោយគោរព,* **ធម្មោ បទីបោ វិយ តស្ស សត្ថុនោ,** *ព្រះធម៌នៃព្រះសាស្តាអង្គនោះដូចជាប្រទីបដ៏ភ្លឺរុងរឿង,* **យោ មគ្គបាកាម-តភេទភិន្នកោ,** *ជាធម៌ផ្សេងដោយប្រភេទ គឺមគ្គ ផល ព្រះនិព្វាន,* **លោកុត្តរោ យោ ច តទត្ថទីបនោ,** *និងជាធម៌បំភ្លឺនូវអត្ថនៃលោកុត្តរធម៌នោះ,* **វន្ទាមិ ធម្មំ អហមាទរេន តំ,** *ខ្ញុំក្រាបថ្វាយបង្គំនូវព្រះធម៌នោះដោយគោរព,* **សង្ឃោ សុខេត្តាភ្យតិខេត្ត-**

**សញ្ញិតោ**, *ព្រះសង្ឃជាស្រែបុណ្យដ៏ល្អនិងឈ្មោះថាជាស្រែបុណ្យដ៏ប្រសើរលើស*, **យោ ទិដ្ឋសន្តោ សុគតានុពោធកោ**, *បានឃើញធម៌ស្ងប់ហើយត្រាស់ដឹងតាមព្រះសុគត*, **លោលប្បហីនោ អរិយោ សុមេធសោ**, *ជាព្រះអរិយៈមានប្រាជ្ញាល្អ លះបង់ចិត្តល្មោភអស់ហើយ*, **វន្ទាមិ សង្ឃំ អហមាទរេន តំ**, *ខ្ញុំក្រាបថ្វាយបង្គំនូវព្រះសង្ឃអង្គនោះដោយគោរព*, **ឥច្ចេវមេកន្តភិបូជនេយ្យកំ, វត្ថុត្តយំ វន្ទយតាភិសង្ខតំ, បុញ្ញំ មយា យំ មម សព្ពុបទ្ទវា, មា ហោន្តុ វេ តស្ស បភាវសិទ្ធិយា**, *បុណ្យណាដែលខ្ញុំបានធ្វើហើយដោយកិរិយាថ្វាយបង្គំ នូវប្រជុំបីនៃវត្ថុគួរបូជាដោយពិតយ៉ាងនេះ, ដោយអានុភាពនៃបុណ្យនោះ ឧបទ្រពចង្រៃទាំងពួងចូរកុំមានដល់ខ្ញុំឡើយ ។*

**ឥធ តថាគតោ លោកេ ឧប្បន្នោ**, *ព្រះតថាគតកើតឡើងហើយក្នុងលោកនេះ*, **អរហំ**, *ព្រះអង្គឆ្ងាយចាកកិលេសហើយ*, **សម្មាសម្ពុទ្ធោ**, *ព្រះអង្គត្រាស់ដឹងនូវព្រះធម៌ដ៏ប្រពៃដោយព្រះអង្គឯង*, **ធម្មោ ច ទេសិតោ**, *ព្រះធម៌ដែលព្រះអង្គទ្រង់សម្តែងហើយ*, **និយ្យានិកោ**, *ជាធម៌នាំសត្វចេញចាកសង្សារទុក្ខ*, **ឧបសមិកោ**, *ជាធម៌ប្រព្រឹត្តទៅដើម្បីសេចក្តីស្ងប់*, **បរិនិព្វានិកោ**, *ជាធម៌ប្រព្រឹត្តទៅដើម្បីព្រះនិព្វាន*, **សម្ពោធគាមី**, *ជាធម៌ប្រព្រឹត្តទៅដើម្បីសេចក្តី*

*ត្រាស់ដឹង,* **សុគតប្បវេទិតោ,** *ព្រះសុគតទ្រង់ប្រកាសហើយ,* **មយន្តំ ធម្មំ សុត្វា ឯវំ ជានាម,** *យើងខ្ញុំបានស្តាប់ធម៌នោះហើយទើបដឹងយ៉ាងនេះថា,* **ជាតិបិ ទុក្ខា,** *សេចក្តីកើតក៏ជាទុក្ខ,* **ជរាបិ ទុក្ខា,** *សេចក្តីចាស់គ្រាំគ្រាក៏ជាទុក្ខ,* **មរណម្បិ ទុក្ខំ,** *សេចក្តីស្លាប់ក៏ជាទុក្ខ,* **សោកបរិទេវទុក្ខទោមនស្សុបាយាសាបិ ទុក្ខា,** *សេចក្តីក្រៀមក្រំ យំរៀបរាប់ លំបាកកាយ លំបាកចិត្ត និងសេចក្តីចង្អៀតចង្អល់ចិត្តក៏ជាទុក្ខ,* **អប្បិយេហិ សម្ប-យោគោ ទុក្ខោ,** *ការជួបប្រសព្វដោយសត្វនិងសង្ខារដែលមិនជាទីស្រឡាញ់ក៏ជាទុក្ខ,* **បិយេហិ វិប្បយោគោ ទុក្ខោ,** *ការព្រាត់ប្រាសចាកសត្វនិងសង្ខារដែលជាទីស្រឡាញ់ក៏ជាទុក្ខ,* **យម្បិច្ឆំ ន លភតិ តម្បិ ទុក្ខំ,** *កាលប្រាថ្នារបស់ណាមិនបាននោះក៏ជាទុក្ខ,* **សង្ខិត្តេន បញ្ចុបាទានក្ខន្ធា ទុក្ខា,** *ពោលដោយបំប្រួញឧបាទានក្ខន្ធទាំងប្រាំជាទុក្ខ,* **សេយ្យថីទំ?** *ឧបាទានក្ខន្ធទាំងប្រាំនោះដូចម្តេចខ្លះ?* **រូបូបាទានក្ខន្ធោ,** *ឧបាទានក្ខន្ធគឺរូប ១,* **វេទនូបាទានក្ខន្ធោ,** *ឧបាទានក្ខន្ធគឺវេទនា ១,* **សញ្ញូបាទា-នក្ខន្ធោ,** *ឧបាទានក្ខន្ធគឺសញ្ញា ១,* **សង្ខារូបាទានក្ខន្ធោ,** *ឧបាទានក្ខន្ធគឺសង្ខារ ១,* **វិញ្ញាណូបាទានក្ខន្ធោ,** *ឧបាទានក្ខន្ធគឺវិញ្ញាណ ១,* **យេសំ បរិញ្ញាយ, ធរមានោ សោ ភគវា,**

**ឯវំ ពហុលំ សាវកេ វិនេតិ,** *ព្រះមានព្រះភាគអង្គនោះ, កាលគង់ព្រះជន្មនៅឡើយ, ទ្រង់ទូន្មាននូវសាវ័កទាំងឡាយ ដើម្បីឲ្យកំណត់ដឹងនូវឧបាទានក្ខន្ធទាំងប្រាំដោយច្រើន,* **ឯវំ ភាគា ច បនស្ស ភគវតោ សាវកេសុ អនុសាសនី, ពហុលា បវត្តតិ,** *ទាំងអនុសាសនី ពាក្យប្រៀនប្រដៅដ៏ច្រើនរបស់ព្រះមានព្រះភាគអង្គនោះ, ក៏ប្រព្រឹត្តទៅក្នុងពួកសាវ័កយ៉ាងនេះថា,* **រូបំ អនិច្ចំ,** *រូបមិនទៀង,* **វេទនា អនិច្ចា,** *វេទនាមិនទៀង,* **សញ្ញា អនិច្ចា,** *សញ្ញាមិនទៀង,* **សង្ខារា អនិច្ចា,** *សង្ខារទាំងឡាយមិនទៀង,* **វិញ្ញាណំ អនិច្ចំ,** *វិញ្ញាណមិនទៀង,* **រូបំ អនត្តា,** *រូបមិនមែនខ្លួន,* **វេទនា អនត្តា,** *វេទនាមិនមែនខ្លួន,* **សញ្ញា អនត្តា,** *សញ្ញាមិនមែនខ្លួន,* **សង្ខារា អនត្តា,** *សង្ខារទាំងឡាយមិនមែនខ្លួន,* **វិញ្ញាណំ អនត្តា,** *វិញ្ញាណមិនមែនខ្លួន,* **សព្វេ សង្ខារា អនិច្ចា,** *សង្ខារទាំងឡាយទាំងពួងមិនទៀង,* **សព្វេ ធម្មា អនត្តាតិ,** *ធម៌ទាំងឡាយទាំងពួងមិនមែនខ្លួន,* **{តេ[១] / តា} មយំ, ឱតិណ្ណាម្ហ ជាតិយា ជរាមរណេន សោកេហិ បរិទេវេហិ ទុក្ខេហិ ទោមនស្សេហិ ឧបាយាសេហិ,** *យើងខ្ញុំទាំងឡាយនោះគឺ*

១- តេ សម្រាប់បុរសថា, តា សម្រាប់ស្ត្រីថា ។

សេចក្តីកើត ចាស់ ស្លាប់, និងសេចក្តីក្រៀមក្រំយំរៀបរាប់ លំបាកកាយ លំបាកចិត្ត, និងសេចក្តីចង្អៀតចង្អល់ចិត្ត គ្របសង្កត់ហើយ, **ទុក្ខោតិណ្ណា**, ជាអ្នកគឺទុក្ខគ្របសង្កត់ហើយ, **ទុក្ខបរេតា**, ជាអ្នកគឺទុក្ខបៀតបៀនហើយ, **អប្បេវនាមិមស្ស កេវលស្ស ទុក្ខក្ខន្ធស្ស អន្តកិរិយា បញ្ញាយេថាតិ**, ដូចម្តេចនឹងគប្បីធ្វើនូវទីបំផុតនៃកងទុក្ខទាំងអស់នេះឲ្យប្រាកដបាន, **ចិរបរិនិព្វុតម្បិ តំ ភគវន្តំ សរណំ គតា, ធម្មញ្ច ភិក្ខុសង្ឃញ្ច**, យើងខ្ញុំដល់ហើយនូវព្រះមានព្រះភាគអង្គនោះ, សូម្បីទ្រង់បរិនិព្វានហើយអស់កាលដ៏យូរ, ព្រមទាំងព្រះធម៌និងព្រះសង្ឃជាទីពឹង, **តស្ស ភគវតោ សាសនំ, យថាសត្តិ យថាពលំ មនសិករោម អនុបដិបជ្ជាម**, ហើយយកចិត្តទុកដាក់បដិបត្តិតាម, នូវសាសនានៃព្រះមានព្រះភាគអង្គនោះតាមសេចក្តីអាចនិងកម្លាំង, **សា សា នោ បដិបត្តិ**, សេចក្តីបដិបត្តិនោះៗរបស់យើងខ្ញុំ, **ឥមស្ស កេវលស្ស ទុក្ខក្ខន្ធស្ស អន្តកិរិយាយ សំវត្តតុ**, ចូរប្រព្រឹត្តទៅដើម្បីធ្វើនូវទីបំផុតនៃកងទុក្ខទាំងអស់នេះ ។

បើបព្វជិត[១] គឺភិក្ខុ សាមណេរ កាលសូត្រមកដល់បាលីថា

---

១- បានជាយកបាលីសូត្រសម្រាប់បព្វជិត គឺភិក្ខុ សាមណេរ ទៅដាក់ខាងចុង ហើយយកបាលីសូត្រសម្រាប់គ្រហស្ថគឺ ឧបាសក ឧបាសិកា ដាក់នៅខាងដើមវិញនោះ ព្រោះច្បាប់នេះបំពោះគ្រហស្ថគឺ ឧបាសក ឧបាសិកា ។

"**បញ្ញាយេថាតិ**" *ហើយ ត្រូវសូត្របន្តទៅទៀតដូច្នេះថា ៖*

**ចិរបរិនិព្វុតម្បិ តំ ភគវន្តំ ឧទ្ទិស្ស អរហន្តំ សម្មាសម្ពុទ្ធំ, សទ្ធា អគារស្មា អនគារិយំ បព្វជិតា,** *យើងខ្ញុំមានសទ្ធាចេញចាកផ្ទះ, ហើយបួសជាអ្នកមិនមានផ្ទះ, ឧទ្ទិសចំពោះព្រះពុទ្ធជាម្ចាស់អង្គនោះ, ដែលព្រះអង្គឆ្ងាយចាកកិលេសហើយ, ត្រាស់ដឹងនូវព្រះធម៌ដ៏ប្រពៃដោយព្រះអង្គឯង, ទ្រង់ចែកធម៌ដល់សត្វទាំងឡាយ, សូម្បីទ្រង់បរិនិព្វានហើយអស់កាលដ៏យូរ,* **តស្មឹ ភគវតិ ព្រហ្មចរិយំ ចរាម,** *ហើយប្រព្រឹត្តនូវព្រហ្មចរិយធម៌ក្នុងសំណាក់នៃព្រះដ៏មានព្រះភាគអង្គនោះ,* **ភិក្ខូនំ សិក្ខាសាជីវសមាបន្នា** *ជាអ្នកដល់ព្រមហើយដោយសិក្ខា និងសាជីវៈរបស់ភិក្ខុទាំងឡាយ,* **តំ នោ ព្រហ្មចរិយំ, ឥមស្ស កេវលស្ស ទុក្ខក្ខន្ធស្ស អន្តកិរិយាយ សំវត្តតុ,** *រីព្រហ្មចរិយធម៌នោះរបស់យើងខ្ញុំ, ចូរប្រព្រឹត្តទៅដើម្បីធ្វើនូវទីបំផុតនៃកងទុក្ខទាំងអស់នេះ ។*

*បើសាមណេរសូត្រដល់* "**ព្រហ្មចរិយំ ចរាម**" *ត្រូវឈប់បន្ថែងកុំសូត្រថា* "**ភិក្ខូនំ សិក្ខាសាជីវសមាបន្នា**" *ត្រូវចាប់សូត្រពី* "**តំ នោ ព្រហ្មចរិយំ**" *ទៅទល់នឹងចប់ ។*

វត្តព្រឹកប្រែ ចប់តែប៉ុណ្ណោះ

# ថ្វាយបង្គំព្រះរតនត្រ័យវត្តល្ងាច(១)-ប្រែ

*ឯវិធីថ្វាយបង្គំព្រះវត្តល្ងាច កំមានកិច្ចដែលត្រូវធ្វើជាខាងដើមដូចវិធីថ្វាយបង្គំព្រះវត្តព្រឹកដែរ, បើឧបាសកឧបាសិកា ត្រូវធ្វើកិច្ចទី ១ ទី ២ ទី ៣ ជាមុនសិន សឹមធ្វើកិច្ចទី ៤ គឺថ្វាយបង្គំព្រះវត្តល្ងាចតទៅ ។*

*បើភិក្ខុសាមណេរ ត្រូវធ្វើកិច្ចទី ២ ទី ៣ ជាមុនសិន សឹមធ្វើកិច្ចទី ៤ តទៅ ដូចន័យខាងក្រោមនេះ ៖*

## ទី ៤- កិច្ចថ្វាយបង្គំព្រះរតនត្រ័យវត្តល្ងាច-ប្រែ

*មេនាំ សូត្របណាមវចនៈថា*

**ហន្ទ មយំ ពុទ្ធស្ស ភគវតោ បុព្វភាគនមការំ ករោម សេ**, *មុនដំបូងយើងទាំងឡាយ នមស្ការចំពោះព្រះមានព្រះភាគដែលព្រះអង្គត្រាស់ដឹងហើយ ។*

*សូត្រនមស្ការព្រមគ្នាថា*

**នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។**

*សូត្រ ៣ ដង ។ សូមនមស្ការចំពោះព្រះពុទ្ធជាម្ចាស់អង្គនោះ, ព្រះ*

១- តាំងពីកិច្ចទី ១ រហូតដល់នឹងចប់វត្តល្ងាចប្រែនេះ ស្រង់យកបាលីទាំងសេចក្តីប្រែពីច្បាប់វិធីថ្វាយបង្គំព្រះផ្សាយចេញពីសង្ឃបណ្ណាល័យវត្តបទុមវតី ។

អង្គឆ្ងាយចាកកិលេសហើយ, ត្រាស់ដឹងនូវព្រះធម៌ដ៏ប្រពៃដោយព្រះអង្គឯង, ទ្រង់ចែកធម៌ដល់សត្វទាំងឡាយ ។

## ពុទ្ធានុស្សតិ

*មេនាំ សូត្រថា*

**ហន្ទ មយំ ពុទ្ធានុស្សតិនយំ ករោម សេ,** *យើងទាំងឡាយនឹកព្រះពុទ្ធគុណ ។*

*សូត្រព្រមគ្នា*

**តំ ខោ បន ភគវន្តំ ឯវំ កល្យាណោ កិត្តិសទ្ទោ អព្ភុគ្គតោ,** *រីកិត្តិស័ព្ទសរសើរព្រះមានព្រះភាគអង្គនោះ, ពីរោះខ្ចរខ្ចាយទៅយ៉ាងនេះថា,* **ឥតិ បិ,** *ពិតដូច្នេះ,* **សោ ភគវា,** *រីព្រះមានព្រះភាគអង្គនោះ,* **អរហំ,** *ព្រះអង្គឆ្ងាយចាកកិលេសហើយ,* **សម្មាសម្ពុទ្ធោ,** *ព្រះអង្គត្រាស់ដឹងនូវព្រះធម៌ដ៏ប្រពៃដោយព្រះអង្គឯង,* **វិជ្ជាចរណសម្បន្នោ,** *ព្រះអង្គដល់ព្រមដោយវិជ្ជានិងចរណៈហើយ,* **សុគតោ,** *ព្រះអង្គយាងទៅប្រពៃហើយ,* **លោកវិទូ,** *ព្រះអង្គទ្រង់ជ្រាបច្បាស់នូវលោកហើយ,* **អនុត្តរោ បុរិសទម្មសារថិ,** *ព្រះអង្គទ្រង់ទូន្មាននូវបុរសដ៏គួរទូន្មានពុំមានអ្នកណាលើស,* **សត្ថា ទេវមនុស្សានំ,** *ព្រះអង្គជាគ្រូនៃទេវតានិងមនុស្សទាំងឡាយ,* **ពុទ្ធោ,** *ព្រះអង្គមានព្រះគុណរីកពេញហើយ,* **ភគវាតិ,** *ព្រះអង្គទ្រង់ចែកធម៌*

ដល់សត្វទាំងឡាយ ។

ឈប់រំពឹងព្រះពុទ្ធគុណ

## ពាក្យសូត្រសរសើរព្រះពុទ្ធគុណ

មេនាំ សូត្រថា

**ហន្ទ មយំ ពុទ្ធាភិតីតឹ ករោម សេ,** យើងទាំងឡាយសូត្រគាថាសរសើរព្រះពុទ្ធគុណ ។

សូត្រព្រមគ្នា

**ពុទ្ធារហន្តវរតាទិគុណាភិយុត្តោ,** ព្រះពុទ្ធជាម្ចាស់ទ្រង់ប្រកបដោយគុណ មានភាពជាព្រះអរហន្តដ៏ប្រសើរជាដើម, **សុទ្ធា-ភិញ្ញាណករុណាហិ សមាគតត្តោ,** ទ្រង់មានព្រះទ័យប្រកបដោយព្រះវិសុទ្ធិគុណ បញ្ញាគុណ និងករុណាគុណ, **ពោធេសិ យោ សុជនតំ កមលំវ សូរោ,** ទ្រង់ញុំាងប្រជុំជនឲ្យត្រាស់ដឹងហើយ, ដូចព្រះអាទិត្យញុំាងផ្កាឈូកឲ្យរីក, **វន្ទាមហំ តមរណំ សិរសា ជិនេន្ទំ,** ខ្ញុំក្រាបថ្វាយបង្គំនូវព្រះពុទ្ធជាម្ចាស់អង្គនោះ, ព្រះអង្គជាធំជាងអ្នកឈ្នះមារមិនមានកិលេសជាសត្រូវដោយសិរសា, **ពុទ្ធោ យោ សព្វចាណីនំ, សរណំ ខេមមុត្តមំ,** ព្រះពុទ្ធជាម្ចាស់អង្គណាជាទីពឹងដ៏ក្សេមនិងឧត្តមរបស់សព្វសត្វទាំងឡាយ, **បឋមានុស្ស-តិដ្ឋានំ, វន្ទាមិ តំ សិរេនហំ,** ខ្ញុំក្រាបថ្វាយបង្គំនូវព្រះពុទ្ធជាម្ចាស់

*អង្គនោះ, ដែលជាទីតាំងនៃអនុស្សតិទីមួយដោយសិរសា,* **ពុទ្ធស្សា-ហស្មិ { ទាសោ[1] / ទាសី }, ពុទ្ធោ មេ សាមិកិស្សរោ,** *ខ្ញុំជា { ទាសៈ / ទាសី } នៃព្រះពុទ្ធជាម្ចាស់, ព្រះពុទ្ធជាម្ចាស់ជាធំរបស់ខ្ញុំ,* **ពុទ្ធោ ទុក្ខស្ស ឃាតា ច, វិធាតា ច ហិតស្ស មេ,** *ព្រះពុទ្ធជាម្ចាស់ទ្រង់កម្ចាត់បង់នូវទុក្ខ ហើយធ្វើប្រយោជន៍ដល់ខ្ញុំ,* **ពុទ្ធស្សាហំ និយ្យាទេមិ, សរីរញ្ជីវិតញ្ចិទំ,** *ខ្ញុំប្រគល់កាយថ្វាយជីវិតនេះដល់ព្រះពុទ្ធជាម្ចាស់,* **វន្ទ { ន្តោ[2] / ន្តី } ហំ ចរិស្សាមិ, ពុទ្ធស្សេវ សុពោធិតំ,** *ខ្ញុំនឹងប្រព្រឹត្តក្រាបថ្វាយបង្គំ, នូវសេចក្តីត្រាស់ដឹងដោយប្រពៃនៃព្រះពុទ្ធជាម្ចាស់អង្គនោះ,* **នត្ថិ មេ សរណំ អញ្ញំ, ពុទ្ធោ មេ សរណំ វរំ,** *ទីពឹងដទៃរបស់ខ្ញុំមិនមាន, ព្រះពុទ្ធជាម្ចាស់ជាទីពឹងដ៏ប្រសើររបស់ខ្ញុំ,* **ឯតេន សច្ចវជ្ជេន, វឌ្ឍេយ្យំ សត្ថុ សាសនេ,** *ដោយការពោលនូវពាក្យសច្ចៈនេះ, សូមឲ្យខ្ញុំចម្រើនក្នុងសាសនានៃព្រះសាស្តា,* **ពុទ្ធំ មេ វន្ទមា { នេន[3] / នាយ }, យំ បុញ្ញំ បសុតំ ឥធ,** *បុណ្យណាដែលខ្ញុំបានហើយ, ដោយកិរិយាថ្វាយបង្គំនូវព្រះពុទ្ធជាម្ចាស់ក្នុងទីនេះ,*

---

១- ទាសោ ២- វន្ទន្តោ សម្រាប់បុរសថា, -ទាសី- វន្ទន្តី សម្រាប់ស្ត្រីថា ។
៣- វន្ទមានេន សម្រាប់បុរសថា, វន្ទមានាយ សម្រាប់ស្ត្រីថា ។

សព្វេបិ អន្តរាយា មេ, មាហេសុំ តស្ស តេជសា, *ដោយតេជះនៃបុណ្យនោះ, អន្តរាយទាំងឡាយទាំងពួងកុំកើតមានដល់ខ្ញុំឡើយ ។*

*គប្បីក្រាបចុះហើយសូត្រតិចៗ ថា*

កាយេន វាចាយ វ ចេតសា វា, ពុទ្ធេ កុកម្មំ បកតំ មយា យំ, *អំពើអាក្រក់ណាដែលខ្ញុំធ្វើហើយដោយកាយ វាចាចិត្តចំពោះព្រះពុទ្ធជាម្ចាស់,* ពុទ្ធោ បដិគ្គណ្ហាតុ អច្ចយន្តំ, កាលន្តរេ សំវរិតុំ វ ពុទ្ធេ, *សូមព្រះពុទ្ធជាម្ចាស់ទ្រង់ទទួលអត់នូវទោសនោះ, ដើម្បីនឹងសង្រួមក្នុងព្រះពុទ្ធជាម្ចាស់អស់កាលតរៀងទៅ ។*

## ធម្មានុស្សតិ

*មេនាំ សូត្រថា*

ហន្ទ មយំ ធម្មានុស្សតិនយំ ករោម សេ, *យើងទាំងឡាយនឹកព្រះធម្មគុណ ។*

*សូត្រព្រមគ្នា*

ស្វាក្ខាតោ ភគវតា ធម្មោ, *ព្រះធម៌ដែលព្រះមានព្រះភាគទ្រង់សម្តែងប្រពៃហើយ,* សន្ទិដ្ឋិកោ, *ជាធម៌ដែលអ្នកបដិបត្តិឃើញច្បាស់ដោយខ្លួនឯង,* អកាលិកោ, *ជាធម៌ឲ្យផលពុំមានកំណត់កាល,* ឯហិបស្សិកោ, *ជាធម៌មានអាការៈអាចហៅអ្នកដទៃ*

*មកមើលបាន,* **ឱបនយិកោ**, *ជាធម៌គួរបង្អោនមកដាក់ក្នុងចិត្តបាន,* **បច្ចត្តំ វេទិតព្វោ វិញ្ញូហីតិ**, *ជាធម៌ដែលអ្នកប្រាជ្ញទាំងឡាយគប្បីដឹងចំពោះខ្លួន ។*

ឈប់ រំពឹងព្រះធម្មគុណ

## ពាក្យសរសើរព្រះធម្មគុណ

*មេនាំ សូត្រថា*

**ហន្ទ មយំ ធម្មាភិកិត្តឹ ករោម សេ**, *យើងទាំងឡាយសូត្រគាថាសរសើរព្រះធម្មគុណ ។*

*សូត្រព្រមគ្នា*

**ស្វាក្ខាតតាទិគុណយោគវសេន សេយ្យោ**, *ព្រះធម៌ដ៏ប្រសើរព្រោះប្រកបដោយគុណ, មានភាពជាធម៌ដែលព្រះមានព្រះភាគទ្រង់សម្តែងប្រពៃហើយជាដើម,* **យោ មគ្គបាកបរិយត្តិ-វិមោក្ខភេទោ**, *ជាធម៌ផ្សេងគ្នាដោយបរិយត្តិ មគ្គ ផល និងព្រះនិព្វាន,* **ធម្មោ កុលោកបតនា តទធារិធារី**, *ជាធម៌ទ្រង់ទុកនូវអ្នកទ្រង់ធម៌មិនឲ្យធ្លាក់ទៅក្នុងលោកដ៏អាក្រក់,* **វន្ទាមហំ តមហរំ វរធម្មមេតំ**, *ខ្ញុំក្រាបថ្វាយបង្គំនូវព្រះធម៌ដ៏ប្រសើរនោះ, ដែលជាធម៌កម្ចាត់បង់នូវងងឹត,* **ធម្មោ យោ សព្វបាណីនំ, សរណំ ខេមមុត្តមំ**, *ព្រះធម៌ណាជាទីពឹងដ៏ក្សេមនិងឧត្តមរបស់សព្វសត្វទាំង*

ឡាយ, ធុតិយានុស្សតិដ្ឋានំ, វន្ទាមិ តំ សិរេនហំ, ខ្ញុំក្រាបថ្វាយបង្គំនូវព្រះធម៌នោះ, ដែលជាទីតាំងនៃអនុស្សតិទីពីរដោយសិរសា,

ធម្មស្សាហស្មិ {ទាសោ / ទាសី} វ, ធម្មោ មេ សាមិកិស្សរោ,

ខ្ញុំជា {ទាសៈ / ទាសី} នៃព្រះធម៌, ព្រះធម៌ជាម្ចាស់ជាធំរបស់ខ្ញុំ, ធម្មោ ទុក្ខស្ស ឃាតា ច, វិធាតា ច ហិតស្ស មេ, ព្រះធម៌កម្ចាត់បង់នូវទុក្ខហើយធ្វើប្រយោជន៍ដល់ខ្ញុំ, ធម្មស្សាហំ និយ្យាតេមិ សរីរញ្ជីវិតញ្ចិទំ, ខ្ញុំប្រគល់កាយថ្វាយជីវិតនេះដល់ព្រះធម៌,

វន្ទ{ន្តោ / ន្តី} ហំ ចរិស្សាមិ, ធម្មស្សេវ សុធម្មតំ, ខ្ញុំនឹងប្រព្រឹត្តក្រាបថ្វាយបង្គំ, នូវសេចក្តីទ្រទ្រង់ដោយប្រពៃនៃព្រះធម៌នោះ, នត្ថិ មេ សរណំ អញ្ញំ, ធម្មោ មេ សរណំ វរំ, ទីពឹងដទៃរបស់ខ្ញុំមិនមាន, ព្រះធម៌ជាទីពឹងដ៏ប្រសើររបស់ខ្ញុំ, ឯតេន សច្ចវជ្ជេន, វឌ្ឍេយ្យំ សត្ថុ សាសនេ, ដោយការពោលនូវពាក្យសច្ចៈនេះ,

សូមឲ្យខ្ញុំចម្រើនក្នុងសាសនានៃព្រះសាស្តា, ធម្មំ មេ វន្ទមា{នេន / នាយ},

យំ បុញ្ញំ បសុតំ ឥធ, បុណ្យណាដែលខ្ញុំបានហើយដោយកិរិយា

*ថ្វាយបង្គំនូវព្រះធម៌ក្នុងទីនេះ,* **សព្វេបិ អន្តរាយា មេ, មាហេសុំ តស្ស តេជសា,** *ដោយតេជះនៃបុណ្យនោះ, អន្តរាយទាំងឡាយ ទាំងពួងកុំកើតមានដល់ខ្ញុំឡើយ ។*

*គប្បីក្រាបចុះហើយសូត្រតិច ៗ ថា*

**កាយេន វាចាយ វ ចេតសា វា, ធម្មេ កុកម្មំ បកតំ មយា យំ,** *អំពើអាក្រក់ណាដែលខ្ញុំធ្វើហើយដោយកាយ វាចាចិត្តចំពោះព្រះធម៌,* **ធម្មោ បដិគ្គណ្ហាតុ អច្ចយន្តំ, កាលន្តរេ សំវរិតុំ វ ធម្មេ,** *សូមព្រះធម៌ទទួលអត់នូវទោស នោះ, ដើម្បីនឹងសង្រួមក្នុងព្រះធម៌អស់កាលតរៀងទៅ ។*

## សង្ឃានុស្សតិ

*មេនាំ សូត្រថា*

**ហន្ទ មយំ សង្ឃានុស្សតិនយំ ករោម សេ,** *យើងទាំងឡាយនឹកព្រះសង្ឃគុណ ។*

*សូត្រព្រមគ្នា*

**សុបដិបន្នោ ភគវតោ សាវកសង្ឃោ,** *ព្រះសង្ឃ សាវ័កនៃព្រះមានព្រះភាគលោកបដិបត្តិប្រពៃហើយ,* **ឧជុបដិបន្នោ ភគវតោ សាវកសង្ឃោ,** *ព្រះសង្ឃសាវ័កនៃព្រះមានព្រះ ភាគលោកបដិបត្តិត្រង់ហើយ,* **ញាយបដិបន្នោ ភគវតោ**

**សាវកសង្ឃោ,** *ព្រះសង្ឃសាវ័កនៃព្រះមានព្រះភាគលោកបដិបត្តិដើម្បីចេញចាកសង្សារទុក្ខហើយ,* **សាមីចិបដិបន្នោ ភគវតោ សាវកសង្ឃោ,** *ព្រះសង្ឃសាវ័កនៃព្រះមានព្រះភាគលោកបដិបត្តិសមគួរនឹងព្រះនិព្វានហើយ,* **យទិទំ,** *ព្រះសង្ឃសាវ័កអង្គនោះគឺ,* **ចត្តារិ បុរិសយុគានិ,** *បើរាប់ជាគូនៃបុរសមានបួនគូ,* **អដ្ឋ បុរិសបុគ្គលា,** *បើរាប់រៀងបុរសបុគ្គលមានប្រាំបី,* **ឯស ភគវតោ សាវកសង្ឃោ,** *នេះជាព្រះសង្ឃសាវ័កនៃព្រះមានព្រះភាគ,* **អាហុនេយ្យោ,** *លោកគួរទទួលរបស់ដែលគេនាំមកបូជា,* **បាហុនេយ្យោ,** *លោកគួរទទួលរបស់ដែលគេនាំមកទទួលភ្ញៀវ,* **ទក្ខិណេយ្យោ,** *លោកគួរទទួលទក្ខិណាទាន,* **អញ្ជលិករណីយោ,** *លោកគួរទទួលអញ្ជលីប្រណម្យ,* **អនុត្តរំ បុញ្ញក្ខេត្តំ លោកស្សាតិ,** *លោកជាស្រែបុណ្យដ៏ប្រសើរលើសនៃសត្វលោក ។*

ឈប់ រំពឹងព្រះសង្ឃគុណ

## ពាក្យសូត្រសរសើរព្រះសង្ឃគុណ

*មេនាំ សូត្រថា*

**ហន្ទ មយំ សង្ឃាភិកិត្តឹ ករោម សេ,** *យើងទាំងឡាយសូត្រគាថាសរសើរព្រះសង្ឃគុណ ។*

*សូត្រព្រមគ្នា*

**សទ្ធម្មជោ សុបដិបត្តិគុណាភិយុត្តោ,** *ព្រះសង្ឃកើត*

*អំពីព្រះសទ្ធម្ម, ប្រកបដោយគុណមានសេចក្ដីបដិបត្តិប្រពៃជាដើម,* **យោ ឧដ្ឋពិ្វជោ អរិយបុគ្គលសង្ឃសេដ្ឋោ,** *ជាពួកព្រះអរិយបុគ្គលដ៏ប្រសើរទាំងប្រាំបី,* **សីលាទិធម្មបវរាសយកាយចិត្តោ,** *មានកាយនិងចិត្ត ជាទីអាស្រ័យនៅនៃព្រះធម៌ដ៏ប្រសើរ មានសីលជាដើម,* **វន្ទាមហំ តមរិយានគណំ សុសុទ្ធំ,** *ខ្ញុំក្រាបថ្វាយបង្គំនូវព្រះសង្ឃអង្គនោះ, ដែលជាពួកនៃព្រះអរិយៈដ៏បរិសុទ្ធប្រពៃ,* **សង្ឃោ យោ សព្វចាណីនំ, សរណំ ខេមមុត្តមំ,** *ព្រះសង្ឃអង្គណាជាទីពឹងដ៏ក្សេមនិងឧត្តមរបស់សព្វសត្វទាំងឡាយ,* **តតិយានុស្សតិដ្ឋានំ, វន្ទាមិ តំ សិរេនហំ,** *ខ្ញុំក្រាបថ្វាយបង្គំនូវព្រះសង្ឃអង្គនោះ, ដែលជាទីតាំងនៃអនុស្សតិទីបីដោយសិរសា,*

**សង្ឃស្សាហាស្មិ { ទាសោ / ទាសី } វ, សង្ឃោ មេ សាមិកិស្សរោ,**

*ខ្ញុំជា { ទាសៈ / ទាសី } នៃព្រះសង្ឃ, ព្រះសង្ឃជាម្ចាស់ជាធំរបស់ខ្ញុំ,* **សង្ឃោ ទុក្ខស្ស ឃាតា ច, វិធាតា ច ហិតស្ស មេ,** *ព្រះសង្ឃកម្ចាត់បង់នូវទុក្ខហើយធ្វើប្រយោជន៍ដល់ខ្ញុំ,* **សង្ឃស្សាហំ និយ្យាទេមិ, សរីរញ្ជីវិតញ្ចិទំ,** *ខ្ញុំប្រគល់កាយថ្វាយជីវិតនេះដល់ព្រះសង្ឃ,*

**វន្ទ { ន្តោ / ន្តី } ហំ ចរិស្សាមិ, សង្ឃស្សោបដិបន្នតំ,** *ខ្ញុំនឹងប្រព្រឹត្ត*

ក្រាបថ្វាយបង្គំនូវសេចក្តីបដិបត្តិដោយប្រពៃនៃព្រះសង្ឃអង្គនោះ, នត្ថិ មេ សរណំ អញ្ញំ, សង្ឃោ មេ សរណំ វរំ, ទីពឹងដទៃរបស់ខ្ញុំមិនមាន, ព្រះសង្ឃជាទីពឹងដ៏ប្រសើររបស់ខ្ញុំ, ឯតេន សច្ចវជ្ជេន, វឌ្ឍេយ្យំ សត្ថុ សាសនេ, ដោយការពោលនូវពាក្យសច្ចៈនេះ, សូមឲ្យខ្ញុំចម្រើនក្នុងសាសនានៃព្រះសាស្តា, សង្ឃំ មេ វន្ទមា {នេន / នាយ}, យំ បុញ្ញំ បសុតំ ឥធ, បុណ្យណាដែលខ្ញុំបានហើយ, ដោយកិរិយាថ្វាយបង្គំនូវព្រះសង្ឃក្នុងទីនេះ, សព្វេបិ អន្តរាយា មេ, មាហេសុំ តស្ស តេជសា, ដោយតេជះនៃបុណ្យនោះ, អន្តរាយទាំងឡាយទាំងពួងកុំកើតមានដល់ខ្ញុំឡើយ ។

គប្បីក្រាបចុះហើយសូត្រតិច ៗ ថា

កាយេន វាចាយ វ ចេតសា វា, សង្ឃេ កុកម្មំ បកតំ មយា យំ, អំពើអាក្រក់ណាដែលខ្ញុំធ្វើហើយដោយកាយ វាចា ចិត្ត ចំពោះព្រះសង្ឃ សង្ឃោ បដិគ្គណ្ហាតុ អច្ចយន្តំ, កាលន្តរេ សំវរិតុំ វ សង្ឃេ, សូមព្រះសង្ឃទទួលអត់នូវទោសនោះ, ដើម្បីនឹងសង្រួមក្នុងព្រះសង្ឃអស់កាលតរៀងទៅ ។

វគ្គល្ងាចប្រែ ចប់តែប៉ុណ្ណោះ

---

*កាលឧបាសក ឧបាសិកា សូត្រថ្វាយបង្គំព្រះរតនត្រ័យវត្តព្រឹកវត្តល្ងាចចប់ហើយ ទើបអន្ទុយរាបសូត្រធមិចុងវត្តខ្លះៗ ថែមទៀត មាន អសុភភាវនា, អភិណ្ហបច្ចវេក្ខណៈ, មរណស្សតិភាវនា និងទេវតាទិ-បត្តិទានគាថា, បត្តិទានគាថាជាដើម ឬនឹងសូត្រធមិដទៃទៀតក៏បាន ។ បើនឹងសូត្រកម្មបថជាវិន័យរបស់ខ្លួនបញ្ចូលផងក៏បាន តាមសមគួរដល់ពេលវេលានិងអធ្យាស្រ័យ ។*

## អសុភភាវនា[១]

**អយមេវ កាយោ**, *រីកាយនេះ*, **ឧទ្ធំ បាទតលា**, *ខាងលើអំពីបាតជើងឡើងទៅ*, **អធោ កេសមត្ថកា**, *ខាងក្រោមអំពីចុងសក់ចុះមក*, **តចបរិយន្តោ**, *មានស្បែកព័ទ្ធជុំវិញ*, **បូរោ នានប្បការស្ស អសុចិនោ**, *ដ៏ពេញដោយអាការៈមិនស្អាតមានប្រការផ្សេងៗ*, **អត្ថិ ឥមស្មឹ កាយេ**, *មានក្នុងកាយនេះ គឺ*, **កេសា លោមា នខា ទន្តា តចោ**, *សក់ រោម ក្រចក ធ្មេញ ស្បែក*, **មំសំ នហារូ អដ្ឋី អដ្ឋិមិញ្ជំ វក្កំ**, *សាច់ សរសៃ ឆ្អឹង ខួរក្នុងឆ្អឹង ទាច*, **ហទយំ យកនំ កិលោមកំ បិហកំ បប្ផាសំ**, *បេះដូង ថ្លើម វាវ ក្រពះ សួត*, **អន្តំ អន្ត-**

១- អសុភភាវនា, អភិណ្ហបច្ចវេក្ខណៈ, មរណស្សតិភាវនា, ទេវតាទិបត្តិទានគាថា និង បត្តិទានគាថា នេះបានដកស្រង់យកបាលីទាំងសេចក្តីប្រែពីច្បាប់ វិធីថ្វាយបង្គំព្រះ ផ្សាយចេញពីសង្ឃបណ្ណាល័យ វត្តបទុមវតី ។

**កុណំ ឧទរិយំ ករីសំ,** *ពោះវៀនធំ ពោះវៀនតូច អាហារថ្មី អាហារចាស់,* **បិត្តំ សេម្ហំ បុព្វោ លោហិតំ សេទោ មេទោ,** *ប្រមាត់ ស្លេស្ម ខ្ទុះ ឈាម ញើស ខ្លាញ់ខាប់,* **អស្សុ វសា ខេឡោ សិង្ឃាណិកា លសិកា មុត្តន្តិ,** *ទឹកភ្នែក ខ្លាញ់រាវ ទឹកមាត់ ទឹកសំបោរ ទឹករំអិល ទឹកមូត្រ ។*

## អភិណ្ហបច្ចវេក្ខណ

**ជរាធម្មោម្ហិ ជរំ អនតីតោ,** *យើងមានសេចក្ដីចាស់ជរាជាធម្មតា, មិនកន្លងសេចក្ដីចាស់ជរាទៅបានឡើយ,* **ព្យាធិធម្មោម្ហិ ព្យាធឹ អនតីតោ,** *យើងមានសេចក្ដីឈឺចាប់ជាធម្មតា, មិនកន្លងសេចក្ដីឈឺចាប់ទៅបានឡើយ,* **មរណធម្មោម្ហិ មរណំ អនតីតោ,** *យើងមានសេចក្ដីស្លាប់ជាធម្មតា, មិនកន្លងសេចក្ដីស្លាប់ទៅបានឡើយ,* **សព្វេហិ មេ បិយេហិ មនាបេហិ នានាភាវោ វិនាភាវោ,** *យើងមានសេចក្ដីព្រាត់ប្រាសចាកសត្វនិងសង្ខារ, ជាទីស្រឡាញ់ជាទីគាប់ចិត្តទាំងពួង,* **កម្មស្សកោម្ហិ,** *យើងមានកម្មជារបស់ខ្លួន,* **កម្មទាយាទោ,** *ជាអ្នកទទួលនូវផលនៃកម្ម,* **កម្មយោនិ,** *មានកម្មជាកំណើត,* **កម្មពន្ធុ,** *មានកម្មជាផៅពង្ស,* **កម្មបដិស្សរណោ,** *មានកម្មជាទីពំនាក់អាស្រ័យ,* **យំ កម្មំ ករិស្សាមិ,** *យើងនឹងធ្វើនូវកម្មណា,* **កល្យាណំ វា បាបកំ វា,**

*ជាបុណ្យក្តី ជាបាបក្តី,* **តស្ស ទាយាទោ ភវិស្សាមិ,** *យើងនឹងជាអ្នកទទួលនូវផលនៃកម្មនោះ ។*

## មរណស្សតិភាវនា

**អទ្ធុវំ មេ ជីវិតំ,** *សេចក្តីរស់នៅនៃយើងមិនទៀង,* **ធុវំ មរណំ,** *សេចក្តីស្លាប់ទៀង,* **អវស្សំ មយា មរិតព្វំ,** *យើងគង់ស្លាប់ដោយពិត,* **មរណបរិយោសានំ មេ ជីវិតំ,** *សេចក្តីរស់នៅនៃយើងមានសេចក្តីស្លាប់ជាទីបំផុត,* **ជីវិតំ អទ្ធុវំ ធុវំ មរណន្តិ,** *សេចក្តីរស់នៅមិនទៀង សេចក្តីស្លាប់ទៀង ។*

## ទេវតាទិបត្តិទានគាថា

**អាកាសដ្ឋា ច ភុម្មដ្ឋា, ទេវា នាគា មហិទ្ធិកា,** *ទេវតាទាំងឡាយដែលឋិតនៅក្នុងអាកាសក្តី លើផែនដីក្តី, នាគទាំងឡាយដែលមានឫទ្ធិច្រើនក្តី,* **បុញ្ញំ តំ អនុមោទន្តុ, ចិរំ រក្ខន្តុ សាសនំ,** *សូមអនុមោទនានូវបុណ្យនោះហើយរក្សានូវព្រះពុទ្ធសាសនាអស់កាលដ៏យូរ ។*

**អាកាសដ្ឋា ច ភុម្មដ្ឋា, ទេវា នាគា មហិទ្ធិកា,** *ទេវតាទាំងឡាយដែលឋិតនៅក្នុងអាកាសក្តី លើផែនដីក្តី, នាគទាំងឡាយដែលមានឫទ្ធិច្រើនក្តី,* **បុញ្ញំ តំ អនុមោទន្តុ, ចិរំ រក្ខន្តុ**

**រាជានោ**, *សូមអនុមោទនានូវបុណ្យនោះ ហើយរក្សានូវព្រះរាជាទាំងឡាយអស់កាលដ៏យូរ ។*

**អាកាសដ្ឋា ច ភុម្មដ្ឋា, នាគា ចាគា មហិទ្ធិកា,** *ទេវតាទាំងឡាយដែលឋិតនៅក្នុងអាកាសក្តី លើផែនដីក្តី, នាគទាំងឡាយដែលមានឫទ្ធិច្រើនក្តី,* **បុញ្ញំ តំ អនុមោទន្តុ, ចិរំ រក្ខន្តុ មំ បរត្ថិ,** *សូមអនុមោទនានូវបុណ្យនោះហើយរក្សានូវខ្ញុំ និងជនដទៃអស់កាលដ៏យូរ ។*

## បត្តិទានគាថា

**យង្កិញ្ចិ កុសលកម្មំ, កត្តព្វំ កិរិយំ មម, កាយេន វាចាមនសា, តិទសេ សុគតំ កតំ,** *អំពើជាកុសលណាមួយដែលខ្ញុំគប្បីធ្វើដោយ កាយ វាចា ចិត្ត, គឺខ្ញុំធ្វើឲ្យជាអំពើគួរនាំទៅកើតក្នុងឋានតាវត្តិង្ស,* **យេ សត្តា សញ្ញិនោ អត្ថិ, យេ ច សត្តា អសញ្ញិនោ,** *សត្វទាំងឡាយណាមានសញ្ញាក្តី មិនមានសញ្ញាក្តី,* **កតំ បុញ្ញផលំ មយ្ហំ, សព្វេ ភាគី ភវន្តុ តេ,** *សូមសត្វទាំងឡាយទាំងពួងនោះ បាននូវចំណែកផលនៃបុណ្យដែលខ្ញុំធ្វើហើយ,* **យេ តំ កតំ សុវេទិសុ**[១], **ទិន្នំ បុញ្ញផលំ មយា,** *សត្វទាំងឡាយណាបានដឹងច្បាស់នូវអំពើជាកុសលនោះហើយ, សូម*

---

១- គម្ពីរបាលីមង្គលត្ថទីបនីឋា សុវិទិតំ ប៉ុន្តែ កែឲ្យត្រូវតាមបាទគាថាជាយគណៈក្នុងបថ្យាវត្តឋា សុវេទិសុ វិញ ។

*សត្វទាំងឡាយនោះបានទូវចំណែកផលនៃបុណ្យដែលខ្ញុំឲ្យហើយ,* **យេ ច តត្ថ ន ជានន្តិ, ទេវា គន្ត្វា និវេទយុំ,** *បើសត្វទាំងឡាយណាមិនដឹងច្បាស់ទេ, សូមទេព្តាទាំងឡាយទៅប្រាប់សត្វទាំងឡាយនោះផង,* **សព្វេ លោកម្ហិ យេ សត្តា, ជីវន្តាហារហេតុកា,** *សត្វទាំងឡាយទាំងពួងណាក្នុងលោក ដែលរស់នៅព្រោះអាហារ,* **មនុញ្ញំ ភោជនំ សព្វេ, លភន្តុ មម ចេតសាតិ,** *សត្វទាំងឡាយទាំងពួងនោះ ចូរបានទូវភោជនជាទីគាប់ចិត្ត, ដោយឧទ្ទិសចេតនារបស់ខ្ញុំ ។*

## វិធីឧបាសកឧបាសិកា

# សមាទាននិច្ចសីល[១]-ប្រែ

*វិធីសមាទាននិច្ចសីលនេះ ឧបាសក ឧបាសិកា គប្បីធ្វើកិច្ចឲ្យសម្រេចជាមុនសិនគឺ៖*

*ទី ១- កិច្ចប្រកាសខ្លួន សូត្រ* **អហំ ពុទ្ធញ្ច...........**

*ទី ២- កិច្ចថ្វាយបង្គំព្រះរតនត្រ័យ សូត្រ* **អរហំ...........**

*ទី ៣- កិច្ចថ្វាយគ្រឿងសក្ការៈ សូត្រ* **ឥមានិ មយំ,** *ឬ* **យមហំ..............,**

---

១- ស្រង់យកបាលីទាំងសេចក្តីប្រែពីច្បាប់វិធីថ្វាយបង្គំព្រះផ្សាយចេញពីសង្ឃបណ្ណាល័យវត្តបទុមវតី ។

*ទី ៤- កិច្ចនមស្ការព្រះរតនត្រ័យ សូត្រ នមោ....................,*

*កាលធ្វើកិច្ចទាំងនេះតាមសមគួរដល់វេលារួចហើយ គប្បីអារាធនានិច្ចសីល ដោយបន្ទីវាចាព្រមទាំងតាំងចេតនាឲ្យប្រាកដផង ដូចន័យខាងក្រោមនេះ*

## អារាធនាសមាទាននិច្ចសីល

**អហំ(១) / មយំ ភន្តេ, តិសរណេន សហ, បញ្ចង្គសមន្នាគតំ,**

**និច្ចសីលំ យាចាម ទុតិយម្បិ(២) ។ ៣ ដង ។ បពិត្រព្រះករុណាដ៏ចម្រើន, ម,**

*ខ្ញុំព្រះករុណា(៣) / យើងខ្ញុំព្រះករុណា សុំនូវនិច្ចសីល, ដែលប្រកបដោយអង្គប្រាំប្រការ, ព្រមទាំងព្រះត្រៃសរណគមន៍(៤) ។*

*លោកអ្នកឲ្យសីល ត្រូវនាំសូធ្យនមស្ការព្រះរតនត្រ័យ សមាទានសរណគមន៍ សមាទាននិច្ចសីល ព្រមទាំងឲ្យឱវាទនិងប្រាប់អានិសង្សដូចតទៅនេះ៖*

## នមស្ការព្រះរតនត្រ័យ

**នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។**

---

១- អហំ, ២- មិ សម្រាប់មនុស្សម្នាក់ថា, បើគ្នាច្រើនត្រូវថា មយំ, ម ។

៣- ខ្ញុំព្រះករុណា សម្រាប់មនុស្សម្នាក់ថា, បើគ្នាច្រើនត្រូវថា យើងខ្ញុំព្រះករុណា ។

៣ ដង ។ សូមនមស្ការចំពោះព្រះពុទ្ធជាម្ចាស់អង្គនោះ ព្រះអង្គឆ្ងាយចាកកិលេសហើយ, ត្រាស់ដឹងនូវព្រះធម៌ដ៏ប្រពៃដោយព្រះអង្គឯង, ទ្រង់ចែកធម៌ដល់សត្វទាំងឡាយ ។

## សមាទានព្រះត្រៃសរណគមន៍

ពុទ្ធំ សរណំ គច្ឆាមិ, ខ្ញុំព្រះករុណាដល់នូវព្រះពុទ្ធជាទីពឹង,

ធម្មំ សរណំ គច្ឆាមិ, ខ្ញុំព្រះករុណាដល់នូវព្រះធម៌ជាទីពឹង,

សង្ឃំ សរណំ គច្ឆាមិ, ខ្ញុំព្រះករុណាដល់នូវព្រះសង្ឃជាទីពឹង ។

ទុតិយម្បិ ពុទ្ធំ សរណំ គច្ឆាមិ, ខ្ញុំព្រះករុណាដល់នូវព្រះពុទ្ធជាទីពឹង អស់វារៈគម្រប់ ២ ដងផង,

ទុតិយម្បិ ធម្មំ សរណំ គច្ឆាមិ, ខ្ញុំព្រះករុណាដល់នូវព្រះធម៌ជាទីពឹង អស់វារៈគម្រប់ ២ ដងផង,

ទុតិយម្បិ សង្ឃំ សរណំ គច្ឆាមិ, ខ្ញុំព្រះករុណាដល់នូវព្រះសង្ឃជាទីពឹង អស់វារៈគម្រប់ ២ ដងផង ។

តតិយម្បិ ពុទ្ធំ សរណំ គច្ឆាមិ, ខ្ញុំព្រះករុណាដល់នូវព្រះពុទ្ធជាទីពឹង អស់វារៈគម្រប់ ៣ ដងផង,

តតិយម្បិ ធម្មំ សរណំ គច្ឆាមិ, ខ្ញុំព្រះករុណាដល់នូវព្រះធម៌ជាទីពឹង អស់វារៈគម្រប់ ៣ ដងផង,

តតិយម្បិ សង្ឃំ សរណំ គច្ឆាមិ, ខ្ញុំព្រះករុណាដល់នូវ

ព្រះសង្ឃជាទីពឹង អស់វារៈគម្រប់ ៣ ដងផង ។

ទីបំផុតនេះ លោកអ្នកឲ្យ ត្រូវថា "**តិសរណគមនំ និដ្ឋិតំ**, ព្រះត្រៃសរណគមន៍ចប់ហើយ" ។ អ្នកសមាទានត្រូវឆ្លើយថា "**អាម ភន្តេ** ព្រះករុណា" ។

## សមាទាននិច្ចសីល មានសិក្ខាបទ ៥

១- **បាណាតិបាតា វេរមណីសិក្ខាបទំ សមាទិយាមិ**, ខ្ញុំព្រះករុណា សមាទាននូវសិក្ខាបទ, គឺវៀរចាកសម្លាប់សត្វដោយខ្លួនឯង, និងប្រើអ្នកដទៃឲ្យសម្លាប់ ។

២- **អទិន្នាទានា វេរមណីសិក្ខាបទំ សមាទិយាមិ**, ខ្ញុំព្រះករុណា សមាទាននូវសិក្ខាបទ, គឺវៀរចាកលួចលាក់បំបាត់ទ្រព្យអ្នកដទៃដោយខ្លួនឯង, និងប្រើអ្នកដទៃឲ្យលួចលាក់បំបាត់ ។

៣- **កាមេសុ មិច្ឆាចារា វេរមណីសិក្ខាបទំ សមាទិយាមិ**, ខ្ញុំព្រះករុណា សមាទាននូវសិក្ខាបទ, គឺវៀរចាកប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ។

៤- **មុសាវាទា វេរមណីសិក្ខាបទំ សមាទិយាមិ**, ខ្ញុំព្រះករុណាសមាទាននូវសិក្ខាបទ, គឺវៀរចាកនិយាយកុហកអ្នកដទៃ ។

៥- **សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណីសិក្ខាបទំ សមាទិយាមិ**, ខ្ញុំព្រះករុណា សមាទាននូវសិក្ខាបទ, គឺវៀរចាកហេតុ

*ជាទីតាំងនៃសេចក្តីប្រមាទ, គឺផឹកនូវសុរានិងមេរ័យ, ដែលជាគ្រឿងស្រវឹងផ្សេង ៗ ។*

## លោកអ្នកឲ្យសីល ត្រូវឲ្យឱវាទថា

**ឥមានិ បញ្ច សិក្ខាបទានិ និច្ចសីលវសេន សាធុកំ រក្ខិតព្វានិ**, *លោក-អ្នក គប្បីរក្សានូវសិក្ខាបទទាំង ៥ នេះ, ឲ្យបានជានិច្ចសីលដ៏បរិសុទ្ធប្រពៃ ។ អ្នកសមាទានត្រូវទទួលថា* "**អាម ភន្តេ**, *ព្រះករុណា" ។*

## លោកអ្នកឲ្យសីល ត្រូវប្រាប់អានិសង្សថា

**សីលេន សុគតឹ យន្តិ**, *ជនទាំងឡាយ បានសុគតិដោយសារសីល,* **សីលេន ភោគសម្បទា**, *ជនទាំងឡាយបានភោគ-សម្ប័ទដោយសារសីល,* **សីលេន និព្វុតឹ យន្តិ**, *ជនទាំងឡាយបានព្រះនិព្វានដោយសារសីល,* **តស្មា សីលំ វិសោធយេ**, *ព្រោះហេតុនោះ គប្បីញុំាងសីលឲ្យបរិសុទ្ធប្រពៃ ។ អ្នកសមាទានត្រូវទទួលថា* "**សាធុ**, *ប្រពៃហើយ" ។*

*លំដាប់អំពីនេះ អ្នកសមាទានសីលត្រូវសូធ្យ* **កាយេន . . .**, *ទាំង ៣ ចប់, រួចហើយបើពុំមានកិច្ចអ្វីដែលត្រូវធ្វើបន្ទាប់ពីនោះទៀតទេ លោកអ្នកឲ្យសីលគប្បីអនុមោទនា គឺសូធ្យ* **យថា, ភវតុ សព្វ . . .**, *លុះចប់អនុមោទនាហើយ អ្នកសមាទានសីល ត្រូវសូត្រ*

*ទេវតាទិបត្តិទានគាថា គឺ* **អាកាសដ្ឋា** *. . . , បត្តិទានគាថា គឺ* **យង្កិញ្ចិ** *. . . ។*

## វិធីឧបាសក ឧបាសិកា

## សមាទានឧបោសថសីល-ប្រែ

*វិធី[១] សមាទានឧបោសថសីលនេះ កាលដល់ថ្ងៃឧបោសថ ឧបាសក ឧបាសិកា ភ្ញាក់ពីព្រលឹមឡើងហើយគប្បីជម្រះកាយខ្លួនមាត់ឲ្យស្អាត តាំងចិត្តឲ្យល្អហើយថ្វាយបង្គំព្រះរតនត្រ័យ តាំងអធិដ្ឋានចំពោះព្រះភក្ត្រព្រះពុទ្ធរូបដោយបាលីថា* **ឥមញ្ច រត្តឹ ឥមញ្ច ទិវសំ ពុទ្ធប្បញ្ញត្តំ ឧបោសថំ អធិដ្ឋាមិ** *។ ថា ៣ ដង ។ ប្រែថា ខ្ញុំសូមអធិដ្ឋាននូវឧបោសថ ដែលព្រះពុទ្ធជាម្ចាស់ទ្រង់បញ្ញត្តទុកមកហើយ កំណត់អស់ថ្ងៃនេះ និងយប់នេះ[២] ។ ហើយសូត្រឧបោសថសីលឲ្យគ្រប់សិក្ខាបទទាំង ៨ តទៅ រួចហើយបើមានព្រះសង្ឃ គប្បីសមាទានអំពីលោកថែមទៀត បើគ្មានទេ អធិដ្ឋានត្រឹមប៉ុណ្ណោះទុកជាការស្រេចបាន ។*

*ឯការសមាទានឧបោសថសីលនេះ អ្នកសមាទានគប្បីធ្វើកិច្ចទី ១ ទី ២ ទី ៣ និងទី ៤ តាមសមគួរដល់វេលាឲ្យស្រេចជាមុនសិន ហើយអ្នកមេនាំ គប្បីសូត្រប្រកាសឧបោសថដូចតទៅនេះ ។*

---

១- សេចក្តីពន្យល់នេះតាមច្បាប់ពុទ្ធមាមកវិធី ។ ២- អធិដ្ឋានតែសម្រាយក៏បាន ។

*ប្រកាសឧបោសថ*[១]

អជ្ជ ភោន្តោ {សុក្ក / កាឡ} បក្ខស្ស {អដ្ឋមី / ចាតុទ្ទសី / បណ្ណរសី} ទិវសោ

ឯវរូបោ ខោ ភោន្តោ ទិវសោ, ពុទ្ធេន ភគវតា បញ្ញត្តស្ស ធម្មស្សវនស្ស ចេវ តទត្ថាយ, ឧបាសកុបាសិកានំ ឧបោសថកម្មស្ស ច កាលោ ហោតិ, ហន្ទ មយំ ភោន្តោ សព្វេ ឥធ សមាគតា, តស្ស ភគវតោ ធម្មានុធម្មប្បដិបត្តិយា បូជនត្ថាយ, ឥមញ្ច រត្តឹ ឥមញ្ច ទិវសំ អដ្ឋង្គសមន្នាគតំ ឧបោសថំ ឧបវសិស្សាមាតិ, កាលបរិច្ឆេទំ កត្វា តំ តំ វេរមណឹ អារម្មណំ ករិត្វា អវិក្ខិត្តចិត្តា ហុត្វា, សក្កច្ចំ ឧបោសថង្គានិ សមាទិយេយ្យាម, ឦទិសំ ហិ ឧបោសថកាលំ សម្បត្តានំ អម្ហាកំ ជីវិតំ មា និរត្ថកំ ហោតុ ។

*សេចក្តីប្រែ*

*បពិត្រលោកអ្នកទាំងឡាយ ខ្ញុំសូមប្រកាសរបៀបដែលនឹងសមាទាន រក្សាឧបោសថសីល ព្រមដោយសិក្ខាបទ ៨ ប្រការតាមកាលវេលា*

---

១- ស្រង់យកតាមច្បាប់ឧបោសថកថា និងពុទ្ធមាមកវិធី ។

សូមសាធុសប្បុរសទាំងឡាយជ្រាប ក្នុងកាលឥឡូវនេះជាមុន ។ រីឯថ្ងៃ

| | | | | | | |
|---|---|---|---|---|---|---|
| | អដ្ឋមី | | ៨ | | | |
| នេះជាថ្ងៃ | ចាតុទ្ទសី | តិថីទី | ១៤ | នៃបក្ខខាង | ខ្នើត<br>រនោច | មកដល់ |
| | បណ្ណរសី | | ១៥ | | | |

ព្រមហើយ ឯកាលដូច្នេះជាកាលនៃឧបោសថកម្មដែលព្រះពុទ្ធអង្គទ្រង់បញ្ញត្តទុកដល់ពួកឧបាសកឧបាសិកាទាំងឡាយ ដើម្បីជាប្រយោជន៍ដល់ការស្តាប់ធម៌និងរក្សាឧបោសថសីលនោះ សូមពួកយើងបណ្តាដែលមកប្រជុំក្នុងទីនេះទាំងអស់គ្នា គប្បីតាំងចិត្តថា យើងរក្សានូវឧបោសថសីលអស់ថ្ងៃ ១ យប់ ១ ឲ្យបរិសុទ្ធបរិបូណ៌ប្រពៃ គប្បីតាំងចិត្តវៀរនូវទោសនោះៗ ឲ្យជាអារម្មណ៍ គឺតាំងចិត្តវៀរសម្លាប់សត្វដោយខ្លួនឯង ឬប្រើអ្នកដទៃឲ្យសម្លាប់ ១ វៀរលួចលាក់បំបាត់ទ្រព្យអ្នកដទៃដោយខ្លួនឯង ឬប្រើអ្នកដទៃឲ្យលួចលាក់បំបាត់ ១ វៀរសេពមេថុនធម្ម ១ វៀរកុហកបញ្ឆោតអ្នកដទៃ ១ វៀរផឹកសុរានិងមេរ័យដ៏ជាទីតាំងនៃសេចក្តីប្រមាទ ១ វៀរបរិភោគអាហារក្នុងវេលាព្រះអាទិត្យជ្រេទៅហើយ លុះអរុណរះឡើងមកជាថ្មី ១ វៀររាំច្រៀងដេញដំប្រគំផ្សេងៗ និងលាបស្រឡាបប្រដាប់ប្រដាសៀតពាក់កម្រងផ្កា និងគ្រឿងក្រអូបគ្រឿងរចនាផ្សេងៗ វៀរដេកអង្គុយ លើទីដេកទីអង្គុយដ៏ខ្ពស់ដ៏ប្រសើរ គឺគ្រែតាំងមានជើងខ្ពស់ហួសប្រមាណ នូវពូកប្រកគនិងសំឡី នូវកម្រាលដ៏វិចិត្ររចនាផ្សេងៗ ១ ។

យើងទាំងឡាយ កុំគប្បីមានចិត្តរវើរវាយរាយមាយទៅកាន់អារម្មណ៍ដទៃ គប្បីតាំងចិត្តសមាទាននូវអដ្ឋង្គឧបោសថសីលទាំង ៨ ប្រការដោយគោរពចុះ ដើម្បីនឹងបូជាដល់ព្រះមានព្រះភាគនោះ ដោយធម្មានុធម្មបដិបត្តិ, មួយវិញទៀត ជីវិតរបស់យើងទាំងឡាយដែលបានរស់នៅដរាបមកដល់ថ្ងៃឧបោសថសីលដូច្នេះនេះ ចូរកុំឲ្យកន្លងប្រាសចាកប្រយោជន៍ឡើយ ។

កាលធ្វើកិច្ចប្រកាសឧបោសថសីលរួចហើយ គប្បីអារាធនាសមាទានឧបោសថសីល ដោយបន្ទីវាចានិងតាំងចេតនាឲ្យប្រាកដផង ដូចន័យខាងក្រោមនេះ៖

## អារាធនាសមាទានឧបោសថសីល[១]

**អហំ / មយំ** } **ភន្តេ, តិសរណេន សហ, អដ្ឋង្គសមន្នាគតំ, ឧបោសថំ យាចា{មិ / ម}** ។ ៣ ដង ។

*ខ្ញុំព្រះករុណា / យើងខ្ញុំព្រះករុណា* } *សុំនូវឧបោសថសីល, ដែលប្រកបដោយអង្គប្រាំបីប្រការ, ព្រមទាំងព្រះត្រៃសរណគមន៍ ។*

---

១- ស្រង់យកបាលីព្រមទាំងសេចក្ដីប្រែពីច្បាប់វិធីថ្វាយបង្គំព្រះផ្សាយចេញពីសង្ឃបណ្ណាល័យវត្តបទុមវតី ។

លោកអ្នកឲ្យសីលគប្បីនាំសូត្រនមស្ការព្រះរតនត្រ័យ និងសមាទានសរណគមន៍ ដូចក្នុងនិច្ចសីលដរាបដល់ចប់ ហើយគប្បីនាំសមាទាននូវឧបោសថសីល ដូចតទៅនេះ៖

## សមាទានឧបោសថសីលមានសិក្ខាបទប្រាំបី

១- **បាណាតិបាតា វេរមណីសិក្ខាបទំ សមាទិយាមិ**, ខ្ញុំព្រះករុណា សមាទាននូវសិក្ខាបទ, គឺវៀរចាកសម្លាប់សត្វដោយខ្លួនឯង, និងប្រើអ្នកដទៃឲ្យសម្លាប់ ។

២- **អទិន្នាទានា វេរមណីសិក្ខាបទំ សមាទិយាមិ**, ខ្ញុំព្រះករុណា សមាទាននូវសិក្ខាបទ, គឺវៀរចាកលួចលាក់បំបាត់ទ្រព្យអ្នកដទៃដោយខ្លួនឯង, និងប្រើអ្នកដទៃឲ្យលួចលាក់បំបាត់ ។

៣- **អព្រហ្មចរិយា វេរមណីសិក្ខាបទំ សមាទិយាមិ**, ខ្ញុំព្រះករុណា សមាទាននូវសិក្ខាបទ, គឺវៀរចាកសេពសមនូវមេថុនធម្ម ។

៤- **មុសាវាទា វេរមណីសិក្ខាបទំ សមាទិយាមិ**, ខ្ញុំព្រះករុណា សមាទាននូវសិក្ខាបទ, គឺវៀរចាកនិយាយកុហកអ្នកដទៃ ។

៥- **សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណីសិក្ខាបទំ សមាទិយាមិ**, ខ្ញុំព្រះករុណា សមាទាននូវសិក្ខាបទ, គឺវៀរចាកហេតុជាទីតាំងនៃសេចក្តីប្រមាទ, គឺផឹកនូវសុរានិងមេរ័យដែលជា

*គ្រឿងស្រវឹងផ្សេងៗ ។*

៦- **វិកាលភោជនា វេរមណីសិក្ខាបទំ សមាទិយាមិ**, *ខ្ញុំព្រះករុណា សមាទាននូវសិក្ខាបទ, គឺវៀរចាកបរិភោគអាហារក្នុងវេលាខុស ។*

*៧-* **នច្ចគីតវាទិតវិសូកទស្សនមាលាគន្ធវិលេបនធារណមណ្ឌនវិភូសនដ្ឋានា វេរមណីសិក្ខាបទំ សមាទិយាមិ**, *ខ្ញុំព្រះករុណាសមាទាននូវសិក្ខាបទ, គឺវៀរចាករាំច្រៀង(១)ប្រគំតូរ្យតន្ត្រី, ព្រមទាំងមើលស្ដាប់របាំ ចម្រៀង តូរ្យតន្ត្រី, ដែលជាសត្រូវ ដល់កុសលធម៌, និងវៀរចាកប្រដាប់តាក់តែងរាងកាយ, ដោយកម្រងផ្កា គ្រឿងក្រអូប គ្រឿងលាបនិងគ្រឿងអលង្ការផ្សេង ៗ ។*

*៨-* **ឧច្ចាសយនមហាសយនា វេរមណីសិក្ខាបទំ សមាទិយាមិ**, *ខ្ញុំព្រះករុណា សមាទាននូវសិក្ខាបទ, គឺវៀរចាកទីដេកទីអង្គុយដ៏ខ្ពស់, និងទីដេក ទីអង្គុយដ៏ធំនិងប្រសើរ ។*

លោកអ្នកឲ្យសីលគប្បីនាំឲ្យធ្វើកាលបរិច្ឆេទថា

**ឥមំ អដ្ឋង្គសមន្នាគតំ ពុទ្ធប្បញ្ញត្តំ ឧបោសថំ, ឥមញ្ច រត្តឹ ឥមញ្ច ទិវសំ, សម្មទេវ អភិរក្ខិតុំ សមាទិយាមិ**, *ខ្ញុំព្រះករុណា សមាទាននូវឧបោសថ, ដ៏ប្រកបដោយអង្គ*

---

១- បានជាប្រែរាំមុនច្រៀង ព្រោះប្រែតាមបាលីនៃសិក្ខាបទនេះគឺ នច្ច រាំ ឬរបាំ គីត ច្រៀង ឬចម្រៀង ។

*ប្រាំបីប្រការ, ដែលព្រះពុទ្ធជាម្ចាស់ទ្រង់ត្រាស់បញ្ញត្តទុកមកនេះ, ដើម្បីរក្សាឲ្យបរិសុទ្ធបរិបូណ៌ប្រពៃ, កំណត់អស់ថ្ងៃមួយយប់មួយ មានវេលានេះជាដើម ។*

## លោកអ្នកឲ្យសីលត្រូវឲ្យឱវាទថា

**ឥមានិ អដ្ឋ សិក្ខាបទានិ, អជ្ជេកំ រត្តិន្ទិវំ, ឧបោសថសីលវសេន, តុម្ហេហិ**(១) **ឧបាសកឧបាសិកាភូតេហិ**(២) **សាធុកំ អខណ្ឌំ កត្វា អប្បមាទេន រក្ខិតព្វានិ**, *លោកអ្នកជាឧបាសកឧបាសិកាទាំងឡាយ, គប្បីរក្សាសិក្ខាបទទាំងឡាយប្រាំបីនេះ, ឲ្យបានជាឧបោសថសីលដ៏ប្រពៃ, ដោយសេចក្ដីមិនប្រមាទអស់ថ្ងៃនិងយប់នេះ កុំឲ្យដាច់និងសៅហ្មងឡើយ ។ អ្នកសមាទានត្រូវទទួលថា* "**អាម ភន្តេ**, *ព្រះករុណា*" ។

## លោកអ្នកឲ្យសីលគប្បីប្រាប់អានិសង្សថា

**សីលេន សុគតឹ យន្តិ**, *ជនទាំងឡាយ បានសុគតិដោយសារសីល*, **សីលេន ភោគសម្បទា**, *ជនទាំងឡាយបានភោគសម្ប័ទដោយសារសីល*, **សីលេន និព្វុតឹ យន្តិ**, *ជនទាំងឡាយបានព្រះនិព្វានដោយសារសីល*, **តស្មា សីលំ វិសោធយេ**,

---

១- បើឧបាសក ឬឧបាសិកាតែម្នាក់ ត្រូវថា តយា ។

២- បើឧបាសកតែម្នាក់ថា ឧបាសកភូតេន, បើច្រើននាក់ថា ឧបាសកភូតេហិ បើឧបាសិកាតែម្នាក់ថា ឧបាសិកាភូតាយ, បើច្រើននាក់ថា ឧបាសិកាភូតាហិ ។

*ព្រោះហេតុនោះ គប្បីញុំាងសីលឲ្យបរិសុទ្ធប្រពៃ ។ អ្នកសមាទាន ត្រូវទទួលថា* **សាធុ**, *ប្រពៃហើយ ។ បើលោកអ្នកឲ្យសីលនឹង ប្រាប់អានិសង្សសីល ដោយពាក្យបាលី ឬសម្រាយ ឲ្យបានច្រើនលើស ពីនេះទៅទៀត ក៏រឹតតែប្រពៃ ។*

*លំដាប់ពីនេះ អ្នកសមាទានសីលត្រូវសូត្រ* **កាយេន**... *ទាំង ៣ ចប់, រួចហើយបើពុំមានកិច្ចអ្វីដែលត្រូវធ្វើបន្ទាប់ពីនោះទេ លោកអ្នកឲ្យ សីល, គប្បីអនុមោទនា គឺសូត្រ* **យថា**... **ភវតុ សព្វ**.., *លុះចប់អនុមោទនាហើយ អ្នកសមាទានសីលត្រូវសូត្រទេវតាទិបត្តិទាន- គាថាគឺ* **អាកាសដ្ឋា**.., *បត្តិទានគាថាគឺ* **យង្កិញ្ចិ**.., *។*

## ពាក្យអារាធនាបរិត្ត[១]

*អាចារ្យ គប្បីសូត្រថា*

**វិបត្តិបដិពាហាយ, សព្វសម្បត្តិសិទ្ធិយា**
**សព្វទុក្ខវិនាសាយ, បរិត្តំ ព្រូថ មង្គលំ ។**
**វិបត្តិបដិពាហាយ, សព្វសម្បត្តិសិទ្ធិយា,**
**សព្វភយវិនាសាយ, បរិត្តំ ព្រូថ មង្គលំ ។**
**វិបត្តិបដិពាហាយ, សព្វសម្បត្តិសិទ្ធិយា,**
**សព្វរោគវិនាសាយ, បរិត្តំ ព្រូថ មង្គលំ ។**

---

១- ស្រង់យកបាលីព្រមទាំងសេចក្តីប្រែពីច្បាប់ពុទ្ធមាមកវិធី ។

*សេចក្តីប្រែ*

*សូមលោកម្ចាស់ទាំងឡាយ សូត្របរិត្តជាមង្គល ដើម្បីការពារនូវសេចក្តីវិបត្តិ ដើម្បីឲ្យបានសម្រេចនូវសម្បត្តិទាំងពួង ដើម្បីឲ្យ ទុក្ខ ភ័យ រោគ ទាំងអស់វិនាសបាត់បង់ទៅ ។*

## សេចក្តីប្រែម្យ៉ាងទៀត[១]

*សម្រាប់សូត្រ សរភញ្ញ*

*សូមលោកម្ចាស់ទាំងឡាយ សូមរីករាយដោយអនុគ្រោះ, សូត្របរិត្តដ៏ខ្ពង់ខ្ពស់ ជាមង្គលដល់យើងខ្ញុំ, ដើម្បីការពារទោស ការកំហុសទាំងតូចធំ, ដែលមករួបរុំជុំ ជិតរូបអង្គនិងចិន្តា, ដើម្បីឲ្យសម្រេច នូវសម្បត្តិទាំងឡាយណា, ដែលយើងខ្ញុំប្រាថ្នា បានគ្រប់ប្រការកុំបីឃ្លាត, ដើម្បីវិនាសទៅ និងអស់ទៅរោគាពាធ, ទុក្ខាភយាជាតិ កុំបីបៀតយើងខ្ញុំបាន ។*

## វិធីអារាធនាធម្មទេសនា[២]

*អាចារ្យគប្បីសូធ្យថា*

**ព្រហ្មា ច លោកាធិបតី សហម្បតិ**
**កតញ្ជលី អធិវរំ អាយាចថ**

១- ប្រែបន្ថែមថ្មីជាពាក្យកាព្យតាមយោបល់ខ្ញុំ ។

២- ស្រង់យកបាលីព្រមទាំងសេចក្តីប្រែពីច្បាប់ឧបោសថិកថា ។

សន្តីធ សត្តាប្បរជក្ខជាតិកា,
ទេសេតុ ធម្មំ អនុកម្បិមំ បជំ ។
ឯវញ្ហិ លោកាភិមតេន ព្រហ្មុនា,
អជ្ឈេសិតោ សោ ភគវា អនុត្តរោ,
សត្តេសុ ការុញ្ញត្តមោក្កមន្តតោ,
ឱលោកយិ លោកមិមំ សុចក្ខុនា ។
អទក្ខិ វេនេយ្យជនេ អនប្បកេ,
សន្តេវ លោកុត្តរពោធនារហេ,
វិញ្ញាបយេ អប្បរជក្ខជាតិកេ,
អថេវ មជ្ឈេសនមាធិវាសយិ ។
អបារុតា តេ អមតស្ស ទ្វារា,
យេ សោតវន្តោ បមុញ្ចន្តុ សទ្ធំ,
វិហឹសសញ្ញី បគុណំ ន ភាសឹ
ធម្មំ បណីតំ មនុជេសុ ព្រហ្មេ ។
តតោ មហាការុណិកោ មហេសី,
សម្ពុទ្ធកិច្ចំ ភគវា អកាសឹ,
សទ្ធម្មចក្កស្ស បវត្តនាទឹ,
បបេសិ សោ សាសនធម្មសេដ្ឋំ ។

**ធម្មំ ធម្មំ មោចយិ ភព្វសត្តេ,**
**សំសារទុក្ខា ពហុកោបិ តេន,**
**សទ្ធម្មជីបំ តិវិជម្បិ លោកេ,**
**ហិតាយ សម្មា រ បវត្តយិត្ថ ។**

*សេចក្តីប្រែ*

*រីព្រហ្មដ៏ជាធំ ក្រៃលែងព្រហ្មផងនានា, ទើបលុតព្រះជង្ឃា លើកហត្ថានមស្ការ, បពិត្រព្រះអង្គអើយ ព្រះគុណអើយសូមមេត្តា ប្រោសសត្វមនុស្សទេវតា ទ្រង់ករុណាសម្តែងធម៌, ដ្បិតសត្វទន្ទឹងណាស់ ឮព្រះត្រាស់ហើយត្រេកអរ, នឹងបានស្តាប់ព្រះធម៌ ហើយនឹងចរចេញចាកទុក្ខ, ដ្បិតសត្វផងនានា មានអវិជ្ជាពោលគឺលាមក, ដូចធូលីផង់ដីកក់ កករល្អក់ជាប់នេត្រា, ព្រោះហេតុមោហៈធំ ចងរួបរុំជុំកាយា, បាត់បង់អប្បប្រាជ្ញា មិនឲ្យឃើញព្រះត្រៃលក្ខណ៍, ងងឹតងងល់ងប់ ឲ្យជ្រុលជ្រប់ដូចមនុស្សខ្វាក់, លលើហើយលលាក់ ដូចអន្ទាក់ធ្លាក់រឹតក, នឹងរកអ្នកណាមួយ ឲ្យមកជួយស្រាយក៏ក្រ, មានបុណ្យតែព្រះសុធម៌ ទើបនឹងមកជួយស្រាយបាន, ហេតុនោះព្រះអង្គអើយ ព្រះគុណអើយសូមប្រោសប្រាណ, ដ្បិតព្រហ្មខ្ញុំរាប់អាន ចុះមកឋានអារាធនា, ព្រះធម៌ថ្លៃវិសេស លត់កិលេសនូវតណ្ហា, នាំចិត្តឲ្យជ្រះថ្លា សោមនស្សាឥតសៅហ្មង, ហេតុនោះព្រះអង្គអើយ ព្រះគុណអើយសូមចម្លង, នាំសត្វឲ្យបានធ្ងង់ដាក់ដល់ត្រើយព្រះនិព្វាន ។*

ចាតុទ្ទសី បណ្ណរសី, យា ច បក្ខស្ស អដ្ឋមី,
កាលា ពុទ្ធេន បញ្ញត្តា, សទ្ធម្មស្សវនស្សិមេ ។
(បណ្ណរសី)[១] ខោ អយជ្ជាដិ, សម្បត្តា អភិលក្ខិតា,
តេនាយំ បរិសា ធម្មំ, សោតុំ ឥធ សមាគតា ។
សាធុ អយ្យោ ភិក្ខុសង្ឃោ, ករោតុ ធម្មទេសនំ,
អយញ្ច បរិសា សព្វា, អដ្ឋិកត្វា សុណាតុ តំ ។

*វថ្ងៃបីប្រការ[២] នេះឯងណាមានប្រាកដ, គឺអង្គព្រះសុគត ទ្រង់កំណត់បញ្ញត្តា, ប្រញាប្តប្រទានមក គិតលែលកតាមប្រាជ្ញា, ជាកាលសវនា ធម៌ទេសនាវិសេសសុទ្ធ, ឯថ្ងៃពួកខាងខ្នើត ចំណែកធើតជាប្រាកដ, គឺថ្ងៃ ១៤ គត់ ១៥ និង ៨, ចំណែកខាងរនោច ថ្ងៃនោះសោតក៏មានបី, គឺអង្គព្រះជិនស្រី ទ្រង់បញ្ញត្តមានដូចគ្នា, ក្នុងកាលឥឡូវនេះក៏ដល់ព្រមដោយសិក្ខា, កំណត់ព្រះសាសនា គឺជាថ្ងៃ(ដប់ប្រាំ)គត់[៣], ហេតុនោះអស់យើងខ្ញុំ សុទ្ធសឹងជាបរិស័ទ, មកព្រមតាមកំណត់ ដើម្បីស្តាប់ធម៌ទេសនា, សូមព្រះភិក្ខុសង្ឃ ដែលឋិតផ្ចង់ក្នុងសិក្ខា, សម្តែងធម៌ទេសនា ដោយករុណាដល់យើងខ្ញុំ, សូមពួកបរិស័ទ ដែលលះកាត់*

---

១- ត្រង់នេះត្រូវផ្លាស់ បើថ្ងៃ ៨ កើត ៨ រោច ត្រូវថា អដ្ឋមី, បើថ្ងៃ ១៤ កើត ១៤ រោច ត្រូវថា ចាតុទ្ទសី, បើថ្ងៃ ១៥ កើត ១៥ រោច ត្រូវថា បណ្ណរសី ។

២- ស្រង់យកសេចក្តីប្រែតាមច្បាប់ចាស់ដែលបានកត់ត្រាទុកមកបន្ថែមទៀត ។

៣- ត្រូវផ្លាស់ពាក្យឲ្យស្របតាមបាលីដែលផ្លាស់ខាងលើ។

នូវសមាគម, សេចក្តីកង្វល់ធំ បានមកជុំក្នុងសភា, សូមតាំងសោត-ប្រសាទ ប្រសើរស្អាតទាំងទ្វេហារ, ចាំស្តាប់សព្ទទេសនា ដើម្បីធ្វើប្រយោជន៍ខ្លួន, សូមអស់សាធុជន ខំគិតគន់ឲ្យខ្ជាប់ខ្ជួន, តាំងចិត្តឲ្យមាំមួន ប្រឹងថែជូនអង្គបញ្ញា, **អហំ** រីខ្លួនខ្ញុំ ថ្វាយបង្គំធម៌ទេសនា, និមន្តព្រះករុណា ដោយព្រហ្មាចែងចប់ហោង ។

## អារាធនាធម្មទេសនា ម្យ៉ាងទៀត[១]

*អាចារ្យ គប្បីសូត្រថា*

**ព្រហ្មា ច លោកាធិបតី សហម្បតិ,**
**កតញ្ជលី អន្ធិវរំ អាយាចថ**
**សន្តីធ សត្តាប្បរជក្ខជាតិកា,**
**ទេសេតុ ធម្មំ អនុកម្បិមំ បជំ ។ល។**[២]

*សេចក្តីប្រែ*

កាលអង្គព្រះសម្ពុទ្ធ ជាម្កុដលើសលោកា, ទ្រង់មានព្រះទយាមិនប្រាថ្នាប្រោសសត្វា, ព្រោះហេតុសត្វទាំងឡាយ នៅសប្បាយដោយ

---

១- តាមច្បាប់ចាស់ ដែលបានកត់ត្រាទុក ។

២- ។ល។ បានសេចក្តីថា បំប្រួញសេចក្តីឬបាលី វែងឲ្យខ្លី, គប្បីដឹងថាត្រូវសូត្រតពីបាលីអនុកម្បិមំ បជំ នេះទៅរហូតដល់ ហិតាយ សម្មា វ បវត្តយិត្ថ ដូច បាលីខាងដើម ។ បើអ្នកសូត្រ ត្រូវការត្រឹម អនុកម្បិមំ បជំ ប៉ុណ្ណោះ ក៏បាន ។

តណ្ហា, ប្រកាន់នូវសាសនា នៃព្រហ្មាថាល្អក្រៃ ហេតុនោះព្រះចម
កព ទ្រង់បញ្ឈប់នូវព្រះទ័យ, តែមានករុណាក្រៃ ទើបព្រះអង្គគង់ស្ងៀម
នៅ, បង្កើតជាអស្ចារ្យ ជាកោលាហលសន្ធៅ, លាន់ឮទូរទ័រទៅ ដល់
ព្រះកាណ៌ស្តេចព្រហ្ម, កាលណោះស្តេចព្រហ្ម៌ សន្ធាប់ខ្ទាំងដោយសទ្ទា,
សំឡេងឮខ្ទរខ្ទារ ប្រកាសប្រាប់ព្រហ្មទាំងឡាយ ថានៃអស់គ្នាយើង
មកឆាប់ឡើងដោយរួសរាយ ទៅកាន់មនុស្សលោកនាយ ដើម្បីធ្វើ
អារាធនា, ឲ្យអង្គព្រះសម្ពុទ្ធ ជាម្កុដលើសលោកា, ភាសិតនូវធម្មា
ជាសណ្តាប់ដល់ពួកសត្វ, ស្រេចហើយទើបស្តេចព្រហ្ម, ដ៏ជាធំ
ដោយនូវម័តិ, ប្រាជ្ញប្រសើរក្តាត់ ជាជាងព្រហ្មផងនានា, រៀប
ស្រេចលីលាមក ដោយពពកដែននភា, ដល់លុតព្រះជង្ឃា លើក
ហត្ថានមស្ការ, បពិត្រព្រះអង្គអើយ ព្រះគុណអើយសូមមេត្តា, ប្រោស
សត្វមនុស្សទេវតា ទ្រង់ករុណាសម្តែងធម៌, ដ្បិតសត្វទន្ទឹងណាស់ ឮ
ព្រះត្រាស់ហើយត្រេកអរ, នឹងបានស្តាប់ព្រះធម៌ ហើយនឹងចរចេញចាក
ទុក្ខ, ដ្បិតសត្វផងនានា មានអវិជ្ជាពោលគឺលាមក, ដូចធូលីផង់ដីភក់ កករ
ល្អក់ជាប់នេត្រា, ព្រោះហេតុមោហៈធំ ចងរួបរំជុំកាយា, បាត់បង់អប្ប-
ប្រាជ្ញ មិនឲ្យឃើញព្រះត្រៃលក្ខណ៍, ផងឹតងងល់ងប់ ឲ្យជ្រុលជ្រប់
ដូចមនុស្សខ្វាក់ លលើហើយលលាក់ ដូចអន្ទាក់ធ្លាក់រឹតក, នឹងរក
អ្នកណាមួយ ឲ្យមកជួយស្រោយក៏ក្រ, មានតែបុណ្យព្រះសុធម៌ ទើបនឹង

*មកជួយស្រាយបាន, ហេតុនោះព្រះអង្គអើយ ព្រះគុណអើយសូមប្រោសប្រាណ, ដ្បិតព្រហ្មខ្ញុំរាប់អាន ចូលមកប្តានអារាធនា, ព្រះធម៌ថ្លៃវិសេស លត់កិលេសនូវតណ្ហា, នាំចិត្តឲ្យជ្រះថ្លា សោមនស្សាផុតសៅហ្មង, ហេតុនោះព្រះអង្គអើយ ព្រះគុណអើយសូមចម្លង, នាំសត្វឲ្យបានឆ្លង ដាក់ដល់ត្រើយនិព្វានំ ។*

**សទ្ធម្មភេរី វិនយញ្ច កាយំ, សុត្តញ្ច ពន្ធំ អភិធម្មចម្មំ, អក្កោធយន្តោ ចតុសច្ចទណ្ឌំ, បញ្ចោធនេយ្យេ បរិសាយ មជ្ឈេ ។**

*ព្រះវិន័យទុកដូចស្គរ តែងឮខ្ទរស្នូរគឹកកង, លាន់ឮឡើងរំពងពីរោះមូលក្រាំងក្រអៅ, ព្រះសូត្រដ៏ពីរោះ គឺមោះទុកដូចខ្សែផ្តៅ, បរមត្ថសាច់ធម៌ជ្រៅ ទុកដូចស្បែកជាសស្គរណា ព្រះអរិយសច្ច ៤ ជាធម៌មាំមួនណាស់សារ, ទុកដូចអន្ទងណា សម្រាប់វាយស្នូរស័ព្ទសាន, នឹងនាំសត្វទៅទុក ក្នុងទីសុខគឺព្រះនិព្វាន, សត្វណាដែលនៅមាន ជាប់និស្ស័យពីបុព្វេ, កាលណោះឯព្រះអង្គ ទ្រង់ទទួលអារាធនា, សហម្បតីស្តេចព្រហ្មា មានទ្វារនិព្វានបើកហើយ, អ្នកណាដែលបានស្តាប់ ចូរត្រងត្រាប់កុំព្រងើយ, ជាបុណ្យភ័ព្វគាប់ហើយ ចូរឲ្យមានចិត្តជ្រះថ្លា ។*

**ចាតុទ្ទសី បណ្ណរសី, យា ច បក្ខស្ស អដ្ឋមី,**
**កាលា ពុទ្ធេន បញ្ញត្តា, សទ្ធម្មស្សវនស្សិមេ ។**
**(បណ្ណរសី) ខោ អយជ្ជាធិ, សម្បត្តា អភិលក្ខិតា,**

តេជាយំ បរិសា ជម្មំ, សោតុំ ឥជ សមាគតា ។
សាធុ អយ្យោ ភិក្ខុសង្ឃោ, ករោតុ ជម្មទេសនំ,
អយញ្ច បរិសា សព្វា, អដ្ឋិកត្វា សុណាតុ តំ ។

*រីថ្ងៃបីប្រការ នេះឯងណាមានប្រាកដ, គឺអង្គព្រះសុគត ទ្រង់កំណត់បញ្ញត្តា, ប្រញប្តប្រទានមក គិតលែលកតាមប្រាជ្ញា, ជាកាលសវនាធម៌ទេសនាវិសេសសុទ្ធ, ឯថ្ងៃពួកខាងខ្មើត ចំណែកកើតជាប្រាកដ, គឺថ្ងៃ ១៤ គត់ ១៥ និង ៨, ចំណែកខាងរនោច ថ្ងៃនោះសោតក៏មានបី, គឺអង្គព្រះជិនស្រី ទ្រង់បញ្ញត្តមានដូចគ្នា, ក្នុងកាលឥឡូវនេះ ក៏ដល់ព្រមដោយសិក្ខា, កំណត់ព្រះសាសនា គឺជាថ្ងៃ(ដប់ប្រាំ)គត់, ហេតុនោះអស់យើងខ្ញុំ សុទ្ធសឹងជាបរិស័ទ, មកព្រមតាមកំណត់ ដើម្បីស្តាប់ធម៌ទេសនា, សូមព្រះភិក្ខុសង្ឃ ដែលឋិតថ្កង់ក្នុងសិក្ខា, សម្តែងធម៌ទេសនាដោយករុណាដល់យើងខ្ញុំ, សូមពួកបរិស័ទ ដែលលះកាត់នូវសមាគម, សេចក្តីកង្វល់ធំ បានមកជុំក្នុងសភា, សូមតាំងសោតប្រសាទ ប្រសើរស្អាតទាំងទ្វេហារ, ចាំស្តាប់សព្វទេសនា ដើម្បីធ្វើប្រយោជន៍ខ្លួន, សូមអស់សាធុជន ទំគិតគន់ឲ្យខ្ជាប់ខ្ជួន, តាំងចិត្តឲ្យមាំមួន ប្រឹងថែថួនអង្គបញ្ញា,* **អហំ** *រីខ្លួនខ្ញុំ ថ្វាយបង្គំធម៌ទេសនា, និមន្តព្រះករុណា ដោយព្រហ្មាចែងចប់ហោង ។*

*លុះទេសនាចប់ហើយ, ឧបាសក ឧបាសិកា គប្បីសូត្រសរសើរ គុណព្រះរតនត្រ័យ*[១] *ថា៖*

**សាធុ ពុទ្ធស្ស សុពោធិតា** *សេចក្ដីត្រាស់ដឹងនៃព្រះពុទ្ធ ប្រពៃហើយ ឲ្យសម្រេចប្រយោជន៍ដល់សត្វទាំងឡាយ,*

**សាធុ ធម្មស្ស សុធម្មតា** *សេចក្ដីទ្រទ្រង់នៃព្រះធម៌ប្រពៃ ហើយ ឲ្យសម្រេចប្រយោជន៍ដល់សត្វទាំងឡាយ,*

**សាធុ សង្ឃស្ស សុបដិបត្តិ** *សេចក្ដីបដិបត្តិនៃព្រះសង្ឃ ប្រពៃហើយ ឲ្យសម្រេចប្រយោជន៍ដល់សត្វទាំងឡាយ,*

**អហោ ពុទ្ធោ** *ព្រះពុទ្ធព្រះអង្គមានគុណជាអស្ចារ្យ គួរជ្រះថ្លា មែនហើយ,*

**អហោ ធម្មោ** *ព្រះធម៌មានគុណជាអស្ចារ្យ គួរជ្រះថ្លាមែនហើយ*

**អហោ សង្ឃោ** *ព្រះសង្ឃមានគុណជាអស្ចារ្យ គួរជ្រះថ្លា មែនហើយ ។*

---

១- ស្រង់យកបាលីព្រមទាំងសេចក្ដីប្រែពីច្បាប់ពុទ្ធមាមកវិធី ។

# វិធីវេរភត្តថ្វាយសង្ឃ[១]

*ឯវិធីវេរភត្តថ្វាយសង្ឃនេះ មុនដំបូងឧបាសក ឧបាសិកាគប្បីសូត្រនមស្ការ (នមោ...) ព្រមគ្នា រួចហើយអាចារ្យគប្បីនាំសូត្រពាក្យវេរមួយឃ្លាឈប់បន្តិចម្តង ដើម្បីឲ្យអ្នកឯទៀតសូត្រតាមគ្រប់ឃ្លា ដែលមានកណ្តុកសញ្ញា (,) និងខណ្ឌ (។) ជាគ្រឿងសម្គាល់ ដូចន័យខាងក្រោមនេះ ៖*

**អយំ នោ ភន្តេ, បិណ្ឌាចាតាភិហារោ, ធម្មិកោ ធម្មលទ្ធោ, ធម្មេនេវ, ឧប្បាទិតោ, មាតាបិតុអាទិកេ, គុណវន្តេ, ឧទ្ទិស្ស, ឥមំ, (សង្ឃភត្តំ)[២], សប្បរិវារំ, ឥទ ពុទ្ធប្បមុខស្ស, សង្ឃស្ស ទេម, តេ ឥមំ, អត្តនោ សន្តកំ វិយ, មញ្ញមានា, អនុមោទន្តុ, អនុមោទិត្វាន, យថិច្ឆិតសម្បត្តីហិ, សមិជ្ឈន្តុ, សព្វទុក្ខា, បមុញ្ចន្តុ,[៣] ឥមិនា និស្សន្ទេន ។ ទុតិយម្បិ..តតិយម្បិ.។**

---

១- ស្រង់យកបាលីព្រមទាំងសេចក្តីប្រែពីច្បាប់វិធីថ្វាយបង្គំព្រះ ផ្សាយចេញពីសង្ឃបណ្ណាល័យវត្តបទុមវតី ។

២-៣- ត្រង់វង់ក្រចកនេះបើវេរភត្តអ្វី គប្បីចេញឈ្មោះ តាមឈ្មោះភត្ត មានសង្ឃភត្ត, ឧទ្ទេសភត្ត, បក្ខិកភត្ត, និងសលាកភត្តជាដើម ដែលមានក្នុងបាលី ឬ អដ្ឋកថា ។

# *សេចក្តីប្រែ*

*បពិត្រព្រះសង្ឃដ៏ចម្រើន, រីអាហារបិណ្ឌបាត, នៃខ្ញុំព្រះករុណាទាំងឡាយ, ដែលនាំមកចំពោះនេះ, ប្រកបដោយធម៌, បានមកដោយធម៌, បង្កើតឡើងដោយធម៌, ខ្ញុំព្រះករុណាទាំងឡាយ, សូមឧទ្ទិសចំពោះ, ដល់លោកអ្នកដ៏មានគុណទាំងឡាយ, មានមាតាបិតាជាដើម, ហើយវេរថ្វាយ, នូវ(សង្ឃភត្ត)(១) ព្រមទាំងបរិវារនេះ, ដល់ព្រះសង្ឃ, មានព្រះពុទ្ធរូបស្នងព្រះអង្គ, ជាប្រធានក្នុងទីនេះ, សូមលោកអ្នកដ៏មានគុណទាំងឡាយនោះ, សម្គាល់នូវ(សង្ឃភត្ត)(១), ព្រមទាំងបរិវារនេះ, ថាដូចជារបស់នៃលោក, ហើយអនុមោទនា, លុះអនុមោទនារួចហើយ, សូមបានសម្រេច, ដោយសម្បត្តិទាំងឡាយ, តាមដែលលោកប្រាថ្នាចុះ, សូមរួចចាកទុក្ខទាំងពួង(២) ដោយផលានិសង្ស, ដែលហូរមកមិនដាច់នេះហោង ។*

---

១- តពីភុញ្ជន្តុ នឹងថែម អម្ហាកញ្ច, ទីឃរត្តំ, អត្ថាយ, ហិតាយ, សុខាយ ទៀតក៏បាន បើត្រូវការ ។

២- តពីរួបចាកទុក្ខទាំងពួង នឹងថែមថា (ម្យ៉ាងទៀត, ដើម្បីជាប្រយោជន៍, ជាគុណ, និងសេចក្តីសុខ, ដល់យើងខ្ញុំទាំងឡាយផង, អស់កាលជាវែងឆ្ងាយទៅ) ក៏បាន បើត្រូវការ ។

## *ថ្វាយទានផ្សេងៗ*[១]

### *ថ្វាយសង្ឃទានថា:*

**ឥមានិ មយំ ភន្តេ, ភត្តានិ, សបរិវារានិ, សង្ឃស្ស ឱណោជយាម, សាធុ នោ ភន្តេ សង្ឃោ, ឥមានិ ភត្តានិ, សបរិវារានិ, បដិគ្គណ្ហាតុ, ឥមា ជានបត្តិយោ, មាតាបិតុអាទីនញ្ច អម្ហាកញ្ច, សមិជ្ឈន្តុ, ទីឃរត្តំ, អត្ថាយ, ហិតាយ សុខាយ ។**

*សេចក្តីប្រែ*

*បពិត្រព្រះសង្ឃដ៏ចម្រើន, យើងខ្ញុំទាំងឡាយ, សូមបង្អោនថ្វាយ, នូវចង្ហាន់ទាំងឡាយនេះ, ព្រមទាំងបរិវារដល់ព្រះសង្ឃ, សូមព្រះសង្ឃចូរទទួលយក, នូវចង្ហាន់ទាំងឡាយនេះ, ព្រមទាំងបរិវារ, របស់យើងខ្ញុំទាំងឡាយ, ហើយសូមចំណែកផលទាន, អំបាលនេះចូរសម្រេច, ដើម្បីជាប្រយោជន៍, ជាគុណ និងសេចក្តីសុខ ដល់លោកអ្នកមានគុណទាំងឡាយ, មានមាតាបិតាជាដើមផង, ដល់យើងខ្ញុំទាំងឡាយផង, អស់កាលវែងឆ្ងាយទៅហោង ។*

*ត្រង់ពាក្យថា* "**ភត្តានិ**" *សម្រាប់ប្រើថ្វាយចង្ហាន់បិណ្ឌបាតដែលជាសង្ឃភត្ត បើជាថ្វាយភត្តដទៃ ឬរបស់ដទៃវិញ ត្រូវផ្លាស់បាលីតាមឈ្មោះភត្ត ឬរបស់នោះៗ ជំនួសត្រង់ ភត្តានិ ។*

---

១- ស្រង់យកបាលី ព្រមទាំងសេចក្តីប្រែពីច្បាប់ពុទ្ធមាមកវិធី ។

*បើថ្វាយសលាកកត្តថា* **សលាកភត្តានិ** *នូវចង្ហាន់ដែលកាន់យកដោយស្លាកទាំងឡាយ ។*

*មតកកត្តថា* **មតកភត្តានិ** *នូវចង្ហាន់ដើម្បីបុគ្គលស្លាប់ទាំងឡាយ ។*

*ចីវរថា* **ចីវរានិ** *នូវចីវរទាំងឡាយ ។*

*សំពត់វស្សិកសាដកថា* **វស្សិកសាដិកានិ** *នូវសំពត់ងូតទឹកភ្លៀងទាំងឡាយ ។*

*សំពត់ចំណាំវស្សាថា* **វស្សាវាសិកានិ** *នូវសំពត់ចំណាំវស្សាទាំងឡាយ ។*

*សំពត់អច្ចេកចីវរថា* **អច្ចេកចីវរានិ** *នូវសំពត់ដែលប្រញាប់ទាំងឡាយ ។*

*ថ្នាំកែរោគថា* **ភេសជ្ជានិ** *នូវថ្នាំកែរោគទាំងឡាយ ។*

*សេនាសនៈថា* **សេនាសនានិ** *នូវសេនាសនៈទាំងឡាយ ។*

*បើថ្វាយសេនាសនៈតែមួយ ដូចជាថ្វាយកុដិមួយជាដើម ត្រូវផ្លាស់ពាក្យពហុវចនៈ ជាឯកវចនៈ ថាដូច្នេះ*

ឥមំ ភន្តេ, សេនាសនំ, សបរិវារំ, សង្ឃស្ស, ឱណោជយាម, សាធុ នោ ភន្តេ សង្ឃោ, ឥមំ

**សេនាសនំ, សបរិវារំ, បដិគ្គណ្ហាតុ, ឥមា ធានបត្តិយោ, មាតាបិតុអាទីនញ្ច អម្ហាកញ្ច, សមិជ្ឈន្តុ, ចីរយត្តំ, អត្ថាយ, ហិតាយ សុខាយ ។**

*សេចក្តីប្រែ*

*បពិត្រព្រះសង្ឃដ៏ចម្រើន យើងខ្ញុំទាំងឡាយ, សូមបង្អោនថ្វាយនូវសេនាសនៈនេះ, ព្រមទាំងបរិវារដល់ព្រះសង្ឃ, សូមព្រះសង្ឃទទួលយកនូវសេនាសនៈនេះព្រមទាំងបរិវារ, របស់យើងខ្ញុំទាំងឡាយ, ហើយសូមចំណែកផលទាន, អំបាលនេះចូរសម្រេច, ដើម្បីជាប្រយោជន៍, ជាគុណនិងសេចក្តីសុខ, ដល់លោកអ្នកមានគុណទាំងឡាយ, មានមាតាបិតាជាដើមផង, ដល់យើងខ្ញុំទាំងឡាយផង, អស់កាលវែងឆ្ងាយទៅហោង ។*

*ពាក្យថា* **សបរិវារានិ** *ក្តី ថា* **សបរិវារំ** *ក្តី សម្រាប់ប្រើថ្វាយកត្តប្តុថ្វាយរបស់នោះៗ ដែលមានបរិក្ខារដទៃជាបរិវារអមនៅផង ដូចជាថ្វាយកត្តមានរបស់ដទៃក្រៅពីចង្ហាន់នោះថ្វាយផង នឹងថ្វាយចីវរមានរបស់ដទៃក្រៅពីចីវរនោះថ្វាយផង ទើបប្រើពាក្យបាលីថា* **សបរិវារានិ** *ឬ* **សបរិវារំ** *បើគ្មានបរិក្ខារដទៃជាបរិវារទេ មិនចាំបាច់ថាឡើយ កាត់ពាក្យបាលីនិងពាក្យសម្រាយត្រង់នោះចោលចេញ ។*

*ម៉្យាងទៀត ត្រង់ពាក្យថា* **មាតាបិតុអាចីនញ្ច** *ក្តី* **អម្ហា-កាញ្ច** *ក្តី បើត្រូវការវេរថ្វាយឧទ្ទិសកុសលចំពោះលោកអ្នកណា ត្រូវយកលោកអ្នកនោះមកបញ្ចូលហើយកាត់ពាក្យថា* **មាតាបិតុអាចីនញ្ច អម្ហាកាញ្ច** *ចេញ ឬមួយត្រូវការបញ្ចូលជាមួយគ្នាក៏បាន ។*

*ថ្វាយសំពត់កឋិនថា៖*

**ឥមំ ភន្តេ, កឋិនទុស្សំ, សង្ឃស្ស, ឱណោ-ជយាម សាធុ នោ ភន្តេ សង្ឃោ, ឥមំ កឋិនទុស្សំ, បដិគ្គណ្ហាតុ, បដិគ្គហេត្វា ច, ឥមិនា ទុស្សេន, កឋិនំ អត្ថរតុ, អម្ហាកំ, ទីឃរត្តំ, អត្ថាយ ហិតាយ សុខាយ ។**

*សេចក្តីប្រែ*

*បពិត្រព្រះសង្ឃដ៏ចម្រើន, យើងខ្ញុំទាំងឡាយ, សូមបង្អោនថ្វាយ, នូវសំពត់កឋិននេះ, ដល់ព្រះសង្ឃ, សូមព្រះសង្ឃទទួលយក, នូវសំពត់កឋិននេះ, របស់យើងខ្ញុំទាំងឡាយ, លុះទទួលហើយ, សូមក្រាលគ្រង់កឋិនដោយសំពត់នេះ, ដើម្បីជាប្រយោជន៍, ជាគុណ និងសេចក្តីសុខ, ដល់យើងខ្ញុំទាំងឡាយ, អស់កាលវែងឆ្ងាយទៅហោង ។*

ថ្វាយគ្រឿងបរិក្ខារជាបរិវារកឋិនថា៖

**យេនម្ហាកំ, កឋិនំ, គហិតំ, កឋិនានិសំសានិ, តស្សេវ ទេម ។**

សេចក្តីប្រែ

វីសំពត់នៃយើងខ្ញុំទាំងឡាយ, ដែលលោកម្ចាស់អង្គណាទទួលកាន់យកហើយ, យើងខ្ញុំទាំងឡាយ, សូមថ្វាយនូវបរិក្ខារទាំងឡាយដ៏ជាបរិវារនៃកឋិន, ដល់លោកម្ចាស់អង្គនោះហោង ។

ពាក្យបវារណាបច្ច័យ

បើត្រូវការប្រគេនបច្ច័យ គឺរូបិយគ្រប់បែប ដែលគេសន្មតប្រើទិញដូរដូរសមាសប្រាក់ក្នុងប្រទេសនោះៗ គួរបវារណាជាបច្ច័យ ៤ កុំប្រគេនផ្ទាល់ដៃលោកឡើយ ត្រូវបវារណាជាកប្បិយវោហារ តាមផ្លូវវិន័យបញ្ញត្តិថា៖

ខ្ញុំព្រះករុណាសូមបវារណាចំពោះ { លោកម្ចាស់ / លោកម្ចាស់គ្រប់ព្រះអង្គ } ដោយបច្ច័យ ៤ គឺ ចីវរ បិណ្ឌបាត សេនាសនៈ និងគិលានភេសជ្ជៈ បើ { លោកម្ចាស់ / លោកម្ចាស់គ្រប់ព្រះអង្គ } ត្រូវការដោយបច្ច័យណាមួយ សូមទារយកហៅរកអំពីវេយ្យាវច្ចករឈ្មោះ (គង់-គួន) ឲ្យអស់ចំនួនស្មើនឹងតម្លៃ ២០ រៀល តាមពុទ្ធានុញ្ញាត ។

បវារណាបច្ច័យ ៤ ដរាបអស់ជីវិតថា៖

ខ្ញុំព្រះករុណាសូមបវារណាចំពោះ {លោកម្ចាស់ / លោកម្ចាស់គ្រប់ព្រះអង្គ} ដោយបច្ច័យ ៤ គឺ ចីវរ បិណ្ឌបាត សេនាសនៈ និងគិលានភេសជ្ជៈ បើ {លោកម្ចាស់ / លោកម្ចាស់គ្រប់ព្រះអង្គ} ត្រូវការដោយបច្ច័យណាមួយវេលាណា សូមទារយកហៅរកអំពីខ្ញុំព្រះករុណាដរាបអស់ជីវិត ។

ពាក្យសូមលាព្រះសង្ឃត្រឡប់ទៅទីលំនៅវិញ

មេនាំ នាំសូត្រលាព្រះសង្ឃថា៖

"**ហន្ទជានិ មយំ ភន្តេ**, បពិត្រព្រះសង្ឃដ៏ចម្រើនអើយ, វេលានេះសមគួរហើយ, **អាបុច្ឆាម**, យើងទាំងឡាយ សូមថ្វាយបង្គំលា, **ពហុ កិច្ចា មយំ**, ដ្បិតយើងខ្ញុំទាំងឡាយ, មានកិច្ចការធុរៈច្រើន, **ពហុ ករណីយា**, មានកិច្ចដែលយើងខ្ញុំទាំងឡាយត្រូវធ្វើ, ក៏ច្រើន" ។

ព្រះសង្ឃត្រូវឆ្លើយថា "**យស្សិទានិ តុម្ហេ កាលំ មញ្ញថ**, ចូរអស់លោក-អ្នកសម្គាល់នូវកាលតាមសមគួរ (នឹងទៅ)ចុះ...។

ឧបាសកបដិបត្តិ សង្ខេបប៉ុណ្ណោះ

ឧបាសកវណ្ណោតា

បប់

---